ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

( គ.ជ.ប )

# បទបញ្ញា និង នីតិវិធី

សម្រាប់

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត
ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
អាណត្តិទី៣

[ ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩ ]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៩៧ គ.ជ.ប.ស.ស.រ

## សេចក្ដីសម្រេច
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃ២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្ដីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញសេចក្តីសម្រេចលេខ ០៥៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រកាសឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងការអនុម័តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ លើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩ ។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់ជាផ្លូវការបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩ ដែលមាន ២ ជំពូក ១៣ផ្នែក និង ១៦០ ប្រការ និងឧបសម្ព័ន្ធចំនួន ៧។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងបទបញ្ជា និងនីតិវិធីនេះ ត្រូវចាត់ទុកជានិរាករណ៍។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩

**ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

# មាតិកា

ទំព័រ


**ជំពូកទី ១. បទប្បញ្ញត្តិទូទៅ** ........................................ ០១

**ជំពូកទី ២. អំពីការបោះឆ្នោត** ........................................ ០៤

**ផ្នែកទី១. ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា** ........................................ ០៤

- សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត ........................................ ០៤
- ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការរៀបចំការ បោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត ........................................ ០៧
- សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប ........................................ ០៧
- លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាជិក គធ.ខប ........................................ ០៨
- សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប ........................................ ០៨
- បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំ តែងតាំងសមាសភាព គ.ក.ប ........................................ ០៩
- ប្រព័ន្ធជ្រើសរើសសមាជិក គធ.ខប មន្ត្រី លគធ.ខប និងសមាសភាព គ.ក.ប ........................................ ១២
- ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត ........................................ ១៣
- អាណត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ ........................................ ១៣
- ការតែងតាំងក្នុងរយៈពេលមានកំណត់ ........................................ ១៣
- គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខាររបស់ គ.ជ.ប ........................................ ១៤
- ប្រតិទិននៃការងារបោះឆ្នោត ........................................ ១៥
- ការងារសន្តិសុខបោះឆ្នោត ........................................ ១៥

**ផ្នែកទី២. ប្រព័ន្ធបោះឆ្នោត និងរូបមន្ត** ........................................ ២១

- ប្រព័ន្ធបោះឆ្នោត ........................................ ២១

- រូបមន្តនៃការបែងចែកអាសនៈ...................................................................២១
- ករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន...................................................................៣៣
- ករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន...................................................................៣៨
- ការចាប់ឆ្នោតជាសាធារណៈ...................................................................៤២
- ការប្រកាសឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងការកំណត់បេក្ខជនជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ..........................៤៤
- ករណីបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយក្នុងអាណត្តិ ..........................៤៧

**ផ្នែកទី៣. ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ**........ ៦៦

- ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត........ ៧០
- ការពិនិត្យ សម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត...................................................................៧១
- ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត...................................................................៧៤

**ផ្នែកទី៤. បញ្ជីបោះឆ្នោត**...................................................................៧៨

- អ្នកបោះឆ្នោត...................................................................៧៨
- លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត...................................................................៧៩
- ការិយាល័យចុះឈ្មោះបោះឆ្នោត...................................................................៧៩
- សង្ខេបដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ...................................................................៧៩
- រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ...................................................................៨០
- ការទទួលខុសត្រូវរបស់ កបឃ.ស ក្នុងការចុះឈ្មោះបោះឆ្នោត ..................៨១
- សម្ភារ ឯកសារសម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោត...... ៨៣
- ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការបញ្ជូនបញ្ជីឈ្មោះមក គ.ជ.ប ..... ៨៣
- ការប្រគល់ និងការទទួលបញ្ជីឈ្មោះ និងការរៀបចំបញ្ជីបោះឆ្នោតដំបូងដោយប្រព័ន្ធកុំព្យូទ័រនៅ គ.ជ.ប ..........................៩០

- ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ........ ៩២
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ........ ៩៣
- គោលការណ៍ទូទៅ ........ ៩៣
- នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ឃប ... ៩៤
- ការដាក់ ការទទួលពាក្យបណ្ដឹងនៅ គធ.ឃប ........ ៩៤
- ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ឃប ........ ៩៧
- នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ..... ៩៨
- ការដាក់ ការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ........ ៩៨
- ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ........ ១០០
- ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ឃប ឬសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ........ ១០១
- ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ឃប ........ ១០១
- ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ........ ១០១
- លក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ........ ១០៤

**ផ្នែកទី៥. ការិយាល័យបោះឆ្នោត** ........ ១០៦
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ........ ១០៦
- ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ........ ១០៧
- ទីតាំងរដ្ឋបាល និងសន្តិសុខសម្រាប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ........ ១០៨
- វិធានការការពារសន្តិសុខ ........ ១០៩

**ផ្នែកទី៦. ការឃោសនាបោះឆ្នោត** ........ ១១២
- បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត ........ ១១២
- សម្ភារអប់រំអ្នកបោះឆ្នោត ........ ១២៣
- រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ ........ ១២៦
- កិច្ចសហការ និងភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ........ ១៣៤

**ផ្នែកទី៧. ការបោះឆ្នោត** ....................................................................................... ១៣៦

- សម្ភារ ឯកសារបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោត........................ ១៣៦
- ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ.................................. ១៣៨
- ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យ បោះឆ្នោត .........................................................................................១៤៧
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត .... ១៥២
- ការប្រព្រឹត្តទៅនៃការបោះឆ្នោត ............................................................ ១៥៣
- ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត..........១៧៣

**ផ្នែកទី៨. ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោត** .......................................១៧៩

- ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត.........................................១៧៩
- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ..................................... ១៨៩
- ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុ នៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារ បោះឆ្នោតពាក់ព័ន្ធ ............................................................................ ១៩២
- ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់ សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គធ.ខប.......១៩៧
- ការរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គធ.ខប ឬទីតាំង សុវត្ថិភាពណាមួយ .......................................................................២០០
- ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹង កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬ/និងលទ្ធផល បណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទៅ គធ.ខប..........២០៥
- ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងភាព មិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោតទៅ គធ.ខប......២០៩
- ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផល បណ្ដោះអាសន្ននៃការបោះឆ្នោតនៅ គធ.ខប ........................................ ២១១
- កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុប លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា..............២១៤

- ការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ហើយត្រូវបាន គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " .................. ២១៩
- ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ .................. ២២១
- ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ.................. ២២៥
- ការវេចខ្ចប់ និងការបញ្ជូនលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធបញ្ជូនទៅ គ.ជ.ប .................. ២២៩
- ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់នៅ គ.ជ.ប ពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា.............. ២៣៧
- ការបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបម្រើការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសក្រុមប្រឹក្សា .................. ២៤០
- ការប្រគល់ និងការទទួលស្បោង " ឃ " និងកញ្ចប់ " ឃពិសេស " ដាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្ដីការ គ.ជ.ប........................ ២៤៧
- កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ.................. ២៥០
- ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដែល គធ.ខប បានសម្រេចព្យួរលទ្ធផលជាបណ្ដោះអាសន្ន .... ២៥៣
- ការត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យបោះឆ្នោតដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ត្រូវបានដាក់នៅ គ.ជ.ប.................. ២៥៨

- ការត្រួតពិនិត្យ ការផ្ទៀងផ្ទាត់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គ.ជ.ប ........ ២៦៤
- ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ........ ២៦៩

**ផ្នែកទី៩. ការបោះឆ្នោតសាជាថ្មី** ........ ២៧០
- ការបិទការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន ........ ២៧០
- ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីកាលៈទេសៈមានអាសន្ន ឬដែលលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបានបដិសេធដោយ គ.ជ.ប ........ ២៧៣

**ផ្នែកទី១០. ការដាក់ជំនួសសមាជិកក្រុមប្រឹក្សា** ........ ២៧៧

**ផ្នែកទី១១. សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត** ........ ២៧៨
- សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងការបោះឆ្នោត ........ ២៧៨
- សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ........ ២៧៨
- ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ........ ២៨០
- ការដកពាក្យបណ្តឹង ........ ២៨១
- ការរួមបញ្ចូលរឿងក្តី ........ ២៨២
- សិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ........ ២៨២
- សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ........ ២៨៤
- នីតិវិធីប្រជុំផ្សះផ្សា នីតិវិធីសវនាការ ........ ២៨៥
- ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប ........ ២៨៩
- នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានដែលអាចនាំឱ្យមានការផាកពិន័យ ........ ២៩៣
- ពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ........ ២៩៣
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ........ ២៩៣
- ការដាក់ និងការទទួលពាក្យបណ្តឹងនៅ គធ.ខប ........ ២៩៣
- ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ........ ២៩៥
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ........ ២៩៧

- ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ........................................ ២៩៧
- ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ........................................ ២៩៨
- បណ្ដឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត ........................................ ៣០០

**ផ្នែកទី១២. ការបោះឆ្នោតឡើងវិញ** ........................................ ៣០២

**ផ្នែកទី១៣. ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន** ........................................ ៣០៧

- ភ្នាក់ងារគណបក្សនយោបាយ ........................................ ៣០៧
- អ្នកសង្កេតការណ៍ ........................................ ៣១២
- អ្នកសង្កេតការណ៍ជាតិ ........................................ ៣១៣
- អ្នកសង្កេតការណ៍អន្តរជាតិ ........................................ ៣១៦
- អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ........................................ ៣១៨

## ឧបសម្ព័ន្ធ

១- ក្រមសីលធម៌ សម្រាប់មន្ត្រីបោះឆ្នោត ........................................ ៣២២

២- ក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ........................................ ៣៣៨

៣-ក្រមសីលធម៌ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត ........................................ ៣៥៥

៤- ក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ........................................ ៣៦៤

៥- ក្រមសីលធម៌ សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ........................................ ៣៧៥

៦- សម្ភារ ឯកសារដែលត្រូវប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល ........................................ ៣៨៧

៧- សម្ភារ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គ.ក.ប/គ.ក.រ សម្រាប់ប្រើប្រាស់ ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........................................ ៣៨៩

# អក្សរកាត់

| | | |
|---|---|---|
| ១- | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ២- | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ៣- | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៤- | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៥- | ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៦- | ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ | ច.ប.ត.រ |
| ៧- | ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ច.ប.ក |
| ៨- | ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | ច.គ.ខ.ស |
| ៩- | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ | ប.ន.ក |
| ១០- | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ១១- | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១២- | អ្នករាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | អ.គ.ជ.ប |
| ១៣- | ឯកសារបញ្ជាក់អត្តសញ្ញាណ | ឯ.អ |
| ១៤- | ទម្រង់បែបបទលេខ | ទ. |

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**ប្រការ ១.១.-**

អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ច.គ.ជ.ប) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ច.ប.ក) និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសិទ្ធិ និងមានភារកិច្ចរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ប.ន.ក) ដើម្បីកំណត់បែបបទ វិធាន និងបញ្ញត្តិនានាសម្រាប់ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហៅកាត់ថា "ក្រុមប្រឹក្សា" ។

**ប្រការ ១.២.-**

អនុលោមតាមមាត្រា ១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច.គ.ខ.ស) ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ ដូចខាងក្រោម ៖

១.២.១ ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពី ២៧ (ម្ភៃប្រាំពីរ) រូប ។

១.២.២ ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពី ១៥ (ដប់ប្រាំ) ដល់ ២៧ (ម្ភៃប្រាំពីរ) រូប ។

១.២.៣ ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពី ១១ (ដប់មួយ) ដល់ ២១ (ម្ភៃមួយ) រូប ។

១.២.៤ ក្រុមប្រឹក្សាស្រុក ខណ្ឌ មានចំនួនសមាជិកពី ១១ (ដប់មួយ) ដល់ ២១ (ម្ភៃមួយ) រូប។

**ប្រការ ១.៣.-**

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិច ១២០ (មួយរយម្ភៃ) ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។ ក្នុងករណីគ្មានអនុក្រឹត្យចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សាសម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

**ប្រការ ១.៤.-**

សមាជិកក្រុមប្រឹក្សាត្រូវជ្រើសរើសឡើងដោយការបោះឆ្នោតអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) នៅក្នុងមុខតំណែង គឺជាអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សា ។

**ប្រការ ១.៥.-**

អនុលោមតាមមាត្រា ៤ និងមាត្រា ៥ នៃ ច.គ.ខ.ស រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម៖

១.៥.១ ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។ រាជធានីភ្នំពេញចែកជាខណ្ឌ ។ ខណ្ឌចែកជាសង្កាត់ ។

១.៥.២ ខេត្តចែកជាក្រុង និងជាស្រុក ។ ក្រុងចែកជាសង្កាត់ ។ ស្រុកចែកជាឃុំ និងជាសង្កាត់ ។

**ប្រការ ១.៦.-**

មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ ត្រូវបានរៀបចំតាមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ។ មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗរួមមាន៖

១.៦.១ រាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

១.៦.២ ក្រុង ស្រុក ខណ្ឌ ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

១.៦.៣ ករណីមានការបង្កើតខេត្ត ក្រុង ស្រុក ខណ្ឌថ្មី ដែលជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ តែពុំទាន់មានការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធរដ្ឋបាលនៅឡើយ រដ្ឋបាលដែលធ្លាប់ដឹកនាំ និងចាត់ចែងពីមុនត្រូវបន្តអនុវត្តការងាររដ្ឋបាលនានាពាក់ព័ន្ធនឹងការបោះឆ្នោត រហូតដល់មានការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធរដ្ឋបាលនៅមណ្ឌលបោះឆ្នោតទាំងនោះ ។

**ប្រការ ១.៧.-**

អាណត្តិរបស់ក្រុមប្រឹក្សាមាន ៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

**ប្រការ ១.៨.-**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើតែមួយថ្ងៃ នៅថ្ងៃអាទិត្យណាមួយរៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង។

១.៨.១ កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោត ត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

១.៨.២ កាលបរិច្ឆេទនៃការបោះឆ្នោតលើកទី៣ ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានកំណត់យកថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩ ផ្អែកតាមសេចក្តីសម្រេចលេខ ៧៧ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ។

# ជំពូកទី ២
# អំពីការបោះឆ្នោត

## ផ្នែកទី ១
## ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

### សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត

**ប្រការ ២.១.–**

ការចាត់ចែង រៀបចំ និងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជាសមត្ថកិច្ចរបស់ គ.ជ.ប ដូចមានចែងក្នុង ច.គ.ជ.ប និង ច.ប.ក។

គ.ជ.ប ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។

សមាជិកទាំងឡាយនៃ គ.ជ.ប និងសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹត ឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត។

**ប្រការ ២.២.–**

គ.ជ.ប ត្រូវដាក់ចេញបទបញ្ជា និងនីតិវិធីសម្រាប់ចាត់ចែង រៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុង ច.គ.ជ.ប ច.ប.ក ច.ប.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

**ប្រការ ២.៣.–**

គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្ម ការរៀបចំ ការចាត់ចែង និងត្រួតពិនិត្យការបោះឆ្នោត ដូចតទៅ ៖

២.៣.១ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តាមរយៈការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតដោយសម្ងាត់ ។

២.៣.២ រៀបចំគម្រោងផែនការការងារ ថវិកា និងសម្ភារបម្រើឱ្យការបោះឆ្នោត និងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

២.៣.៣ តែងតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និងគណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) ។

២.៣.៤ ធ្វើបទបញ្ជា នីតិវិធី និងសេចក្តីណែនាំនានាសម្រាប់ដំណើរការបោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

២.៣.៥ លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

២.៣.៦ ត្រួតពិនិត្យការងាររបស់គណៈកម្មការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

២.៣.៧ កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

២.៣.៨ ចេញសេចក្តីសម្រេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ។

២.៣.៩ ផលិត និងបែងចែកសម្ភារ បរិក្ខារ បម្រើឱ្យការបោះឆ្នោត ។

២.៣.១០ លើកសំណើជូនក្រសួងមហាផ្ទៃ ដើម្បីធ្វើប្រតិភូកម្មអំណាចដល់ កបឃ.ស ឱ្យជួយបំពេញការងារស្រង់ឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងដើម្បីបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោត ស្របតាមច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

២.៣.១១ រៀបចំបញ្ជីបោះឆ្នោត ។

២.៣.១២ ពិនិត្យ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោត ។

២.៣.១៣ ទទួល និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ស្របតាមច្បាប់បោះឆ្នោតជាធរមាន ។

២.៣.១៤ គ្រប់គ្រង និងត្រួតពិនិត្យការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត ។

២.៣.១៥ រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល ។

២.៣.១៦ ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ។

ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។
លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះបោះឆ្នោតឡើងវិញ ។

២.៣.១៧ ត្រួតពិនិត្យចំណូល និងចំណាយក្នុងរយៈពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ ។

២.៣.១៨ ចាត់វិធានការ និងសម្របសម្រួលដើម្បីឱ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនាសាធារណៈ តាមគោលការណ៍ស្មើភាព និងសមធម៌ ។

២.៣.១៩ ផ្តល់ព័ត៌មាន ទិន្នន័យ និងស្ថិតិអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។
ធានាឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំអំពីកិច្ចដំណើរការបោះឆ្នោតរវាង គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា ។

២.៣.២០ ផលិតឯកសារផ្សព្វផ្សាយអំពីការងារបោះឆ្នោត ។

២.៣.២១ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត ។

២.៣.២២ រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ។

២.៣.២៣ ពិនិត្យសម្រេច និងចេញបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។

២.៣.២៤ ត្រួតពិនិត្យ ដើម្បីធានាភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

២.៣.២៥ សម្រេចដោយបើកសវនាការជាសាធារណៈលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត លើកលែងតែបណ្ដឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

២.៣.២៦ បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

២.៣.២៧ អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ២.៤.–**

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គ.ជ.ប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុងផ្នែកទី២ ផ្នែកទី៣ និងផ្នែកទី៥ នៃជំពូកទី១ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

**ប្រការ ២.៥.–**

គ.ជ.ប មានសិទ្ធិតែងតាំង គធ.ខប ឬ គ.ក.ប ក្នុងរយៈពេលមានកំណត់ នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោតជាទូទៅត្រូវបានបញ្ចប់ ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មី (ប្រសិនបើមាន) ។

## ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត

**ប្រការ ២.៦.–**

យោងតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប អាចចេញសេចក្ដីសម្រេចប្រគល់សិទ្ធិអំណាចរបស់ខ្លួនដល់ គធ.ខប គ.ក.ប ឬមន្ត្រី ឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត ។

## សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប

**ប្រការ ២.៧.–**

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលបង្កើតឡើងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោត។ សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុងផ្នែកទី១ និងផ្នែកទី២ នៃជំពូកទី២ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

## លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាជិក គធ.ខប

### ប្រការ ២.៨.-

បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ត្រូវអនុវត្តតាមមាត្រា ១៦ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

២.៨.១ សមាសភាព គធ.ខប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងជនដែលត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

២.៨.២ សមាសភាព គធ.ខប ត្រូវបានជ្រើសរើសដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ដូចបានកំណត់ក្នុងផ្នែកទី១ នៃជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

## សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប

### ប្រការ ២.៩.-

សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប ត្រូវអនុវត្តតាមផ្នែកទី៤ នៃជំពូកទី២ នៃ ច.គ.ជ.ប និងជំពូកទី៤ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.៩.១ គ.ក.ប ត្រូវមានសមាសភាព ៦ (ប្រាំមួយ) រូប ដែលរួមមានប្រធាន ១ (មួយ) រូប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងសមាជិកចំនួន ៣ (បី) រូប។ ភារកិច្ចទទួលខុសត្រូវរបស់សមាសភាព គ.ក.ប ត្រូវបានកំណត់ ដូចខាងក្រោម ៖

២.៩.១.១ ប្រធាន គ.ក.ប មានភារៈទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ។

២.៩.១.២ អនុប្រធាន គ.ក.ប មានភារៈជាជំនួយការរបស់ប្រធាន ទទួលខុសត្រូវក្នុងការពិនិត្យការស៊កសន្លឹកឆ្នោតទៅក្នុងហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងផ្តល់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តជូនអ្នកបោះឆ្នោត នៅពេលបោះឆ្នោត ព្រមទាំងក្នុងការកត់ត្រាសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

២.៩.១.៣ លេខាធិការ មានភារៈទទួលខុសត្រូវក្នុងការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត និងផ្តល់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌជូនអ្នកបោះឆ្នោតពេលបោះឆ្នោត ព្រមទាំងការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.៩.១.៤ សមាជិកទី១ ដែលនៅក្នុងការិយាល័យបោះឆ្នោត មានភារៈទទួលខុសត្រូវពិនិត្យការសើកសន្លឹកឆ្នោតទៅក្នុងហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោតចូលក្នុងដបទឹកខ្មៅលុបមិនជ្រះ និងទទួលគូសសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

២.៩.១.៥ សមាជិកទី២ ដែលនៅខាងក្រៅការិយាល័យបោះឆ្នោត មានភារៈទទួលខុសត្រូវជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ជូនអ្នកបោះឆ្នោត និងចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើ ដើម្បីធ្វើមោឃភាព ។

២.៩.១.៦ សមាជិកទី៣ មានភារៈទទួលខុសត្រូវការងារសណ្តាប់ធ្នាប់ រៀបរៀបរយ និងថែរក្សាសម្ភារ ឯកសារបោះឆ្នោតនៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត ។

២.៩.២ គ.ក.ប ត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ ២.១០៤ ដល់ប្រការ ២.១១៤ នៃ ប.ន.ក នេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.៩.៣ គ.ក.ប ត្រូវទទួលខុសត្រូវចំពោះមុខ គធ.ខប ។

២.៩.៤ គ.ក.ប ទទួលសេចក្តីណែនាំពី គ.ជ.ប តាមរយៈ គធ.ខប ។

**បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំងសមាសភាព គ.ក.ប**

**ប្រការ ២.១០.-**

បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គ.ក.ប ត្រូវអនុវត្តតាមផ្នែកទី៤ នៃជំពូកទី២ នៃ ច.គ.ជ.ប និងផ្នែកទី៣ និងផ្នែកទី៤ នៃជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និងតាមសេចក្តីសម្រេចរបស់ គ.ជ.ប ។

២.១០.១ សមាសភាព គ.ក.ប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

២.១០.២ អ្នកដែលត្រូវបានជ្រើសរើសជាសមាជិក គ.ក.ប គឺជាបេក្ខជនដាក់ពាក្យសុំចូលបម្រើការងារណាដែលបានទទួលជោគជ័យក្នុងការធ្វើសម្ភាសន៍ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង និងបានចុះហត្ថលេខាលើកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប (ទ.១០០២) នៅក្រោយពេលវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់។ ក្នុងការជ្រើសរើសនេះ ត្រូវផ្តល់អាទិភាពចំពោះបេក្ខជនដែលជាអ្នកធ្លាប់មានបទពិសោធន៍ក្នុងការងារបោះឆ្នោតពីមុនមក ឬបទពិសោធន៍ការងារពាក់ព័ន្ធនឹងមុខតំណែង ។

២.១០.៣ បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួមវគ្គបណ្តុះបណ្តាលត្រូវដាក់ជំនួសជាបន្ទាន់ដោយបេក្ខជនបម្រុង ។

២.១០.៤ ប្រសិនបើគ្មានបេក្ខជនបម្រុងសម្រាប់ជំនួស គធ.ខប ត្រូវចាត់ចែងស្នើសុំ គ.ជ.ប ជ្រើសរើសអ្នកជំនួសជាបន្ទាន់ ។

២.១០.៥ ដើម្បីទទួលបានការជ្រើសរើស និងបានបម្រើការងារក្នុងលក្ខណជាប់កិច្ចសន្យាជាសមាជិក គ.ក.ប បេក្ខជនដាក់ពាក្យសុំចូលបម្រើការងារត្រូវ ៖

២.១០.៥.១ ឆ្លងកាត់ដោយជោគជ័យនូវការធ្វើសម្ភាសន៍ ដែលគ្រប់គ្រង និងត្រួតពិនិត្យដោយអនុគណៈកម្មការជ្រើសរើស ។

២.១០.៥.២ គោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាម ច.គ.ជ.ប ច.ប.ត.រ ច.ប.ក និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

២.១០.៥.៣ យល់ព្រមធ្វើសច្ចាប្រណិធានថា ប្រកាន់ជំហរអព្យាក្រឹត និងមិនលម្អៀង ។

២.១០.៥.៤ យល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កម្រៃ ។

២.១០.៥.៥ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង ។

២.១០.៥.៦ ចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប ។

២.១០.៦ ទម្រង់បែបបទសម្រាប់បំពេញកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប (ទ.១០០២) ត្រូវបញ្ជាក់ ៖

២.១០.៦.១ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតដែលបុគ្គលនោះត្រូវបានតែងតាំង ។

២.១០.៦.២ ឈ្មោះ អាសយដ្ឋាន និងភស្តុតាងបញ្ជាក់ពីភាពមានសិទ្ធិបោះឆ្នោតនៃអ្នកដែលត្រូវតែងតាំង ។

២.១០.៦.៣ មុខតំណែងក្នុង គ.ក.ប នៃអ្នកដែលត្រូវតែងតាំង ។

២.១០.៦.៤ លក្ខខណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវនៃអ្នកដែលត្រូវបានតែងតាំង ។

២.១០.៦.៥ ការសន្យាយល់ព្រមទទួលយកភារកិច្ច លក្ខខណ្ឌការងារ និងប្រាក់កម្រៃ ។

២.១០.៦.៦ ការសន្យាថា នឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និងមិនលម្អៀង ។

២.១០.៦.៧ ការសន្យាថា នឹងអនុវត្តតាម ច.គ.ជ.ប ច.ប.ត.រ ច.ប.ក និងបទបញ្ជា និងនីតិវិធី ព្រមទាំងរាល់សេចក្តីណែនាំរបស់ គ.ជ.ប ។

២.១០.៦.៨ ការសន្យាថា នឹងគោរពតាមគោលការណ៍នៃការបោះឆ្នោត ។

២.១០.៦.៩ ហត្ថលេខារបស់អ្នកដែលត្រូវតែងតាំង ហត្ថលេខាសមាជិកទទួលបន្ទុករដ្ឋបាល និងហត្ថលេខារបស់ប្រធាន គធ.ខប ។

២.១០.៧ សមាសភាព គ.ក.ប ត្រូវតែជ្រើសរើសដោយផ្អែកតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

២.១០.៨ គធ.ខប ត្រូវប្រគល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងជាសមាជិក គ.ក.ប ទាំងអស់តាមរាជធានី ខេត្តរបស់ខ្លួន ដោយភ្ជាប់ជាមួយនូវកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប (ទ.១០០២) ដែលបានបំពេញ និងចុះហត្ថលេខារួចម្នាក់ៗ ១ (មួយ) ច្បាប់ ដើម្បីស្នើសុំសេចក្តីសម្រេចតែងតាំងពី គ.ជ.ប ។

២.១០.៩ នៅពេលទទួលបានសំណើតែងតាំង ដូចមានចែងក្នុងចំណុច ២.១០.៨ ខាងលើ គ.ជ.ប ត្រូវពិនិត្យ និងចេញសេចក្តីសម្រេចតែងតាំង គ.ក.ប ជាផ្លូវការ ហើយត្រូវរក្សាទុកឯកសារនៃបញ្ជីឈ្មោះ គ.ក.ប ទាំងនោះ ។

២.១០.១០ បន្ទាប់ពីទទួលបានសេចក្ដីសម្រេចរបស់ គ.ជ.ប គធ.ខប ត្រូវបំពេញ និងផ្ដល់បណ្ណសម្គាល់ខ្លួនជូនសមាជិក គ.ក.ប សម្រាប់ពាក់នៅពេលបំពេញភារកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន ។

២.១០.១១ សមាជិក គ.ក.ប ត្រូវស្ថិតនៅក្នុងមុខតំណែង រហូតដល់បញ្ចប់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនិងក្រោយពីបានប្រគល់កំណត់ហេតុនៃការបោះឆ្នោតកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គធ.ខប រួចរាល់ហើយ។ ផ្អែកតាមមុខតំណែងរបស់ខ្លួន សមាជិក គ.ក.ប ម្នាក់ៗនឹងទទួលបានប្រាក់កម្រៃជាប្រាក់រៀល សម្រាប់ការងាររបស់ខ្លួន ដោយគិតបញ្ចូលទាំងថ្លៃម្ហូបអាហារ និងថ្លៃធ្វើដំណើរផង ។

២.១០.១១.១ ចំនួនទឹកប្រាក់ដែលត្រូវបានផ្ដល់ជាកម្រៃ សម្រាប់ការបំពេញការងារនៃសមាជិក គ.ក.ប ក្នុងរយៈពេល ៤ (បួន) ថ្ងៃ ដោយគិតទាំងការចូលរួមវគ្គបណ្ដុះបណ្ដាលផង ។

២.១០.១១.២ ក្នុងករណីសមាជិក គ.ក.ប ណាដែលតម្រូវឱ្យស្ថិតក្នុងមុខតំណែងយូរជាងការកំណត់ ដូចមានចែងក្នុងចំណុច ២.១០.១១.១ ខាងលើ មន្ត្រីនោះនឹងត្រូវទទួលបានប្រាក់កម្រៃបន្ថែម តាមសេចក្ដីសម្រេចរបស់ គ.ជ.ប ។

២.១០.១២ គធ.ខប ត្រូវអនុវត្តការវាយតម្លៃសមាជិក គ.ក.ប ទាំងអស់ចំណុះរាជធានី ខេត្ត រយៈពេល ២ (ពីរ) សប្ដាហ៍យ៉ាងយូរ បន្ទាប់ពីថ្ងៃបោះឆ្នោត។

២.១០.១២.១ នៅមុនបញ្ចប់ភារកិច្ចរបស់ខ្លួន គធ.ខប ត្រូវផ្ដល់កំណត់ហេតុវាយតម្លៃសមាជិក គ.ក.ប (ទ.១១១៣) ដែលបានបំពេញរួចហើយទៅ គ.ជ.ប។

២.១០.១២.២ គ.ជ.ប ត្រូវកត់ត្រាបន្ថែមទិន្នន័យនៃកំណត់ហេតុវាយតម្លៃសមាជិក គ.ក.ប ទាំងអស់ទៅក្នុងបញ្ជីឈ្មោះនៃសមាជិក គ.ក.ប ដែលត្រូវរក្សាទុក ។

## ប្រព័ន្ធជ្រើសរើសសមាជិក គធ.ខប មន្ត្រី លគធ.ខប និងសមាសភាព គ.ក.ប

## ប្រការ ២.១១.-

ប្រព័ន្ធជ្រើសរើសសមាជិក គធ.ខប មន្ត្រី លគធ.ខប និងសមាសភាព គ.ក.ប ត្រូវឈរលើគោលការណ៍ស្មើភាព ដោយត្រឹមត្រូវ តម្លាភាព អព្យាក្រឹត សមត្ថភាព មិនប្រកាន់និន្នាការនយោបាយ និងការងារពាក់ព័ន្ធដែលមានកំណត់នៅក្នុងបទបញ្ញាផ្ទៃក្នុងរបស់ គ.ជ.ប និងតាមសេចក្ដីសម្រេចរបស់ គ.ជ.ប។ គ.ជ.ប លើកទឹកចិត្ត និងផ្ដល់អាទិភាពដល់បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងការងារពាក់ព័ន្ធ ។

## ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត

### ប្រការ ២.១២.-

ប្រាក់កម្រៃរបស់សមាជិក និងមន្ត្រី បុគ្គលិកនៃគណៈកម្មាធិការជាតិ និងសមាជិក និងមន្ត្រី បុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដោយសេចក្ដីសម្រេចរបស់ គ.ជ.ប ។

២.១២.១ ប្រាក់កម្រៃត្រូវបើកជារៀងរាល់ខែចំពោះ អ.គ.ជ.ប និងមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា ហើយត្រូវបើកផ្ដាច់ចំពោះមន្ត្រី បុគ្គលិកក្រោយការបញ្ចប់ការងារ ។

២.១២.២ ប្រាក់កម្រៃត្រូវបើកជូនជាប្រាក់រៀល បន្ទាប់ពី គ.ជ.ប ទទួលបានប្រាក់ពីអគ្គនាយកដ្ឋានរតនាគារជាតិ ។

## អាណត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

### ប្រការ ២.១៣.-

អាណត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ រួមមាន៖

២.១៣.១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់មានសមាសភាព គ.ជ.ប ថ្មី ចូលកាន់តំណែង ។

២.១៣.២ គធ.ខប ត្រូវបំពេញភារកិច្ចរបស់ខ្លួន រហូតដល់ ៣០ (សាមសិប) ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ អាណត្តិរបស់ គធ.ខប ដូចមានចែងក្នុងចំណុចនេះ អាចកំណត់ផ្សេងពីនេះ ដោយសេចក្ដីសម្រេចរបស់ គ.ជ.ប តាមតម្រូវការជាក់ស្ដែង។

២.១៣.៣ គ.ក.ប ត្រូវបំពេញការងាររបស់ខ្លួន រហូតដល់បញ្ចប់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងក្រោយពីបានប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គធ.ខប រួចរាល់ហើយ។

## ការតែងតាំងក្នុងរយៈពេលមានកំណត់

### ប្រការ ២.១៤.-

គ.ជ.ប មានសិទ្ធិតែងតាំង គធ.ខប ឬ គ.ក.ប ក្នុងរយៈពេលមានកំណត់នៅពេលណាមួយ បន្ទាប់ពីការបោះឆ្នោតជាទូទៅត្រូវបានបញ្ចប់ ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មី (ប្រសិនបើមាន) ។

២.១៤.១ ក្នុងការតែងតាំងក្នុងរយៈពេលមានកំណត់នេះ នីតិវិធីនៃការជ្រើសរើស រចនាសម្ព័ន្ធ សមាសភាព លក្ខណៈវិនិច្ឆ័យ សិទ្ធិអំណាច ការទទួលខុសត្រូវ ប្រាក់កម្រៃត្រូវអនុលោមតាម ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប.ន.ក នេះ និងតាមការសម្រេចរបស់ គ.ជ.ប ។

២.១៤.២ អាណត្តិរបស់ គធ.ខប និង គ.ក.ប ដែលត្រូវបានតែងតាំងក្នុងរយៈពេលមានកំណត់ត្រូវបញ្ចប់នៅពេលចប់ភារកិច្ចតាមការកំណត់របស់ គ.ជ.ប ។

## គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខាររបស់ គ.ជ.ប

### ប្រការ ២.១៥.-

សម្ភារ និងបរិក្ខាររបស់ គ.ជ.ប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការងាររៀបចំការបោះឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់ គ.ជ.ប ។

២.១៥.១ គ្មានសមាជិក ឬបុគ្គលិកនៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយ អាចប្រើប្រាស់បរិក្ខារ ឬ/និងសម្ភាររបស់ គ.ជ.ប ក្រៅពីការរៀបចំការបោះឆ្នោតឡើយ។ ត្រូវបានកំណត់ជាសម្ភារ និងបរិក្ខារមានដូចជា រថយន្ត ម៉ូតូ សម្ភារការិយាល័យ សម្ភារចុះឈ្មោះបោះឆ្នោត សម្ភារបោះឆ្នោត និងសម្ភាររាប់សន្លឹកឆ្នោត ឬសម្ភារផ្គត់ផ្គង់ការបោះឆ្នោត និងប្រេងឥន្ធនៈ ។

២.១៥.២ ប្រសិនបើសមាជិក ឬបុគ្គលិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយល្មើសនឹងចំណុច ២.១៥.១ ជននោះនឹងត្រូវដាក់វិន័យ ។ វិធានការដាក់វិន័យ គឺគិតចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

២.១៥.៣ សមាជិក ឬបុគ្គលិកនៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយ ដែលល្មើសក្នុងការប្រើប្រាស់សម្ភារ បរិក្ខារទាំងនេះ ត្រូវទូទាត់សងតម្លៃទៅតាមការកំណត់របស់ គ.ជ.ប ។

២.១៥.៤ ប្រសិនបើសមាជិក ឬបុគ្គលិកណាម្នាក់នៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ធ្វើឱ្យសម្ភារ បរិក្ខារបាត់បង់ ឬខូចខាតក្នុងពេលប្រើប្រាស់ខុសច្បាប់ បុគ្គលនោះត្រូវទូទាត់សងតម្លៃនៃសម្ភារ បរិក្ខារដែលបានបាត់បង់ ឬខូចខាតនោះ។

២.១៥.៥ គ.ជ.ប ត្រូវចេញផ្សាយបទបញ្ជាជាមូលដ្ឋានសម្រាប់ការប្រើប្រាស់សម្ភារ បរិក្ខារទាំងនោះ ។

## ប្រតិទិននៃការងារបោះឆ្នោត

### ប្រការ ២.១៦.-

គ.ជ.ប ត្រូវផ្សព្វផ្សាយប្រតិទិននៃការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១៦.១ បន្ទាប់ពីប្រកាសថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គ.ជ.ប ត្រូវចាត់ចែងធ្វើប្រតិទិនការងារបោះឆ្នោត និងផ្សព្វផ្សាយជាបន្ទាន់ ។

២.១៦.២ ប្រតិទិននៃការបោះឆ្នោតត្រូវកំណត់ ៖

- ថ្ងៃចាប់ផ្តើមចុះឈ្មោះអ្នកសង្កេតការណ៍ និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើមចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត
- ថ្ងៃចាប់ផ្តើមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងថ្ងៃបញ្ឈប់ទទួលពាក្យ
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត និងថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន និងលទ្ធផលផ្លូវការ
- ថ្ងៃទទួល និងដោះស្រាយពាក្យបណ្តឹងតាមដំណាក់កាលនីមួយៗ ។

## ការងារសន្តិសុខបោះឆ្នោត

### ប្រការ ២.១៧.-

គ.ជ.ប មានសិទ្ធិ អំណាច ភារកិច្ច និងការទទួលខុសត្រូវក្នុងការលើកវិធានការ និងចាត់ចែងការងារដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការបោះឆ្នោត ក្នុងនោះត្រូវណែនាំ គធ.ខប និង គ.ក.ប ឱ្យសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច លើកវិធានការការពារ បង្ការ និងដោះស្រាយជាក់ស្តែង តាមពេលវេលា ទីកន្លែងក្នុងភូមិសាស្ត្រ និងចាត់ចែងឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងធ្វើការផ្សព្វផ្សាយ ក្នុងករណីចាំបាច់ ។

### ប្រការ ២.១៨.-

ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត តាមសំណើរបស់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

២.១៨.១ ផ្អែកតាមផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប លេខ ០០៩ ផក/១៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ - ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦-២០១៩ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ អក្សរកាត់ (គ.ស.អ) ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានតួនាទី ភារកិច្ចត្រូវសហការ និងរៀបចំចាត់វិធានការ ឬសេចក្តីណែនាំផ្សេងៗ ស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ និងតាមដាន ត្រួតពិនិត្យ គ្រប់គ្រងការប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត នៅក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១៨.២ គ.ជ.ប មានលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន ដែលត្រូវបង្កើតឡើងតាមសេចក្តីសម្រេចរបស់ គ.ជ.ប ជាជំនួយការផ្នែកការងារសន្តិសុខបោះឆ្នោតឱ្យ គ.ជ.ប មានភារកិច្ចសម្របសម្រួល និងសហការជាមួយលេខាធិការដ្ឋានរបស់ គ.ស.អ ឬ/និងអង្គភាពជំនាញនៃស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំខ្លឹមសារនៃផែនការ ឬសេចក្តីណែនាំផ្សេងៗស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដើម្បីជួយការងារបច្ចេកទេស និងរដ្ឋបាល ។

២.១៨.៣ យន្តការ និងរចនាសម្ព័ន្ធផ្នែកសន្តិសុខរបស់ គ.ជ.ប និង គ.ស.អ ។



២.១៨.៤ គ.ជ.ប (លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន) គធ.ខប និង គ.ក.ប/គ.ក.រ ត្រូវសហការតាមឋានានុក្រមនៃរចនាសម្ព័ន្ធចាត់តាំងផ្នែកសន្តិសុខរបស់ គ.ស.អ ដែលរួមមាន៖ លេខាធិការដ្ឋានរបស់ គ.ស.អ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដូចបានកំណត់បង្ហាញក្នុងចំណុច ២.១៨.៣ ខាងលើ ។ ដោយនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ពុំមានគណៈកម្មការរៀបចំការបោះឆ្នោត ដូចនេះអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលជាប្រធានគណៈបញ្ជាការឯកភាពក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំក្រុមប្រឹក្សាឃុំ សង្កាត់ និងប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ឱ្យផ្តល់កិច្ចសហការ និងគាំទ្រដល់ គ.ក.ប/គ.ក.រ លើការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងដំណើរការបោះឆ្នោត ។

២.១៨.៥ ភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ត្រូវស្ថិតក្នុងឯកសណ្ឋានផ្លូវការរបស់នគរបាលជាតិ ឬកងយោធពលខេមរភូមិន្ទឱ្យបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមគោលការណ៍នៃ ច.ប.ក ច.ប.គ.រ ប.ន.ក នេះ និងក្រមសីលធម៌ ព្រមទាំងសេចក្តីណែនាំផ្សេងៗ។ យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតត្រូវចាត់ចែងភ្នាក់ងារសន្តិសុខបោះឆ្នោតឱ្យការពារមុខសញ្ញា និងគោលដៅសំខាន់ៗតាមសំណូមពររបស់ គ.ជ.ប ឬ/និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីការពារមុខសញ្ញា ឬគោលដៅខ្លះដែលត្រូវការពារជារួម ឬការពារដោយប្រយោល ដោយយោងទៅលើលទ្ធភាពនៃការប្រើប្រាស់កម្លាំង មធ្យោបាយ សម្ភារនៅក្នុងការការពារមុខសញ្ញា និងគោលដៅដែលបានកំណត់។ មុខសញ្ញា និងគោលដៅសំខាន់ៗ រួមមាន ៖

**ក. មុខសញ្ញាការពារ**

- សមាជិក គ.ជ.ប មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់របស់ គ.ជ.ប
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងអ្នកគាំទ្រ
- អ្នកមានសិទ្ធិបោះឆ្នោត
- អ្នកសង្កេតការណ៍បោះឆ្នោតនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ភ្នាក់ងារគណបក្សនយោបាយដែលទទួលបានការអនុញ្ញាត

- តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬប្រទេសនានា និង តំណាងអង្គការអន្តរជាតិដែលត្រូវបាន គ.ជ.ប អញ្ជើញឱ្យចូលរួមជាអ្នកសង្កេតការណ៍ ។

**ខ. គោលដៅការពារ**

- ទីស្តីការ គ.ជ.ប និង លគធ.ខប
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត
- កន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងសម្ភារិមបម្រើការងារបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅគោលដៅមួយដែលកំណត់ដោយ គ.ជ.ប ឬ គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ទីស្នាក់ការ និងកន្លែងជួបប្រជុំ ឬក្បួនព្យុហយាត្រាឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ។

២.១៨.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មដែលជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន មានភារកិច្ចពិនិត្យរៀបចំគម្រោងផលិតឯកសារ និងសម្ភារទាក់ទងការងារសន្តិសុខសំខាន់ៗរួមមាន សៀវភៅក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ខិត្តប័ណ្ណផ្សព្វផ្សាយផ្សេងៗទាក់ទងការងារសន្តិសុខ និងប្រឡង់ដៃសន្តិសុខ ដើម្បីសុំគោលការណ៍សម្រេចពី គ.ជ.ប ។

២.១៨.៧ គធ.ខប ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះ ក្នុងគោលដៅជួបពិភាក្សា និងស្វែងរកដំណោះស្រាយសមស្រប រួមនឹងការចាត់វិធានការផ្សេងៗដើម្បីបង្ការ ទប់ស្កាត់ និងកាត់បន្ថយឱ្យបានរាល់បញ្ហាទំនាស់ ឬក៏បាតុភាពនានា ដែលអាចនឹងកើតមានឡើងជាយថាហេតុនៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត។ កិច្ចប្រជុំត្រូវរៀបចំប្រជុំម្តងក្នុងមួយសប្តាហ៍ និងអាចកោះប្រជុំតាមការចាំបាច់។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន ៖

- ប្រធាន គធ.ខប ជាសហប្រធាន
- អភិបាលរាជធានី ខេត្ត ឬតំណាង ១ នាក់ ជាសហប្រធាន
- តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជាសមាជិក
- តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ជាសមាជិក

- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង ១ នាក់ ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ១ នាក់ ជាសមាជិក
- មេបញ្ជាការយោធភូមិភាគពិសេស ឬយោធភូមិភាគ ១-៥ នៃរាជធានី ខេត្តពាក់ព័ន្ធ ឬតំណាង ១ នាក់ ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត ឬតំណាង ១ នាក់ ជាសមាជិក

២.១៨.៨ នៅពេលឃោសនាបោះឆ្នោត យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលកំពុងបំពេញភារកិច្ចមិនត្រូវ ៖

២.១៨.៨.១ ឈរក្បែរ ឬដើរកៀកពេកនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា ដោយត្រូវធានាចំពោះគ្រប់គណបក្សនយោបាយឈរឈ្មោះ និងបេក្ខជនគ្រប់រូបនូវសិទ្ធិស្មើៗគ្នាក្នុងការធ្វើសកម្មភាព និងក្នុងការទទួលបានសេវាសន្តិសុខ សុវត្ថិភាព ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយពីអាជ្ញាធរមានសមត្ថកិច្ច ។

២.១៨.៨.២ ចូលរួមគាំទ្រ ឬប្រឆាំងចំពោះសកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះណាមួយ ឬបេក្ខជនណាម្នាក់ដាច់ខាត ។

២.១៨.៩ នៅថ្ងៃបោះឆ្នោតភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣ (បី) នាក់ ដែលការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតែមួយដាច់តែឯងត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប រហូតដល់ចប់ភារកិច្ច ។

២.១៨.៩.១ ភ្នាក់ងារសន្តិសុខបោះឆ្នោត ១ (មួយ) នាក់ ត្រូវចល័តការពារជុំវិញការិយាល័យ ឬក៏ចល័តការពារនៅក្នុងបរិវេណខាងក្រៅនៃការិយាល័យ ដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១៥ (ដប់ប្រាំ) ម៉ែត្រ ទៅ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យ និងមិនចាំបាច់ប្រើប្រាស់អាវុធ ។

២.១៨.៩.២ ភ្នាក់ងារសន្តិសុខបោះឆ្នោត ២ (ពីរ) នាក់ ត្រូវចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យ ដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១០០ (មួយរយ) ម៉ែត្រ ទៅ ១៥០ (មួយរយហាសិប) ម៉ែត្រ អាចប្រើប្រាស់អាវុធវែង ១(មួយ)ដើមដែលមានគ្រាប់យ៉ាងច្រើន ៣០(សាមសិប)គ្រាប់ ។

២.១៨.១០ ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតច្រើន ប្រមូលផ្តុំនៅក្នុងបរិវេណ ឬអគារតែមួយ ចំនួនភ្នាក់ងារសន្តិសុខបោះឆ្នោតសម្រាប់ការិយាល័យនីមួយៗ ត្រូវសមស្របទៅនឹងស្ថានភាពជាក់ស្តែង ប៉ុន្តែមិនត្រូវឱ្យលើសពី ៣ (បី) នាក់ក្នុងមួយការិយាល័យ ។

២.១៨.១១ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីជៀសវាងការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬក៏ហេតុការណ៍អសន្តិសុខផ្សេងៗ ដែលនឹងអាចកើតមានជាថែដន្យ ។

២.១៨.១២ ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ ឬ/និងក្រុមពន្លត់អគ្គិភ័យ...) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានតែក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ.ខប ឬពីប្រធាន គ.ក.ប/គ.ក.រ ។

# ផ្នែកទី ២
# ប្រព័ន្ធបោះឆ្នោត និងរូបមន្ត

**ប្រព័ន្ធបោះឆ្នោត**

**ប្រការ ២.១៩.–**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវអនុវត្តតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយយករាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងយកក្រុង ស្រុក ខណ្ឌ ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយការបែងចែកអាសនៈតាមមណ្ឌលនីមួយៗ ត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ។

**ប្រការ ២.២០.–**

អាសនៈក្នុងក្រុមប្រឹក្សារាជធានី ខេត្ត និងអាសនៈក្នុងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានបែងចែកដោយផ្អែកលើចំនួនអាសនៈតាមក្រុមប្រឹក្សា និងលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលបោះឆ្នោតនីមួយៗ។ គជ.ខប ត្រូវធ្វើការបែងចែកអាសនៈ និងកំណត់ចំនួនអាសនៈដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សា សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតតាមមណ្ឌលបោះឆ្នោតនីមួយៗ ។

**ប្រការ ២.២១.–**

បេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាត្រូវបានស្រង់ចេញ ដោយផ្អែកតាមលំដាប់លេខរៀងនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដែលបានជាប់ឆ្នោតនៅក្នុងមណ្ឌលនៃក្រុមប្រឹក្សានីមួយៗ ។

**រូបមន្តនៃការបែងចែកអាសនៈ**

**ប្រការ ២.២២.–**

ដើម្បីបែងចែកអាសនៈតាមមណ្ឌលបោះឆ្នោតក្រុមប្រឹក្សានីមួយៗ គជ.ខប ត្រូវអនុវត្តតាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទី១ : ការកំណត់កូតា (Quota)**

២.២២.១ កូតាគឺជាចំនួនសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលបោះឆ្នោតនីមួយៗដែលកំណត់ឡើងសម្រាប់ឱ្យគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅក្នុងមណ្ឌលនោះ ទទួលបាន ១ (មួយ) អាសនៈ ។

២.២២.២ ដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ចែកនឹងចំនួនអាសនៈសរុប ដែលបានកំណត់សម្រាប់មណ្ឌលបោះឆ្នោតនោះ តាមរូបមន្ត ៖

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ៖

- $ក_{ត}$ តាងឱ្យកូតា ជាផលចែកដែលត្រូវគិតដល់ ២ (ពីរ) ខ្ទង់ក្រោយក្បៀស។
- $ស_{ស}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប។
- $អ_{ស}$ តាងឱ្យចំនួនអាសនៈសរុប ។

**ឧទាហរណ៍ : ការកំណត់កូតា**

នៅមណ្ឌលបោះឆ្នោតក្រុមប្រឹក្សាខេត្ត A មាន ៖

- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ = ១.៧៦៥ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ៩ អាសនៈ

$$ក_{ត} = \frac{ស_{ស}}{អ_{ស}} = \frac{១.៧៦៥}{៩} = ១៩៦,១១$$

កូតាស្មើនឹង ១៩៦,១១ ($ក_{ត}$ = ១៩៦,១១)

**ជំហានទី២ : ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈលើកទី១**

២.២២.៣ ដើម្បីកំណត់ចំនួនអាសនៈបឋម សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន មកចែកនឹងកូតា ដោយមិនគិតសំណល់ចែក តាមរូបមន្តដូចខាងក្រោម ៖

$$អ_{១} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ ៖

- $អ_{១}$ តាងឱ្យចំនួនអាសនៈ ជាផលចែកមិនគិតសំណល់ចែក ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ។

- ស$_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ។
- ក$_{ត}$ តាងឱ្យកូតា ។

**ឧទាហរណ៍ : ការបែងចែកអាសនៈលើកទី១**

នៅមណ្ឌលបោះឆ្នោតក្រុមប្រឹក្សាខេត្ត A ដដែល មានបញ្ជីបេក្ខជននៃគណបក្សនយោបាយ ចំនួន ៧ ៖

| | | | | | | |
|---|---|---|---|---|---|---|
| គណបក្ស | **ក** | មានសន្លឹកឆ្នោតបានការ | ស$_{ប}$ក | = | ១២៣ | សន្លឹក |
| គណបក្ស | **ខ** | មានសន្លឹកឆ្នោតបានការ | ស$_{ប}$ខ | = | ៣៣១ | សន្លឹក |
| គណបក្ស | **គ** | មានសន្លឹកឆ្នោតបានការ | ស$_{ប}$គ | = | ៩៨ | សន្លឹក |
| គណបក្ស | **ឃ** | មានសន្លឹកឆ្នោតបានការ | ស$_{ប}$ឃ | = | ៥១២ | សន្លឹក |
| គណបក្ស | **ង** | មានសន្លឹកឆ្នោតបានការ | ស$_{ប}$ង | = | ៣៩៥ | សន្លឹក |
| គណបក្ស | **ច** | មានសន្លឹកឆ្នោតបានការ | ស$_{ប}$ច | = | ៥៤ | សន្លឹក |
| គណបក្ស | **ឆ** | មានសន្លឹកឆ្នោតបានការ | ស$_{ប}$ឆ | = | ២៥២ | សន្លឹក |

អនុវត្តតាមរូបមន្ត ដូចមានចែងក្នុងចំណុច ២.២២.៣ យើងបាន ៖

គណបក្ស **ក** អ$_{ទ}$ក $= \frac{១២៣}{១៩៦,១១} =$ ០,៦២ ត្រូវជា ០ អាសនៈ

គណបក្ស **ខ** អ$_{ទ}$ខ $= \frac{៣៣១}{១៩៦,១១} =$ ១,៦៨ ត្រូវជា ១ អាសនៈ

គណបក្ស **គ** អ$_{ទ}$គ $= \frac{៩៨}{១៩៦,១១} =$ ០,៤៩ ត្រូវជា ០ អាសនៈ

គណបក្ស **ឃ** អ$_{ទ}$ឃ $= \frac{៥១២}{១៩៦,១១} =$ ២,៦១ ត្រូវជា ២ អាសនៈ

គណបក្ស **ង** អ$_{ទ}$ង $= \frac{៣៩៥}{១៩៦,១១} =$ ២,០១ ត្រូវជា ២ អាសនៈ

គណបក្ស **ច** អ$_{ទ}$ច $= \frac{៥៤}{១៩៦,១១} =$ ០,២៧ ត្រូវជា ០ អាសនៈ

គណបក្ស **ឆ** អ$_{ទ}$ឆ $= \frac{២៥២}{១៩៦,១១} =$ ១,២៨ ត្រូវជា ១ អាសនៈ

២.២២.៤ បន្ទាប់ពីការគណនាបែងចែកអាសនៈ គ្រប់គណបក្សនយោបាយទាំងអស់ក្នុងជំហានទី២ រួច ប្រសិនបើគ្មានអាសនៈនៅសល់ នោះចំនួនអាសនៈត្រូវកំណត់យកតែម្តង ។

**ជំហានទី៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត**

២.២២.៥ ក្នុងករណីមានអាសនៈនៅសល់ គជ.ឧប ត្រូវបន្តបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមការគណនាដូចខាងក្រោម ៖

២.២២.៥.១ ត្រូវកំណត់ជាដំបូងនូវមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ចែកនឹងចំនួនអាសនៈបឋម ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលបន្ទាប់ពីការគណនាក្នុងជំហានទី២ បូកនឹងលេខនិមិត្តចំនួន ១ (មួយ) តាមរូបមន្តដូចខាងក្រោម ៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ទ} + ១}$$

ក្នុងនោះ៖

- $ម_{ធ}$ តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $ស_{ប}$ តាងឱ្យសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $អ_{ទ}$ តាងឱ្យចំនួនអាសនៈបឋម ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបាន បន្ទាប់ពីការបែងចែកលើកទី១ ។
- ១ ជាលេខនិមិត្ត ។

២.២២.៥.២ ក្នុងការគណនារកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ប្រសិនបើលេខចែកមិនដាច់ ត្រូវបន្តចែកដល់ ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់រកបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ ។

២.២២.៥.៣ បន្ទាប់ពីកំណត់បានមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចហើយ ត្រូវធ្វើការប្រៀបធៀបគ្នា។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណា មានមធ្យមភាគធំជាងគេដែលជាមធ្យមភាគខ្ពស់បំផុតត្រូវទទួលបានអាសនៈ ១ (មួយ)។

**ឧទាហរណ៍** : **ការបែងចែកអាសនៈលើកទី២**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល តាមការបែងចែកអាសនៈលើកទី១ យើងបាន ៖

គណបក្ស **ក** បានទទួលអាសនៈ ០

គណបក្ស **ខ** បានទទួលអាសនៈ ១

គណបក្ស **គ** បានទទួលអាសនៈ ០

គណបក្ស **ឃ** បានទទួលអាសនៈ ២

គណបក្ស **ង** បានទទួលអាសនៈ ២

គណបក្ស **ច** បានទទួលអាសនៈ ០

គណបក្ស **ឆ** បានទទួលអាសនៈ ១

- អាសនៈដែលបានបែងចែកលើកទី១ មាន ៦ អាសនៈ
- អាសនៈសរុបក្នុងមណ្ឌលខេត្ត A មាន ៩ អាសនៈ
- អាសនៈនៅសល់ដែលត្រូវបន្តធ្វើការបែងចែកមាន ៣ អាសនៈ

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងការបែងចែកអាសនៈលើកទី២ នេះ យើងបាន ៖

គណបក្ស **ក** ម$_{ធ}$ក = $\frac{១២៣}{០ + ១}$ = ១២៣,០០

គណបក្ស **ខ** ម$_{ធ}$ខ = $\frac{៣៣១}{១ + ១}$ = ១៦៥,៥០

គណបក្ស **គ** ម$_{ធ}$គ = $\frac{៩៨}{០ + ១}$ = ៩៨,០០

គណបក្ស **ឃ** ម$_{ធ}$ឃ = $\frac{៥១២}{២ + ១}$ = **១៧០,៦៦**

គណបក្ស **ង** ម$_{ធ}$ង = $\frac{៣៩៥}{២ + ១}$ = ១៣១,៦៦

គណបក្ស **ច** ម$_{ធ}$ច = $\frac{៥៤}{០ + ១}$ = ៥៤,០០

គណបក្ស **ឆ** ម$_{ធ}$ឆ = $\frac{២៥២}{១ + ១}$ = ១២៦,០០

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៧ (ប្រាំពីរ) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគខ្ពស់ជាងគេគឺ **១៧០,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះបញ្ជីបេក្ខជននៃគណបក្ស ឃ ត្រូវទទួលបានអាសនៈ ១ (មួយ)។

២.២២.៦ ក្នុងករណីមាននៅសល់អាសនៈ គធ.ខប ត្រូវបន្តបែងចែកទៀតតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដដែល ដោយបង្កើនតម្លៃ អ៖ ចំនួន ១ (មួយ) ចំពោះគណបក្សនយោបាយណាដែលទើបទទួលបានអាសនៈបន្ថែមចំនួន ១ (មួយ) បន្ទាប់ពីការបែងចែកមួយលើកៗ ។

**ឧទាហរណ៍ : ការបែងចែកអាសនៈលើកទី៣**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល តាមការបែងចែកអាសនៈលើកទី២ យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ: ០ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ: ១ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ: ០ ដដែល

**បញ្ជីបេក្ខជននៃគណបក្ស ឃ បានទទួលអាសនៈ: ៣ (បាន ១ អាសនៈបន្ថែម)**

បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ: ២ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ: ០ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **ឆ** បានទទួលអាសនៈ: ១ ដដែល

- សរុបអាសនៈដែលបានបែងចែកលើកទី១ និងលើកទី២មាន ៧ អាសនៈ
- អាសនៈសរុបក្នុងមណ្ឌលបោះឆ្នោតក្រុមប្រឹក្សាខេត្ត A មាន ៩ អាសនៈ

ដូចនេះនៅសល់អាសនៈ ២ (ពីរ) ទៀត ដែលត្រូវបន្តបែងចែក។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងការបែងចែកអាសនៈលើកទី៣ នេះ យើងបាន ៖

គណបក្ស **ក** មធក = ១២៣ / (០ + ១) = ១២៣,០០

គណបក្ស **ខ** មធខ = ៣៣១ / (១ + ១) = **១៦៥,៥០**

គណបក្ស **គ** មធគ = ៩៨ / (០ + ១) = ៩៨,០០

គណបក្ស **ឃ** មធឃ = ៥១២ / (៣ + ១) = ១២៨,០០

គណបក្ស **ង** មធង = ៣៩៥ / (២ + ១) = ១៣១,៦៦

គណបក្ស **ច** មធច = ៥៨ / (០ + ១) = ៥៨,០០

គណបក្ស **ឆ** មធឆ = ២៥២ / (១ + ១) = ១២៦,០០

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៧ (ប្រាំពីរ) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេ **១៦៥,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ខ ត្រូវបានទទួលអាសនៈ ១ (មួយ) នាំឱ្យ ៖

បញ្ជីបេក្ខជននៃគណបក្ស **ក** បានទទួលអាសនៈ ០ ដដែល

**បញ្ជីបេក្ខជននៃគណបក្ស ខ បានទទួលអាសនៈ២ (ទទួលបន្ថែម១អាសនៈ)**

បញ្ជីបេក្ខជននៃគណបក្ស **គ** បានទទួលអាសនៈ ០ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ៣ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **ង** បានទទួលអាសនៈ ២ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **ច** បានទទួលអាសនៈ ០ ដដែល

បញ្ជីបេក្ខជននៃគណបក្ស **ឆ** បានទទួលអាសនៈ ១ ដដែល

សរុប = ៨ (ប្រាំបី) អាសនៈ

២.២២.៧ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀត ការគណនាត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ហើយបន្តបែងចែកតាមរបៀបនេះម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈដែលនៅសល់ ។

**ឧទាហរណ៍ : ការបែងចែកអាសនៈបន្ត**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល បន្ទាប់ពីការបែងចែកអាសនៈលើកទី៣ នៅមានសល់អាសនៈចំនួន ១ (មួយ) ទៀត ដែលត្រូវបន្តបែងចែក។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងការបែងចែកលើកទី៤ នេះ យើងបាន៖

គណបក្ស **ក** ម្ធក = $\frac{១២៣}{០ + ១}$ = ១២៣,០០

គណបក្ស **ខ** ម្ធខ = $\frac{៣៣១}{២ + ១}$ = ១១០,៣៣

គណបក្ស **គ** ម្ធគ = $\frac{៩៨}{០ + ១}$ = ៩៨,០០

គណបក្ស **ឃ** ម្ធឃ = $\frac{៥១២}{៣ + ១}$ = ១២៨,០០

គណបក្ស **ង** ម្ធង = $\frac{៣៩៥}{២ + ១}$ = **១៣១,៦៦**

គណបក្ស **ច** ម្ធច = $\frac{៥៤}{០ + ១}$ = ៥៤,០០

គណបក្ស **ឆ** ម្ធឆ = $\frac{២៥២}{១ + ១}$ = ១២៦,០០

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ៧ (ប្រាំពីរ) ខាងលើឃើញថា បញ្ជីបេក្ខជននៃគណបក្ស **ង** មានមធ្យមភាគធំជាងគេ **១៣១,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះ បញ្ជីបេក្ខជននៃគណបក្ស ង ត្រូវបានទទួលអាសនៈ ១ (មួយ) ដែលនៅសល់ចុងក្រោយនេះ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈ នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ: ២

បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស **ឆ** បានទទួលអាសនៈ ១

បញ្ជីបេក្ខជននៃគណបក្ស **ក គ** និង **ច** ពុំបានទទួលអាសនៈ

សរុប = ៥ (ប្រាំបួន) អាសនៈ

**ប្រការ ២.២៣.-**

ក្នុងករណី ការបែងចែកអាសនៈលើកទី១ តាមរូបមន្តជំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈទេនោះ គធ.ខប ត្រូវបន្តបែងចែក ដោយអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី៣ ម្តង ១ (មួយ) អាសនៈៗ រហូតដល់អស់អាសនៈ ។

**ឧទាហរណ៍**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត B មាន៖

| | | |
|---|---|---|
| - បញ្ជីបេក្ខជននៃគណបក្សនយោបាយមានចំនួន | | = ៩ |
| - សន្លឹកឆ្នោតបានការសរុប | $សស_{ស}$ | = ៨៤៦ សន្លឹក |
| - អាសនៈសរុប | $អ_{ស}$ | = ៧ អាសនៈ |
| - កូតា | $ក_{ត}$ | = ១២០,៨៥ |

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ទាំង ៧ (ប្រាំពីរ) លើក យើងទទួលបាន ៖

| បញ្ជីបេក្ខជននៃ | សប | អទ១ | មធ១ | អទ២ | មធ២ | អទ៣ | មធ៣ | អទ៣ | មធ៤ | អទ៥ | មធ៥ | អទ៦ | មធ៦ | អទ៧ | មធ៧ | អទ៨ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គណបក្ស **ក** | ១១៣ | ០ | ១១៣<br>០+១ | ០ | ១១៣<br>០+១ | ១ | ១១៣<br>១+១ | ០ | ១១៣<br>១+១ | ០ | ១១៣<br>១+១ | ០ | ១១៣<br>១+១ | ០ | ១១៣<br>១+១ | ០ |
| គណបក្ស **ខ** | ៩៧ | ០ | ៩៧<br>០+១ | ០ | ៩៧<br>០+១ | ០ | ៩៧<br>០+១ | ០ | ៩៧<br>០+១ | ០ | ៩៧<br>០+១ | ១ | ៩៧<br>១+១ | ០ | ៩៧<br>០+១ | ០ |
| គណបក្ស **គ** | ៨៦ | ០ | ៨៦<br>០+១ | ០ | ៨៦<br>០+១ | ០ | ៨៦<br>០+១ | ០ | ៨៦<br>០+១ | ០ | ៨៦<br>០+១ | ០ | ៨៦<br>០+១ | ០ | ៨៦<br>០+១ | ១ |
| គណបក្ស **ឃ** | ១១៥ | ០ | ១១៥<br>០+១ | ១ | ១១៥<br>១+១ | ០ | ១១៥<br>១+១ | ០ | ១១៥<br>១+១ | ០ | ១១៥<br>១+១ | ០ | ១១៥<br>១+១ | ០ | ១១៥<br>១+១ | ០ |
| គណបក្ស **ង** | ៧៣ | ០ | ៧៣<br>០+១ | ០ | ៧៣<br>០+១ | ០ | ៧៣<br>០+១ | ០ | ៧៣<br>០+១ | ០ | ៧៣<br>០+១ | ០ | ៧៣<br>០+១ | ០ | ៧៣<br>០+១ | ០ |
| គណបក្ស **ច** | ១០៦ | ០ | ១០៦<br>០+១ | ០ | ១០៦<br>០+១ | ០ | ១០៦<br>០+១ | ១ | ១០៦<br>១+១ | ០ | ១០៦<br>១+១ | ០ | ១០៦<br>១+១ | ០ | ១០៦<br>១+១ | ០ |
| គណបក្ស **ឆ** | ៩២ | ០ | ៩២<br>០+១ | ០ | ៩២<br>០+១ | ០ | ៩២<br>០+១ | ០ | ៩២<br>០+១ | ០ | ៩២<br>០+១ | ០ | ៩២<br>០+១ | ១ | ៩២<br>១+១ | ០ |
| គណបក្ស **ជ** | ១០១ | ០ | ១០១<br>០+១ | ០ | ១០១<br>០+១ | ០ | ១០១<br>០+១ | ០ | ១០១<br>០+១ | ១ | ១០១<br>១+១ | ០ | ១០១<br>១+១ | ០ | ១០១<br>១+១ | ០ |
| គណបក្ស **ឈ** | ៦៣ | ០ | ៦៣<br>០+១ | ០ | ៦៣<br>០+១ | ០ | ៦៣<br>០+១ | ០ | ៦៣<br>០+១ | ០ | ៦៣<br>០+១ | ០ | ៦៣<br>០+១ | ០ | ៦៣<br>០+១ | ០ |

ករណីនេះ អាចកើតមានក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយ មានចំនួនសន្លឹកឆ្នោតបានការប្រហាក់ប្រហែលគ្នា។

តាមតារាងឧទាហរណ៍ខាងលើ យើងបាន ៖

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ
- $អ_{ទ}១$ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ដែលក្នុងនោះពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈ និងត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី៣ ។
- $ម_{ធ}១$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគធំជាងគេ **១១៥,០០** ដែលជាមធ្យមភាគខ្ពស់បំផុត។
- $អ_{ទ}២$ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ឃ** ។
- $ម_{ធ}២$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ក** មានមធ្យមភាគធំជាងគេ **១១៣,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}៣$ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៣ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ក** ។
- $ម_{ធ}៣$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៣ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ច** មានមធ្យមភាគធំជាងគេ **១០៦,០០** ដែលជាមធ្យមភាគខ្ពស់បំផុត។
- $អ_{ទ}៤$ តាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៤ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ច** ។
- $ម_{ធ}៤$ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៤ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេ **១០១,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}៥$ តាងឱ្យអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៥ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ខ** ។

- $ម_{ធ}$៥ គាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៥ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេ ៩៧,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$៦ គាងឱ្យអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៦ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ខ** ។
- $ម_{ធ}$៦ គាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៦ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ឆ** មានមធ្យមភាគធំជាងគេ ៩២,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$៧ គាងឱ្យអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៧ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ឆ** ។
- $ម_{ធ}$៧ គាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៧ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ជ** មានមធ្យមភាគធំជាងគេ ៨៦,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$៨ គាងឱ្យអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៨ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅបញ្ជីបេក្ខជននៃគណបក្ស **ជ** ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈ ក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត B យើងបាន ៖

- គណបក្ស **ឃ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ក** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ច** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ង** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ខ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ឆ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ជ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ខ** និង **ឈ** មិនបានទទួលអាសនៈ

សរុប = ៧ (ប្រាំពីរ) អាសនៈ

## ករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន

**ប្រការ ២.២៩.-**

ក្នុងករណីដែលគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើនក្នុងក្រុមប្រឹក្សាណាមួយ ប៉ុន្តែស្ថិតក្នុងស្ថានភាពដូចមានចែងក្នុងចំណុច ឃ មាត្រា ១២ថ្មី នៃ ច.ប.ក ឬបានប្រកាសបោះបង់ចោលអាសនៈដែលខ្លួនបានទទួល គ.ជ.ប ត្រូវបែងចែកអាសនៈដែលបោះបង់ចោលនោះទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាពាក់ព័ន្ធ ក្នុងអំឡុងពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃចេញសេចក្ដីសម្រេចថា គណបក្សនយោបាយនោះបានបោះបង់ចោលអាសនៈ ឬទទួលបានលិខិតបោះបង់អាសនៈចោល ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយ ដូចខាងក្រោម ៖

**ជំហានទី១ : ការកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល**

២.២៩.១ ដើម្បីកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល សម្រាប់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយពាក់ព័ន្ធទទួលបាន ១ (មួយ) អាសនៈ ត្រូវយកសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងក្រុមប្រឹក្សានោះ ដកនឹងចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ រួចយកមកចែកនឹងចំនួនអាសនៈដែលបោះបង់ចោល តាមរូបមន្ត ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ៖

- ក'ត តាងឱ្យកូតានៃអាសនៈដែលបោះបង់ចោល ដែលជាផលចែកគិតដល់ ២ (ពីរ) ខ្ទង់ក្រោយក្បៀស ។
- ស'ស តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយទាំងអស់ដែលមានអាសនៈក្នុងក្រុមប្រឹក្សាពាក់ព័ន្ធ ដកចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ។
- អ'ប តាងឱ្យចំនួនអាសនៈ ដែលបោះបង់ចោលក្នុងក្រុមប្រឹក្សា ។

**ឧទាហរណ៍ : ការកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល ៖

បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ២

បញ្ជីបេក្ខជននៃគណបក្ស **ឃ** បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស **ខ** បានទទួលអាសនៈ ៣

បញ្ជីបេក្ខជននៃគណបក្ស **ឆ** បានទទួលអាសនៈ ១

បញ្ជីបេក្ខជននៃគណបក្ស **ក គ** និង **ច** ពុំបានទទួលអាសនៈ

- គណបក្សនយោបាយ **ខ** បានបោះបង់ចោលអាសនៈទាំង ២ (ពីរ)។
- គណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សាខេត្ត A មាន គឺ គណបក្សនយោបាយ **ខ ឃ ខ** និង **ឆ** ។

នៅពេលដែលគណបក្សនយោបាយ **ខ** បានបោះបង់ចោលអាសនៈរបស់ខ្លួន អាសនៈដែលបោះបង់ចោលនោះ ត្រូវយកមកបែងចែកឱ្យគណបក្សនយោបាយ **ឃ ខ** និង **ឆ** ដែលមានអាសនៈក្នុងក្រុមប្រឹក្សាខេត្ត A រីឯគណបក្ស **ក គ** និង **ច** ដែលពុំបានទទួលអាសនៈក្នុងក្រុមប្រឹក្សានេះ មិនត្រូវបានរាប់បញ្ចូលក្នុងការបែងចែកអាសនៈដែលគណបក្ស **ខ** បានបោះបង់ចោលឡើយ ។

នៅពេលអនុវត្តតាមរូបមន្តក្នុងចំណុច ២.២៨.១ ខាងលើ យើងបាន៖

$ស'_{ស}$ = (៣៣១+៥១២+៣៩៥+២៥២) - ៣៣១ = ១.១៥៩ សន្លឹក

$អ'_{ប}$ = ២ អាសនៈ

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}} = \frac{១.១៥៩}{២} = ៥៧៩,៥០$$

កូតាស្មើនឹង ៥៧៩,៥០ ($ក'_{ត}$ = ៥៧៩,៥០)

**ជំហានទី២ : ការបែងចែកអាសនៈដែលបោះបង់ចោល (លើកទី១)**

២.២៨.២ ដើម្បីបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី១ ឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស **ឃ ខ** និង **ឆ** ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗបានទទួល មកចែកនឹងកូតានៃអាសនៈដែលបោះបង់ចោលតាមរូបមន្តដូចខាងក្រោម ៖

$$\text{អ}'_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ៖

- $\text{អ}'_{\text{ទ}}$ តាងឱ្យចំនួនអាសនៈដែលបោះបង់ចោលដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗបានទទួលក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២។
- $\text{ស}_{\text{ប}}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $\text{ក}'_{\text{ត}}$ តាងឱ្យកូតានៃអាសនៈដែលបានបោះបង់ចោល ដែលបានកំណត់ក្នុងជំហានទី១។

**ឧទាហរណ៍ : ការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី១**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល

បន្ទាប់ពីអនុវត្តការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោល តាមរូបមន្តក្នុងជំហានទី២ យើងបាន ៖

$$\text{គណបក្ស } \textbf{ឃ} \text{ អ}'_{\text{ទ}}\text{ឃ} = \frac{៥១២}{៥៧៩,៥០} = ០,៨០$$

$$\text{គណបក្ស } \textbf{ខ} \text{ អ}'_{\text{ទ}}\text{ង} = \frac{៣៩៥}{៥៧៩,៥០} = ០,៦៨$$

$$\text{គណបក្ស } \textbf{ឆ} \text{ អ}'_{\text{ទ}}\text{ឆ} = \frac{២៥២}{៥៧៩,៥០} = ០,៤៣$$

តាមការគណនាខាងលើ ពុំមានគណបក្សណាមួយទទួលបានអាសនៈ ដែលត្រូវបានបោះបង់ចោលនេះទេ។

២.២៤.៣ ក្នុងករណីគ្មានអាសនៈនៅសល់សម្រាប់បែងចែកបន្ត បន្ទាប់ពីការបែងចែកលើកទី១ តាមរូបមន្តក្នុងជំហានទី២ ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយបានទទួលក្នុងមណ្ឌលនោះ ត្រូវកំណត់យកតែម្តង ។

## ជំហានទី៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត

២.២៨.៤ ក្នុងករណីបន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី១ តាមរូបមន្តជំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សណាមួយទទួលបានអាសនៈ ឬនៅមានសល់អាសនៈ អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ខាងក្រោម ។

២.២៨.៥ ដើម្បីគណនារកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ចែកនឹងចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សទាំងនោះបានទទួល បន្ទាប់ពីការបែងចែកលើកទី១ ក្នុងជំហានទី២ បូកនឹងលេខនិមិត្តចំនួន ១ (មួយ) តាមរូបមន្តខាងក្រោម ៖

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ទ} + ១}$$

ក្នុងនោះ៖

- $ម'_{ធ}$ តាងឱ្យមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ។
- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $អ'_{ទ}$ តាងឱ្យចំនួនអាសនៈដែលបោះបង់ចោលដែលបញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ ។
- ១ ជាលេខនិមិត្ត ។

២.២៨.៦ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ រួចហើយ ត្រូវធ្វើការប្រៀបធៀបគ្នា។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុតនឹងត្រូវទទួលបានអាសនៈ ១(មួយ)។

### ឧទាហរណ៍ : ការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោល(លើកទី២)

បន្ទាប់ពីការបែងចែកលើកទី១ តាមរូបមន្តក្នុងជំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សណាមួយទទួលអាសនៈដែលត្រូវបានបោះបង់ចោលទេ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

$$\text{គណបក្ស ឃ ម´ធឃ} = \frac{៥១២}{០ + ១} = ៥១២,០០$$

$$\text{គណបក្ស ខ ម´ធខ} = \frac{៣៩៥}{០ + ១} = ៣៩៥,០០$$

$$\text{គណបក្ស ឆ ម´ធឆ} = \frac{២៥២}{០ + ១} = ២៥២,០០$$

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៣ (បី) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគធំជាងគេគឺ **៥១២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស **ឃ** ត្រូវទទួលបានអាសនៈដែលត្រូវបានបោះបង់ចោល ១ (មួយ) អាសនៈ ។

២.២៤.៧ ប្រសិនបើនៅមានសល់អាសនៈ បន្ទាប់ពីការបែងចែកលើកទី២ អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែកម្តងមួយអាសនៈៗរហូតដល់អស់អាសនៈ តាមរូបមន្តក្នុងជំហានទី៣ ដដែល ដោយបង្កើនតម្លៃ អ´ទ ចំនួន ១ (មួយ) ចំពោះគណបក្សនយោបាយដែលទើបទទួលបានអាសនៈបន្ថែមចំនួនមួយ សម្រាប់ការបែងចែកមួយលើកៗ ។

**ឧទាហរណ៍** : **ការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោល**( **លើកទី៣** )

បន្ទាប់ពីការបែងចែកលើកទី២ នៅមានសល់អាសនៈ ១ (មួយ) ទៀត ត្រូវបន្តបែងចែក។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

$$\text{គណបក្ស ឃ ម´ធឃ} = \frac{៥១២}{១ + ១} = ២៥៦,០០$$

$$\text{គណបក្ស ខ ម´ធខ} = \frac{៣៩៥}{០ + ១} = ៣៩៥,០០$$

$$\text{គណបក្ស ឆ ម´ធឆ} = \frac{២៥២}{០ + ១} = ២៥២,០០$$

តាមការប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៣ (បី) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេគឺ **៣៩៥,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស **ខ** ត្រូវទទួលបានអាសនៈ ១ (មួយ) ដែលនៅសល់ចុងក្រោយ ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ៖

| | | | |
|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | បានទទួលអាសនៈ | ៤ |
| បញ្ជីបេក្ខជននៃគណបក្ស | **ខ** | បានទទួលអាសនៈ | ៤ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឆ** | បានទទួលអាសនៈ | ១ |

សរុប = ៩ (ប្រាំបួន) អាសនៈ

**ករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន**

**ប្រការ ២.២៥.–**

ក្នុងករណីការគណនាតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដូចមានចែងក្នុងចំណុច ២.២២.៥.១ និងចំណុច ២.២៤.៥ នៃ ប.ន.ក នេះ មានលទ្ធផលមធ្យមភាគស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួននោះការបែងចែកអាសនៈត្រូវកំណត់ ដូចខាងក្រោម ៖

២.២៥.១ ក្នុងករណីអាសនៈនៅសល់ បន្ទាប់ពីការបែងចែកលើកទី១ មានចំនួនស្មើ ឬលើសពីបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គធ.ខប ត្រូវផ្តល់ឱ្យទៅបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងនោះ ១ (មួយ) អាសនៈ សម្រាប់គណបក្សនីមួយៗ។ បើមាននៅសល់អាសនៈទៀត ត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដដែល។

**ឧទាហរណ៍**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត C មាន ៖

- បញ្ជីបេក្ខជននៃគណបក្សនយោបាយមានចំនួន ៥
- សន្លឹកឆ្នោតបានការសរុប $ស_ស$ = ១.៣៥១ សន្លឹក
- អាសនៈសរុប $អ_ស$ = ១៥ អាសនៈ
- កូតា $ក_ត$ = ៩០,០៦

| បញ្ជីបេក្ខជន | ស$_{ប}$ | អ$_{ទ}$១ លើកទី១ | ម$_{ធ}$១ | អ$_{ទ}$២ លើកទី២ |
|---|---|---|---|---|
| គណបក្ស **ក** | ៨០ | ០ | ៨០ / (០ + ១) = ៨០,០០ | ០ |
| គណបក្ស **ខ** | ២៥៩ | ២ | ២៥៩ / (២ + ១) = **៨៦,៣៣** | **១** |
| គណបក្ស **គ** | ៩៣ | ១ | ៩៣ / (១ + ១) = ៤៦,៥០ | ០ |
| គណបក្ស **ឃ** | ១៨២ | ២ | ១៨២ / (២ + ១) = ៦០,៦៦ | ០ |
| គណបក្ស **ង** | ៧៧៧ | ៨ | ៧៧៧ / (៨ + ១) = **៨៦,៣៣** | **១** |

- ស$_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- អ$_{ទ}$១ តាងឱ្យចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១។
- ម$_{ធ}$១ តាងឱ្យលទ្ធផលនៃការគណនាមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្ស **ខ** និង **ង** មានមធ្យមភាគធំជាងគេស្មើគ្នា គឺ ៨៦,៣៣ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះអនុវត្តតាមចំណុច ២.២៥.១ គជ.ខប ត្រូវបែងចែកអាសនៈដែលនៅសល់ ២ (ពីរ) នោះឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស **ខ** ១ (មួយ) អាសនៈ និងគណបក្ស **ង** ១ (មួយ) អាសនៈ ។
- អ$_{ទ}$២ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** និង **ង** ត្រូវទទួលបាន ១ (មួយ) អាសនៈបន្ថែមសម្រាប់គណបក្សនីមួយៗ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត C គឺ ៖

- គណបក្សនយោបាយ **ខ** ទទួលបាន ៣ (បី) អាសនៈ
- គណបក្សនយោបាយ **គ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្សនយោបាយ **ឃ** ទទួលបាន ២ (ពីរ) អាសនៈ
- គណបក្សនយោបាយ **ខ** ទទួលបាន ៩ (ប្រាំបួន) អាសនៈ
- គណបក្សនយោបាយ **ក** ពុំបានទទួលអាសនៈ

សរុប = ១៥ (ដប់ប្រាំ) អាសនៈ។

២.២៥.២ ក្នុងករណីអាសនៈនៅសល់ មានចំនួនតិចជាងចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលមានលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា គធ.ឧប ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈនោះ ។

**ឧទាហរណ៍**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង D មាន ៖

| | | | |
|---|---|---|---|
| - ចំនួនបញ្ជីបេក្ខជននៃគណបក្សនយោបាយ | | | ៧ |
| - ចំនួនសន្លឹកឆ្នោតបានការសរុប | $ស_{ស}$ | = | ៦៦៣ |
| - ចំនួនអាសនៈសរុប | $អ_{ស}$ | = | ១១ អាសនៈ |
| - កូតា | $ក_{ត}$ | = | ៦០,២៧ |

| បញ្ជីបេក្ខជន | $ស_{ប}$ | $អ_{ទ}១$ | $ម_{ធ}១$ | | | $អ_{ទ}២$ | $ម_{ធ}២$ | | | $អ_{ទ}៣$ |
|---|---|---|---|---|---|---|---|---|---|---|
| គណបក្ស **ក** | ៥២ | ០ | ៥២ / (០ + ១) | = | ៥២,០០ | ១ | ៥២ / (១ + ១) | = | ២៦,០០ | ០ |
| គណបក្ស **ខ** | ១៥៥ | ២ | ១៥៥ / (២ + ១) | = | ៥១,៦៦ | ០ | ១៥៥ / (២ + ១) | = | **៥១,៦៦** | ១ ? |
| គណបក្ស **គ** | ៦៣ | ១ | ៦៣ / (១ + ១) | = | ៣១,៥០ | ០ | ៦៣ / (១ + ១) | = | ៣១,៥០ | ០ |
| គណបក្ស **ឃ** | ៣១០ | ៥ | ៣១០ / (៥ + ១) | = | ៥១,៦៦ | ០ | ៣១០ / (៥ + ១) | = | **៥១,៦៦** | ១ ? |
| គណបក្ស **ង** | ១៨ | ០ | ១៨ / (០ + ១) | = | ១៨,០០ | ០ | ១៨ / (០ + ១) | = | ១៨,០០ | ០ |
| គណបក្ស **ច** | ៨ | ០ | ៨ / (០ + ១) | = | ៨,០០ | ០ | ៨ / (០ + ១) | = | ៨,០០ | ០ |
| គណបក្ស **ឆ** | ៦១ | ១ | ៦១ / (១ + ១) | = | ៣០,៥០ | ០ | ៦១ / (១ + ១) | = | ៣០,៥០ | ០ |

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។
- $អ_{ទ}១$ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ក្នុងនោះ ៖
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** ទទួលបាន ២ (ពីរ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ **គ** ទទួលបាន ១ (មួយ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ឃ** ទទួលបាន ៥ (ប្រាំ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ឆ** ទទួលបាន ១ (មួយ) អាសនៈ
  - បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក ង** និង **ច** ទទួលបាន ០ (សូន្យ) អាសនៈ ។

- មធ១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ តាមរូបមន្ត ជំហានទី៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលក្នុងនោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ **ក** មានមធ្យមភាគ ធំជាងគេគឺ **៥២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ១២ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយ នីមួយៗ ទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះបញ្ជីបេក្ខជន នៃគណបក្សនយោបាយ **ក** ត្រូវទទួលបាន ១ (មួយ) អាសនៈ ។
- មធ២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ តាមរូបមន្ត ជំហានទី៣ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ក្នុងនោះ បញ្ជីបេក្ខជននៃគណបក្សនយោបាយ **ខ** និង **ឃ** មានមធ្យមភាគធំ ជាងគេស្មើគ្នាគឺ **៥១,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត ។
- អ១៣ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយ នីមួយៗ ទទួលបានក្នុងការបែងចែកលើកទី៣ ដែលក្នុងនោះ ចំនួនអាសនៈនៅសល់មានតែ ១ (មួយ) តិចជាងចំនួនបញ្ជីបេក្ខជន នៃគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគ ខ្ពស់បំផុតស្មើគ្នា។ អនុវត្តតាមចំណុច ២.២៥.២ គធ.ខប ត្រូវរៀបចំ ការចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្ស នយោបាយណាដែលត្រូវទទួលបានអាសនៈនៅសល់ ១ (មួយ) ចុងក្រោយនេះ ។

**ការចាប់ឆ្នោតជាសាធារណៈ**

**ប្រការ ២.២៦.–**

ក្នុងករណីដូចមានចែងក្នុងចំណុច ២.២៥.២ គធ.ខប ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បី កំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលត្រូវទទួលបានអាសនៈនៅសល់នេះ ។

២.២៦.១ ក្នុងករណីបែបនេះ គធ.ខប ត្រូវចាត់ចែងរៀបចំការចាប់ឆ្នោតជាសាធារណៈ ។

២.២៦.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើនៅ លគធ.ខប ក្រោយពេលបញ្ចប់ការបែងចែក អាសនៈនៅតាមមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្នុងរាជធានី ខេត្តពាក់ព័ន្ធ ។

២.២៦.២.១ គធ.ខប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីនៃការចាប់ឆ្នោត ហើយត្រូវនិមន្ត ឬអញ្ជើញ ចូលរួមក្នុងពិធីចាប់ឆ្នោត ៖

- ព្រះសង្ឃ ដែលត្រូវចាប់ឆ្នោត ។
- តំណាងផ្លូវការនៃគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា។
- តំណាងផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ។
- អ្នកសង្កេតការណ៍ ។

២.២៦.២.២ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

- មន្ត្រីទទួលបន្ទុកប្រតិបត្តិការត្រូវសរសេរ ឬបោះពុម្ពនៅលើក្រដាសដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នានូវឈ្មោះនៃគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាស្មើគ្នា។ ក្រដាសឆ្នោតមួយសន្លឹកត្រូវសរសេរ ឬបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ។ តួអក្សរជាឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា។ ក្រដាសសន្លឹកឆ្នោតដែលសរសេរ ឬបោះពុម្ពឈ្មោះរបស់គណបក្សនយោបាយរួចហើយ ត្រូវបត់ជាផ្នត់ដូចគ្នា ដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំដូចគ្នា រួចបិទភ្ជិត និងមូរចងនឹងកៅស៊ូកងពណ៌ដូចគ្នា ។
- មន្ត្រីទទួលបន្ទុកប្រតិបត្តិការ ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈ មុននឹងដាក់សំបុត្រសន្លឹកឆ្នោតចូលទៅក្នុងហិបនោះ និងបិទគម្រប ។
- មន្ត្រីទទួលបន្ទុកប្រតិបត្តិការត្រូវក្រឡុកហិបឆ្នោត រួចលើកហិបឆ្នោតនោះទៅដាក់លើតុខ្ពស់ ។
- ព្រះសង្ឃ ត្រូវចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបនោះ រួចជូនទៅប្រធាន គធ.ខប ឬតំណាង គធ.ខប ដែលត្រូវបានប្រគល់សិទ្ធិ ។

- ប្រធាន ឬតំណាង គធ.ខប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រនោះជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលចូលរួមបានឃើញ និងប្រាកដថាឈ្មោះគណបក្សដែលបានប្រកាសដូចគ្នានឹងឈ្មោះរបស់គណបក្សដែលបានសរសេរ ឬបោះពុម្ពនៅលើសន្លឹកឆ្នោតនោះប្រាកដមែន ។

២.២៦.២.៣ មន្ត្រីផ្នែកប្រតិបត្តិការ និងបញ្ជីបោះឆ្នោតត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងតំណាងចូលរួម (គធ.ខប តំណាងគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា អ្នកសង្កេតការណ៍...) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត។

២.២៦.២.៤ កំណត់ហេតុ ត្រូវចុះហត្ថលេខាដោយ ៖

- អ្នកធ្វើកំណត់ហេតុ
- ប្រធាន គធ.ខប ឬតំណាង គធ.ខប ដែលត្រូវបានប្រគល់សិទ្ធិ
- តំណាងគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា។

២.២៦.២.៥ កំណត់ហេតុត្រូវធ្វើជាច្រើនច្បាប់ តាមតម្រូវការ ដូចខាងក្រោម៖

- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- ផ្ញើជូនគ្រប់គណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

**ការប្រកាសឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ និងការកំណត់បេក្ខជនជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ**

**ប្រការ ២.២៧.–**

បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលហើយ គធ.ខប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

២.២៧.១ ឈ្មោះអ្នកជាប់ឆ្នោតទាំងអស់ ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលជាប់ឆ្នោតជាសមាជិកតាមប្រភេទក្រុមប្រឹក្សានីមួយៗ។ ចំនួនឈ្មោះអ្នកជាប់ឆ្នោតដែលត្រូវស្រង់ត្រូវស្មើគ្នានឹងចំនួនអាសនៈដែលបានកំណត់ដោយអនុក្រឹត្យ ។

២.២៧.២ ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវស្រង់តាមលំដាប់អាទិភាពពីខ្ពស់មកទាបនៃបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

២.២៧.៣ ក្នុងករណីនៅមណ្ឌលបោះឆ្នោតរាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌណាមួយមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតែមួយគត់ ដែលត្រូវបានយល់ព្រមឱ្យចុះបញ្ជី ឬមានបញ្ជីបេក្ខជនតែមួយគត់ជាប់ឆ្នោត ឈ្មោះបេក្ខជនជាប់ឆ្នោតត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប រហូតដល់គ្រប់អាសនៈក្នុងក្រុមប្រឹក្សារាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌពាក់ព័ន្ធ ។

២.២៧.៤ ឈ្មោះបេក្ខជនណាដែលត្រូវបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាតាមប្រភេទនីមួយៗរួចហើយ ឈ្មោះបេក្ខជននោះត្រូវដកចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយនោះ ។

២.២៧.៥ ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃគណបក្សនយោបាយមានអ្នកជាប់ឆ្នោតណាម្នាក់ទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយនោះ ត្រូវបានស្រង់ជាអ្នកជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារបស់សាមីគណបក្សនយោបាយ ។

២.២៧.៦ ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយមានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុ ដូចមានចែងក្នុងចំណុច ២.២៧.៥ គ.ជ.ប ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនយោបាយនោះ ឱ្យបន្ថែមឈ្មោះបេក្ខជនក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃក្រោយពីទទួលបានសំណើ ។

២.២៧.៦.១ បែបបទនៃការទទួលពិនិត្យ និងអនុម័តឈ្មោះបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៥ មាត្រា ១៦ មាត្រា ១៧ថ្មី មាត្រា ១៨ មាត្រា ២០ មាត្រា ២២ ដល់មាត្រា ២៦ នៃ ច.ប.ក ។

២.២៧.៦.២ ក្នុងករណីគណបក្សនយោបាយណាមួយមិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលម្អការខ្វះខាតដែលស្នើឡើងដោយ គ.ជ.ប ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈទំនេរបាននោះ គ.ជ.ប ត្រូវចាត់ទុកថាគណបក្សនយោបាយនោះបានបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

២.២៧.៦.៣ ក្នុងករណីគណបក្សនយោបាយណាមួយ បោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ដូចកំណត់ក្នុងចំណុច ២.២៧.៦.២ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈដែលបោះបង់ចោលនោះ ក្នុងរយៈពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ បន្ទាប់ពីថ្ងៃបោះបង់ចោលជាផ្លូវការដោយអនុវត្តតាមវិធីគណនា ដូចមានចែងក្រោមប្រការ ២.២៤ នៃ ប.ន.ក នេះ ។

២.២៧.៧ បន្ទាប់ពីបានស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ រួចហើយ គធ.ខប ត្រូវកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលទទួលតំណែងជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៧ នៃ ច.គ.ខ.ស ដូចខាងក្រោម ៖

២.២៧.៧.១ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ត្រូវជ្រើសរើសបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សា។

២.២៧.៧.២ ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវបានជ្រើសរើសយកបេក្ខជនដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ។

២.២៧.៧.៣ ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយមានសំឡេងឆ្នោតនិងចំនួនអាសនៈស្មើគ្នានោះ គធ.ខប ត្រូវរៀបចំការចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់បញ្ជីបេក្ខជនដែលត្រូវទទួលតំណែងប្រធានក្រុមប្រឹក្សា តាមលំនាំដូចមានចែងក្រោមប្រការ ២.២៦ នៃ ប.ន.ក នេះ ។

**ប្រការ ២.២៨.-**

ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្រោមប្រការ ២.២២ ប្រការ ២.២៣ ប្រការ ២.២៤ ប្រការ ២.២៥ និងប្រការ ២.២៦ នៃ ប.ន.ក នេះ គ.ជ.ប ត្រូវប្រកាសផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗ ជាបន្តបន្ទាប់ ។

**ប្រការ ២.២៩.-**

មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គ.ជ.ប ត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់គណបក្សនយោបាយដែលបានចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ពសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ពីការប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗនោះ។

## ករណីបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយក្នុងអាណត្តិ

### ប្រការ ២.៣០.-

ក្នុងអាណត្តិនៃក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ប្រសិនបើមានគណបក្សនយោបាយណាមួយប្រកាសបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយ ស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់នៃគណបក្សនយោបាយនោះ លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។

២.៣០.១ គ.ជ.ប ត្រូវបែងចែកអាសនៈដែលនៅទំនេរនោះទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ បន្ទាប់ពីទទួលបានសេចក្ដីសម្រេចថា គណបក្សនយោបាយនោះបានបោះបង់ចោលអាសនៈ ឬទទួលបានលិខិតបោះបង់ចោលអាសនៈ ឬលិខិតជូនដំណឹងពីក្រសួងមហាផ្ទៃ ។

២.៣០.២ គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត អាចប្រកាសមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ តាមការកំណត់របស់ គ.ជ.ប ។

២.៣០.៣ គ.ជ.ប ត្រូវបង្កើតក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យសំឡេងឆ្នោត បែងចែកអាសនៈ ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាជាប្រធានក្រុមប្រឹក្សាតាមប្រភេទក្រុមប្រឹក្សា រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច ។

២.៣០.៤ នៅមុនការបែងចែកអាសនៈដែលនៅទំនេរតាមករណីដូចខាងលើ គ.ជ.ប ត្រូវធ្វើលិខិតជាផ្លូវការទៅគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងកំណត់បញ្ហាមួយចំនួន ដូចខាងក្រោម ៖

ទី១- ការប្រកាសយល់ព្រមទទួលយក ឬមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ ។

ទី២- ការធ្វើបច្ចុប្បន្នភាពបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន ដែលត្រូវបានយល់ព្រមឱ្យចុះបញ្ជីក្នុងអាណត្តិពាក់ព័ន្ធ ដោយត្រូវលុបចេញឈ្មោះបេក្ខជនដែល ៖

- ទទួលមរណភាព ឬ
- បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬ
- លាលែងជាលាយលក្ខណ៍អក្សរ ឬ
- ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬ
- បាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

ទី៣- ករណីគណបក្សនយោបាយណាមួយពុំបានឆ្លើយតបតាមលិខិតផ្លូវការរបស់ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ តាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប នោះចាត់ទុកថា គណបក្សនយោបាយនោះបានយល់ព្រមទទួលយកតាមការបែងចែកអាសនៈដែលនៅទំនេរ និងរក្សាទុកជាបានការនូវបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន ដែលត្រូវបានយល់ព្រមឱ្យចុះបញ្ជីក្នុងអាណត្តិពាក់ព័ន្ធ ។

**ប្រការ ២.៣១.-**

ការបែងចែកអាសនៈដែលនៅទំនេរត្រូវអនុវត្តតាមករណី និងជំហានទាំងឡាយ ដូចខាងក្រោម ៖

២.៣១.១ ករណីដូចមានចែងក្នុងចំណុច ២.៣០.១ នៃប្រការ ២.៣០ ខាងលើ ការបែងចែកអាសនៈដែលនៅទំនេរត្រូវអនុវត្តតាមជំហានទាំងឡាយ ដូចខាងក្រោម ៖

**ជំហានទី១ : កំណត់កូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ**

២.៣១.១.១ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់

ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មកចែកជាមួយនឹងចំនួនអាសនៈដែលនៅទំនេរនោះ តាមរូបមន្តដូចខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

- $ក'_{ត}$ តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់ ២ (ពីរ) ខ្ទង់ក្រោយក្បៀស ។
- $ស'_{ស}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ។
- $អ'_{ប}$ តាងឱ្យចំនួនអាសនៈរបស់គណបក្សដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ។

**ឧទាហរណ៍**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A មានអាសនៈ ៩ មានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ៧ និងមានលទ្ធផលនៃការបោះឆ្នោត ដូចខាងក្រោម៖

- បញ្ជីបេក្ខជននៃគណបក្ស **ក** មាន ស$_{ប}$ក ១២៣ ទទួលបាន ០ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ខ** មាន ស$_{ប}$ខ ៣៣១ ទទួលបាន ២ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **គ** មាន ស$_{ប}$គ ៩៨ ទទួលបាន ០ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ឃ** មាន ស$_{ប}$ឃ ៥១២ ទទួលបាន ៣ អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ង** មាន ស$_{ប}$ង ៣៩៥ ទទួលបាន ៣ អាសនៈ

- បញ្ជីបេក្ខជននៃគណបក្ស **ច** មាន $\text{ស}_{\text{ប}}$ច ៥៣ ទទួលបាន 0 អាសនៈ
- បញ្ជីបេក្ខជននៃគណបក្ស **ឆ** មាន $\text{ស}_{\text{ប}}$ឆ ២៥២ ទទួលបាន ១ អាសនៈ

ករណីគណបក្សនយោបាយ **ខ** បានបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដែលនាំឱ្យបញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សាខេត្តទាំងអស់នៃគណបក្សនយោបាយ **ខ** លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ។ អាសនៈចំនួន ២ ដែលគណបក្ស **ខ** ទទួលបានត្រូវនៅទំនេរ និងត្រូវបែងចែកទៅឱ្យគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត គឺគណបក្ស **ក គ ឃ ខ ច** និង **ឆ** ។

ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបាន ១ (មួយ) អាសនៈ ដោយអនុវត្តតាមរូបមន្តក្នុងចំណុច ២.៣១.១.១ ខាងលើ យើងបាន៖

$\text{ស}'_{\text{ស}}$ = (១២៣+៣៣១+៩៨+៥១២+៣៩៥+៥៣+២៥២) - ៣៣១ = ១.៤៣៣

$\text{អ}'_{\text{ប}}$ = ២

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ស}}}{\text{អ}'_{\text{ប}}} = \frac{\text{១.៤៣៣}}{\text{២}} = \text{៧១៦,៥០}$$

កូតាស្មើនឹង ៧១៦,៥០ ។

**ជំហានទី២** : **ការកំណត់ចំនួនអាសនៈជាបឋម** (**លើកទី១**)

២.៣១.១.២ ការកំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗបានទទួល ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗដែលបានទទួលមកចែកនឹងកូតា តាមរូបមន្តដូចខាងក្រោម ៖

$$\text{អ}'_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ ៖

- $\text{អ}'_{\text{ទ}}$ តាងឱ្យចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣ ។

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប   បោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។
- $ក'_{ត}$ តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១ ។

**ឧទាហរណ៍**

ការបែងចែកអាសនៈដែលនៅទំនេរ (លើកទី១) នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ខេត្ត A ដដែល ។

អនុវត្តតាមការបែងចែកអាសនៈដែលនៅទំនេរលើកទី១  តាមរូបមន្តក្នុងជំហានទីពីរ ចំណុច ២.៣១.១.២ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** $អ'_{ទក} = \frac{១២៣}{៧១៦,៥០} =$ 0,១៧

បញ្ជីបេក្ខជននៃគណបក្ស **គ** $អ'_{ទគ} = \frac{៩៨}{៧១៦,៥០} =$ 0,១៣

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $អ'_{ទឃ} = \frac{៥១២}{៧១៦,៥០} =$ 0,៧១

បញ្ជីបេក្ខជននៃគណបក្ស **ង** $អ'_{ទង} = \frac{៣៩៥}{៧១៦,៥០} =$ 0,៥៥

បញ្ជីបេក្ខជននៃគណបក្ស **ច** $អ'_{ទច} = \frac{៥៣}{៧១៦,៥០} =$ 0,0៧

បញ្ជីបេក្ខជននៃគណបក្ស **ឆ** $អ'_{ទឆ} = \frac{២៥២}{៧១៦,៥០} =$ 0,៣៥

តាមលទ្ធផលនៃការគណនាខាងលើ   ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈដែលនៅទំនេរនេះទេ។ បន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី១ តាមរូបមន្តជំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈ   អាសនៈទាំងនោះត្រូវយកមកបែងចែកបន្តទៀត ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តដូចខាងក្រោម៖

**ជំហានទី៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត  និងការបែងចែកអាសនៈដែលនៅទំនេរ (លើកទី២)**

២.៣១.១.៣   ដើម្បីកំណត់មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវធ្វើការគណនាដោយយកចំនួនសន្លឹកឆ្នោតបានការ

សរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ចែកនឹងចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះបានទទួល បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី១ បូកនឹងលេខនិមិត្តចំនួន ១ តាមរូបមន្តខាងក្រោម ៖

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ទ} + ១}$$

ក្នុងនោះ៖

- ម'ធ តាងឱ្យមធ្យមភាគខ្ពស់បំផុត។
- សប តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។
- អ'ទ តាងឱ្យចំនួនអាសនៈ ដែលបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ទទួលបានក្នុងការបែងចែកអាសនៈដែលនៅទំនេរលើកទី១ ។
- ១ ជាលេខនិមិត្ត ។

២.៣១.១.៤ ក្នុងការរកមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាឱ្យដល់ចំនួន ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណា ដែលមានមធ្យមភាគខ្ពស់ជាងគេ ។

២.៣១.១.៥ បន្ទាប់ពីកំណត់បានមធ្យមភាគ របស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតដល់ចំនួន ២ (ពីរ) ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសនៈ ១ (មួយ) ។

**ឧទាហរណ៍**

ការបែងចែកអាសនៈដែលនៅទំនេរ (លើកទី២) តាមរូបមន្តមធ្យមភាគខ្ពស់បំផុតនៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល ។

បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរ (លើកទី១) តាមរូបមន្តជំហានទី២ រួចមកពុំមានបញ្ជីបេក្ខជននៃគណបក្សណាមួយទទួលបានអាសនៈទេ ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស **ក** $ម'_{ធ}ក = \frac{១២៣}{០+១} = ១២៣,០០$

បញ្ជីបេក្ខជននៃគណបក្ស **គ** $ម'_{ធ}គ = \frac{៩៨}{០+១} = ៩៨,០០$

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $ម'_{ធ}ឃ = \frac{៥១២}{០+១} =$ **៥១២,០០**

បញ្ជីបេក្ខជននៃគណបក្ស **ង** $ម'_{ធ}ង = \frac{៣៩៥}{០+១} = ៣៩៥,០០$

បញ្ជីបេក្ខជននៃគណបក្ស **ច** $ម'_{ធ}ច = \frac{៥៣}{០+១} = ៥៣,០០$

បញ្ជីបេក្ខជននៃគណបក្ស **ឆ** $ម'_{ធ}ឆ = \frac{២៥២}{០+១} = ២៥២,០០$

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៦ (ប្រាំមួយ) ខាងលើ បញ្ជីបេក្ខជន នៃគណបក្ស **ឃ** មានមធ្យមភាគធំជាងគេគឺ **៥១២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស **ឃ** ត្រូវទទួលបានអាសនៈដែលនៅទំនេរចំនួន ១ (មួយ) ក្នុងការបែងចែកលើកនេះ។

២.៣១.១.៦ ប្រសិនបើមាននៅសល់អាសនៈទៀត អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែកម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ដដែល ដោយបង្កើនតម្លៃ អ$_{ទ}$ ចំនួន ១ (មួយ) ចំពោះគណបក្សនយោបាយដែលទើបទទួលបានអាសនៈបន្ថែមចំនួនមួយ ។

**ឧទាហរណ៍**

ការបែងចែកអាសនៈដែលនៅទំនេរ (លើកទី៣) នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល ។

បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី ២ តាមរូបមន្តជំហានទី៣ រួចមកមាននៅសល់អាសនៈចំនួន ១ (មួយ) ទៀត ត្រូវបែងចែកបន្ត។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

បញ្ជីបេក្ខជននៃគណបក្ស ក ម´ធក = ១២៣ / ០+១ = ១២៣,០០

បញ្ជីបេក្ខជននៃគណបក្ស គ ម´ធគ = ៩៨ / ០+១ = ៩៨,០០

បញ្ជីបេក្ខជននៃគណបក្ស ឃ ម´ធឃ = ៥១២ / ១+១ = ២៥៦,០០

បញ្ជីបេក្ខជននៃគណបក្ស ង ម´ធង = ៣៩៥ / ០+១ = **៣៩៥,០០**

បញ្ជីបេក្ខជននៃគណបក្ស ច ម´ធច = ៥៣ / ០+១ = ៥៣,០០

បញ្ជីបេក្ខជននៃគណបក្ស ឆ ម´ធឆ = ២៥២ / ០+១ = ២៥២,០០

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៦ (ប្រាំមួយ) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ខ** មានមធ្យមភាគធំជាងគេគឺ ៣៩៥,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស **ខ** ត្រូវទទួលបានអាសនៈដែលនៅទំនេរចំនួន ១ (មួយ) ចុងក្រោយនេះ ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ៖

| | | | |
|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | បានទទួលអាសនៈ ១ អាសនៈបន្ថែមទៀតសរុប | ៤ |
| បញ្ជីបេក្ខជននៃគណបក្ស | **ខ** | បានទទួលអាសនៈ ១ អាសនៈបន្ថែមទៀតសរុប | ៤ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឆ** | បានទទួលអាសនៈ | ១ |

**សរុប = ៩ (ប្រាំបួន) អាសនៈ**

២.៣១.២ ករណីដូចមានចែងក្នុងចំណុច ២.៣០.២ នៃប្រការ ២.៣០ ការបែងចែកអាសនៈដែលនៅទំនេរត្រូវអនុវត្តតាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទី១ : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ទទួលបានមួយអាសនៈ**

២.៣១.២.១ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ មកចែកជាមួយនឹងចំនួនអាសនៈដែលនៅទំនេរនោះ តាមរូបមន្តដូចខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ឋ}}$$

ក្នុងនោះ៖

- $ក'_{ត}$ តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់ ២ (ពីរ) ខ្ទង់ក្រោយក្បៀស។
- $ស'_{ស}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ ។

- អ'$_{ប}$ តាងឱ្យចំនួនអាសនៈរបស់គណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈ ឬដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ។

**ឧទាហរណ៍**

នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល គឺ៖

| | | | | |
|---|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **ក** | ស$_{ប}$ក | ១២៣ | ទទួលបាន 0 អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ខ** | ស$_{ប}$ខ | ៣៣១ | ទទួលបាន ២ អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **គ** | ស$_{ប}$គ | ៩៨ | ទទួលបាន 0 អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | ស$_{ប}$ឃ | ៥១២ | ទទួលបាន ៣ អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ង** | ស$_{ប}$ង | ៣៩៥ | ទទួលបាន ៣ អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ច** | ស$_{ប}$ច | ៥៣ | ទទួលបាន 0 អាសនៈ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឆ** | ស$_{ប}$ឆ | ២៥២ | ទទួលបាន ១ អាសនៈ |

ករណីគណបក្សនយោបាយ **ខ** បានបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយដែលនាំឱ្យបញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សាខេត្តទាំងអស់នៃគណបក្សនយោបាយ **ខ** លែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀត និងករណីគណបក្ស **ង** ប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ។ អាសនៈចំនួន ២ ដែលគណបក្ស **ខ** ទទួលបាន ត្រូវនៅទំនេរ និងត្រូវបែងចែកទៅឱ្យគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត លើកលែងតែគណបក្ស **ង** ដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ។ ដូចនេះអាសនៈដែលនៅទំនេរនឹងត្រូវបែងចែកឱ្យគណបក្ស **ក គ ឃ ច** និង **ឆ** ។

ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជន នៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ដោយអនុវត្តតាមរូបមន្តក្នុងចំណុច ២.៣១.២.១ ខាងលើយើងបាន ៖

ស'$_{ស}$ = (១២៣+៣៣១+៩៨+៥១២+៣៩៥+៥៣+២៥២) - (៣៣១+៣៩៥) = ១.០៣៨

**អ'**$_{ប}$ = ២

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}} = \frac{១.០៣៨}{២} = ៥១៩,០០$$

កូតាស្មើនឹង ៥១៩,០០ ។

**ជំហានទី២ : ការកំណត់ចំនួនអាសនៈបឋម (លើកទី១)**

២.៣១.២.២ ការកំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗបានទទួល ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនីមួយៗ មកចែកនឹងកូតាតាមរូបមន្ត ដូចខាងក្រោម ៖

$$អ'_{ទ} = \frac{ស_{ប}}{ក'_{ត}}$$

ក្នុងនោះ ៖

- $អ'_{ទ}$ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជន នៃគណបក្សនយោបាយមួយបានទទួល ។
- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។
- $ក'_{ត}$ តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១ ។

**ឧទាហរណ៍**

ការបែងចែកអាសនៈដែលនៅទំនេរលើកទី ១ នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល ។

អនុវត្តតាមការបែងចែកអាសនៈដែលនៅទំនេរលើកទី១ តាមរូបមន្តក្នុងជំហានទី២ ចំណុច ២.៣១.២.២ យើងបាន ៖

| | | | |
|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **ក** | $អ'_{ទ}ក = \frac{១២៣}{៥១៩,០០}$ | $= ០,២៣$ |
| បញ្ជីបេក្ខជននៃគណបក្ស | **គ** | $អ'_{ទ}គ = \frac{៩៨}{៥១៩,០០}$ | $= ០,១៨$ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | $អ'_{ទ}ឃ = \frac{៥១២}{៥១៩,០០}$ | $= ០,៩៨$ |
| បញ្ជីបេក្ខជននៃគណបក្ស | **ច** | $អ'_{ទ}ច = \frac{៥៣}{៥១៩,០០}$ | $= ០,១០$ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឆ** | $អ'_{ទ}ឆ = \frac{២៥២}{៥១៩,០០}$ | $= ០,៤៨$ |

តាមលទ្ធផលនៃការគណនាខាងលើ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈដែលនៅទំនេរនេះទេ។ បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី១ តាមរូបមន្តជំហានទី២ ពុំមានបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈ អាសនៈទាំងនោះត្រូវយកមកបែងចែកបន្តទៀត ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តដូចខាងក្រោម ៖

**ជំហានទី៣ : ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសនៈដែលនៅទំនេរ (លើកទី ២)**

២.៣១.២.៣ ដើម្បីកំណត់មធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវធ្វើការគណនាដោយយកចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ចែកនឹងចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះបានទទួលបន្ទាប់ពីការបែងចែកអាសនៈលើកទី ១ បូកនឹងលេខនិមិត្តចំនួន ១ តាមរូបមន្តខាងក្រោម ៖

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ទ} + ១}$$

ក្នុងនោះ ៖

- $ម'_{ធ}$ តាងឱ្យមធ្យមភាគខ្ពស់បំផុត ។
- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។
- $អ'_{ទ}$ តាងឱ្យចំនួនអាសនៈ ដែលបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ទទួលបានក្នុងការបែងចែកអាសនៈដែលនៅទំនេរលើកទី ១ ។
- ១ ជាលេខនិមិត្ត ។

២.៣១.២.៤ ក្នុងការរកមធ្យមភាគរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាឱ្យដល់ចំនួន ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយណា ដែលមានមធ្យមភាគខ្ពស់ជាងគេ ។

២.៣១.២.៥ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជន នៃគណបក្សនយោបាយនីមួយៗ រួចមកត្រូវធ្វើការប្រៀបធៀបគ្នា ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតដល់ចំនួន ២ (ពីរ) ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសនៈ ១ (មួយ) ។

**ឧទាហរណ៍**

ការបែងចែកអាសនៈដែលទំនេរលើកទី២ តាមរូបមន្តមធ្យមភាគខ្ពស់បំផុត នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល។

បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី១ តាមរូបមន្តជំហានទី២ រួចមកពុំមានបញ្ជីបេក្ខជននៃគណបក្សណាមួយទទួលបានអាសនៈទេ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស **ក** $ម'_{ធ}ក = \frac{១២៣}{០+១} = ១២៣,០០$

បញ្ជីបេក្ខជននៃគណបក្ស **គ** $ម'_{ធ}គ = \frac{៩៨}{០+១} = ៩៨,០០$

បញ្ជីបេក្ខជននៃគណបក្ស **ឃ** $ម'_{ធ}ឃ = \frac{៥១២}{០+១} =$ **៥១២,០០**

បញ្ជីបេក្ខជននៃគណបក្ស **ច** $ម'_{ធ}ច = \frac{៥៣}{០+១} = ៥៣,០០$

បញ្ជីបេក្ខជននៃគណបក្ស **ឆ** $ម'_{ធ}ឆ = \frac{២៥២}{០+១} = ២៥២,០០$

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៥ (ប្រាំ) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគធំជាងគេគឺ **៥១២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស **ឃ** ត្រូវទទួលបានអាសនៈដែលនៅទំនេរចំនួន ១ (មួយ) ក្នុងការបែងចែកលើកនេះ ។

២.៣១.២.៦ ប្រសិនបើមាននៅសល់អាសនៈទៀត អាសនៈនៅសល់នោះ ត្រូវបន្តបែងចែកម្តងមួយអាសនៈរហូតដល់អស់អាសនៈ តាមរូបមន្ត

មធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ដដែល ដោយត្រូវបង្កើនតម្លៃ អ₉ ចំនួន ១ (មួយ) ចំពោះគណបក្សនយោបាយណាដែលទើប ទទួលបានអាសនៈបន្ថែមចំនួនមួយ។

**ឧទាហរណ៍**

ការបែងចែកអាសនៈដែលទំនេរលើកទី៣ នៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ដដែល ។

បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរលើកទី ២ តាមរូបមន្តជំហានទីបីរួចមក នៅមានសល់អាសនៈចំនួន ១ (មួយ) ទៀត ត្រូវបែងចែកបន្ត ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន ៖

បញ្ជីបេក្ខជននៃគណបក្ស **ក** ម៉ធក = ១២៣ / ០+១ = ១២៣,០០

បញ្ជីបេក្ខជននៃគណបក្ស **គ** ម៉ធគ = ៩៨ / ០+១ = ៩៨,០០

បញ្ជីបេក្ខជននៃគណបក្ស **ឃ** ម៉ធឃ = ៥១២ / ១+១ = **២៥៦,០០**

បញ្ជីបេក្ខជននៃគណបក្ស **ច** ម៉ធច = ៥៣ / ០+១ = ៥៣,០០

បញ្ជីបេក្ខជននៃគណបក្ស **ឆ** ម៉ធឆ = ២៥២ / ០+១ = ២៥២,០០

ប្រៀបធៀបមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំង ៥ (ប្រាំ) ខាងលើ បញ្ជីបេក្ខជននៃគណបក្ស **ឃ** មានមធ្យមភាគធំជាងគេគឺ **២៥៦,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស **ឃ** ត្រូវទទួលបានអាសនៈដែលនៅទំនេរចំនួន ១ (មួយ) ក្នុងការបែងចែកលើកចុងក្រោយនេះ ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត A ៖

| | | | |
|---|---|---|---|
| បញ្ជីបេក្ខជននៃគណបក្ស | **ឃ** | បានទទួលអាសនៈ ២ អាសនៈបន្ថែមទៀតសរុប | ៥ |
| បញ្ជីបេក្ខជននៃគណបក្ស | **ខ** | បានទទួលអាសនៈ | ៣ |
| បញ្ជីបេក្ខជននៃគណបក្ស | **ឆ** | បានទទួលអាសនៈ | ១ |

**សរុប = ៩ (ប្រាំបួន) អាសនៈ**

**ប្រការ ២.៣២.–**

ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេររបស់គណបក្សនយោបាយ ដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ គ.ជ.ប ត្រូវចាត់នីតិវិធីឡើងវិញ ដើម្បីសម្របសម្រួលជាមួយគណបក្សនយោបាយទាំងនោះ ។

**ប្រការ ២.៣៣.–**

ក្នុងករណីគណនាតាមរូបមន្តដូចក្នុងប្រការ ២.៣១ និងប្រការ ២.៣២ ខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នា ដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឱ្យគណបក្សណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយ ដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយ តាមការចាប់ឆ្នោតដែលកំណត់ដោយ គ.ជ.ប។ គ.ជ.ប ត្រូវប្រគល់ភារកិច្ចជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប ចាត់ចែងរៀបចំការចាប់ឆ្នោត ។

វិធីចាប់ឆ្នោតត្រូវដំណើរការតាមនីតិវិធី ដែលកំណត់ដោយ គ.ជ.ប ដូចខាងក្រោម៖

២.៣៣.១ ការចាប់ឆ្នោត ដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយឈ្នះឆ្នោត ត្រូវធ្វើជាសាធារណៈ ។

២.៣៣.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើនៅទីស្តីការ គ.ជ.ប ក្រោយពេលបញ្ចប់ការបែងចែកអាសនៈតាមមណ្ឌលបោះឆ្នោតនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្សេងទៀត ។

២.៣៣.២.១ គ.ជ.ប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីនៃការចាប់ឆ្នោត ហើយត្រូវនិមន្ត និងអញ្ជើញ ចូលរួមក្នុងពិធីចាប់ឆ្នោត ៖

- ព្រះសង្ឃ ជាអធិបតីក្នុងពិធីចាប់ឆ្នោត ។
- តំណាងផ្លូវការនៃគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- តំណាងផ្លូវការនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។
- អ្នកសង្កេតការណ៍ ។

២.៣៣.២.២ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖

- ត្រូវសរសេរ ឬបោះពុម្ពនៅលើក្រដាសដែល មានប្រភេទ ទំហំ និងពណ៌ ដូចគ្នា នូវឈ្មោះនៃគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាស្មើគ្នា ។ ក្រដាសឆ្នោតមួយសន្លឹក

ត្រូវសរសេរ ឬបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ។ តួអក្សរជាឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា ។ ក្រដាសសន្លឹកឆ្នោតដែលសរសេរ ឬបោះពុម្ពឈ្មោះរបស់គណបក្សនយោបាយ រួចហើយត្រូវបត់ជាផ្នត់ដូចគ្នា ដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទពណ៌ និងទំហំដូចគ្នា រួចបិទភ្ជិត ដោយមូរចងនឹងកៅស៊ូកងពណ៌ដូចគ្នា ។

- ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈ មុននឹងដាក់សំបុត្រសន្លឹកឆ្នោត ចូលទៅក្នុងហិបនោះ និងបិទគម្រប ។
- ត្រូវក្រឡុកហិបឆ្នោតរួចលើកហិបឆ្នោតនោះទៅដាក់លើតុខ្ពស់ ។
- ត្រូវនិមន្តព្រះសង្ឃ ចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបនោះ រួចជូនទៅមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ។
- មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រនោះជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលចូលរួមបានឃើញ និងប្រាកដថាឈ្មោះ គណបក្សដែលបានប្រកាសដូចគ្នានឹងឈ្មោះរបស់គណបក្សដែលបានសរសេរ ឬបោះពុម្ពនៅលើសន្លឹកឆ្នោតនោះមែន ។

២.៣៣.២.៣ អគ្គលេខាធិការ គ.ជ.ប ត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងតំណាងចូលរួម ( គ.ជ.ប តំណាងគណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា អ្នកសង្កេតការណ៍...) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត ។

២.៣៣.២.៤ កំណត់ហេតុ ត្រូវចុះហត្ថលេខាដោយ ៖

- អ្នកធ្វើកំណត់ហេតុ ដែលត្រូវបានចាត់តាំង
- អគ្គលេខាធិការ គ.ជ.ប
- តំណាងគណបក្សនយោបាយដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា។

២.៣៣.២.៥ កំណត់ហេតុត្រូវធ្វើតាមតម្រូវការប្រើប្រាស់ដូចខាងក្រោម ៖

- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ។
- ផ្ញើជូនទៅគ្រប់គណបក្សនយោបាយ ដែលបញ្ជីបេក្ខជនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

**ប្រការ ២.៣៤.-**

ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ គ.ជ.ប ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ ក្រោយពីបានទទួលសំណើ។ បែបបទនៃការទទួលពិនិត្យ និងការអនុម័តឈ្មោះបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា១៥ មាត្រា ១៦ មាត្រា ១៧ថ្មី មាត្រា១៨ មាត្រា២០ មាត្រា២២ ដល់មាត្រា២៦ នៃ ច.ប.ក និងនីតិវិធីនៃការចុះបញ្ជីបេក្ខជនបម្រុងបន្ថែម ដូចបានកំណត់ខាងក្រោម ៖

២.៣៤.១ ដើម្បីដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម គណបក្សនយោបាយត្រូវធ្វើពាក្យសុំតាមបែបបទដែលកំណត់ដោយ គ.ជ.ប ។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម (ទ.១០០៨ប) ជា ២ (ពីរ) ច្បាប់។ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។ ការផ្ទេរសិទ្ធិបន្ត ត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។ ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម ត្រូវភ្ជាប់ជាមួយនូវ ៖

- បញ្ជីរាយនាមបេក្ខជន ចំនួន ៣ (បី) ច្បាប់ ដែលមានចំនួនបេក្ខជនបម្រុងបន្ថែម យ៉ាងតិចស្មើនឹងចំនួនអាសនៈក្រុមប្រឹក្សានៃក្រុមប្រឹក្សាពាក់ព័ន្ធ ។
- សេចក្តីបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោតចំនួន ១ (មួយ) ច្បាប់ សម្រាប់បេក្ខជនបម្រុងបន្ថែមម្នាក់ៗ ។
- សេចក្តីប្រកាសរបស់បេក្ខជនយល់ព្រមតាមការតែងតាំងជាបេក្ខជនរបស់គណបក្សចំនួន ១ (មួយ) ច្បាប់ សម្រាប់បេក្ខជនបម្រុងបន្ថែមម្នាក់ៗ ។

២.៣៤.២ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតមកទល់ថ្ងៃដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម
- មានសិទ្ធិបោះឆ្នោត និងលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយ ច.ប.ក ។

២.៣៤.៣ ជនគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយ ៖

- សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងចៅក្រម
- សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សមាជិក គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង
- មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់
- ជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច
- ជនដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប
- ព្រះសង្ឃ ឬបព្វជិតសាសនា ។

២.៣៤.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃគណបក្សនយោបាយជាបន្ទាន់សមស្របបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម ។

- ក្នុងករណីគណបក្សនយោបាយ បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនបម្រុងបន្ថែមជូនសាមីគណបក្សនយោបាយ ដោយភ្ជាប់មកជាមួយនូវបញ្ជីបេក្ខជនបម្រុងបន្ថែមផ្លូវការ ១ (មួយ) ច្បាប់ ។ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជនបម្រុងបន្ថែមនៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

- ក្នុងករណីគណបក្សនយោបាយពុំបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌ ដូចបានកំណត់ខាងលើ គ.ជ.ប ត្រូវបដិសេធបេក្ខភាពបម្រុងបន្ថែមណាដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះតែប៉ុណ្ណោះ ។ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយ ។

២.៣៤.៥ គ.ជ.ប ត្រូវរៀបចំបញ្ជីរាយនាមបេក្ខជនបម្រុងបន្ថែមចំនួន ៣ (បី) ច្បាប់ ដើម្បីប្រើប្រាស់ ១ (មួយ) ច្បាប់ជូនសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់ផ្ញើជូន លធ.ឧប ពាក់ព័ន្ធ និង ១ (មួយ) ច្បាប់រក្សាទុកជាឯកសារនៅ គ.ជ.ប ។

២.៣៤.៦ ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាដូចមានចែងក្នុងប្រការ ២.៣៤ នេះ ឬមិនបានកែលម្អការខ្វះខាត ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។ ករណីនេះ គ.ជ.ប ត្រូវបែងចែកអាសនៈដែលនៅទំនេរនេះតាមបទប្បញ្ញត្តិនៃ ប.ន.ក នេះ ។

**ប្រការ ២.៣៥.-**

បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវទទួលបានរួចហើយ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ជាប្រធានក្រុមប្រឹក្សាតាមប្រភេទក្រុមប្រឹក្សា តាមលំដាប់លេខរៀងពីបញ្ជីបេក្ខជនដែលនៅជាធរមាន ឬបញ្ជីដែលបានធ្វើបច្ចុប្បន្នភាព ឬបញ្ជីបេក្ខជនបម្រុងបន្ថែមរបស់គណបក្សដែលជាប់ឆ្នោត រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច ។

# ផ្នែកទី ៣
# ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**ប្រការ ២.៣៦.–**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញលក្ខខណ្ឌ និងមានលក្ខណសម្បត្តិដូចខាងក្រោម ៖

២.៣៦.១ មានសញ្ជាតិខ្មែរពីកំណើត ។

២.៣៦.២ មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត ។

២.៣៦.៣ មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយ ច.ប.ក ។

**ប្រការ ២.៣៧.–**

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺ ៖

២.៣៧.១ សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងចៅក្រម ។

២.៣៧.២ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

២.៣៧.៣ អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

២.៣៧.៤ សមាជិក គបឃ.ស ។

២.៣៧.៥ សមាជិក គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

២.៣៧.៦ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង ។

២.៣៧.៧ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ ។

២.៣៧.៨ ជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

២.៣៧.៩ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

២.៣៧.១០ ជនដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប ។

២.៣៧.១១ ព្រះសង្ឃ ឬបព្វជិតសាសនា ។

**ប្រការ ២.៣៨.-**

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រី បុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

២.៣៨.១ មន្ត្រីរាជការស៊ីវិលរួមមាន មន្ត្រីរាជការក្នុងក្របខ័ណ្ឌនីតិបញ្ញត្តិ ក្របខ័ណ្ឌនីតិប្រតិបត្តិ ក្របខ័ណ្ឌតុលាការ និងក្របខ័ណ្ឌពិសេសផ្សេងទៀត ។

២.៣៨.២ ប្រសិនបើសាមីខ្លួនជាប់ឆ្នោត ហើយមានបំណងបម្រើការងារជាសមាជិកក្រុមប្រឹក្សានោះ សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬស្ថាប័នសាមី ដើម្បីទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា ។

២.៣៨.៣ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬឋានន្តរស័ក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

២.៣៨.៤ នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចសុំត្រឡប់មកបម្រើការងារនៅក្រសួង ឬស្ថាប័នដើមវិញ ប៉ុន្តែមុខងារ និងតំណែងអាស្រ័យដោយក្រសួង ឬស្ថាប័នជាអ្នកសម្រេច ។

**ប្រការ ២.៣៩.-**

លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬស្ថាប័នដើម អាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។ ក្នុងករណីមិនអាចធ្វើទាន់ត្រូវផ្ញើពាក្យសុំច្បាប់ឈប់ពិសេសជូន គធ.ខប ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើកការឃោសនាបោះឆ្នោត។ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះសាមីជនដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬស្ថាប័នដែលសាមីជនកំពុងបម្រើការងារ កាលបរិច្ឆេទសុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំរបស់ខ្លួន ពោលគឺនៅថ្នាក់លើមួយថ្នាក់ដែលខ្លួននៅក្រោមឱវាទ ។

**ប្រការ ២.៤០.-**

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ មានសិទ្ធិចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ គណបក្សនយោបាយដែលមានបំណងចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ផ្ដើមដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅ គធ.ខប យ៉ាងតិច ៨០ (ប៉ែតសិប) ថ្ងៃ មុនកាលបរិច្ឆេទនៃការបោះឆ្នោត ។

២.៤០.១ គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីឈរឈ្មោះបោះឆ្នោតដោយឡែកៗពីគ្នា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រភេទណាមួយ ដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ។

២.៤០.២ គណបក្សនយោបាយដែលមានបំណងចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវរៀបចំបញ្ជីបេក្ខជនរបស់ខ្លួនតាមមណ្ឌលបោះឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.៤០.៣ ក្នុងការរៀបចំបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត គណបក្សនយោបាយត្រូវបំពេញបែបបទ សេចក្ដីប្រកាសបេក្ខភាពដែលផ្ដល់ដោយ គ.ជ.ប តាមរយៈ គធ.ខប ។ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលបោះឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវ ៖

២.៤០.៣.១ បញ្ជាក់ច្បាស់ពីប្រភេទក្រុមប្រឹក្សា ដែលបញ្ជីបេក្ខជនត្រូវឈរឈ្មោះបោះឆ្នោត ។

២.៤០.៣.២ រៀបចំឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ និងត្រូវធានាឱ្យមានបេក្ខជនស្ត្រីចូលរួម និងមានឈ្មោះនៅលំដាប់លេខរៀងសមស្របក្នុងបញ្ជីបេក្ខជននោះ។

២.៤០.៣.៣ បញ្ជីបេក្ខជននៃគណបក្សនយោបាយ ត្រូវមានបេក្ខជនពេញសិទ្ធិ និងបេក្ខជនបម្រុង ដែលមានចំនួនបេក្ខជនយ៉ាងតិច ២ (ពីរ) ដង នៃចំនួនអាសនៈសម្រាប់ក្រុមប្រឹក្សាណាមួយ ដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ។

២.៤០.៣.៤ បេក្ខជនម្នាក់ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយ និងមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាតែមួយប៉ុណ្ណោះ ។

២.៤០.៣.៥ បេក្ខជន ដែលមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយលើសពីមួយ ឬឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាលើសពីមួយ ត្រូវបានប្រកាសថា បាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គ.ជ.ប ។

២.៤០.៤ បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលត្រូវបានដាក់ពាក្យសុំចុះបញ្ជីនៅ គធ.ខប រួចហើយ មិនអនុញ្ញាតឱ្យបេក្ខជនលាឈប់ ឬប្តូរបេក្ខជន ឬដកបញ្ជីបេក្ខជនឈរឈ្មោះឡើយ។ បេក្ខជនអាចលាឈប់ពីបញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយបានបន្ទាប់ពី គធ.ខប ទទួលស្គាល់ជាផ្លូវការនូវការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។

២.៤០.៥ គណបក្សនយោបាយដែលទទួលបានអាសនៈនៅក្នុងក្រុមប្រឹក្សា ហើយបេក្ខជនពេញសិទ្ធិ និងបម្រុងផ្លូវការរបស់ខ្លួនមានចំនួនមិនគ្រប់គ្រាន់សម្រាប់បំពេញអាសនៈរបស់ខ្លួនដែលនៅទំនេរ ដោយមូលហេតុទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបម្រុងបន្ថែម កំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប ។

**ប្រការ ២.៤១.-**

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជាផ្លូវការ គណបក្សនយោបាយត្រូវដាក់ពាក្យសុំតាមបែបបទកំណត់ដោយ គ.ជ.ប ទៅ គធ.ខប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើមចុះបញ្ជី ។

២.៤១.១ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គឺជាទម្រង់បែបបទលេខ ១០០៨ (ទ.១០០៨)។ ពាក្យសុំចុះបញ្ជីនេះ ត្រូវបានផ្តល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីនេះ ជា ២ (ពីរ) ច្បាប់ ។

២.៤១.២ ពាក្យសុំនេះត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត ។

២.៤១.៣ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវភ្ជាប់មកជាមួយនូវៈ

២.៩១.៣.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់ ។

២.៩១.៣.២ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ ។

២.៩១.៣.៣ អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ និងអាសយដ្ឋានទីស្នាក់ការរបស់គណបក្សនយោបាយនៅតាមរាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌ ។

២.៩១.៣.៤ បញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។ បញ្ជីនេះត្រូវមានចំនួនបេក្ខជនពេញសិទ្ធិ និងបម្រុងដែលមានចំនួនបេក្ខជនយ៉ាងតិច ២ (ពីរ) ដង នៃចំនួនអាសនៈក្រុមប្រឹក្សាណាមួយ ដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ។

២.៩១.៣.៥ សេចក្តីបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលសាមីបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ។

២.៩១.៣.៦ សេចក្តីប្រកាសរបស់គណបក្សនយោបាយថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលបោះឆ្នោត ដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ក ច.ប.ត.រ ច្បាប់ស្តីពីគណបក្សនយោបាយ ប.ន.ក និងក្រមសីលធម៌របស់ គ.ជ.ប ។

២.៩១.៣.៧ សេចក្តីប្រកាសរបស់បេក្ខជន យល់ព្រមឱ្យគណបក្សនយោបាយតែងតាំងខ្លួន ជាបេក្ខជនដើម្បីឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត**

**ប្រការ ២.៩២.–**

គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៩២.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ ទីកន្លែង និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

២.៤២.២ ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេល ៥ (ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ២:០០នាទី ដល់ ៥:៣០នាទី ។

២.៤២.៣ គធ.ខប ត្រូវចេញបង្កាន់ដៃបញ្ជាក់ការទទួលពាក្យជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជី ១ (មួយ) ច្បាប់ ទុកជាឯកសារ ។

២.៤២.៤ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារដែលបានទទួល ដោយត្រូវចុះកាលបរិច្ឆេទប្រគល់ ទទួល និងចុះហត្ថលេខា ឬស្នាមមេដៃរបស់អ្នកប្រគល់ ទទួល ។

២.៤២.៥ នៅពេលបញ្ចប់ការទទួលពាក្យ គធ.ខប ត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួន ៣ (បី) ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា គធ.ខប រួចបិទផ្សាយ ១ (មួយ) ច្បាប់ នៅ លគធ.ខប ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន ។

**ការពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត**

**ប្រការ ២.៤៣.-**

គធ.ខប ត្រូវពិនិត្យ សម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

២.៤៣.១ ក្នុងករណី គធ.ខប យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គធ.ខប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ ។

២.៤៣.២ ក្នុងករណី គធ.ខប ពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ២.៣៦ ដល់ប្រការ ២.៤១ ខាងលើ គធ.ខប ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម ឬកែតម្រូវ ។ សាមីគណបក្សនយោបាយត្រូវបំពេញលក្ខខណ្ឌ ឬកែតម្រូវចំណុចដែលខ្វះខាតយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងនេះ ។

២.៤៣.៣ ក្នុងករណីគណបក្សនយោបាយដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពី គធ.ខប ឱ្យធ្វើការកែតម្រូវចំណុចខ្វះខាត បានកែតម្រូវត្រឹមត្រូវ និងទាន់ពេលវេលាហើយនោះ គធ.ខប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេល ១ (មួយ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ ។

២.៤៣.៤ ក្នុងករណី គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌ ឬកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលកំណត់ គធ.ខប ត្រូវសម្រេចបដិសេធពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ដោយត្រូវ ៖

២.៤៣.៤.១ ចុះហត្ថលេខា និងកាលបរិច្ឆេទលើបែបបទនៃសេចក្ដីសម្រេចបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជន ចំនួន ៣ (បី) ច្បាប់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធ រួចត្រូវ ៖

- ផ្ញើជូនគណបក្សនយោបាយសាមី ឬតំណាង ឬសាមីខ្លួន ១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកឯកសារ ១ (មួយ) ច្បាប់ ។

២.៤៣.៤.២ ផ្ដល់ព័ត៌មានទៅសាមីគណបក្សនយោបាយ ឬតំណាង ឬសាមីខ្លួនថាគាត់អាចប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធ ។

២.៤៣.៤.៣ ផ្ដល់ពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ជូនគណបក្សនយោបាយ ឬតំណាង ឬសាមីខ្លួន ដែលត្រូវបានបដិសេធ សម្រាប់ប្ដឹងតវ៉ាទៅ គ.ជ.ប ។

**ប្រការ ២.៤៤.–**

គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬបេក្ខភាព ឬបញ្ជីបេក្ខជនរបស់គណបក្សនយោបាយណាមួយដែលត្រូវបានបដិសេធដោយ គធ.ខប សាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធ ។

២.៤៤.១ ក្នុងករណីទទួលបានសេចក្ដីសម្រេចបដិសេធការសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬបេក្ខភាព ឬបញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរ

ឈ្មោះបោះឆ្នោត និងពាក្យបណ្តឹង (ទ.១២០២) រួចហើយ ប៉ុន្តែសាមីគណបក្ស ឬសាមីខ្លួន ឬតំណាងពុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅតាមពេលវេលា ដូចមានចែងក្នុងប្រការ ២.៤៤ ខាងលើនេះ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា ។

២.៤៤.២ ប្រសិនបើសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាងបានដាក់ពាក្យបណ្តឹងតវ៉ាតាមពេលវេលាកំណត់ គ.ជ.ប ត្រូវពិនិត្យបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

**ប្រការ ២.៤៥.-**

ប្រសិនបើសវនាការ គ.ជ.ប សម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា គ.ជ.ប ត្រូវបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ និងផ្តល់ជូនសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៤៥.១ បន្ទាប់ពីបានទទួលសេចក្តីសម្រេចយល់ព្រមពី គ.ជ.ប គធ.ខប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ឬ/និងទទួលយល់ព្រមបេក្ខភាព រួចហើយត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬ/និងទទួលយល់ព្រមបេក្ខភាព ឬ/និងបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ ។

២.៤៥.២ គធ.ខប ត្រូវផ្តល់លិខិតបញ្ជាក់ខាងលើនេះ ជូនសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

**ប្រការ ២.៤៦.-**

ក្នុងករណីសវនាការ គ.ជ.ប សម្រេចបដិសេធពាក្យបណ្តឹងតវ៉ា គ.ជ.ប ត្រូវ ៖

២.៤៦.១ បំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ រួចត្រូវ៖

- ជូន ឬផ្ញើជូនសាមីគណបក្សនយោបាយ ឬសាមីខ្លួន ឬតំណាង ១ (មួយ) ច្បាប់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកឯកសារ ១ (មួយ) ច្បាប់ ។

២.៤៦.២ សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា។

## ការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោត

### ប្រការ ២.៤៧.-

បន្ទាប់ពីបានបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឬ/និងក្រោយពេលដែល គ.ជ.ប បានសម្រេចចុងក្រោយលើពាក្យបណ្តឹងតវ៉ានានាអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គធ.ខប ត្រូវរៀបចំធ្វើការចាប់ឆ្នោតកំណត់យកលេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប ។

២.៤៧.១ ផ្អែកលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផ្លូវការ គធ.ខប ត្រូវធ្វើការចាប់ឆ្នោតកំណត់យកលេខរៀងគណបក្សនយោបាយដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។

២.៤៧.២ ការចាប់ឆ្នោតនេះ ត្រូវធ្វើឡើងជាសាធារណៈ ។ គធ.ខប ត្រូវបិទផ្សាយជាសាធារណៈ អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោង មុនការចាប់ផ្តើមពិធីចាប់ឆ្នោត ។

២.៤៧.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត យ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោង មុនពិធីចាប់ឆ្នោតចាប់ផ្តើម។ ក្នុងការទទួលលិខិតអញ្ជើញនេះ ត្រូវមានចុះហត្ថលេខារបស់អ្នកទទួល ដើម្បីទុកជាឯកសារ ។

២.៤៧.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោម ៖

២.៤៧.៤.១ សុន្ទរកថាបើកពិធីថ្លែងដោយប្រធាន គធ.ខប ។

២.៤៧.៤.២ ការបង្ហាញសន្លឹកឆ្នោត និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត ។

២.៤៧.៤.៣ ការចាប់ឆ្នោតត្រូវធ្វើឡើងដោយព្រះសង្ឃដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ ។

២.៤៧.៤.៤ ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត ។

២.៤៧.៤.៥ ការបិទពិធីចាប់ឆ្នោត ។

២.៤៧.៥ គធ.ខប ត្រូវរៀបចំសន្លឹកឆ្នោត ១ (មួយ) សន្លឹកសម្រាប់គណបក្សនយោបាយនីមួយៗ ។

២.៤៧.៥.១ ក្រដាសសន្លឹកឆ្នោតនេះ ត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា ។

២.៤៧.៥.២ ឈ្មោះគណបក្សនយោបាយត្រូវសរសេរ ឬបោះពុម្ពជាអក្សរដែលមានពណ៌ ប្រភេទ និងទំហំតួអក្សរដូចគ្នានៅលើសន្លឹកឆ្នោតនេះ ។

២.៤៧.៥.៣ សន្លឹកឆ្នោត ១ (មួយ) សន្លឹក ដែលមានសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយមួយ ត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នាដែលមិនអាចសម្គាល់បានរួចមួរ ដោយចងនឹងកៅស៊ូកងពណ៌ដូចគ្នា ។

២.៤៧.៦ មុនចាប់ផ្តើមការចាប់ឆ្នោត គធ.ឧប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនីមួយៗនៅចំពោះមុខអង្គពិធី មុននឹងបត់ដាក់ចូលក្នុងស្រោមសំបុត្ររួចបិទភ្ជិត ។

២.៤៧.៦.១ សន្លឹកឆ្នោតនីមួយៗត្រូវបត់ជាពីរផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្រ រួចបិទភ្ជិត រួចមួរ ដោយចងនឹងកៅស៊ូកងពណ៌ដូចគ្នា ។

២.៤៧.៦.២ ស្រោមសំបុត្រឆ្នោតទាំងអស់ ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងហិបឆ្នោតតែមួយ ហើយត្រូវក្រឡុកហិបឆ្នោតនោះ ។

២.៤៧.៧ បន្ទាប់មកត្រូវនិមន្តព្រះសង្ឃដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌដូចចំណុច ២.៤៧.៤.៣ ចាប់យកស្រោមសំបុត្រឆ្នោតម្តងមួយៗពីក្នុងហិបឆ្នោត ។

២.៤៧.៧.១ ស្រោមសំបុត្រឆ្នោតដែលចាប់បានត្រូវប្រគល់ទៅមន្ត្រី លគធ.ឧប ម្នាក់ ក្នុងចំណោមពីរនាក់ ។

២.៤៧.៧.២ មន្ត្រីរូបនោះត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយ នៅចំពោះមុខអង្គពិធី ហើយជូនសន្លឹកឆ្នោតនោះ ទៅឱ្យមន្ត្រីទីពីរ ។

២.៤៧.៧.៣ មន្ត្រីទីពីរត្រូវអានឈ្មោះគណបក្សនយោបាយ ដែលសរសេរនៅលើសន្លឹកឆ្នោតឱ្យបានឮ បង្ហាញអ្នកចូលរួម និងសរសេរលេខរៀង "ទី១" នៅលើសន្លឹកឆ្នោតនោះ ។

២.៤៧.៧.៤ លទ្ធផលនៃការចាប់ឆ្នោតត្រូវសរសេរនៅលើក្តារខៀន ដើម្បីបង្ហាញបន្ថែម នៅចំពោះមុខអង្គពិធី ។

២.៤៧.៧.៥ ការចាប់ឆ្នោត និងចុះលេខរៀង ត្រូវធ្វើបន្តតាមលំដាប់ រហូតដល់សន្លឹកឆ្នោតចុងក្រោយបង្អស់ ។

២.៤៧.៨ លេខាធិការនៃពិធីចាប់ឆ្នោត ត្រូវធានាបំពេញកំណត់ហេតុនៃការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតឱ្យបានរួចរាល់ ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្សដែលបានចុះលេខរៀងរួចហើយ ដូចមានចែងក្នុងចំណុច ២.៤៧.៧.៣ ។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខានៅលើកំណត់ហេតុនេះ ។

២.៤៧.៩ គធ.ខប ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូន គ.ជ.ប អំពីលទ្ធផលនៃការចាប់ឆ្នោត ដោយភ្ជាប់ជាមួយនូវកំណត់ហេតុនៃពិធីចាប់ឆ្នោតជាសាធារណៈ និងសន្លឹកឆ្នោតរបស់គណបក្សដែលបានចុះលេខរៀងហើយ ដូចមានចែងក្នុងចំណុច ២.៤៧.៨។ កំណត់ហេតុនៃពិធីចាប់ឆ្នោតជាសាធារណៈត្រូវរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់នៅ គធ.ខប និងបិទផ្សាយ ១ (មួយ) ច្បាប់នៅ លគធ.ខប ។

២.៤៧.១០ ផ្អែកតាមរបាយការណ៍ស្ដីពីលទ្ធផលនៃការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតរបស់ គធ.ខប គ.ជ.ប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់មណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ ។

២.៤៧.១០.១ ការបោះពុម្ពសន្លឹកឆ្នោត ត្រូវផ្អែកលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផ្លូវការ តាមមណ្ឌលបោះឆ្នោតនីមួយៗ និងលទ្ធផលនៃការចាប់ឆ្នោតកំណត់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតនៅ គធ.ខប ។

២.៤៧.១០.២ សន្លឹកឆ្នោត សម្រាប់មណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាប្រើប្រាស់បានតែនៅក្នុងមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះប៉ុណ្ណោះ ។

២.៤៧.១០.៣ ឈ្មោះ និងសញ្ញាសម្គាល់គណបក្សនយោបាយនៅលើសន្លឹកឆ្នោតត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយត្រូវដាក់ជាលេខរៀងតាមលទ្ធផលនៃការចាប់ឆ្នោត ។

២.៤៧.១០.៤ សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ឬខេត្ត ត្រូវបោះពុម្ពលើក្រដាសពណ៌ស និងខ្ទប់ដោយក្រដាសពណ៌ស ។

២.៤៧.១០.៥ សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ឬស្រុក ឬខណ្ឌត្រូវបោះពុម្ពលើក្រដាសពណ៌ និងខ្ទប់ដោយក្រដាសពណ៌។

**ប្រការ ២.៤៨.-**

គជ.ខប ត្រូវបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលបានចាប់ឆ្នោតកំណត់លេខរៀងនៅលើសន្លឹកឆ្នោតហើយ ក្នុងរយៈពេលយ៉ាងតិច ៤៥ (សែសិបប្រាំ) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

**ប្រការ ២.៤៩.-**

បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

**ប្រការ ២.៥០.-**

គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការត្រូវគោរពតាម ច.ប.ក ច.ប.ត.រ និង ប.ន.ក នេះ ព្រមទាំងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោតដែលកំណត់ដោយ គ.ជ.ប ។

# ផ្នែកទី ៤
# បញ្ជីបោះឆ្នោត

**អ្នកបោះឆ្នោត**

**ប្រការ ២.៥១.-**

សមាជិក កបឃ.ស នៅក្នុងមុខតំណែង គឺជាអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សា។ គ.ជ.ប ត្រូវណែនាំដល់អ្នកបោះឆ្នោត អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ អំពីបែបបទទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៥១.១ ការចុះឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ក្នុងក្របខ័ណ្ឌក្រុង ស្រុក ខណ្ឌ ទៅក្នុងបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ជាការងារតម្រូវដោយច្បាប់ ។

២.៥១.២ សមាជិក កបឃ.ស នៅក្នុងមុខតំណែងម្នាក់ៗមានសិទ្ធិចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតមួយ ដែលមានទីតាំងនៅទីប្រជុំជនក្រុង ស្រុក ខណ្ឌ ។

២.៥១.៣ ការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមរបៀបស្រង់ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោត និងបញ្ជូនតាមលំដាប់ឋានានុក្រមមក គ.ជ.ប ឱ្យបានតាមកាលបរិច្ឆេទកំណត់ ។

២.៥១.៤ កបឃ.ស ត្រូវរៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង រួចប្រធាន កបឃ.ស និងជាមេឃុំ ចៅសង្កាត់ចុះហត្ថលេខា និងបោះត្រារដ្ឋបាលឃុំ សង្កាត់ ដែលមានការបញ្ជាក់ឯកភាពពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ រួចបញ្ជូនមក គ.ជ.ប ឱ្យបានតាមកាលបរិច្ឆេទកំណត់ ។

២.៥១.៥ ក្នុងករណី កបឃ.ស នៃឃុំ សង្កាត់ណាមួយមិនបានរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងមុខតំណែងមក គ.ជ.ប ដូចមានចែងក្នុងចំណុច ២.៥១.៤ ខាងលើ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មមុខងារដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដើម្បីរៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នោះ និងចុះហត្ថលេខា បោះត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការបញ្ជាក់ឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ រួចបញ្ជូនមក គ.ជ.ប ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។

### លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត

**ប្រការ ២.៥២.-**

អ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

២.៥២.១ ជាសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.៥២.២ មិនចាំបាច់បង្ហាញខ្លួន ឬអាចទៅបង្ហាញខ្លួនចំពោះមុខប្រធាន កបឃ.ស នៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីទទួលព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីការិយាល័យបោះឆ្នោត និងអំពីតម្រូវការឯកសារនៅពេលបោះឆ្នោត ។

### ការិយាល័យចុះឈ្មោះបោះឆ្នោត

**ប្រការ ២.៥៣.-**

ការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ត្រូវបានកំណត់សម្រាប់ កបឃ.ស នីមួយៗ។ ការិយាល័យចុះឈ្មោះបោះឆ្នោត គឺជាការិយាល័យស្ថិតនៅមួយកន្លែង ។ ការិយាល័យចុះឈ្មោះបោះឆ្នោតសម្រាប់សមាជិក កបឃ.ស នៅក្នុងមុខតំណែងត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ឬទីតាំងណាមួយសមស្របក្នុងឃុំ សង្កាត់ ។

### សង្ខេបដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ

**ប្រការ ២.៥៤.-**

ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាចែកជាដំណាក់កាល ដូចខាងក្រោម ៖

២.៥៤.១ ការចុះឈ្មោះបោះឆ្នោតជូនសមាជិក កបឃ.ស នៅក្នុងមុខតំណែងក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៥៤.២ ការរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង តាមលំដាប់ឋានានុក្រមមក គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត) ដើម្បីបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ និងរៀបចំជាបញ្ជីបោះឆ្នោតដំបូង ។

២.៥៤.៣ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងធ្វើឡើងនៅ លគច.ខប និងនៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.៥៤.៤ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ ដែលទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ។

២.៥៤.៥ ការកែតម្រូវបញ្ជីបោះឆ្នោត ការបោះពុម្ព និងការផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៥៤.៦ ការកែប្រែបញ្ជីបោះឆ្នោតផ្លូវការ ក្នុងករណីមានអ្នកបោះឆ្នោតទទួលមរណភាព ។

**រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ**

**ប្រការ ២.៥៥._**

គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្ដល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ដើម្បីធានាឱ្យការចុះឈ្មោះបោះឆ្នោត ការរៀបចំបញ្ជីបោះឆ្នោតដំបូង ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងការផ្ដល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការដំណើរការទៅយ៉ាងរលូន និងទាន់ពេលវេលាដែលកំណត់ដោយច្បាប់ គ.ជ.ប ត្រូវកំណត់រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតសម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់នីមួយៗ ។

២.៥៥.១ ការចុះឈ្មោះបោះឆ្នោតរួមនឹងការរៀបចំ និងការបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង នៅក្នុងក្របខ័ណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ តាមលំដាប់ឋានានុក្រមមកដល់ គ.ជ.ប ត្រូវបានកំណត់រយៈពេលសរុបត្រឹម ២០ (ម្ភៃ) ថ្ងៃ ដោយមិនគិតបញ្ចូលថ្ងៃអាទិត្យ និងថ្ងៃបុណ្យផ្លូវការ ។

២.៥៥.១.១ រយៈពេលសម្រាប់ការចុះឈ្មោះបោះឆ្នោត តាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗត្រូវបានកំណត់ស្មើនឹង ១៣ (ដប់បី) ថ្ងៃ ។

២.៥៥.១.២ រយៈពេលសម្រាប់ការបញ្ជាក់ឯកភាព និងការបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងក្នុងក្របខ័ណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ តាមលំដាប់ឋានានុក្រមមក គ.ជ.ប ត្រូវបានកំណត់រយៈពេល ៧ (ប្រាំពីរ) ថ្ងៃ ។

២.៥៥.១.៣ ក្នុងករណីការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយបានចុះឈ្មោះជូនសមាជិក កបឃ.ស នៅក្នុងមុខតំណែងរួចរាល់មុនរយៈពេលកំណត់ ការិយាល័យចុះឈ្មោះបោះឆ្នោតនោះ អាចបន្តអនុវត្តជំហានបញ្ជាក់ឯកភាព និងបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង តាមលំដាប់ឋានានុក្រមមក គ.ជ.ប ដោយពុំចាំបាច់រង់ចាំ ។

២.៥៥.២ ការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមធ្វើនៅគ្រប់សាលាឃុំ សង្កាត់ទូទាំងប្រទេស ក្នុងថ្ងៃតែមួយដូចបានកំណត់ក្នុងប្រតិទិនការងាររបស់ គ.ជ.ប។ ការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវបើកអនុវត្តការចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលម៉ោងធ្វើការនៅរៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសៅរ៍។

២.៥៥.៣ គ.ជ.ប ត្រូវណែនាំ គធ.ខប និង កបឃ.ស ឱ្យផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេល និងកាលបរិច្ឆេទដូចមានចែងក្រោមចំណុច ២.៥៥.១ ខាងលើ ព្រមទាំងប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត។

## ការទទួលខុសត្រូវរបស់ កបឃ.ស ក្នុងការចុះឈ្មោះបោះឆ្នោត

### ប្រការ ២.៥៦.-

អនុលោមតាម ច.ប.ក អ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ។ គ.ជ.ប ត្រូវលើកសំណើសុំទៅក្រសួងមហាផ្ទៃ ដើម្បីធ្វើប្រតិភូកម្មអំណាចដល់ កបឃ.ស ឱ្យបំពេញតួនាទីជាតំណាងរបស់ គ.ជ.ប ក្នុងការចុះឈ្មោះបោះឆ្នោត ។

២.៥៦.១ ដើម្បីធានាការពារការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានធ្វើប្រតិភូកម្មអំណាចឱ្យ កបឃ.ស ត្រូវមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

២.៥៦.១.១ អនុវត្តឱ្យបានត្រឹមត្រូវតាម ច.ប.ក និង ប.ន.ក នេះ ។ ប្រកាន់ជំហរអព្យាក្រឹត និងមិនលម្អៀងក្នុងពេលបំពេញការងារ និងធានាឱ្យដំណើរការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ។

២.៥៦.១.២ ចាត់វិធានការសមស្រប ដើម្បីធានាថា ដំណើរការនៃការចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង។

២.៥៦.១.៣ ធានាឱ្យអ្នកសង្កេតការណ៍ ដែលមានការបញ្ជាក់ទទួលស្គាល់ដោយ គ.ជ.ប និងភ្នាក់ងារគណបក្សនយោបាយដែលមានការបញ្ជាក់ទទួលស្គាល់ដោយ គធ.ខប មានលទ្ធភាពសង្កេតការណ៍ក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត ក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ។

២.៥៦.១.៤ ស្រង់ឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង នៅក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗម្នាក់ម្តងៗ និងត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ។ ប្រសិនបើឃើញថាត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់ចូលទៅក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ។

២.៥៦.១.៥ មិនបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ចំពោះអ្នកដែលមិនបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្រោមប្រការ ២.៥២ ខាងលើ ។

២.៥៦.១.៦ ជម្រាបជូនអ្នកដែលត្រូវបានចុះឈ្មោះទៅក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ក្នុងករណីគាត់មកបង្ហាញខ្លួនឱ្យចងចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងឱ្យគាត់យកទៅជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ចេញដោយមេឃុំ ចៅសង្កាត់ ដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

២.៥៦.១.៧ ជូនដំណឹងចំពោះអ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជី ប៉ុន្តែមិនបានមកបង្ហាញខ្លួនតាមមធ្យោបាយដែលមាននូវខ្លឹមសារ និងព័ត៌មានដូចមានចែងក្នុងចំណុច ២.៥៦.១.៦ ខាងលើ ។

២.៥៦.១.៨ ធានាថា សមាជិក កបឃ.ស នៅក្នុងមុខតំណែង នៅក្នុងក្របខណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបានបញ្ចូលទៅក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ។

២.៥៦.១.៩ រាយការណ៍ជូន គ.ជ.ប តាមលំដាប់ឋានានុក្រមនូវរាល់ហេតុការណ៍ដែលបានកើតមានក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហា ។

២.៥៦.១.១០ ធ្វើរបាយការណ៍សរុបលទ្ធផល នៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត នៅពេលដែលការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ និងរៀបចំបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង តាមលំដាប់ឋានានុក្រមមក គ.ជ.ប ដើម្បីរៀបចំជាបញ្ជីបោះឆ្នោតដំបូង ។

២.៥៦.១.១១ ចូលរួមបំភ្លឺក្នុងរាល់សវនាការរបស់ គធ.ខប គ.ជ.ប ដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង (បើមានតម្រូវការជាចាំបាច់) ។

២.៥៦.២ គ.ជ.ប ត្រូវណែនាំជាក់ស្ដែង និងផ្ដល់ទម្រង់បែបបទមួយចំនួនដល់ កបឃ.ស ដើម្បីអនុវត្តការងារនេះ ។

## សម្ភារ ឯកសារសម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោត

**ប្រការ ២.៥៧._**

គ.ជ.ប ត្រូវធានាការផ្គត់ផ្គង់សម្ភារ ឯកសារគ្រប់គ្រាន់សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោតឱ្យបានទាន់ពេលវេលា ។

២.៥៧.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់ គធ.ខប ដើម្បីបន្ដណែនាំសម្របសម្រួលក្នុងការងារចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់នីមួយៗ ចំណុះក្រុង ស្រុក ខណ្ឌ ។

២.៥៧.២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់ កបឃ.ស ដែលទទួលអនុវត្តការចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ ។

## ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការបញ្ជូនបញ្ជីឈ្មោះមក គ.ជ.ប

**ប្រការ ២.៥៨._**

ផ្អែកតាម ប.ន.ក នេះ និងការណែនាំរបស់ គ.ជ.ប និងផ្អែកតាមការកំណត់រយៈពេល និងកាលបរិច្ឆេទសម្រាប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានទទួលសម្ភារ ឯកសារបម្រើការចុះឈ្មោះបោះឆ្នោត កបឃ.ស ត្រូវចាត់ចែងបើកការិយាល័យចុះឈ្មោះបោះឆ្នោតតាមប្រតិទិនកំណត់ និងត្រូវអនុវត្តឱ្យបានរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដើម្បីរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង តាមឋានានុក្រមមក គ.ជ.ប ឱ្យបានទាន់ពេលវេលា ។ កបឃ.ស ត្រូវ ៖

២.៥៨.១ ចាត់ចែងរៀបចំឱ្យមានបន្ទប់មួយ ព្រមទាំងតុ និងកៅអីមួយចំនួនសម្រាប់ប្រើប្រាស់ជាការិយាល័យចុះឈ្មោះបោះឆ្នោត ដូចមានចែងក្រោមប្រការ ២.៥៦ ខាងលើ ។ ការិយាល័យចុះឈ្មោះបោះឆ្នោតអាចតាំងនៅបន្ទប់ធ្វើការរបស់ប្រធាន កបឃ.ស ។

២.៥៨.២ បិទផ្សាយជាសាធារណៈ នូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្ដើមការចុះឈ្មោះបោះឆ្នោត ។ រក្សាទុកបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតចំនួន ១ (មួយ) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងពេលចុះឈ្មោះបោះឆ្នោត ។

២.៥៨.៣ បិទផ្សាយប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោត នៅខាងមុខការិយាល័យចុះឈ្មោះបោះឆ្នោត យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃចុះឈ្មោះបោះឆ្នោត។ ប្រតិទិននេះ ត្រូវតែមានបញ្ជាក់រយៈពេល និងកាលបរិច្ឆេទសម្រាប់ដំណាក់កាលនីមួយៗ ថ្ងៃចាប់ផ្ដើម និងថ្ងៃបញ្ចប់នៃការចុះឈ្មោះបោះឆ្នោត ព្រមទាំងពេលម៉ោង និងថ្ងៃធ្វើការផង ។

២.៥៨.៤ ចាប់ផ្ដើមបើកការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ នៅថ្ងៃតែមួយទូទាំងប្រទេស តាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប ។

**ប្រការ ២.៥៩.-**

ប្រធាន កបឃ.ស និងជាមេឃុំ ចៅសង្កាត់ត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ដើម្បីទទួលចុះឈ្មោះបោះឆ្នោតជូនសមាជិក កបឃ.ស នៅក្នុងមុខតំណែង ដែលត្រូវបំពេញក្នុងទម្រង់បញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង តាមគំរូផ្ដល់ជូនដោយ គ.ជ.ប និងផ្ដល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់សមាជិក កបឃ.ស នៅក្នុងមុខតំណែងទាំងនោះ ។ ប្រធាន កបឃ.ស ត្រូវ ៖

២.៥៩.១ ស្រង់ឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្រោមប្រការ ២.៥២ ខាងលើ ក្នុងករណីមានលក្ខណៈត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់នៅក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ។

២.៥៩.១.១ ការចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងអាចបំពេញដោយដៃ តាមទម្រង់ដែលផ្ដល់ជូនស្រាប់ដោយ គ.ជ.ប ឬអាចរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រ តាមគំរូទម្រង់ដែលផ្ដល់ជូនដោយ គ.ជ.ប ។

២.៥៩.១.២ នាមត្រកូល និងនាមខ្លួនរបស់សមាជិក កបឃ.ស នៅក្នុងមុខតំណែងនៅលើ អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែងចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬ ឯ.អ ដែលត្រូវប្រើប្រាស់នៅថ្ងៃបោះឆ្នោត ត្រូវតែដូចគ្នាជាមួយនឹងនាមត្រកូល និងនាមខ្លួនរបស់សាមីខ្លួន ដែលបានចុះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ។

២.៥៩.២ ជម្រាបជូនសមាជិក កបឃ.ស នៅក្នុងមុខតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង និងដែលបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតអំពី ៖

២.៥៩.២.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅទីប្រជុំជនក្រុង ស្រុក ខណ្ឌពាក់ព័ន្ធដែល គ.ជ.ប បានកំណត់ និងផ្តល់ជូនស្រាប់ ។

២.៥៩.២.២ តម្រូវការជាចាំបាច់នូវ អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬ ឯ.អ របស់សាមីខ្លួន ដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

២.៥៩.២.៣ ការស្នើសុំត្រៀមទុកជាមុននូវ អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ឬ ឯ.អ ។

២.៥៩.៣ ប្រើប្រាស់មធ្យោបាយដែលមាន ដើម្បីជម្រាបជូនសមាជិក កបឃ.ស នៅក្នុងមុខតំណែងដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតអំពីខ្លឹមសារ និងព័ត៌មានទាំងឡាយ ដូចមានចែងក្រោមចំណុច ២.៥៩.២ ខាងលើ ។

២.៥៩.៤ នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត ឬនៅពេលបានចុះឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងរួចរាល់ហើយ ត្រូវថតចម្លងបញ្ជីឈ្មោះសមាជិក កបឃ.ស ក្នុងមុខតំណែងបង្គ្រប់ចំនួន ៥ (ប្រាំ) ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រារដ្ឋបាលឃុំ សង្កាត់។ បន្ទាប់មកត្រូវចាត់ចែងបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងជូន គ.ជ.ប ដោយដាក់ស្នើសុំការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រមពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលក្នុងនោះត្រូវ ៖

២.៥៩.៤.១ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ នៅសាលាឃុំ សង្កាត់ ។

២.៥៩.៤.២ ផ្ញើ ៤ (បួន) ច្បាប់ ដើម្បីស្នើសុំការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រមពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

២.៥៩.៥ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោត តាមគំរូទម្រង់ដែល គ.ជ.ប ផ្តល់ជូនចំនួន ៣ (បី) ច្បាប់ រួចចុះហត្ថលេខាកាលបរិច្ឆេទ និងបោះត្រារដ្ឋបាលឃុំ សង្កាត់ ហើយចាត់ចែងប្រើប្រាស់ដូចខាងក្រោម ៖

២.៥៩.៥.១ រក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ ។

២.៥៩.៥.២ ផ្ញើ ១ (មួយ) ច្បាប់ជូន លធ.ខប និង ១ (មួយ) ច្បាប់ជូន គ.ជ.ប តាមរយៈអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

២.៥៩.៦ បញ្ជូនបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.៥៩.៤.២ និងចំណុច ២.៥៩.៥.២ ខាងលើជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាព ។

២.៥៩.៧ ក្នុងដំណាក់កាលរៀបចំបញ្ជីបោះឆ្នោតដំបូង ករណីមានអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ ដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលជាសមាជិក កបឃ.ស នៅក្នុងមុខតំណែងរួចហើយ ប៉ុន្តែបែរជាលែងស្ថិតក្នុងមុខតំណែងជាសមាជិក កបឃ.ស តទៅទៀត និងដែលមានសមាជិក កបឃ.ស នៅក្នុងមុខតំណែងថ្មី ចូលជំនួសជាផ្លូវការ កបឃ.ស ត្រូវលើកសំណើដោយមានការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រមមក គ.ជ.ប ដើម្បីសុំកែតម្រូវបញ្ជីបោះឆ្នោត ។

២.៥៩.៧.១ សំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ត្រូវតែបានបញ្ជូនមកដល់ គ.ជ.ប យ៉ាងយូរបំផុត មុនថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

២.៥៩.៧.២ គ.ជ.ប ត្រូវពិនិត្យ សម្រេចជាបន្ទាន់លើសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត និងត្រូវចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតកែតម្រូវបញ្ជីបោះឆ្នោតជាបន្ទាន់ តាមការសម្រេចរបស់ គ.ជ.ប ។

**ប្រការ ២.៦០.-**

បន្ទាប់ពីទទួលបានបញ្ជីឈ្មោះសមាជិក គបឃ.ស ក្នុងមុខតំណែង អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវផ្តល់កិច្ចសហការជួយពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តរបស់ខ្លួន ។

គធ.ខប ត្រូវសម្របសម្រួល និងសហការឱ្យបានជិតស្និទ្ធជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការចុះទៅទទួលយកដោយផ្ទាល់នៅសាលាក្រុង ស្រុក ខណ្ឌ ឬក្នុងការចាត់ចែងបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងរាជធានី ខេត្ត ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងរាជធានី ខេត្តពាក់ព័ន្ធសម្រាប់បញ្ជូនទៅ គ.ជ.ប ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។

២.៦០.១ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានា ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ និងត្រូវចាត់ចែងជាបន្ទាន់ ៖

២.៦០.១.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ ។

២.៦០.១.២ សុំឱ្យប្រធាន គបឃ.ស បកស្រាយបំភ្លឺ ឬ/និងកែតម្រូវ ក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នោះ ។

២.៦០.១.៣ រៀបចំបញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួន ៣ (បី) ច្បាប់ និងរបាយការណ៍ទាំង ២ (ពីរ) ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ដើម្បីបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្ត និងត្រូវធ្វើដីកាអមបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្តផង ។

២.៦០.១.៤ រក្សាទុកបញ្ជីឈ្មោះសមាជិក គបឃ.ស នៅក្នុងមុខតំណែង ដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួន ១ (មួយ) ច្បាប់ ជាឯកសារនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

២.៦០.២ គជ.ខប ត្រូវទាក់ទងព័ត៌មានជាប្រចាំជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យដឹងប្រាកដថា អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌបានត្រៀមរៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ សម្រាប់ការបញ្ជូនទៅរដ្ឋបាលរាជធានី ខេត្តរួចរាល់ហើយឬនៅ ។ គជ.ខប ត្រូវចាត់ចែងមន្ត្រីឱ្យចុះទៅទទួលយកបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធដោយផ្ទាល់ ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬស្នើសុំឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍ទាំងនោះមករដ្ឋបាលរាជធានី ខេត្ត ប្រសិនបើរដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចត្រូវឡើងមកទាក់ទងការងារ ស្របពេលគ្នានៅសាលារាជធានី ខេត្ត ។

២.៦០.៣ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានាដែលស្ថិតក្នុងរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ ដែលអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌបានបញ្ជាក់ឯកភាពរួចហើយ និងត្រូវចាត់ចែងជាបន្ទាន់ ៖

២.៦០.៣.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិតប្រាកដ។

២.៦០.៣.២ សុំឱ្យប្រធាន កបឃ.ស និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌបកស្រាយបំភ្លឺ ឬ/និងកែតម្រូវ ក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នោះ ។

២.៦០.៣.៣ រៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួន ២ (ពីរ) ច្បាប់ និងរបាយការណ៍ទាំង ២ (ពីរ) ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ដើម្បីបញ្ជូនទៅ គ.ជ.ប តាមរយៈ គជ.ខប ។

២.៦០.៣.៤ រក្សាទុកបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួន ១ (មួយ) ច្បាប់ ជាឯកសារនៅរដ្ឋបាលរាជធានី ខេត្ត ។

២.៦០.៤ ប្រធាន គធ.ខប ត្រូវទាក់ទងព័ត៌មានជាប្រចាំជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីទៅទទួលយកបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែង ដែលមានការបញ្ជាក់ឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់នានាដែលស្ថិតក្នុងរាជធានី ខេត្ត ។ ប្រធាន គធ.ខប ត្រូវត្រៀមបែងចែក វេចខ្ចប់ និងប្រើប្រាស់បញ្ជីឈ្មោះ និងរបាយការណ៍ទាំងនេះ ដូចខាងក្រោម ៖

២.៦០.៤.១ បញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ ១ (មួយ) ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ១ (មួយ) ច្បាប់ ជូន គ.ជ.ប ។

២.៦០.៤.២ រក្សាទុកបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ ១ (មួយ) ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ចំនួន ១ (មួយ) ច្បាប់ ជាឯកសារនៅ គធ.ខប ។

២.៦០.៥ ប្រធាន គធ.ខប ត្រូវធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទូទាំងរាជធានី ខេត្តចំនួន ២ (ពីរ) ច្បាប់ ដែលក្នុងនោះត្រូវរក្សាទុក ១ (មួយ) ច្បាប់ជាឯកសារ និងបញ្ជូន ១ (មួយ) ច្បាប់ជូន គ.ជ.ប ។

២.៦០.៦ ប្រធាន គធ.ខប ត្រូវបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៃឃុំ សង្កាត់នីមួយៗ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទូទាំងរាជធានី ខេត្ត ១ (មួយ) ច្បាប់ ជូន គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត) ឱ្យបានតាមការកំណត់ ដូចមានចែងក្រោមចំណុច ២.៥៥.១ ខាងលើ ឬឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ។

២.៦០.៧ ប្រធាន គធ.ខប ត្រូវត្រៀមជាស្រេចនូវលិខិតបញ្ជាក់ការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការប្រគល់ ទទួលបញ្ជីឈ្មោះ និងរបាយការណ៍ ដូចមានចែងក្នុងចំណុច ២.៦០.៦ ខាងលើ ដើម្បីបញ្ជាក់ថា គ.ជ.ប បានទទួលរួចហើយ ។

## ការប្រគល់ និងការទទួលបញ្ជីឈ្មោះ និងការរៀបចំបញ្ជីបោះឆ្នោតដំបូងដោយប្រព័ន្ធកុំព្យូទ័រ នៅ គ.ជ.ប

### ប្រការ ២.៦១.-

នៅពេលទទួលបញ្ជីឈ្មោះពី លធ.ខប ដូចមានចែងក្នុងចំណុច ២.៦០.៦ ខាងលើ មន្ត្រីទទួលឯកសារនៃនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវចាត់ចែងពិនិត្យសំណុំឯកសារដែលបានប្រគល់ រួចចុះហត្ថលេខាបញ្ជាក់ការទទួល ប្រសិនបើពិនិត្យឃើញថា គ្រប់គ្រាន់ហើយ ។ ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវចាត់ចែងមន្ត្រីឱ្យផ្ទៀងផ្ទាត់របាយការណ៍បូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ចំណុះក្រុង ឬស្រុក ឬខណ្ឌនីមួយៗ ក្នុងក្របខណ្ឌរាជធានី ឬខេត្ត ជាមួយនឹងបញ្ជីឈ្មោះសមាជិក កបឃ.ស នៅក្នុងមុខតំណែងពាក់ព័ន្ធ ។ ក្នុងករណីត្រឹមត្រូវហើយត្រូវចាត់ចែងឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីរៀបចំជាបញ្ជីបោះឆ្នោតដំបូង ។ ក្នុងដំណើរការនៃការរៀបចំបញ្ជីបោះឆ្នោតដំបូង ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវ ៖

២.៦១.១ ធានាថា នៅរាល់ពេលប្រគល់ ទទួលបញ្ជីឈ្មោះ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត មន្ត្រីទទួលឯកសារបានចុះហត្ថលេខាលើដីកាអម ឬលិខិតប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ឱ្យមន្ត្រី លធ.ខប ដែលទទួលបន្ទុកបញ្ជូនសំណុំឯកសារវិញ ១ (មួយ) ច្បាប់ ដើម្បីបញ្ជាក់ថាបានទទួលគ្រប់ចំនួនមែន និងត្រូវរក្សាទុក ១ (មួយ) ច្បាប់ ជាឯកសារ ។ ក្នុងករណីសំណុំឯកសារដែលបានប្រគល់មានលក្ខណៈមិនទាន់គ្រប់គ្រាន់ មន្ត្រីទទួលឯកសារអាចស្នើសុំឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូនយកមកបន្ថែមនូវឯកសារដែលខ្វះ ។

២.៦១.២ ធានាថា សំណុំឯកសារនៃការចុះឈ្មោះបោះឆ្នោតដែលបានទទួល ត្រូវបានបំបែករួចផ្តុំបញ្ចូលគ្នាទៅតាមក្រុង ស្រុក ខណ្ឌដោយឡែកពីគ្នា និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ។

២.៦១.៣ ធានាថា តួលេខ និងទិន្នន័យនៃបញ្ជីឈ្មោះនីមួយៗ ត្រូវបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមឱ្យបានហ្មត់ចត់ និងត្រឹមត្រូវ ដើម្បីត្រៀមសម្រាប់ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ ។ ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមនេះ ត្រូវផ្អែកជាមូលដ្ឋានលើបញ្ជីបេក្ខជនសមាជិក កបឃ.ស ផ្លូវការដែលមានរក្សាទុកជាឯកសារនៅ គ.ជ.ប ។ ក្នុងករណីមានភាពមិនប្រក្រតី ឬភាពមិនត្រឹមត្រូវពាក់ព័ន្ធនឹងចំនួន និងទិន្នន័យក្នុងបញ្ជីឈ្មោះ ត្រូវរាយការណ៍ជាបន្ទាន់តាមឋានានុក្រមទៅ គ.ជ.ប ដើម្បីសុំយោបល់ណែនាំ ។

២.៦១.៤ ចាត់ចែងមន្ត្រីឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយផ្អែកតាមបញ្ជីឈ្មោះ និងរបាយការណ៍ដែលបានពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវរួច ក្នុងនោះត្រូវធានាថា ៖

២.៦១.៤.១ មន្ត្រីបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ មានការទទួលខុសត្រូវខ្ពស់ក្នុងការវាយបញ្ចូលឈ្មោះអ្នកបោះឆ្នោត និងទិន្នន័យពាក់ព័ន្ធបានយ៉ាងត្រឹមត្រូវ និងឆាប់រហ័ស ។

២.៦១.៤.២ ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗក្នុងប្រព័ន្ធកុំព្យូទ័រត្រូវតែស្មើគ្នានឹងចំនួនដែលមានក្នុងបញ្ជីឈ្មោះដែលបានកំណត់សម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.៦១.៤.៣ បញ្ជីបោះឆ្នោតដំបូងតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានទិន្នន័យ ដូចខាងក្រោម ៖

- លេខកូដ និងឈ្មោះរាជធានី ខេត្ត
- លេខកូដ និងឈ្មោះក្រុង ស្រុក ខណ្ឌ
- លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត
- លេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង
- អត្តលេខ (បញ្ជីបោះឆ្នោតសកល)
- រូបថត
- នាមត្រកូល និងនាមខ្លួន ដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ
- លេខ អ.ខ ឬ ឯ.អ (បញ្ជីបោះឆ្នោតសកល)
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- ឋានៈក្នុងមុខតំណែង
- លំនៅឋាន ឬទីសំណាក់នៃអ្នកបោះឆ្នោត ។

២.៦១.៤.៤ នៅគ្រប់ទំព័រនៃបញ្ជីបោះឆ្នោតដំបូង តាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតដំបូងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ហើយនៅទំព័រចុងក្រោយនៃបញ្ជីបោះឆ្នោតដំបូងនេះ ទុកឱ្យមានចន្លោះសម្រាប់ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា គ.ជ.ប ។ នៅគ្រប់ទំព័រផ្សេងទៀតនៃបញ្ជីបោះឆ្នោតដំបូងរបស់ការិយាល័យបោះឆ្នោតនីមួយៗ ក៏ត្រូវមានបោះត្រា គ.ជ.ប ផងដែរ ។

២.៦១.៤.៥ ឈ្មោះអ្នកបោះឆ្នោត និងរាល់ទិន្នន័យពាក់ព័ន្ធនៅលើបញ្ជីបោះឆ្នោតដំបូងត្រូវតែបានត្រួតពិនិត្យ និងកែតម្រូវយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ មុននឹងបោះពុម្ព និងដាក់ជូន គ.ជ.ប ពិនិត្យ សម្រេចជាបញ្ជីបោះឆ្នោតដំបូង ។

## ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង

### ប្រការ ២.៦២.-

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវបោះពុម្ពបញ្ជីបោះឆ្នោតដែលបានរៀបចំរួចស្រេចចំនួន ២ (ពីរ) ច្បាប់ ហើយដាក់ជូន គ.ជ.ប ពិនិត្យ សម្រេចជាបញ្ជីបោះឆ្នោតដំបូង ។ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវធានាថា បញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតនីមួយៗត្រូវបានថតចម្លងបន្ថែមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់វេចខ្ចប់ និងបញ្ជូនទៅ គធ.ខប ប្រើប្រាស់ក្នុងការបិទផ្សាយ ដើម្បីបម្រើគោលដៅនៃការពិនិត្យ កែតម្រូវតាមរយៈការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនោះ ។

២.៦២.១ បញ្ជីបោះឆ្នោតដំបូងនឹងត្រូវបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប (www.voterlist.org.kh)។

២.៦២.២ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវរក្សាទុកច្បាប់ដើមនៃបញ្ជីបោះឆ្នោតដំបូងដែល គ.ជ.ប បានពិនិត្យសម្រេចរួចហើយ ១ (មួយ) ច្បាប់ ជាឯកសារនៅ គ.ជ.ប និងត្រូវវេចខ្ចប់តាមការិយាល័យបោះឆ្នោតនីមួយៗ ដោយឡែកពីគ្នានូវបញ្ជីបោះឆ្នោតដំបូងច្បាប់ដើម ១ (មួយ) ច្បាប់ និងច្បាប់ចម្លង ៤ (បួន) ច្បាប់ រួចបញ្ជូនទៅ គធ.ខប ឱ្យបានទាន់ពេលវេលាមុនការកំណត់ឱ្យបិទផ្សាយ ។

២.៦២.៣ ពេលទទួលបានកញ្ចប់បញ្ជីបោះឆ្នោតដំបូង គធ.ខប ត្រូវដករក្សាទុកច្បាប់ដើម ១ (មួយ) ច្បាប់ជាឯកសារ និងត្រូវចាត់ចែងបិទផ្សាយច្បាប់ចម្លងយ៉ាងតិច ៣៤ (សាមសិបបួន) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដោយត្រូវបិទផ្សាយ ដូចខាងក្រោម ៖

២.៦២.៣.១ នៅ លគធ.ខប ១ (មួយ) ច្បាប់ ។

២.៦២.៣.២ នៅកន្លែង ៣ (បី) ផ្សេងគ្នាក្នុងទីប្រជុំជនរាជធានី ខេត្ត ក្នុងកន្លែងនីមួយៗ ១ (មួយ) ច្បាប់ ។

២.៦២.៤ នៅពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនេះ គធ.ខប ត្រូវធ្វើកំណត់ហេតុស្ដីពីការបិទផ្សាយនេះ ៦ (ប្រាំមួយ) ច្បាប់ ដោយមានបញ្ជាក់អំពីពេលវេលា កាលបរិច្ឆេទ

និងទីកន្លែងនៃការបិទផ្សាយ ហើយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ឃប ផង។ គធ.ឃប ត្រូវបិទផ្សាយកំណត់ហេតុនេះ ១ (មួយ) ច្បាប់ អមជាមួយនឹងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង នៅតាមទីតាំងដូចដែលបានចែងក្រោមចំណុច ២.៦២.៣ ខាងលើ រួចផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៦២.៥ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង គឺដើម្បីបម្រើគោលដៅនៃការពិនិត្យ កែតម្រូវតាមរយៈការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនេះ។ ជនណាក៏ដោយក៏មានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនេះបានដែរ ក្នុងរយៈពេល ៥ (ប្រាំថ្ងៃ) យ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយ ។ ការដាក់ពាក្យបណ្តឹងត្រូវធ្វើនៅ គធ.ឃប ។

២.៦២.៦ គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោត មានសិទ្ធិសុំបញ្ជីបោះឆ្នោតដំបូងច្បាប់ថតចម្លងបានដោយបង់ថ្លៃ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។ ម៉្យាងទៀតក៏អាចទទួលបាននូវទិន្នន័យបញ្ជីបោះឆ្នោតតាមទម្រង់ PDF ដែលមានបង្ហោះតាមគេហទំព័រ គ.ជ.ប www.voterlist.org.kh ផងដែរ ។

២.៦២.៧ គធ.ឃប អាចទទួលថតចម្លងបញ្ជីបោះឆ្នោតដំបូងដោយផ្ទាល់ តាមលទ្ធភាពជាក់ស្តែងរបស់ខ្លួន ដើម្បីផ្គត់ផ្គង់តាមសំណើសុំ ដូចមានចែងក្នុងចំណុច ២.៦២.៦ ខាងលើ (ប្រសិនបើមាន) ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

### គោលការណ៍ទូទៅ

**ប្រការ ២.៦៣.-**

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងទៅ គធ.ឃប និងប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គធ.ឃប ទៅ គ.ជ.ប ។

២.៦៣.១ ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់) ។ ទម្រង់ពាក្យបណ្តឹង (ទ.១២០២) នេះ ត្រូវបានប្រគល់ជូនអ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ ។

២.៦៣.២ អ្នកប្ដឹងអាចថតចម្លងពាក្យបណ្ដឹង (ទ.១២០២) ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជូនខ្លួនបាន ។

២.៦៣.៣ ពាក្យបណ្ដឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួន ដូចខាងក្រោម ៖

២.៦៣.៣.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង ។

២.៦៣.៣.២ កម្មវត្ថុនៃពាក្យបណ្ដឹង ។

២.៦៣.៣.៣ មូលហេតុនៃពាក្យបណ្ដឹង ។

២.៦៣.៣.៤ ពេលវេលា និងទីកន្លែងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

២.៦៣.៣.៥ បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលពាក់ព័ន្ធ ។

២.៦៣.៣.៦ អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់។

២.៦៣.៣.៧ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន) ។

២.៦៣.៣.៨ ភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន) ។

២.៦៣.៤ ពាក្យបណ្ដឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា ។

២.៦៣.៥ ក្នុងដំណើរការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ថ្ងៃធ្វើការត្រូវបានកំណត់គិតទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ប៉ុន្តែការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការទេ ។

២.៦៣.៦ គ្រប់ពាក្យបណ្ដឹង (ទ.១២០២) សម្រង់សេចក្ដីសម្រេច (ទ.១២០៣) និងសេចក្ដីសម្រេចទាំងមូលពាក់ព័ន្ធនឹងពាក្យបណ្ដឹង ត្រូវបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប (www.necelect.org.kh) ។

## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

### ការដាក់ ការទទួលពាក្យបណ្ដឹងនៅ គធ.ខប

២.៦៣.៧ ជនណាក៏ដោយមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្ដឹង (ទ.១២០២) ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងទៅ គធ.ខប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

២.៦៣.៨ ពាក្យបណ្ដឹងតវ៉ាអាចធ្វើឡើងអំពីការបាត់ឈ្មោះ ឬសុំប្ដូរឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ទៅតាមករណីដូចខាងក្រោម ៖

២.៦៣.៨.១ សាមីអ្នកប្ដឹងតវ៉ាជាសមាជិក កបយ.ស នៅក្នុងមុខតំណែង ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់ នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតណាមួយនៅក្រុង ស្រុក ខណ្ឌ ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៅក្រុង ស្រុក ខណ្ឌផ្សេង ។

២.៦៣.៨.២ សាមីអ្នកប្ដឹងតវ៉ាជាសមាជិក កបយ.ស នៅក្នុងមុខតំណែងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធដែលគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូងមានភាពមិនច្បាស់លាស់ ឬមិនដូចគ្នានឹងទិន្នន័យក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបយ.ស នៅក្នុងមុខតំណែង ឬ ឯ.អ របស់គាត់ ។

២.៦៣.៨.៣ សាមីគណបក្សនយោបាយ បានស្នើសុំប្ដូរឈ្មោះអ្នកបោះឆ្នោត ដោយសារអ្នកបោះឆ្នោតនោះ បាត់បង់មុខតំណែងជាសមាជិក កបយ.ស នៅក្នុងក្របខ័ណ្ឌក្រុង ស្រុក ខណ្ឌ ។

២.៦៣.៩ ពាក្យបណ្ដឹងជំទាស់ អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ៖

២.៦៣.៩.១ ក្នុងករណីដែលជននោះគ្មានសិទ្ធិបោះឆ្នោត ដោយសារមិនមែនជាសមាជិក កបយ.ស នៅក្នុងមុខតំណែងនៅក្នុងក្របខ័ណ្ឌនៃក្រុង ស្រុក ខណ្ឌនីមួយៗ ។

២.៦៣.៩.២ ក្នុងករណីដែលជននោះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង ។

២.៦៣.១០ អ្នកប្ដឹងត្រូវបំពេញពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្ដឹងតវ៉ា) ឬ ៤ (បួន) ច្បាប់ (ករណីប្ដឹងជំទាស់)។ អ្នកប្ដឹងដំបូងអាចថតចម្លងទម្រង់បែបបទដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ដិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹង ឬតវ៉ាជួសខ្លួនបាន ។

២.៦៣.១១ នៅពេលបានទទួលពាក្យបណ្ដឹង សមាជិក គធ.ឧប ដែលបានទទួលសិទ្ធិត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង ទី២ កម្មវត្ថុនៃបណ្ដឹង និងការគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

២.៦៣.១២ បន្ទាប់មកសមាជិក គធ.ឧប ដែលបានទទួលសិទ្ធិត្រូវធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ សមាជិក គធ.ឧប ដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ ។

២.៦៣.១៣ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុ ហើយឃើញថា ៖

២.៦៣.១៣.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ នៃការដាក់ពាក្យបណ្ដឹង ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ប្រធាន គធ.ឧប ឬសមាជិក គធ.ឧប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ.ឧប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៦៣.១៣.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ដូចមានចែងក្នុងចំណុច ២.៦៣.៣ ខាងលើ សមាជិក គធ.ឧប ដែលបានទទួលសិទ្ធិត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ឧប ឬសមាជិក គធ.ឧប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ.ឧប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៦៣.១៣.៣ ពាក្យបណ្តឹងគោរពពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងមានព័ត៌មានចាំបាច់ សមាជិក គធ.ខប ដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) រក្សាទុកក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

**ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប**

២.៦៣.១៤ គធ.ខប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

២.៦៣.១៥ ក្នុងករណីដែល គធ.ខប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្តឹង គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបានទៅដើមបណ្តឹង ហើយផ្ញើជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៦៣.១៦ ក្នុងករណីដែល គធ.ខប បើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង គធ.ខប ត្រូវចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៤ (បួន)ច្បាប់ (ករណីប្តឹងជំទាស់)។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ សរសេរឈ្មោះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចត្រូវជូន ឬផ្ញើជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៦៣.១៧ បន្ទាប់ពី គធ.ខប បើកសវនាការលើពាក្យបណ្តឹងតវ៉ា ក្នុងករណីដែល ៖

២.៦៣.១៧.១ **បដិសេធលើពាក្យបណ្តឹងតវ៉ា៖** គធ.ខប ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ។

២.៦៣.១៧.២ **យល់ព្រមលើពាក្យបណ្តឹងតវ៉ា ៖** គធ.ខប ធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដើម្បីសុំបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.៦៣.១៨ បន្ទាប់ពី គធ.ខប បើកសវនាការលើពាក្យបណ្តឹងជំទាស់ ក្នុងករណីដែល ៖

២.៦៣.១៨.១ **បដិសេធលើពាក្យបណ្តឹងជំទាស់ ៖** គធ.ខប ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ។

២.៦៣.១៨.២ **យល់ព្រមលើពាក្យបណ្តឹងជំទាស់ ៖** គធ.ខប ជូនដំណឹងទៅអ្នកដែលត្រូវគេប្តឹងជំទាស់ថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ព្រមទាំងធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយសម្រង់សេចក្តីសម្រេច (ទ.១២០៣) ។

២.៦៣.១៩ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវបានកំណត់ដូចក្នុងផ្នែកទី ១១ នៃ ប.ន.ក នេះ ។

## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

២.៦៣.២០ អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ ឬអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គធ.ខប មានសិទ្ធិប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ។

២.៦៣.២១ អ្នកប្តឹង ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់) ។

២.៦៣.២២ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង ទី២ កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ។

២.៦៣.២៣ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុសាកសួរនោះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ ។

២.៦៣.២៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុ ហើយឃើញថា ៖

- ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។
- ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ២.៦៣.៣ ខាងលើ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។
- ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប និងមានព័ត៌មានចាំបាច់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម

ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១(មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១(មួយ) ច្បាប់ និង ទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

**ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប**

២.៦៣.២៥ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

២.៦៣.២៦ ក្នុងករណីដែល គ.ជ.ប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្តឹង គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបានទៅដើមបណ្តឹង ហើយប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៦៣.២៧ ក្នុងករណីដែល គ.ជ.ប បើកសវនាការសង្ខេប ឬជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង គ.ជ.ប ត្រូវចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់) ។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវចុះហត្ថលេខាដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ សរសេរឈ្មោះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.៦៣.២៨ បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្តឹងតវ៉ា ក្នុងករណីដែល ៖

២.៦៣.២៨.១ **បដិសេធលើពាក្យបណ្តឹងតវ៉ា** ៖ គ.ជ.ប ជម្រាបអ្នកប្តឹងថា សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

២.៦៣.២៨.២ **យល់ព្រមលើពាក្យបណ្តឹងតវ៉ា** ៖ គ.ជ.ប ចាត់ចែងអនុវត្តការចុះឈ្មោះបោះឆ្នោត ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.៦៤.២.១ ខាងក្រោម ។

២.៦៣.២៩ បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្តឹងជំទាស់ ក្នុងករណីដែល ៖

២.៦៣.២៩.១ **បដិសេធលើពាក្យបណ្ដឹងជំទាស់** ៖ គ.ជ.ប ជម្រាបអ្នកប្ដឹងថា សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

២.៦៣.២៩.២ **យល់ព្រមលើពាក្យបណ្ដឹងជំទាស់** ៖ គ.ជ.ប ជម្រាបអ្នកត្រូវគេប្ដឹងជំទាស់ថា សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

២.៦៣.៣០ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវបានកំណត់ដូចក្នុងផ្នែកទី ១១ នៃ ប.ន.ក នេះ ។

២.៦៣.៣១ សេចក្ដីសម្រេចរបស់ គ.ជ.ប ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

## ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ឬសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប

**ប្រការ ២.៦៤.-**

សេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ឬ គ.ជ.ប ត្រូវអនុវត្តដូចខាងក្រោម ៖

### ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប

២.៦៤.១ បន្ទាប់ពីបានទទួលរបាយការណ៍ដែលមានភ្ជាប់មកជាមួយនូវសេចក្ដីសម្រេច (ទ.១២០៣) ដូចមានចែងក្នុងចំណុច ២.៦៣.១៧.២ និងចំណុច ២.៦៣.១៨.២ ខាងលើ ដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែល ៖

២.៦៤.១.១ **យល់ព្រមលើពាក្យបណ្ដឹងតវ៉ា** ៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់ ។

២.៦៤.១.២ **យល់ព្រមលើពាក្យបណ្ដឹងជំទាស់** ៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត លុបឈ្មោះអ្នកដែលត្រូវគេប្ដឹងជំទាស់ ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់ ។

### ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប

២.៦៤.២ បន្ទាប់ពីសេចក្ដីសម្រេច (ទ.១២០៣) របស់ គ.ជ.ប បានចូលជាស្ថាពរហើយ ក្នុងករណីដែល ៖

២.៦៤.២.១ **យល់ព្រមលើពាក្យបណ្តឹងតវ៉ា** ៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់ ។

២.៦៤.២.២ **យល់ព្រមលើពាក្យបណ្តឹងជំទាស់** ៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតលុបឈ្មោះអ្នកដែលត្រូវគេប្តឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់ ។

## ប្រការ ២.៦៥.–

គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ជាផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរយៈពេលយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

## ប្រការ ២.៦៦.–

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវធានាថា សេចក្តីព្រាងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងទម្រង់ឯកភាពតែមួយ ដែលបានពិនិត្យកែតម្រូវរួចក្នុងប្រព័ន្ធកុំព្យូទ័រ ត្រូវតែបានបោះពុម្ពដោយឡែកពីគ្នាតាមការិយាល័យបោះឆ្នោតនីមួយៗ និងដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

២.៦៦.១ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវសេចក្តីព្រាងបញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ដែលមានទិន្នន័យដូចខាងក្រោម៖

- លេខកូដ និងឈ្មោះរាជធានី ខេត្ត
- លេខកូដ និងឈ្មោះក្រុង ស្រុក ខណ្ឌ
- លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត
- ប្រអប់តូចសម្រាប់គូសសម្គាល់ពេលមកបោះឆ្នោត
- លេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត
- អត្តលេខ (បញ្ជីបោះឆ្នោតសកល)
- រូបថត
- នាមត្រកូល និងនាមខ្លួន ដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ
- លេខ អ.ខ ឬ ឯ.អ (បញ្ជីបោះឆ្នោតសកល)

- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- ឋានៈក្នុងមុខតំណែង
- លំនៅឋាន ឬទីសំណាក់នៃអ្នកបោះឆ្នោត
- ការបញ្ជាក់ចំនួនអ្នកបោះឆ្នោតសរុបក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗ
- ការបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅគ្រប់ទំព័រ
- ចន្លោះបម្រុងទុកសម្រាប់ការចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប នៅលើទំព័រចុងក្រោយ។

២.៦៦.២ សេចក្តីព្រាងបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដូចមានចែងក្នុងចំណុច ២.៦៦.១ ខាងលើ ត្រូវដាក់ជូន គ.ជ.ប ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការនៅលើទំព័រចុងក្រោយ។ នៅគ្រប់ទំព័រផ្សេងទៀតនៃបញ្ជីបោះឆ្នោតផ្លូវការនេះ ក្រៅពីទំព័រចុងក្រោយក៏ត្រូវមានបោះត្រារបស់ គ.ជ.ប ផងដែរ ។

២.៦៦.៣ ច្បាប់ដើមនៃបញ្ជីបោះឆ្នោតផ្លូវការតាមការិយាល័យបោះឆ្នោតនីមួយៗ ១ (មួយ) ច្បាប់ ត្រូវរក្សាទុកជាឯកសារនៅ គ.ជ.ប ។

២.៦៦.៤ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗ ដូចមានចែងក្នុងចំណុច ២.៦៦.១ ខាងលើ ត្រូវបានថតចម្លងបន្ថែមចំនួន ៥ (ប្រាំ) ច្បាប់ទៀត ដែលត្រូវរៀបចំតាមលំដាប់លេខកូដនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ និងវេចខ្ចប់ដោយឡែកពីគ្នាតាមរាជធានី ខេត្តនីមួយៗ។ ក្នុងការវេចខ្ចប់បញ្ជីបោះឆ្នោតផ្លូវការនេះ ត្រូវតែត្រៀមលក្ខណៈសម្រាប់បែងចែកជាស្រេចឱ្យដល់ គធ.ខប ចំនួន ៣ (បី) ច្បាប់ និង គ.ក.ប នីមួយៗ ចំនួន ២ (ពីរ) ច្បាប់ ។

២.៦៦.៥ រាល់កញ្ចប់បញ្ជីបោះឆ្នោតផ្លូវការដែលវេចខ្ចប់ និងបញ្ជូនខាងលើនេះ ត្រូវតែមានសម្គាល់ លេខកូដមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឈ្មោះរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ក្រុង ស្រុក ខណ្ឌទាំងអស់ក្នុងរាជធានី ខេត្ត ព្រមទាំងគោលដៅដែលត្រូវទទួល និងប្រើប្រាស់បញ្ជីបោះឆ្នោតនោះ ។

២.៦៦.៦ បញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដែលត្រូវបាន គ.ជ.ប ផ្ដល់សុពលភាពរួចហើយ មិនអាចកែប្រែបានទេ លើកលែងមានអ្នកបោះឆ្នោតណាម្នាក់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

២.៦៦.៧ ក្នុងករណីមានសមាជិក កបឃ.ស ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទផ្លាស់ប្ដូរសមាជិក កបឃ.ស នោះ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យ គ.ជ.ប ដាក់ជំនួសក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

២.៦៦.៨ គ.ជ.ប ត្រូវធានាថា នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបានចាត់វិធានការហ្មត់ចត់ ក្នុងការថែរក្សាសុវត្ថិភាពបញ្ជីបោះឆ្នោតផ្លូវការ ដូចមានចែងក្នុងចំណុច ២.៦៦.១ ជាឯកសាររបស់ គ.ជ.ប និងរក្សាសុវត្ថិភាពទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការនេះ ក្នុងប្រព័ន្ធកុំព្យូទ័របានល្អប្រសើរ ។

២.៦៦.៩ គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ និងអង្គការសង្កេតការណ៍បោះឆ្នោត មានសិទ្ធិស្នើសុំបញ្ជីបោះឆ្នោតផ្លូវការច្បាប់ថតចម្លងបានដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។ ម្យ៉ាងទៀតក៏អាចទទួលបាននូវព័ត៌មានអេឡិចត្រូនិចតាមទម្រង់ PDF ដែលបង្ហាញទិន្នន័យអំពីលេខកូដ និងឈ្មោះរាជធានី ខេត្ត លេខកូដ និងឈ្មោះក្រុង ស្រុក ខណ្ឌ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត នាមត្រកូល និងនាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើត តាមតម្លៃផលិត។

២.៦៦.១០ គ.ជ.ប ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ក្នុងរយៈពេលយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃមុនថ្ងៃបោះឆ្នោត និងបង្ហោះបញ្ជីបោះឆ្នោតផ្លូវការនៅលើគេហទំព័ររបស់ខ្លួន (www.voterlist.org.kh) ។ ទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការ ត្រូវបានរក្សាទុកដោយសុវត្ថិភាព (Backup Database) និងអាចត្រួតពិនិត្យបាន ។

## លក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

### ប្រការ ២.៦៧.-

អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺសមាជិក កបឃ.ស នៅក្នុងមុខតំណែងនៅក្នុងក្របខ័ណ្ឌក្រុង ស្រុក ខណ្ឌនីមួយៗ ។ គ.ជ.ប ត្រូវណែនាំដល់អ្នកបោះឆ្នោត អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធអំពីសិទ្ធិបោះឆ្នោត និងលក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៦៧.១ ដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបាន សមាជិក កបឃ.ស នៅក្នុងមុខតំណែង ត្រូវមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងមាន អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ឬ ឯ.អ ។

២.៦៧.២ នៅថ្ងៃបោះឆ្នោត សមាជិក កបឃ.ស នៅក្នុងមុខតំណែងណាដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ទោះបីមាន អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ឬ ឯ.អ ក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ ។

២.៦៧.៣ ឈ្មោះ ឬ/និងទិន្នន័យអ្នកបោះឆ្នោតនៅលើ អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស នៅក្នុងមុខតំណែង ឬ ឯ.អ ត្រូវតែដូចគ្នានឹងឈ្មោះ ឬ/និងទិន្នន័យអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតផ្លូវការ ។

# ផ្នែកទី ៥
# ការិយាល័យបោះឆ្នោត

## ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

**ប្រការ ២.៦៨.-**

គ.ជ.ប ត្រូវកំណត់ក្នុងជំហានដំបូងនូវការិយាល័យបោះឆ្នោតចំនួន ១ (មួយ) ឬច្រើនសម្រាប់ក្រុង ស្រុក ខណ្ឌនីមួយៗ នៅក្នុងរយៈពេលយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមចុះឈ្មោះបោះឆ្នោត។ ចំនួន និងទីតាំងការិយាល័យបោះឆ្នោតអាចនឹងកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប បន្ទាប់ពីការចុះឈ្មោះបោះឆ្នោតបានបញ្ចប់ និងត្រូវធ្វើឱ្យហើយរួចរាល់នៅក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ ការិយាល័យបោះឆ្នោតទាំងអស់នឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត ។

២.៦៨.១ ក្រុង ស្រុក ខណ្ឌ គឺជាការិយាល័យបោះឆ្នោត ។

២.៦៨.២ ការកែសម្រួលទីតាំងការិយាល័យបោះឆ្នោត ឬ/និងការបង្កើតការិយាល័យបោះឆ្នោតថ្មី ត្រូវគោរពតាមលក្ខខណ្ឌជាក់ស្តែង និងសុវត្ថិភាពនៃកិច្ចប្រតិបត្តិការបោះឆ្នោត ។

២.៦៨.៣ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបម្រើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់។ ការិយាល័យបោះឆ្នោត និងតំបន់បោះឆ្នោតស្ថិតក្នុងដែនសមត្ថកិច្ចដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែរួមបញ្ចូលនូវឃុំ សង្កាត់ទាំងអស់ ដែលស្ថិតក្នុងព្រំប្រទល់រដ្ឋបាលក្រុង ឬស្រុក ឬខណ្ឌពាក់ព័ន្ធ ។

២.៦៨.៤ គ.ជ.ប ត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីបង្កើតការិយាល័យបោះឆ្នោត ១ (មួយ) ឬច្រើនសម្រាប់ក្រុង ស្រុក ខណ្ឌនីមួយៗ ដើម្បីឱ្យសមាជិក កបយ.ស នៅក្នុងមុខតំណែងចំណុះក្រុង ស្រុក ខណ្ឌនោះបានចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតទាំងអស់គ្នា ។

២.៦៨.៥ ការិយាល័យបោះឆ្នោតមួយ ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹមចំនួន ៧៥០ (ប្រាំពីររយហាសិប) នាក់ ។

២.៦៨.៦ ការិយាល័យបោះឆ្នោត ដែលបញ្ជីបោះឆ្នោតនៃការិយាល័យត្រូវបានផ្តល់សុពលភាពជាផ្លូវការដោយ គ.ជ.ប និងត្រូវប្រើជាការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.៦៨.៧ ការិយាល័យបោះឆ្នោត គឺជាការិយាល័យនៅមួយកន្លែងដែល គ.ជ.ប បង្កើតឡើងនៅទីតាំងជាក់លាក់មួយសម្រាប់តំបន់បោះឆ្នោតមួយជាកំណត់ ហើយដែលត្រូវបើកទទួលអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ មកបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

២.៦៨.៨ ក្នុងការកំណត់ទីតាំងការិយាល័យបោះឆ្នោត ត្រូវយកចិត្តទុកដាក់ចំពោះទីតាំងសាលារៀន ទីវត្តអារាម និងទីសាធារណៈ ។

២.៦៨.៩ ការិយាល័យបោះឆ្នោតមិនត្រូវបានបង្កើតនៅក្នុងបរិវេណទីធ្លា និងអគាររបស់រដ្ឋដូចជា សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់ជាដើម ឬនៅបន្ទាយ ឬអគារនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ឬ/និងអគាររបស់គណបក្សនយោបាយនៅគ្រប់លំដាប់ថ្នាក់ ។

## ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

**ប្រការ ២.៦៩.-**

គ.ជ.ប ត្រូវផ្សព្វផ្សាយ និងត្រូវបោះពុម្ពផ្សាយនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅតាមដំណាក់កាលនីមួយៗទៅ គធ.ខប និង កបឃ.ស ដើម្បីចាត់ចែងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យទាំងនោះនៅតាមទីកន្លែង និងតាមកាលបរិច្ឆេទដែល គ.ជ.ប បានកំណត់ ។

២.៦៩.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគេហទំព័រ គ.ជ.ប (www.voterlist.org.kh) និង (www.necelect.org.kh)។

២.៦៩.២ គ.ជ.ប ត្រូវណែនាំ គធ.ខប និង កបឃ.ស ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនៅ គធ.ខប និងសាលាឃុំ សង្កាត់ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនពេលចាប់ផ្ដើមការចុះឈ្មោះបោះឆ្នោត ។

២.៦៩.៣ នៅក្រោយបញ្ចប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប នូវចំនួន និងទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត គ.ជ.ប ត្រូវណែនាំ គធ.ខប ឱ្យបិទផ្សាយជាសាធារណៈ

នូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនៅតាមសាលាឃុំ សង្កាត់ និងនៅទីកន្លែងសាធារណៈណាមួយនៅក្នុងមណ្ឌលបោះឆ្នោត យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.៦៩.៤ សមាជិក គបឃ.ស នៅក្នុងមុខតំណែងទាំងអស់ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមមានសិទ្ធិស្នើសុំពី គ.ជ.ប នូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតផ្លូវការ ដោយត្រូវបង់ថ្លៃត្រឹមតម្លៃផលិត ។ ការផ្តត់ផ្គង់ចំពោះការស្នើសុំនេះ ត្រូវផ្អែកតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុនស្មើនឹង ១០០ (មួយរយ) ភាគរយនៃតម្លៃផលិត ។

២.៦៩.៥ គ.ជ.ប ត្រូវផ្ញើច្បាប់ចម្លងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ ១ (មួយ) ច្បាប់ ជូនក្រសួងមហាផ្ទៃ ។

## ទីតាំងរដ្ឋបាល និងសន្តិសុខសម្រាប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

## ប្រការ ២.៧០.-

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ។

២.៧០.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារដែលការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយវណ្ឌមណ្ឌលមួយមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ និងច្រកចូលមួយ។

២.៧០.២ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលខណ្ឌដោយវណ្ឌមណ្ឌល មានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬតូចជាង អាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងនៃសាលារៀន វត្តអារាម សាលមហោស្រព ឬទីសាធារណៈ ជាដើម ។

២.៧០.៣ នៅទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គធ.ខប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ ។

២.៧០.៤ នៅតំបន់ទីប្រជុំជន ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមួយតាំងប្រមាណ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យពាក់ព័ន្ធមួយផ្សេងទៀត មួយផ្នែកនៃផ្លូវនេះ ត្រូវតែបិទចរាចរណ៍ ។

## វិធានការការពារសន្តិសុខ

### ប្រការ ២.៧១.-

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន អុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គធ.ខប និង គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម ៖

២.៧១.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែក្នុងករណីមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលប្រធាន គ.ជ.ប ឬ/និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានភារកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៨៧ នៃ ច.ប.គ.រ ។

២.៧១.១.១ ប្រធាន គ.ជ.ប និងប្រធាន គធ.ខប ត្រូវប្រគល់សិទ្ធិអំណាចពេញលេញឱ្យដល់ប្រធាន គ.ក.ប/គ.ក.រ ក្នុងការស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីដូចបញ្ជាក់ក្នុងចំណុច ២.៧១.១ ខាងលើ ។

២.៧១.១.២ ក្នុងករណីមានសំណូមពរពីប្រធាន គ.ក.ប/គ.ក.រ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យណាមួយនោះ ភ្នាក់ងារសន្តិសុខបោះឆ្នោតមានបំពាក់អាវុធដែលត្រូវបានចាត់តាំងអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ ។

២.៧១.២ ហាមយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិណាម្នាក់ ក្នុងឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធ ចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខ លើកលែងតែក្នុងករណីអ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធាន គ.ក.ប/គ.ក.រ ស្នើសុំឱ្យធ្វើអន្តរាគមន៍ ដូចមានចែងក្នុងចំណុច ២.៧១.១.២ និងលក្ខខណ្ឌទាំងឡាយក្រោមចំណុច ២.៧១.១ ខាងលើ ។

២.៧១.៣ ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយ ដូចខាងក្រោម ៖

២.៧១.៣.១ មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប ។

២.៧១.៣.២ ភ្នាក់ងារគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប ។

២.៧១.៣.៣ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។

២.៧១.៣.៤ អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

២.៧១.៣.៥ ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនដែលមានពិការភាព ។

២.៧១.៣.៦ ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.ប ធ្វើសំណូមពរក្នុងករណីចាំបាច់ ។

២.៧១.៤ ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយ ដូចខាងក្រោម ៖

២.៧១.៤.១ មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប ។

២.៧១.៤.២ ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប ។

២.៧១.៤.៣ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។

២.៧១.៤.៤ ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.រ ធ្វើសំណូមពរ ក្នុងករណីចាំបាច់ ។

២.៧១.៥ សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

២.៧១.៥.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៧១.៥.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោត បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

២.៧១.៥.៣ ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៧១.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

២.៧១.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៧១.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោតរាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងគណបក្សនយោបាយណាមួយ ។

២.៧១.៧ ក្នុងករណីចាំបាច់ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចអនុវត្តលក្ខខណ្ឌ ដូចមានចែងក្រោមចំណុច ២.៧១.៣ និងចំណុច ២.៧១.៤ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

២.៧១.៨ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ក និង ច.ប.គរ ។

**ប្រការ ២.៧២.-**

ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេងដែលមានសុវត្ថិភាព។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្តីសម្រេចនេះ ។

**ប្រការ ២.៧៣.-**

សាលារៀន ទីវត្តអារាម រាល់សំណង់ អគារ សាល ឬទីសាធារណៈត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

# ផ្នែកទី ៦
# ការឃោសនាបោះឆ្នោត

**បញ្ញត្តិទូទៅនៃការឃោសនាបោះឆ្នោត**

**ប្រការ ២.៧៤.-**

អនុលោមតាម ច.ប.ក ការឃោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ មានដូចជា ៖

២.៧៤.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

២.៧៤.២ ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

២.៧៤.៣ ការជួបជុំ ឬការឃោសនាតាមផ្ទះ ។

២.៧៤.៤ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។

២.៧៤.៥ ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ ។

២.៧៤.៦ សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនាផ្សេងៗ ។

២.៧៤.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ។

២.៧៤.៨ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជនជូនអ្នកបោះឆ្នោត ។

២.៧៤.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទក្រដាស ផ្សាយពីកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬបេក្ខជន ។

២.៧៤.១០ ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ។

២.៧៤.១១ ការរៀបចំកម្មវិធីប្រកួតកីឡា ។

**ប្រការ ២.៧៥.-**

ការឃោសនាត្រូវបើក ៩ (ប្រាំបួន) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ការឃោសនាបោះឆ្នោត មានរយៈពេល ៨ (ប្រាំបី) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ចប់ ២៤ (ម្ភៃបួន)ម៉ោង មុនថ្ងៃបោះឆ្នោត ។

២.៧៥.១ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់) យប់ ។

២.៧៥.២ គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយត្រូវឈប់សម្រាក នៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ៦ (ប្រាំមួយ) ព្រឹក ។

២.៧៥.៣ សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវបានកំណត់ ដូចខាងក្រោម៖

- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២ (ពីរ) រសៀល
- ត្រូវហាមឃាត់នៅក្បែរមន្ទីរពេទ្យ
- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា ។

២.៧៥.៤ ការឃោសនាបោះឆ្នោតត្រូវបញ្ឈប់ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។

២.៧៥.៥ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត ត្រូវបញ្ឈប់ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ការស្ទង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត ។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

- ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង

- រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ
- ការគោរពសិទ្ធិ សេរីភាពបុគ្គល
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត
- ការមិនបង្កឱ្យមានអសន្តិសុខ ភាពចលាចល ឬប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬការធ្វើឱ្យរាំងស្ទះដល់ដំណើរការបោះឆ្នោត
- លទ្ធផលដែលបានមកពីការស្ទង់មតិ ត្រូវផ្ដល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព ។

**ប្រការ ២.៧៦.-**

គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រឹមត្រូវ តាម ច.ប.ក អាចលើកស្លាកសញ្ញាគណបក្ស ឬបិទផ្សាយឯកសារឃោសនាបោះឆ្នោតបម្រើឱ្យគោលដៅឃោសនាបោះឆ្នោតនៅទីសាធារណៈ ឬលំនៅឋានឯកជន ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

២.៧៦.១ ស្លាកសញ្ញា និងសម្ភារឃោសនាផ្សេងៗរបស់គណបក្សនយោបាយ អាចលើក ឬបិទនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរ ឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ ។

២.៧៦.២ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយមិនត្រូវអនុញ្ញាតឱ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ ។

២.៧៦.៣ ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិតប័ណ្ណរបស់គណបក្សណាមួយបាន ។

២.៧៦.៤ ស្លាកសញ្ញា ឬសម្ភារឃោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

២.៧៦.៥ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។

**ប្រការ ២.៧៧.-**

ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៧៧.១ ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងហាមការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

២.៧៧.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋត្រូវបានកំណត់ដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬ/និងរដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល ។

២.៧៧.៣ ការដឹកជញ្ជូនមានលក្ខណៈប្រមូលផ្តុំ ឬរៀបចំទុកជាមុនត្រូវហាមឃាត់ លើកលែងតែករណីចាំបាច់មានការសម្រេចផ្សេងពីនេះដោយ គ.ជ.ប។

**ប្រការ ២.៧៨.-**

ការស្លៀកពាក់ (សម្លៀកបំពាក់-មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា សារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

**ប្រការ ២.៧៩.-**

គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងគណបក្សនយោយបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ អាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅមណ្ឌលរាជធានី ខេត្តបានយ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ដូចខាងក្រោម ៖

២.៧៩.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទត្រូវបានអនុញ្ញាតឱ្យធ្វើក្នុងក្របខណ្ឌមណ្ឌលរាជធានី ខេត្ត ។

២.៧៩.២ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឆ្លងរាជធានី ខេត្ត ។

២.៧៩.៣ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទក្នុងក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត ឬការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទពីក្រុង ស្រុក ខណ្ឌមួយទៅក្រុង ស្រុក ខណ្ឌមួយផ្សេងទៀតក្នុងរាជធានី ខេត្តដដែល ត្រូវបានចាត់ទុកថាជាការហែក្បួនក្នុងក្របខណ្ឌមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ។

២.៧៩.៤ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំ ដូចខាងក្រោម ៖

- មានការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង ។
- មានអ្នកចូលរួមចាប់ពី ២០ (ម្ភៃ) នាក់ឡើងទៅ ដោយប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ក្នុងការឃោសនាបោះឆ្នោត មានដូចខាងក្រោម ៖
  - រថយន្តចាប់ពី ២ (ពីរ) គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ១០ (ដប់) គ្រឿងឡើងទៅ ។
  - ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ២០ (ម្ភៃ) គ្រឿង ។
  - ជលយានគ្រប់ប្រភេទចាប់ពី ៥ (ប្រាំ) គ្រឿងឡើងទៅ ។

**ប្រការ ២.៨០.-**

គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅក្រុង ស្រុក ខណ្ឌ បានយ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ដូចខាងក្រោម ៖

២.៨០.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានអនុញ្ញាតឱ្យធ្វើក្នុងក្របខណ្ឌមណ្ឌល ក្រុង ស្រុក ខណ្ឌ ។

២.៨០.២ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឆ្លងក្រុង ស្រុក ខណ្ឌ ។

២.៨០.៣ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំ ដូចមានចែងក្នុងចំណុច ២.៧៩.៤ ។

**ប្រការ ២.៨១.–**

គណបក្សនយោបាយដែលមានបំណងហែក្បួនឃោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ខប យ៉ាងហោចណាស់ឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនា ។ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី ៖

២.៨១.១ នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ ។

២.៨១.២ កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន ។

២.៨១.៣ ទីតាំងប្រមូលផ្តុំ និងតម្រាយផ្លូវ ដែលត្រូវហែក្បួន ។

២.៨១.៤ ចំនួនអ្នកចូលរួម ។

២.៨១.៥ ចំនួនយានជំនិះតាមប្រភេទនីមួយៗ ។

២.៨១.៦ គធ.ខប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីសម្របសម្រួលទីកន្លែង ផ្លូវ ពេលវេលា និងកម្មវិធីនៃការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ។

២.៨១.៧ ក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ត្រូវរក្សាសុវត្ថិភាពអ្នកចូលរួម និងសណ្តាប់ធ្នាប់ល្អតាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ចរាចរណ៍ ។

**ប្រការ ២.៨២.–**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវធ្វើសកម្មភាពដូចខាងក្រោម ៖

២.៨២.១ ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោតដូចជា ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។

២.៨២.២ ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ ។

២.៨២.៣ ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ។ ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

២.៨២.៣.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

២.៨២.៣.២ ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

២.៨២.៣.៣ ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨២.៣.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨២.៣.៥ ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោតដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។

២.៨២.៣.៦ ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

២.៨២.៣.៧ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

**ប្រការ ២.៨៣.-**

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ ។

**ប្រការ ២.៨៤.-**

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម ៖

២.៨៤.១ ផ្តួចផ្តើម ឬចូលរួមនៅក្នុងការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តួចផ្តើម ឬការចូលរួមឃោសនារួមមាន ៖

២.៨៤.១.១ ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.១.២ ការចូលរួមក្នុងក្បួនដង្ហែ ការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬ បេក្ខជនណាម្នាក់ ។

២.៨៤.១.៤ ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

២.៨៤.២ ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀងរួមមាន ៖

២.៨៤.២.១ ការស្វែងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថ មាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួនដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.៣ ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស រួមមាន ៖

២.៨៤.៣.១ ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.៣.២ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗ ជូនប្រជាពលរដ្ឋសម្រាប់ចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.៣.៣ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ក្បួនដង្ហែឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

២.៨៤.៤ ហាមជនបរទេស ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

**ប្រការ ២.៨៥.–**

មុននឹងបើកការឃោសនាបោះឆ្នោត គជ.ឃប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានរៀបរាប់ក្រោមប្រការ ២.៨២ ខាងលើ តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការទាក់ទិនដល់ការឃោសនាបោះឆ្នោត ។

**ប្រការ ២.៨៦.-**

គជ.ខប ត្រូវចាត់ចែងកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងប្រជុំបន្ថែម តាមការចាំបាច់ ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បី ៖

២.៨៦.១ ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត ។

២.៨៦.២ ជម្រាបជូនជាសង្ខេបពី ប.ន.ក ។

២.៨៦.៣ ស្តាប់មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេងៗ ។

២.៨៦.៤ ពិភាក្សាលើបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត ។

**ប្រការ ២.៨៧.-**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុង ច.ប.ក ច.ប.គ.រ ប.ន.ក ក្រមសីលធម៌សម្រាប់ការបោះឆ្នោត គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២.៨៧.១ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ ។

២.៨៧.២ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងមិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ ។

២.៨៧.៣ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

២.៨៧.៤ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ ។

២.៨៧.៥ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាមួយឡើយ ។

២.៨៧.៦ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ។

២.៨៧.៧ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

២.៨៧.៨ គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគ្រាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះ ឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន៖

២.៨៧.៨.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

២.៨៧.៨.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម ។

២.៨៧.៨.៣ ការវាយតប់បន្តិចបន្តួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់ ។

២.៨៧.៨.៤ ការគំរាមដោយពាក្យសម្តីថានឹងធ្វើទុក្ខទោសដល់រាងកាយ ។

២.៨៧.៨.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។

២.៨៧.៨.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាលដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

២.៨៧.៨.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

២.៨៧.៨.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះ មានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

២.៨៧.៨.៩ ការបណ្ដើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន ។

២.៨៧.៨.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬធ្វើឱ្យខូចផលប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

២.៨៧.៨.១១ ការប្រមូល ឬការដកហូត ឬការបំផ្លាញឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោត ។

២.៨៧.៨.១២ ការដាក់កំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្ដាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា ។

**ប្រការ ២.៨៨.‒**

គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ២.៨៧ នៃ ប.ន.ក នេះ នឹងត្រូវទទួលទោសតាមបញ្ញត្តិនៃ ច.ប.ក ។

**សម្ភារអប់រំអ្នកបោះឆ្នោត**

**ប្រការ ២.៨៩.‒**

នាយកដ្ឋានបណ្ដុះបណ្ដាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត និងសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការបោះឆ្នោត ។

២.៨៩.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចូលរួមយ៉ាងសកម្ម ដើម្បីឱ្យការអប់រំសាធារណជនដែលទាក់ទងដល់ដំណើរការបោះឆ្នោតមានប្រសិទ្ធភាពខ្ពស់ ។

២.៨៩.២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជនអំពីការបោះឆ្នោត អាចទាក់ទងព័ត៌មានជាមួយនឹងនាយកដ្ឋានបណ្ដុះបណ្ដាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ។

២.៨៩.៣ ខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវតែគោរពតាមគោលការណ៍អព្យាក្រឹត និងមិនលម្អៀង។ សម្ភារទាំងនោះមិនត្រូវគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ ហើយត្រូវគោរពទៅតាម ច.ប.ក ច.ប.ត.រ និង ប.ន.ក នេះ ។

២.៨៩.៤ សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំដែលផលិតដោយ គ.ជ.ប និងសម្ភារអប់រំ ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយខ្លឹមសារដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ ។

២.៨៩.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេស និងតាម ច.ប.ក ច.ប.ត.រ និង ប.ន.ក នេះ គ.ជ.ប នឹងជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ យល់ព្រម និងណែនាំដល់អង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារអប់រំនេះ ។

២.៨៩.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាពិនិត្យផ្ទៀងផ្ទាត់ យល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ ។

២.៨៩.៧ ទោះបីជាសម្ភារអប់រំត្រូវបានទទួល ឬមិនបានទទួលលិខិតយល់ព្រមក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយនឹងមិនទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារអប់រំនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ។ ម្ចាស់សម្ភារអប់រំត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

២.៨៩.៨ ករណីដែលមានការស្នើសុំការផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយ ដូចមានចែងក្រោមប្រការ ២.៩១ មានភារកិច្ចក្នុងការផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ យល់ព្រមក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលបានសំណើពីអង្គការមិនមែនរដ្ឋាភិបាលនានា សុំឱ្យជួយពិនិត្យផ្ទៀងផ្ទាត់សម្ភារអប់រំនោះ ។ ករណីពិនិត្យឃើញថា សម្ភារ ឬខ្លឹមសារអប់រំមិនសមស្របតាម

ច.ប.ក ឬ/និង ច.ប.ត.រ ឬ/និង ប.ន.ក គណៈកម្មការសម្របសម្រួលត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវ និងប្រគល់ឱ្យគណៈកម្មការសម្របសម្រួលពិនិត្យឡើងវិញ ។ ក្នុងករណីគណៈកម្មការសម្របសម្រួលធ្វើការពិនិត្យផ្ទៀងផ្ទាត់សម្ភារអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន ។

២.៨៩.៩ សម្ភារអប់រំដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប មានដូចជា ៖

២.៨៩.៩.១ ស្ប៉ុតវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ ។

២.៨៩.៩.២ ឧបករណ៍ផ្ទុកសំឡេងដូចជា ស៊ីឌី (CD) ឬឌីវីឌី (DVD) ឬហ្លាស់មេម៉ូរី (Flash Memory) ។

២.៨៩.៩.៣ ខិត្តប័ណ្ណផ្សេងៗ និងបដា ។

២.៨៩.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត ។

២.៨៩.៩.៥ អត្ថបទ និងរូបភាពចុះលើទំព័រសារព័ត៌មាន។

២.៨៩.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក។

២.៨៩.១០ សម្ភារដែលបានពិនិត្យផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខ ១ (មួយ) ច្បាប់ សម្រាប់ជាឯកសារ ។

២.៨៩.១១ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់យល់ព្រមដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវលើខ្លឹមសារនៃសម្ភារអប់រំតាម ច.ប.ក និង ច.ប.ត.រ ។ ប្រសិនបើព័ត៌មាននៅក្នុងសម្ភារអប់រំ ដែលខ្លួនបានផលិតនោះ ត្រូវបានរកឃើញថា មានភាពលម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយដែលផ្ទុយពី ច.ប.ក ឬ/និងច.ប.ត.រ ឬ/និង ប.ន.ក នេះ ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ក ច.ប.ត.រ និង ប.ន.ក នេះ គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារនោះទាំងស្រុងតែម្តង។ សម្ភារដែលរកឃើញថា មានភាពលម្អៀង ក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ត្រូវបានកំណត់ដូចចំណុច ២.៩០.៥ ខាងក្រោម ។

២.៨៩.១២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋានមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ បានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតតែប៉ុណ្ណោះ ។

២.៨៩.១៣ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬទាំងអស់នៃសម្ភារអប់រំណាដែលមិនគោរពតាមចំណុច ២.៨៩.៣ ២.៨៩.១២ និង ២.៩០.៥ ហើយសាមីអង្គការត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គ.ជ.ប ជាចាំបាច់ ។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាម ច.ប.ក និង ច.ប.គ.រ ។

**រូបភាព និងសម្ភារឃោសនាផ្សព្វផ្សាយ**

**ប្រការ ២.៩០.-**

យោងតាមប្រការ ២.៧៤ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាផ្សព្វផ្សាយបានដូចជា ៖

២.៩០.១ ខិត្តប័ណ្ណឃោសនាបោះឆ្នោត ។

២.៩០.២ ការឃោសនាតាមរលកអាកាស ឬតាមឧបករណ៍បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព ។

២.៩០.២.១ អត្ថបទឃោសនា ។

២.៩០.២.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ ។

២.៩០.២.៣ ការសូត្រកំណាព្យ ។

២.៩០.២.៤ ការប្រគំតន្ត្រីនៅនឹងកន្លែង ។

២.៩០.២.៥ សម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្តផ្ទាល់ ។

២.៩០.២.៦ ការសម្តែងសិល្បៈ ។

២.៩០.២.៧ ការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូជាសាធារណៈ ឬទីធ្លាសាធារណៈ ។

២.៩០.២.៨ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្លូវការរបស់ខ្លួន ។

២.៩០.៣ ក្រៅពីរូបភាព និងសម្ភារ ដូចបានបញ្ជាក់ខាងលើ មធ្យោបាយផ្សេងៗទៀតដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ការឃោសនាបោះឆ្នោតមានដូចខាងក្រោម ៖

២.៩០.៣.១ រឿងល្ខោនខ្លីៗ និងការសម្តែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្តវីដេអូ ។

២.៩០.៣.២ ប៉េងប៉ោង ឬ/និងបង្គោះខ្លែង ។

២.៩០.៣.៣ សម្ភារបោះពុម្ព មានជាអាទិ៍ រូបភាពបិទផ្សាយ សម្លៀកបំពាក់ អាវយឺត មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមរថយន្ត ស្លាកសញ្ញាលោហៈខ្ទាស់ បដា ។ល។

២.៩០.៤ គ្រប់សម្ភារ ឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់និមិត្តសញ្ញារបស់សាមីគណបក្សនយោបាយ (ឈ្មោះ ឬ/និងអាសយដ្ឋាន) ។

២.៩០.៥ សម្ភារអប់រំ និងសម្ភារឃោសនាដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬតាមឧបករណ៍បំពងសំឡេង ឬការចាក់ផ្សាយ មិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាព ឬខ្លឹមសារណាមួយ ដូចខាងក្រោម ៖

២.៩០.៥.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សាបំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសម្ងាត់នៃការបោះឆ្នោត ។

២.៩០.៥.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថ សម្តែងការមាក់ងាយ ឬអសីលធម៌ ឬការរើសអើងប្រកាន់ពូជសាសន៍ ។

២.៩០.៥.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រោះភាពភ័យខ្លាចធ្វើឱ្យភាន់ច្រឡំ ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ និងខូចរបៀបរបបសង្គម ។

២.៩០.៥.៤ ប្រើប្រាស់រូបភាព ឬភាសា ឬព័ត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត ។

២.៩០.៥.៥ ប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយល័ក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន ។

២.៩០.៥.៦ ប្រើប្រាស់រូបភាពសារជាសំឡេង ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់បុគ្គល ដែលត្រូវបានហាមឃាត់ការធ្វើសកម្មភាពនយោបាយដោយស្ថាប័នមានសមត្ថកិច្ច ។

២.៩០.៦ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារអប់រំ និងសម្ភារឃោសនា ដែលត្រូវបានរកឃើញថារំលោភចំណុច ២.៩០.៥ ខាងលើ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារខុសច្បាប់ទាំងនោះ ។

២.៩០.៧ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារអប់រំ និងសម្ភារឃោសនា ដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើសម្ភារទាំងនោះរំលោភលើបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៦ ។

២.៩០.៨ ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រី ព្រះវររាជមាតា និមិត្តសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត ។

២.៩០.៩ ហាមលើកបដាឃោសនា ស្លាកសញ្ញាគណបក្សនយោបាយ និងរូបសញ្ញាណាមួយ ដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ឆ្លងកាត់ទទឹងផ្លូវសាធារណៈ ។

**ប្រការ ២.៩១.-**

គ.ជ.ប ត្រូវបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ហៅថា "គណៈកម្មការសម្របសម្រួល" តាមសេចក្តីសម្រេចរបស់ គ.ជ.ប ដើម្បីត្រួតពិនិត្យសម្ភារអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាល ឬ/និងសម្ភារឃោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្តឹង ព្រមទាំងរៀបចំគោលការណ៍កម្មវិធីស្មើភាព ឬ/និងសមធម៌ ។

២.៩១.១ តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្របសម្រួល ត្រូវបានកំណត់ដូចខាងក្រោម។

២.៩១.១.១ ត្រួតពិនិត្យ និងកែសម្រួលលើខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីមានការស្នើសុំពីសាមីអង្គការ ។

២.៩១.១.២ ត្រួតពិនិត្យសម្ភារអប់រំអ្នកបោះឆ្នោត និងសម្ភារឃោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្តឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាងដទៃទៀត ដោយយោងតាម ច.ប.ត.រ និង ច.ប.ក និងយោងតាមចំណុច ២.៨៧.៨ ២.៩០.៥ និង ២.៩០.៨ នៃ ប.ន.ក នេះ ។

២.៩១.១.៣ សម្របសម្រួលកម្មវិធីស្មើភាព ឬ/និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២.៩១.១.៤ សម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ក្នុងពេលឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីមានឱកាសទិញ ឬជួលម៉ោងផ្សាយផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ ។

២.៩១.១.៥ សម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

២.៩១.២ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានគោលការណ៍សម្រាប់ការរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ ជូនគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជាផ្លូវការឱ្យមានឱកាសផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួន ជូនអ្នកបោះឆ្នោត តាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ ។

២.៩១.២.១ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយឈរឈ្មោះ ដើម្បីពិភាក្សាកំណត់អំពីការរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ ហើយត្រូវមានបទបញ្ជាមួយសម្រាប់ថតកម្មវិធីដែលអនុម័តដោយ គ.ជ.ប ។

២.៩១.២.២ គណៈកម្មការសម្របសម្រួល ត្រូវអនុវត្តតាមគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព ឬ/និងសមធម៌របស់ គ.ជ.ប ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ។

២.៩១.៣ កម្មវិធីស្មើភាព ឬ/និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម ៖

២.៩១.៣.១ កម្មវិធីចាក់ផ្សាយកិច្ចពិភាក្សាតាមប្រធានបទ រវាងបេក្ខជនឈរឈ្មោះបោះឆ្នោត ឬតំណាងគណបក្សនយោបាយអំពីកម្មវិធីនយោបាយរបស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។

២.៩១.៣.២ កម្មវិធីចាក់ផ្សាយស្ប៉ុតរបស់គណបក្សនយោបាយតាមវិទ្យុ និងទូរទស្សន៍រដ្ឋ ។

២.៩១.៣.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត លើព្រឹត្តិបត្រគោលនយោបាយដែលបោះពុម្ពផ្សាយដោយ គ.ជ.ប ។

២.៩១.៤ គណៈកម្មការសម្របសម្រួល ត្រូវជួបពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និងឯកជន និងភាគីពាក់ព័ន្ធ ដើម្បីពន្យល់ណែនាំអំពីបទបញ្ជា និងនីតិវិធី ក្រមសីលធម៌ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំផ្សេងៗរបស់ គ.ជ.ប ។

**ប្រការ ២.៩២.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយនៃការស្នើសុំ ។ គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ត្រូវធ្វើពាក្យសុំទៅអ្នកគ្រប់គ្រងទីកន្លែងនោះ ៣ (បី) ថ្ងៃយ៉ាងតិច មុនថ្ងៃប្រជុំឃោសនា ហើយត្រូវផ្ញើសេចក្តីចម្លងនៃពាក្យសុំនេះ ១ (មួយ) ច្បាប់ដល់ គធ.ខប ។ អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំជួលក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ។

២.៩២.១ គធ.ខប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីកំណត់ ទីសាធារណៈសម្រាប់ការឃោសនាបោះឆ្នោត ហើយត្រូវផ្សព្វផ្សាយជាសាធារណៈនៅក្នុងរាជធានី ខេត្ត យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ។

២.៩២.២ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹង ដូចមានចែងក្នុងប្រការ ២.៩២ គធ.ឧប ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីសម្របសម្រួល អំពីការងារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ឱ្យគណបក្សនយោបាយ ឬបេក្ខជនធ្វើការឃោសនា ។

២.៩២.៣ គធ.ឧប ត្រូវមានសៀវភៅចុះលិខិតចម្លងនៃពាក្យស្នើសុំធ្វើការឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដែលបានទទួល ដើម្បីឱ្យបានដឹងថា គណបក្សនយោបាយណាបានស្នើសុំធ្វើការឃោសនាមុន និងគណបក្សនយោបាយណាបានស្នើសុំធ្វើការឃោសនាបន្តបន្ទាប់ ។

២.៩២.៤ គធ.ឧប ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ ស្តីពីកាលកំណត់តាមលំដាប់មុនក្រោយនៃការស្នើសុំប្រើប្រាស់ទីសាធារណៈ ឬទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅ លគធ.ឧប ១ (មួយ)ច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការឃោសនា ១ (មួយ) ច្បាប់ ។

២.៩២.៥ គធ.ឧប ត្រូវតាមដាន សម្របសម្រួល និងរៀបចំតាមលំដាប់មុនក្រោយនៃការជូនដំណឹងស្តីពីការធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ដោយណែនាំឱ្យគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ និងចាត់វិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាទាំងឡាយណាដែលផ្ទុយនឹង ច.ប.ក ច.ប.គ.រ និង ប.ន.ក នេះ ។

២.៩២.៦ គ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដែលមានបំណងធ្វើសកម្មភាពចែកខិត្តប័ណ្ណនៅក្នុងផ្សារ សាមីគណបក្សនយោបាយទាំងនោះត្រូវស្នើសុំទៅអ្នកគ្រប់គ្រងផ្សារ និងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ឧប ពាក់ព័ន្ធយ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃធ្វើសកម្មភាព ។

២.៩២.៦.១ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ៖

- នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ
- កាលបរិច្ឆេទ ពេលវេលា និងឈ្មោះផ្សារ ដែលត្រូវធ្វើសកម្មភាព
- ចំនួនអ្នកចូលរួម ។

២.៩២.៦.២ ការធ្វើសកម្មភាពក្នុងផ្សារត្រូវកម្រិតយ៉ាងច្រើនត្រឹម ១០ (ដប់) នាក់ប៉ុណ្ណោះ ហើយត្រូវយកចិត្តទុកដាក់គោរព និងរក្សាឱ្យបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងមិនត្រូវយកតាមខ្លួននូវឧបករណ៍បំពងសំឡេងឡើយ ។

២.៩២.៦.៣ ការផ្សព្វផ្សាយតាមឧបករណ៍បំពងសំឡេង អំពីគោលនយោបាយ ឬ/និងកម្មវិធីនយោបាយ ឬ/និងសារនយោបាយរបស់គណបក្ស អាចធ្វើបាននៅក្រៅបរិវេណផ្សារ ។

២.៩២.៦.៤ គធ.ខប ត្រូវសហការ សម្របសម្រួលជាមួយអាជ្ញាធរដែនដី និងអ្នកគ្រប់គ្រងផ្សារ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើសកម្មភាពនេះ ។

**ប្រការ ២.៩៣.-**

គ្រប់សកម្មភាពឃោសនារបស់គណបក្សនយោបាយត្រូវរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយឱ្យបានល្អ និងត្រឹមត្រូវតាមពេលវេលា ទីកន្លែងកំណត់ តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ ។

**ប្រការ ២.៩៤.-**

គណបក្សនយោបាយ ឬ/និងបេក្ខជនអាចធ្វើសកម្មភាពឃោសនានៅតាមកន្លែងឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ខប យ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនា ។ អ្នកគ្រប់គ្រងទីកន្លែងត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់គ្រប់បេក្ខជន ឬគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលមានបំណងសុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព តម្លៃស្មើគ្នា និងតាមលំដាប់នៃពេលវេលាដែលបានស្នើសុំ ។

**ប្រការ ២.៩៥.-**

គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រផ្សេងទៀតឡើយ ។ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខានរាំងស្ទះនោះ រួមមាន ៖

២.៩៥.១ ការនិយាយដៀមដាមប្រមាថមើលងាយ ។

២.៩៥.២ ការធ្វើទុក្ខទោសដល់រាងកាយ ។

២.៩៥.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់ ។

២.៩៥.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សនយោបាយកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ។

២.៩៥.៥ ការរារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមកាលកំណត់ ។

២.៩៥.៦ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ថយបង្អាក់មិនឱ្យក្បួនដង្ហែឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀត ។

២.៩៥.៧ ការហាមឃាត់ ឬរារាំងប្រជាពលរដ្ឋមិនឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ ។

២.៩៥.៨ ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពឃោសនា របស់គណបក្សនយោបាយ ឬបេក្ខជន ។

២.៩៥.៩ ការប្រើឧបករណ៍បំពងសំឡេងដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនា ឬការជួបប្រជុំ ។

២.៩៥.១០ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្សនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ។

២.៩៥.១១ ការបង្កើត ការផ្ញើ ការបញ្ជូនព័ត៌មានក្លែងក្លាយ ឬទិន្នន័យមិនត្រឹមត្រូវ ដោយមធ្យោបាយណាក៏ដោយដើម្បីបង្ខូច ឬបង្អាប់គណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ។

**ប្រការ ២.៩៦.-**

បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

២.៩៦.១ យោធិនកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការឃោសនាបោះឆ្នោត ។

២.៩៦.២ យោធិនកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលបានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត ។

២.៩៦.៣ យោធិនកងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលមានភារកិច្ចការពារ មិនត្រូវឈរក្បែរ ឬដើរកៀកពេកទៅនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ ។

២.៩៦.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គធ.ខប ត្រូវតាមដានកម្រិតសន្តិសុខ និងសុវត្ថិភាពក្នុងរាជធានី ខេត្ត ព្រមទាំងសរុបសភាពការណ៍សន្តិសុខ សុវត្ថិភាព និងរាយការណ៍ជូន គ.ជ.ប ជារៀងរាល់ថ្ងៃ ។

### ប្រការ ២.៩៧.-

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនីដើម្បីកត់ត្រាចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការឃោសនាបោះឆ្នោត ។

២.៩៧.១ ការចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់ ។

២.៩៧.២ វិភាគទានទាំងអស់ដែលគណបក្សនយោបាយទទួលបាន ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនា ត្រូវតែចេញពីគណនីតែមួយនេះ ។

២.៩៧.៣ គ.ជ.ប អាចត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត តាមការចាំបាច់ ។

## កិច្ចសហការ និងភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

### ប្រការ ២.៩៨.-

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតជូនសាធារណជន និងតាមដានការផ្សព្វផ្សាយ ត្រួតពិនិត្យ និងចាត់វិធានការ ក្នុងករណីមិនគោរពតាម ច.ប.ក ច.ប.ត.រ និង ប.ន.ក ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ។

**ប្រការ ២.៩៩.–**

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ឯកជន ដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ត្រូវអនុវត្តតាមក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

**ប្រការ ២.១០០.–**

គ្រប់ប្រព័ន្ធផ្សព្វផ្សាយ ទាំងរដ្ឋ ទាំងឯកជន ត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**ប្រការ ២.១០១.–**

រាល់ពាក្យបណ្ដឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមផ្នែកទី ១១ នៃ ប.ន.ក នេះ។

# ផ្នែកទី ៧
# ការបោះឆ្នោត

**ប្រការ ២.១០២.-**

អនុវត្តតាម ច.ប.ក គ.ជ.ប ត្រូវបោះពុម្ព និងចាត់ចែងឱ្យបិទផ្សាយជាសាធារណៈ នូវបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅតាមសាលាឃុំ សង្កាត់ និងនៅទីកន្លែងសាធារណៈណាមួយនៅក្នុងមណ្ឌលបោះឆ្នោត យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

២.១០២.១ គ.ជ.ប ត្រូវណែនាំដល់ គធ.ខប ឱ្យចាត់ចែងបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំនួន ៣ (បី) ច្បាប់ ដូចខាងក្រោម ៖

២.១០២.១.១ បិទផ្សាយ ១ (មួយ) ច្បាប់ នៅតាមសាលាឃុំ សង្កាត់ ។

២.១០២.១.២ បិទផ្សាយ ១ (មួយ) ច្បាប់ នៅទីកន្លែងសាធារណៈណាមួយ នៅក្នុងមណ្ឌលបោះឆ្នោត ។

២.១០២.១.៣ រក្សា ១ (មួយ) ច្បាប់ នៅ លគធ.ខប ជាឯកសារ និងបម្រើការផ្សព្វផ្សាយជាសាធារណៈ ។

២.១០២.២ នាយកដ្ឋានប្រតិបត្តិការ ត្រូវសហការជាមួយនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ដើម្បីរៀបចំបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ។

២.១០២.៣ នាយកដ្ឋានប្រតិបត្តិការត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ជូននាយកដ្ឋានរដ្ឋបាល ១ (មួយ) ច្បាប់ ដើម្បីសហការគ្នាធ្វើជាសេនាធិការជូន គ.ជ.ប ក្នុងការកំណត់ចំនួនមន្ត្រីការិយាល័យបោះឆ្នោត និងដើម្បីជ្រើសរើសសមាសភាព គ.ក.ប ។

## សម្ភារៈ ឯកសារបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោត

**ប្រការ ២.១០៣.-**

គ.ជ.ប ត្រូវផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឧបករណ៍សម្រាប់បម្រើឱ្យការបោះឆ្នោត តាមការិយាល័យបោះឆ្នោតឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា ។

២.១០៣.១ គ.ជ.ប ត្រូវធានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួនតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។ គ.ជ.ប ត្រូវបោះពុម្ពសន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត លើក្រដាសពណ៌ស និងសន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ លើក្រដាសពណ៌ ។

២.១០៣.២ សន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវមានគល់បញ្ជីសន្លឹកឆ្នោត ។ លេខរៀងតាមលំដាប់គត្តានៃសន្លឹកឆ្នោត ត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត ។

២.១០៣.៣ សន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ ។ សញ្ញាសម្គាល់គណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ដែលត្រូវដាក់នៅលើសន្លឹកឆ្នោត ត្រូវដាក់តាមលំដាប់លំដោយ ផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងនៅលើសន្លឹកឆ្នោត ។

២.១០៣.៤ គ.ជ.ប ត្រូវធានាផ្តល់ហិបឆ្នោតឱ្យបានគ្រប់ចំនួនសម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ។ គ្រប់ហិបឆ្នោតទាំងអស់ត្រូវ ៖

- មានគម្របជាប់មកជាមួយ ដែលអាចចាក់បិទបានដោយប្រើប្រាស់សោឃ្លុំមានលេខ
- ធានាសុវត្ថិភាព ដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបឆ្នោតបាន ប្រសិនបើមិនបើកគម្រប
- មានសោឃ្លុំមានលេខសម្រាប់ចាក់ពេលបិទហិបឆ្នោត
- មានស្លាកលេខកូដការិយាល័យពណ៌ផ្សេងគ្នា នៅផ្នែកខាងក្រៅយ៉ាងច្បាស់ ដែលមិនអាចដូរ ឬលុបបានដោយងាយ សម្រាប់ហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត និងសម្រាប់ហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៣.៥ គ.ជ.ប ត្រូវធានាឱ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នា សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ។

២.១០៣.៦ គ.ជ.ប ត្រូវធានាឱ្យការិយាល័យបោះឆ្នោតនីមួយៗ មានសម្ភារ ឧបករណ៍ ដូចខាងក្រោម ៖

- បញ្ជីបោះឆ្នោត ។
- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។
- ហិបឆ្នោត ដែលអាចចាក់ជាមួយសោឃ្លុំមានលេខ ។
- បន្ទប់សម្ងាត់ ។
- ត្រាការិយាល័យបោះឆ្នោត ។
- ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

- ទឹកខ្មៅលុបមិនជ្រះ សម្រាប់ជ្រលក់ម្រាមដៃសម្គាល់ថាបានបោះឆ្នោតហើយ។
- សោឃ្លុំមានលេខ ។
- ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។
- ប៊ិកសរសេរដែលមានគុណភាពល្អ ។
- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។
- កញ្ចប់ និងស្បោងប្លាស្ទិក ។
- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត ។

## ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ

### ប្រការ ២.១០៤.-

គ.ក.ប នឹងក្លាយទៅជា គ.ក.រ នៅពេលរាប់សន្លឹកឆ្នោត ។ គ.ក.ប/គ.ក.រ នីមួយៗមានភារកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតដែល គ.ក.ប/គ.ក.រ នោះ ទទួលខុសត្រូវ ។

២.១០៤.១ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ដែលខ្លួនទទួលខុសត្រូវ និងត្រូវ ៖

២.១០៤.១.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៤.១.២ ម្ចាស់ការ និងចាត់ចែងក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ក ប.ន.ក ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប ។

២.១០៤.១.៣ ទទួលផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារ ឯកសារសម្រាប់បម្រើឱ្យការបោះឆ្នោត ពិសេសពិនិត្យលេខកូដនៃកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតសម្រាប់ការិយាល័យពាក់ព័ន្ធ ។

២.១០៤.១.៤ រៀបចំទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទៅតាមគំរូប្លង់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបំពាក់គ្រឿងសង្ហារិម ។

២.១០៤.១.៥ តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់សមាសភាព គ.ក.ប/គ.ក.រ នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងអាណត្តិរបស់ខ្លួន ។

២.១០៨.១.៦ ដាក់ជំនួសតំណែងសមាជិក គ.ក.ប/គ.ក.រ ដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ។

២.១០៨.១.៧ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោត ។ ក្នុងពេលដំណើរការបោះឆ្នោត យ៉ាងយូរ ១ (មួយ) ម៉ោងម្តង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីត្រួតពិនិត្យសុវត្ថិភាពសម្ភារបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ ក្នុងករណីគ្មានអ្នកបោះឆ្នោត ក្នុងបន្ទប់សម្ងាត់ ។

២.១០៨.១.៨ ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវបានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយឱ្យចុះហត្ថលេខាជាសាក្សី ។

២.១០៨.១.៩ ចាត់ចែងចែកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

២.១០៨.១.១០ ត្រួតពិនិត្យប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ និងប័ណ្ណសម្គាល់អ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១០៨.១.១១ អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្លាស់ប្តូរទីកន្លែងពិនិត្យមើលដំណើរការបោះឆ្នោត ។

២.១០៨.១.១២ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ដល់អ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

២.១០៨.១.១៣ បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ។

២.១០៨.១.១៤ ធានារបៀបរៀបរយក្នុង និងក្រៅបរិវេណការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៨.១.១៥ ចាក់ ឬកាត់ផ្តាច់សោឃ្លុំការពារហិបឆ្នោត ។

២.១០៨.១.១៦ ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានណែនាំឱ្យចេះពីរបៀបបោះឆ្នោតពីរ (២) សន្លឹក ដែល ១ (មួយ) សន្លឹកសម្រាប់ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និង ១ (មួយ) សន្លឹកទៀត សម្រាប់

ជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។ តាមដានពិនិត្យមើល ដើម្បីឱ្យប្រាកដថានៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើមតាមការណែនាំ ។

២.១០៨.១.១៧ បំពេញក្រដាសព័ត៌មានអំពីអ្នកបោះឆ្នោតណាម្នាក់ ដែលអះអាងថាមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ។

២.១០៨.១.១៨ ធានាឱ្យប្រាកដថា ការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះ ត្រូវតែបានអនុវត្តតាមការណែនាំ ។

២.១០៨.១.១៩ ធានាឱ្យប្រាកដថា ការប្តឹងជំទាស់ ឬ/និងតវ៉ា ក្នុងការិយាល័យបោះឆ្នោត ដោយភ្នាក់ងារគណបក្សនយោបាយ ត្រូវតែបានដោះស្រាយភ្លាម ដោយអនុវត្តស្របតាម ប.ន.ក និងការណែនាំរបស់ គ.ជ.ប ។

២.១០៨.១.២០ ជួយអ្នកបោះឆ្នោតជាជនដែលមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបានតាមការស្នើសុំរបស់សាមីខ្លួន ។

២.១០៨.១.២១ ធានាឱ្យប្រាកដថា សន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗសម្រាប់ការិយាល័យបោះឆ្នោតរបស់ខ្លួន ត្រូវបានពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ និងត្រឹមត្រូវ ។

២.១០៨.១.២២ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត ។

២.១០៨.១.២៣ ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោបាយ ដែលបានទទួលសំឡេងឆ្នោត ។

២.១០៨.១.២៤ ប្រគល់ជូន គធ.ខប នូវកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ។

២.១០៨.១.២៥ ប្រគល់ជូន គធ.ខប នូវកំណត់ហេតុស្តីពីការបោះឆ្នោត និងហិបឆ្នោត ដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងកាលៈទេសៈមានអាសន្ន ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតបាន ។

២.១០៨.១.២៦ បំពេញភារកិច្ចរបស់ខ្លួន ដោយជំហរអព្យាក្រឹត និងមិនលម្អៀង ។

២.១០៨.១.២៧ បំពេញភារកិច្ចផ្សេងៗទៀតដែល គធ.ខប ប្រគល់ឱ្យ ។

២.១០៤.២ អនុប្រធាន គ.ក.ប/គ.ក.រ ត្រូវជួយប្រធាន និងមានភារកិច្ចដោយឡែក ដូចខាងក្រោម ៖

២.១០៤.២.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៤.២.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ក ប.ន.ក ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប ។

២.១០៤.២.៣ ជួសតំណែងប្រធាន ក្នុងករណីប្រធានមិនអាចមកបំពេញការងារបាន ។

២.១០៤.២.៤ រាប់ចំនួនសន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលបានទទួលជាក់ស្តែង សម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោត មុននឹងបើកកិច្ចប្រតិបត្តិការបោះឆ្នោត ។

២.១០៤.២.៥ ពិនិត្យការសើកសន្លឹកឆ្នោតទៅក្នុងហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៤.២.៦ ហែកសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ផ្តាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្តត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត ។

២.១០៤.២.៧ ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត។

២.១០៤.២.៨ អនុញ្ញាតឱ្យអ្នកបោះឆ្នោត ចូលគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់ នៅពេលដែលបន្ទប់សម្ងាត់នោះទំនេរ គ្មានអ្នកបោះឆ្នោតផ្សេងទៀត ។

២.១០៤.២.៩ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅពេលបញ្ចប់ការបោះឆ្នោត ។

២.១០៤.២.១០ ត្រួតពិនិត្យ និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់នៅខាងខ្នង មុននឹងប្រគល់ជូនប្រធាន ។

២.១០៤.២.១១ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗ ទទួលបានតាមប្រភេទក្រុមប្រឹក្សានីមួយៗនៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

២.១០៨.២.១២ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងរួមជាមួយលេខាធិការ ពិនិត្យបញ្ជាក់ឡើងវិញអំពីភាពត្រឹមត្រូវ មុនដាក់ជូនប្រធានចុះហត្ថលេខា ដើម្បីចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

២.១០៨.២.១៣ អមដំណើរប្រធាន ក្នុងការបញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារឯកសារបោះឆ្នោតផ្សេងទៀតជូន គធ.ខប ។

២.១០៨.២.១៤ បំពេញភារកិច្ចផ្សេងទៀត ដែល គធ.ខប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

២.១០៨.៣ លេខាធិការនៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងជាអ្នកទទួលបន្ទុកពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងការបំពេញទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ហើយត្រូវ ៖

២.១០៨.៣.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៨.៣.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ក ប.ន.ក ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប ។

២.១០៨.៣.៣ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៨.៣.៤ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

២.១០៨.៣.៥ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃ អ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បោះឆ្នោត នៅមុនពេលពិនិត្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត ។

២.១០៨.៣.៦ សួរបញ្ជាក់ឈ្មោះ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នារវាងរូបពិត ឈ្មោះ និងទិន្នន័យក្នុង អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបយ.ស របស់សាមីអ្នកបោះឆ្នោត ជាមួយនឹងរូបថត

ឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រួចគូសសម្គាល់ថាបានមកបោះឆ្នោត ក្នុងកូនប្រអប់បួនជ្រុងទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត ។

២.១០៤.៣.៧ ណែនាំអ្នកបោះឆ្នោត ដែលបានមកបោះឆ្នោត ឱ្យផិកសម្គាល់នៅក្នុងបញ្ជីបោះឆ្នោត ត្រង់កន្ទុយឈ្មោះរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ថា សាមីខ្លួនបានមកបោះឆ្នោតរួចហើយ ។

២.១០៤.៣.៨ ហែកសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្ដាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្នត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត ។

២.១០៤.៣.៩ ផ្ដល់ការណែនាំអំពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត ។

២.១០៤.៣.១០ រាប់គំនូសសញ្ញាលើបញ្ជីបោះឆ្នោត រាប់ចំនួនអ្នកបោះឆ្នោតដែលប្រកាសមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រភេទណាមួយ និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត ។

២.១០៤.៣.១១ បំពេញកំណត់ហេតុនៃការបោះឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា រួចដាក់បង្ហាញឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើល ។

២.១០៤.៣.១២ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់តវ៉ា ឬជំទាស់ ឬករណីប្ដឹងតវ៉ា និងប្ដឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៤.៣.១៣ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលតាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

២.១០៤.៣.១៤ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងរួមជាមួយអនុប្រធាន និងសមាជិកទី១ ពិនិត្យបញ្ជាក់ឡើងវិញអំពីភាពត្រឹមត្រូវ មុនដាក់ជូនប្រធានចុះហត្ថលេខា ។

២.១០៤.៣.១៥ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ឧប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

២.១០៨.៤ សមាជិកទី ១ នៃ គ.ក.ប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ច ដូចខាងក្រោម ៖

២.១០៨.៤.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៨.៤.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត ។

២.១០៨.៤.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប ។

២.១០៨.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការសឹកសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៨.៤.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់ បានប៉ុនប៉ងសឹកសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលក្នុងហិបឆ្នោត ។

២.១០៨.៤.៦ ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោត ដែលបានបោះឆ្នោតរួច ទៅក្នុងទឹកខ្មៅលុបមិនជ្រះឱ្យដល់គល់ក្រចក និងណែនាំគាត់ឱ្យរង់ចាំ៣០ វិនាទី ដើម្បីឱ្យទឹកខ្មៅស្ងួត មុននឹងចេញពីការិយាល័យបោះឆ្នោត ។

២.១០៨.៤.៧ រាប់ចំនួនសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយកវត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រដោយឡែក ។

២.១០៨.៤.៨ លាសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដើម្បីត្រួតពិនិត្យស្នាមគ្រាសម្គាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានគ្រាសម្គាត់ ឬគ្មានគ្រាសម្គាត់ ។

២.១០៨.៤.៩ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួល តាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅលើផ្ទាំងក្រដាសធំ ។

២.១០៨.៤.១០ ជួយបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត តាមក្រុមប្រឹក្សានីមួយៗ និងរួមជាមួយលេខាធិការ ពិនិត្យបញ្ជាក់ឡើងវិញអំពីភាពត្រឹមត្រូវ មុនដាក់ជូនលេខាធិការ និងប្រធានចុះហត្ថលេខា ដើម្បីចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

២.១០៨.៤.១១ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ខប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

២.១០៤.៥ សមាជិកទី ២ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

២.១០៤.៥.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៤.៥.២ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប ។

២.១០៤.៥.៣ ជួយរកឈ្មោះអ្នកបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀងឈ្មោះរបស់គាត់ ។

២.១០៤.៥.៤ ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុងករណីចាំបាច់ អាចផ្តល់បណ្ណលេខរៀងតាមលំដាប់អ្នកមកមុនមកក្រោយ) ព្រមទាំងរាយការណ៍ជូនប្រធាន អំពីការរំខាន ឬការអុកឡុកនានាក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត (ប្រសិនបើមាន) ។

២.១០៤.៥.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា មានអ្នកបោះឆ្នោតណាម្នាក់ បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

២.១០៤.៥.៦ ប្រមូល អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស ពីអ្នកបោះឆ្នោត ដែលស្ថិតក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល ប្រសិនបើមាន ។

២.១០៤.៥.៧ ចោះ ឬកាត់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលនៅសល់មិនបានប្រើប្រាស់ បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ។

២.១០៤.៥.៨ សហការជាមួយសមាជិកទី ៣ ក្នុងការការពារមាត់ទ្វារការិយាល័យបោះឆ្នោត ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

២.១០៤.៥.៩ បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១០៤.៥.១០ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ខប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

២.១០៨.៦ សមាជិកទី ៣ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

២.១០៨.៦.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៨.៦.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត ។

២.១០៨.៦.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

២.១០៨.៦.៤ ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោត ឱ្យឈរបន្តគ្នាជាជួរតាមលំដាប់មុនក្រោយ ប្រសិនបើគាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យ អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស របស់គាត់ ។

២.១០៨.៦.៥ អនុញ្ញាតឱ្យអ្នកបោះឆ្នោត មានវត្តមានក្នុងការិយាល័យបោះឆ្នោត ចំនួន ៤ នាក់ ក្នុងពេលតែមួយ ។

២.១០៨.៦.៦ ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ចំពោះអ្នកបោះឆ្នោត ជាជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនដែលមានពិការភាព បន្ទាប់មកគឺអ្នកឈរខាងមុខគេក្នុងជួរ ។

២.១០៨.៦.៧ ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត ។

២.១០៨.៦.៨ ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការអុកឡុករំខានជូនប្រធាន ។

២.១០៨.៦.៩ សហការជាមួយសមាជិកទី ២ ក្នុងការការពារសន្តិសុខនៅច្រកផ្លូវចេញចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

២.១០៨.៦.១០ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ខប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

**ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត**

**ប្រការ ២.១០៥.–**

គ.ជ.ប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវតែបានបញ្ជូន និងប្រគល់ជូន គ.ក.ប មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត ។ នៅពេលព្រឹកនៃថ្ងៃ មុនថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីត្រួតពិនិត្យវត្តមាន ត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរៀបចំគំរូប្លង់ការិយាល័យបោះឆ្នោត ។

២.១០៥.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារគ្រប់គ្រាន់ សម្រាប់បម្រើកិច្ចប្រតិបត្តិការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ជូន គធ.ខប និង គ.ក.ប ទាំងអស់ ។

២.១០៥.២ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវទទួលខុសត្រូវក្នុងការផលិតបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗចំនួន ៣ (បី) ច្បាប់ សម្រាប់បែងចែកជូន គធ.ខប និង គ.ក.ប ដើម្បីប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១០៥.៣ នាយកដ្ឋានប្រតិបត្តិការ ត្រូវរៀបចំផែនការបែងចែក និងត្រៀមសម្ភារ ឯកសារសម្រាប់ដឹកជញ្ជូនទៅកាន់គោលដៅនានា សម្រាប់បម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឱ្យបានគ្រប់គ្រាន់ជាមុន។ សម្ភារ ឯកសារសម្រាប់ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវបានរៀបចំដាក់ក្នុងហិបបរិក្ខារដែលរួមមាន ៣ ប្រភេទ រួមមាន ៖

២.១០៥.៣.១ ហិបបរិក្ខារសម្រាប់បណ្ដុះបណ្ដាល ដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្ដុះបណ្ដាល និងអប់រំអ្នកបោះឆ្នោត និង គធ.ខប។

២.១០៥.៣.២ ហិបបរិក្ខារ គធ.ខប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប នីមួយៗ។

២.១០៥.៣.៣ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប នីមួយៗ ។

២.១០៥.៤ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ ទទួលហិបបរិក្ខារបោះឆ្នោត មន្ត្រីទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) និងត្រូវឱ្យមន្ត្រីទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗ ចុះហត្ថលេខាបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ ។

២.១០៥.៥ ហិបបរិក្ខារ គធ.ខប ដែលត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល ដូចមានឧបសម្ព័ន្ធទី ៦ ។

២.១០៥.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និងឯកសារផ្សេងទៀត ដូចមានក្នុងឧបសម្ព័ន្ធទី ៧ ដែល គធ.ខប ត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប មិនត្រូវឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត ។

២.១០៥.៧ គ.ជ.ប និង គធ.ខប ត្រូវធានាក្នុងការបញ្ជូន និងប្រគល់ឱ្យបានគ្រប់គ្រាន់ជូន គ.ក.ប នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត នូវសម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្រោមចំណុច ២.១០៥.៦ ខាងលើ ។ គធ.ខប ត្រូវជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីចូលរួមសង្កេតមើល គ.ក.ប នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារបោះឆ្នោត ដូចចែងក្នុងចំណុច ២.១០៥.១០ ខាងក្រោម ។

២.១០៥.៨ គ.ជ.ប ត្រូវរៀបចំទម្រង់បែបបទផ្សេងៗដែលប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដោយក្រដាសពណ៌ ហើយទម្រង់បែបបទ ដែលប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដោយក្រដាសស ។

២.១០៥.៩ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវតែមកបង្ហាញខ្លួន តាមការកោះអញ្ជើញរបស់ប្រធាន គ.ក.ប និងត្រូវធានាថា នឹងមានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត ។

២.១០៥.៩.១ មុនថ្ងៃបោះឆ្នោត ២៤ (ម្ភៃបួន) ម៉ោង ប្រធាន គ.ក.ប ត្រូវប្រជុំមន្ត្រីទាំងអស់ ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត ព្រមទាំងសម្ភារ ឯកសារ និងបរិក្ខារបម្រើឱ្យការបោះឆ្នោត ។ ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួសដោយមន្ត្រីថ្មី ដែលជ្រើសតាំងឡើងតាមការសម្រេចរបស់ គធ.ខប ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុង ប.ន.ក ។

២.១០៥.៩.២ ប្រសិនបើប្រធាន គ.ក.ប មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយសមាជិកទី១ ត្រូវចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋ ដែលបានដាក់ពាក្យសម្ភាសន៍ ត្រូវជំនួសតំណែងសមាជិកទី១ ។

២.១០៥.៩.៣ ប្រសិនបើអនុប្រធាន មិនអាចមកធ្វើការបាននោះ ប្រធាន គ.ក.ប ត្រូវតែងតាំងសមាជិកទី១ ជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងត្រូវចូលកាន់តំណែងសមាជិកទី១ ។

២.១០៥.៩.៤ ប្រសិនបើលេខាធិការ មិនអាចមកធ្វើការបាននោះ ប្រធាន គ.ក.ប ត្រូវតែងតាំងសមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងចូលកាន់តំណែងសមាជិកទី១ ។

២.១០៥.៩.៥ សមាសភាពទាំងអស់នៃ គ.ក.ប រួមទាំងអ្នកទើបជ្រើសរើសថ្មី ត្រូវរួមគ្នាសិក្សាឡើងវិញ នូវនីតិវិធីនៃការបោះឆ្នោត ដោយផ្អែកលើសៀវភៅណែនាំ គ.ក.ប ។

២.១០៥.៩.៦ សមាជិកតែងតាំងថ្មីទាំងអស់ ត្រូវតែបានទទួលការបណ្តុះបណ្តាលដូចមានចែងក្នុងចំណុច ២.១០៥.៩.៥ ។

២.១០៥.៩.៧ ប្រធាន គ.ក.ប ត្រូវជូនដំណឹងជាបន្ទាន់ដល់ គជ.ឃប អំពីអ្វីដែលបានអនុវត្តពាក់ព័ន្ធនឹងការដាក់ជំនួសតំណែងសមាសភាពណាម្នាក់នៃ គ.ក.ប ។

២.១០៥.១០ បន្ទាប់ពីអនុវត្តចំណុច ២.១០៥.៩ រួច គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតដែល គ.ក.ប បានទទួល ហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ។ ក្នុងនោះ គ.ក.ប ត្រូវ ៖

២.១០៥.១០.១ ត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត ដោយប្រើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ។

២.១០៥.១០.២ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបានទទួល ត្រឹមត្រូវគ្រប់ចំនួនហើយ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខាលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) នោះ និងរក្សាទុកឱ្យបានហ្មត់ចត់ ។

២.១០៥.១០.៣ ប្រសិនបើសម្ភារ ឯកសារណាមួយ ឬមួយចំនួន ដែលបានទទួលមិនគ្រប់តាមចំនួនកំណត់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារឯកសារបោះឆ្នោតណាដែលបាត់បង់ នៅលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ហើយត្រូវផ្ញើតារាងត្រួតពិនិត្យនេះ ១ (មួយ) ច្បាប់ ជាបន្ទាន់ទៅ គជ.ឃប ។

២.១០៥.១០.៤ ប្រសិនបើសម្ភារ ឯកសារដែលបាត់បង់នោះ ជាសម្ភារ ឯកសារចាំបាច់មិនអាចខ្វះបាន សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក គ.ក.ប ចំនួន ២ (ពីរ) រូប ឱ្យធ្វើដំណើរទៅកាន់លេខាធិការដ្ឋាន គជ.ខប ដើម្បីទទួលសម្ភារ ឯកសារថ្មី ជំនួសសម្ភារឯកសារដែលខ្វះ ឬបានបាត់បង់ទៅ ឬក៏ទូរស័ព្ទបញ្ជូនព័ត៌មានស្នើសុំទៅ គជ.ខប ដើម្បីដោះស្រាយបញ្ហាខាងលើ ។

២.១០៥.១០.៥ ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតខាងលើនេះ គ.ក.ប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារ ដូចខាងក្រោម ៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ និងពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលមានកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោត ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតឡើយ ។
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់ចំនួន ២ (ពីរ) នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត ។

២.១០៥.១១ សម្ភារ ឯកសារសំខាន់ៗដែល គ.ក.ប មិនបានទទួល ហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន ៖

២.១០៥.១១.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

២.១០៥.១១.២ ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោតចំនួន ២ (ពីរ) ។

២.១០៥.១១.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

២.១០៥.១១.៤ ហិបឆ្នោតទាំង ២ (ពីរ) ដែលហិបឆ្នោត ១ (មួយ) មានជញ្ជាំងខាងមុខបិទពាសដោយក្រដាសស (លេខកូដការិយាល័យបោះឆ្នោត) ប្រើសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងហិបឆ្នោត ១ (មួយ) ទៀត មានបិទពាសដោយក្រដាសពណ៌ (លេខកូដការិយាល័យបោះឆ្នោត) ប្រើសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសោឃ្លុំមានលេខ ។

២.១០៥.១១.៥ ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃសម្គាល់ថា បានមកបោះឆ្នោតហើយ ។

២.១០៥.១២ សម្ភារ ឯកសារដទៃទៀត ដែលប្រសិនបើមិនបានផ្តល់ដោយ គជ.ខប នោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ៖

២.១០៥.១២.១ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទបាំង ជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

២.១០៥.១២.២ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុជាគំរូ។

២.១០៥.១២.៣ ប៊ិកសរសេរ បន្ទាត់ ខ្សែចង...។ល។

២.១០៥.១៣ នៅពេលពិនិត្យផ្ទៀងផ្ទាត់ឃើញថា សម្ភារឯកសារបោះឆ្នោតមានគ្រប់ចំនួនហើយ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ១ (មួយ) ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត លើកស្លាក និងលេខកូដការិយាល័យបោះឆ្នោត នៅលើច្រកទ្វារចូលការិយាល័យបោះឆ្នោត ។

២.១០៥.១៤ បន្ទាប់ពីអនុវត្តចំណុច ២.១០៥.១៣ រួច គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ការិយាល័យបោះឆ្នោតដើម្បីឱ្យប្រាកដថា ទីតាំងការិយាល័យបោះឆ្នោតនោះ អាចធ្វើការបោះឆ្នោតបាន ហើយអាចរៀបចំរួចស្រេចនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹកនៃថ្ងៃបោះឆ្នោត ។

២.១០៥.១៤.១ គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោត ឯកភាពគ្នាមួយ ដោយត្រូវគោរពតាមគំរូប្លង់ ដូចមានចែងក្នុងសៀវភៅណែនាំ គ.ក.ប ។

២.១០៥.១៤.២ គ.ក.ប ត្រូវបាំងរាំងនន ឬរបាំងផ្សេងទៀតដែលអាចរកបាន នៅចន្លោះបន្ទប់សម្ងាត់ទាំងពីរ នៅក្នុងការិយាល័យបោះឆ្នោត។ រាំងនន ឬរបាំង ត្រូវមានកម្ពស់មួយជំហរដែលមិនអាចឱ្យអ្នកបោះឆ្នោតមើលគ្នាឃើញ ។

២.១០៥.១៤.៣ ប្រសិនបើគ្មានគ្រឿងសង្ហារិម នៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន គ.ក.ប ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់ នូវគ្រឿងសង្ហារិមចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោត ដូចជា តុ កៅអី និងសម្ភារដទៃទៀត ដែលអាចសម្រួលដល់ការងារបោះឆ្នោត ។

២.១០៥.១៤.៤ ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមកាម រក្សាសន្តិសុខទីតាំងការិយាល័យបោះឆ្នោត ។ ប្រសិនបើអាចធ្វើបាន ប្រធានត្រូវបិទទ្វារចាក់សោទីតាំងការិយាល័យបោះឆ្នោតនោះផង។

២.១០៥.១៥ ប្រធានរួមជាមួយសមាជិក គ.ក.ប ត្រូវការពារសម្ភារ ឯកសារបោះឆ្នោតឱ្យបានហ្មត់ចត់នៅមុនពេលបោះឆ្នោត។

២.១០៥.១៥.១ សម្ភារ ឯកសារបោះឆ្នោត អាចនឹងត្រូវបានរក្សាទុកនៅផ្ទះរបស់ប្រធាន ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថាមានសុវត្ថិភាព ។

២.១០៥.១៥.២ យ៉ាងហោចណាស់ត្រូវមានសមាជិក គ.ក.ប ៣ (បី) នាក់ គិតទាំងប្រធានផង សម្រាកនៅផ្ទះ ឬទីតាំងដែលរក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព ។

២.១០៥.១៥.៣ ប្រធានត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត ។

២.១០៥.១៦ ប្រធាន គ.ក.ប ត្រូវណាត់ជាមួយសមាជិកដទៃទៀតឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០នាទី (ប្រាំសាមសិបនាទី) ព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោត ទៅកាន់ទីតាំងការិយាល័យបោះឆ្នោត ។

២.១០៥.១៧ សមាជិកទាំងអស់នៃ គ.ក.ប ត្រូវត្រៀមអាហារសម្រាប់រយៈពេល ១ (មួយ) ថ្ងៃ ដើម្បីបរិភោគនៅពេលទំនេរ ដែលពុំមានវត្តមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប ។

**ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

**ប្រការ ២.១០៦.-**

ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ដូចចែងក្នុងផ្នែកទី ៥ ក្រោមប្រការ ២.៧០ នៃ ប.ន.ក នេះ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

២.១០៦.១ ប្រធាន គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យចៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារឧបករណ៍ សម្ភារ ឯកសារទាំងអស់ក្នុងការិយាល័យទាំងនោះ ។

២.១០៦.២ ក្របខ័ណ្ឌនៃការិយាល័យបោះឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយ ដែលបានចែងក្នុងប្រការ ២.៧១ និងក្រោមចំណុច ២.៧១.១ ២.៧១.២ ២.៧១.៣ ២.៧១.៥ ២.៧១.៧ និង ២.៧១.៨ នៃ ប.ន.ក នេះត្រូវតែបានអនុវត្ត ។

២.១០៦.៣ ក្របខ័ណ្ឌនៃការិយាល័យរាប់សន្លឹកឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយ ដែលបានចែងក្នុងប្រការ២.៧១ និងក្រោមចំណុច ២.៧១.១ ២.៧១.២ ២.៧១.៤ ២.៧១.៦ ២.៧១.៧ និង ២.៧១.៨ នៃ ប.ន.ក នេះត្រូវតែបានអនុវត្ត ។

២.១០៦.៤ ហាមដាច់ខាតយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេសពី ប្រធាន គ.ជ.ប ។

**ការប្រព្រឹត្តទៅនៃការបោះឆ្នោត**

**ប្រការ ២.១០៧.-**

គ.ក.ប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត ដោយនាំមកជាមួយនូវសម្ភារឯកសារបោះឆ្នោតឱ្យបានទាន់ពេលនៅវេលាម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក នាថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត ។

២.១០៧.១ បន្ទាប់ពី គ.ក.ប បានចូលដល់ក្នុងការិយាល័យភ្លាម ប្រធាន គ.ក.ប ត្រូវប្រកាសឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យប័ណ្ណសម្គាល់ ឬ/និងសេចក្តីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ រួចប្រាប់ទីកន្លែងដែលបម្រុងទុកសម្រាប់ពួកគាត់ ដូចមានចែងក្នុងចំណុច ២.១០៧.២.៧ ខាងក្រោម ។

២.១០៧.២ ទន្ទឹមពេលអនុវត្តចំណុច ២.១០៧.១ ខាងលើ ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិក ទី២ ឱ្យទៅបំពេញមុខនាទីរបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ព្រមទាំងចាត់ចែងសមាជិកដទៃទៀតឱ្យរៀបចំគ្រឿងសង្ហារិម និងដាក់សម្ភារ ឯកសារសម្រាប់ការបោះឆ្នោត ដូចបានកំណត់ឯកភាពគ្នាលើគំរូប្លង់ការិយាល័យបោះឆ្នោត ដែលបានរៀបចំមុនមួយថ្ងៃ និងដូចបានបញ្ជាក់នៅក្នុងសៀវភៅណែនាំ គ.ក.ប ។

២.១០៧.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូល សម្រាប់ប្រធាន គ.ក.ប ដែលនៅលើនោះ មានសម្ភារ ឯកសារបោះឆ្នោត រួមទាំង ទ.១១២០ សម្រាប់អ្នកសង្កេតការណ៍ចុះហត្ថលេខា និង ទ.១២០២ សម្រាប់បំពេញពាក្យបណ្ដឹង ។

២.១០៧.២.២ តុមួយដាក់នៅប៉ែកខាងស្ដាំដៃ បន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ ដែលមានដាក់បញ្ជីបោះឆ្នោត កញ្ចប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ស្រោមសំបុត្រមានដាក់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ទម្រង់បែបបទ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត ទម្រង់បែបបទផ្សេងទៀត និងតាំប៉ុងពណ៌ក្រហម ។

២.១០៧.២.៣ បន្ទប់សម្ងាត់ទី១ សម្រាប់ការគូសសន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមានប៊ិកចងខ្សែភ្ជាប់ស្រាប់ ត្រូវដាក់តម្កល់នៅលើតុមួយ ក្បែរជញ្ជាំងប្រមាណ ១,៥០ម៉ែត្រពីជញ្ជាំង ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ ។ ផ្ទាំងក្រដាស ១ (មួយ) សន្លឹក សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់ ។ បន្ទប់សម្ងាត់ត្រូវមានពន្លឺគ្រប់គ្រាន់ ។

២.១០៧.២.៤ តុវែងមួយស្ថិតនៅចន្លោះកណ្ដាល ប៉ែកខាងមុខរវាងបន្ទប់សម្ងាត់ទី១ និងទី២ សម្រាប់អនុប្រធាន គ.ក.ប ដែលមានដាក់កញ្ចប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ស្រោមសំបុត្រមានដាក់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត តាំប៉ុងពណ៌ក្រហម និងហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៧.២.៥ បន្ទប់សម្ងាត់ទី ២ សម្រាប់ការគូសសន្លឹកឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវឃ្លាតឆ្ងាយពីតុអនុប្រធាន យ៉ាងតិច ១ (មួយ) ម៉ែត្រ និងត្រូវរៀបចំបំពាក់សម្ភារ ដូចបន្ទប់សម្ងាត់ទី ១ ។

២.១០៧.២.៦ ហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ទឹកខ្មៅលុបមិនជ្រះ និងកំណាត់សម្រាប់ជូតត្រូវដាក់នៅលើតុវែងមួយ ស្ថិតនៅកណ្ដាលបន្ទប់ ទល់មុខនឹងតុរបស់ប្រធាន គ.ក.ប ។

២.១០៧.២.៧ តុ និងកៅអី (ប្រសិនបើមាន) សម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវដាក់នៅអែបជញ្ជាំង ប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន និងនៅខាងក្រោយតុលេខាធិការ ។

២.១០៧.២.៨ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានសម្ភារឯកសារមិនទាន់ប្រើប្រាស់ ត្រូវរក្សាទុកនៅក្បែរតុប្រធាន ។

២.១០៧.៣ នៅពេលអនុវត្តចំណុច ២.១០៧.១ និង ២.១០៧.២ រួចរាល់ ប្រធាន គ.ក.ប ត្រូវពន្យល់ណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដែលពួកគេត្រូវគោរព និងអនុវត្ត ដូចខាងក្រោម ៖

២.១០៧.៣.១ ត្រូវគោរព ច.ប.ក ប.ន.ក ក្រមសីលធម៌សម្រាប់គណបក្សនយោបាយបេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្រមសីលធម៌អ្នកសង្កេតការណ៍ និងក្រមសីលធម៌ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ដែលកំណត់ដោយ គ.ជ.ប ។

២.១០៧.៣.២ ត្រូវតាមដានជាប្រចាំរាល់កិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត បង្ការក្រែងមានភាពមិនប្រក្រតីក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២.១០៧.៣.៣ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

២.១០៧.៣.៤ មិនត្រូវណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ ។

២.១០៧.៣.៥ មិនត្រូវណែនាំ ឬសាកសួរអ្វីដល់អ្នកបោះឆ្នោត ។

២.១០៧.៣.៦ មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

២.១០៧.៣.៧ ត្រូវលើកសំណួរ ឬ/និងសំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប ចំពោះភ្នាក់ងារគណបក្ស ។

២.១០៧.៣.៨ ត្រូវបំពេញវត្តមានអ្នកសង្កេតការណ៍ ក្នុងពេលបោះឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសាមីអង្គការ ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា ។

២.១០៧.៣.៩ ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលតាមទីកន្លែង ដូចបានកំណត់ក្នុងចំណុច ២.១០៧.២.៧ ។

២.១០៧.៤ នៅចន្លោះពីម៉ោង ៦:០០ (ប្រាំមួយ) ដល់ម៉ោង ៦:៣០នាទី (ប្រាំមួយសាមសិប) ព្រឹកនៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតទាំង ២ (ពីរ) ជូនអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត តាមនីតិវិធីដូចខាងក្រោម ៖

២.១០៧.៤.១ ប្រធាន គ.ក.ប ត្រូវពិនិត្យហិបឆ្នោតទាំង ២ (ពីរ) ឡើងវិញ ម្តងមួយៗ ដើម្បីឱ្យប្រាកដថា ត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ ។

២.១០៧.៤.២ ប្រធាន គ.ក.ប ត្រូវបើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោតនីមួយៗ រួចបង្ហាញហិបឆ្នោតដែលទទេ ចំពោះអ្នកដែលមានវត្តមាន ក្នុងការិយាល័យបោះឆ្នោតទាំងអស់ បន្ទាប់មកត្រូវបិទគម្របក្នុង នៃហិបឆ្នោតទាំងនោះវិញ មួលក្តិតគម្របសន្ទះបិទប្រឡោះ សម្រាប់បោះឆ្នោត ហើយខ្ទាស់គន្លឹះបិទគម្របក្នុង រួចចាក់សោឃ្លុំ និងបង្គាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំ ដែលចាក់ភ្ជាប់នឹងគន្លឹះហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១០១ស) ដែលមានពណ៌ និងលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងគន្លឹះហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត នៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១០១ខ) ។

២.១០៧.៤.៣ ប្រធាន គ.ក.ប ត្រូវយកក្រដាសលេខកូដការិយាល័យបោះឆ្នោតពណ៌ចំនួន ១ (មួយ) សន្លឹក និងបោះត្រាការិយាល័យ រួចបិទភ្ជាប់នៅលើជញ្ជាំងខាងមុខនៃហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បន្ទាប់មកត្រូវយកក្រដាសលេខកូដការិយាល័យបោះឆ្នោតពណ៌សចំនួន ១ (មួយ) សន្លឹកទៀត និងបោះត្រាការិយាល័យ ដើម្បីបិទភ្ជាប់នៅលើជញ្ជាំងខាងមុខនៃហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ។ បន្ទាប់ពីរៀបចំរួចរាល់ហើយ ប្រធាន គ.ក.ប ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោតទាំង ២ (ពីរ) នៃការិយាល័យបោះឆ្នោតនោះ ។

២.១០៧.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោង នៃការពិនិត្យហិបឆ្នោត នៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៧.៥ ហិបឆ្នោតដែលបានបិទស្លាកសម្គាល់លេខកូដការិយាល័យ និងចាក់សោឃ្លុំរួចហើយ ដូចមានចែងក្រោមចំណុច ២.១០៧.៤ ខាងលើ ត្រូវអនុវត្តដូចខាងក្រោម ៖

២.១០៧.៥.១ មិនអនុញ្ញាតឱ្យបើកចំហដាច់ខាត លើកលែងតែក្នុងគោលបំណងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់ពីការបោះឆ្នោតបានបញ្ចប់ ។

២.១០៧.៥.២ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែ គ.ជ.ប សម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ក្នុងករណីប្រធានសក្តិ ឬកាលៈទេសៈមានអាសន្ន ។

២.១០៧.៦ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោត ត្រូវបានប្រគល់ទទួលនៅក្រោយម៉ោង ៦:៣០នាទី (ប្រាំមួយសាមសិប) ប៉ុន្តែមិនទាន់ហួសម៉ោង ៧ (ប្រាំពីរ) ព្រឹក នៃថ្ងៃបោះឆ្នោតទេនោះ ប្រធាន គ.ក.ប ត្រូវព្យួរការអនុវត្តនីតិវិធី ដូចមានចែងក្រោមចំណុច ២.១០៧.៧ ខាងក្រោម នៅការិយាល័យបោះឆ្នោតនោះ ជាបណ្តោះអាសន្នសិន រហូតទាល់តែនីតិវិធី ដូចមានចែងក្រោមចំណុច ២.១០៧.៤ ខាងលើ ត្រូវបានបំពេញចប់សព្វគ្រប់ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាអំពីពេលម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗ ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឱ្យបានច្បាស់លាស់ ។

២.១០៧.៧ នៅចន្លោះពីម៉ោង ៦:៣០នាទី (ប្រាំមួយសាមសិប) ដល់ម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក នៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតបានទទួលជាក់ស្តែង ព្រមទាំងត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់ផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ។

២.១០៧.៧.១ អនុប្រធានត្រូវត្រួតពិនិត្យមើលកញ្ចប់សន្លឹកឆ្នោតទាំង ២ (ពីរ) ម្តងមួយកញ្ចប់ៗ ដើម្បីធានាថា សន្លឹកឆ្នោតទាំងនេះ ជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិតប្រាកដមែន។ ក្នុងករណីសន្លឹកឆ្នោត ដែលបានទទួលមិនមែនជាសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គធ.ខប មក គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ ។

២.១០៧.៧.២ បន្ទាប់មកអនុប្រធានត្រូវបើកកញ្ចប់សន្លឹកឆ្នោត រួចរាប់សន្លឹកឆ្នោត ដែលប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសន្លឹកឆ្នោត ដែលប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដែលជាធម្មតាកញ្ចប់នីមួយៗ មានចំនួនសន្លឹកឆ្នោតលើសពីចំនួនអ្នកបោះឆ្នោត ដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ២៥ ដល់ ៧៥ សន្លឹក សម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១០៧.៧.៣ លេខាធិការត្រូវកត់ត្រាចំនួនសន្លឹកឆ្នោត ដែលបានរាប់ឃើញជាក់ស្តែង ព្រមទាំងលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកឆ្នោតចុងក្រោយនៃក្បាលចុងក្រោយ តាមប្រភេទក្រុមប្រឹក្សានីមួយៗ នៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។ ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្តែង មានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ទទួលក្តី ក៏លេខាធិការត្រូវកត់ត្រាចំនួនលើស ឬខ្វះនោះ នៅលើកំណត់ហេតុនៃការបោះឆ្នោតដែរ ។

២.១០៧.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោត ដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះនៅលើកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៧.៧.៥ ប្រធានត្រូវបើកស្រោមសំបុត្រទាំង ២ (ពីរ) ដែលមានត្រា សម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រួចដកយកត្រា ទាំងនោះ មកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញឱ្យអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ បានឃើញច្បាស់ និងចំណាំបានរូបសញ្ញាដូចគ្នា នៃត្រាសម្ងាត់នីមួយៗ ។

២.១០៧.៨ ប្រធាន គ.ក.ប ត្រូវប្រកាសបើកការិយាល័យបោះឆ្នោតនៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបោះឆ្នោត ។ ផ្អែកតាមករណីដូចមានចែងក្នុងចំណុច ២.១០៧.៦ ខាងលើ ប្រធាន គ.ក.ប អាចប្រកាសបើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០ (ប្រាំបី) ព្រឹកឡើយ ។

២.១០៧.៩ សមាជិកទី ២ ត្រូវបន្តចាត់ចែងសណ្ដាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុង ដោយជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ប្រាប់លេខរៀង ឈ្មោះរបស់អ្នកបោះឆ្នោត ចេញក្រដាសលេខរៀងលំដាប់មុនក្រោយ និងណែនាំអ្នកបោះឆ្នោតឱ្យឈរជាជួរបន្តកន្ទុយគ្នា ។

២.១០៧.១០ បន្ទាប់ពីប្រធាន គ.ក.ប ប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ សមាជិកទី ៣ ដែលប្រចាំការនៅត្រង់មាត់ទ្វារ ត្រូវជម្រាបអ្នកបោះឆ្នោតដែលកំពុងឈរជាជួរបន្តកន្ទុយគ្នានៅមុខមាត់ទ្វារចូលការិយាល័យបោះឆ្នោត អំពីការផ្ដល់អាទិភាពក្នុងការចូលបោះឆ្នោត ចំពោះអ្នកបោះឆ្នោតដែលជាជនមានវ័យចំណាស់ ស្ត្រីមានផ្ទៃពោះ អ្នកមានជំងឺ ជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯង និងអ្នកជួយជានីតិជនម្នាក់ដែលគាត់ជ្រើសរើសមកជាមួយ ។ សមាជិកទី ៣ ត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោត មានវត្តមានក្នុងការិយាល័យបោះឆ្នោតតែចំនួន ៤ (បួន)នាក់ប៉ុណ្ណោះ ក្នុងពេលតែមួយ ដោយត្រូវយកចិត្តទុកដាក់ ដូចខាងក្រោម ៖

២.១០៧.១០.១ ត្រូវពិនិត្យមើលអ្នកបោះឆ្នោតមាន អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស សម្រាប់បោះឆ្នោត ឬទេ ?

២.១០៧.១០.២ ត្រូវពិនិត្យមើលម្រាមដៃអ្នកបោះឆ្នោត ដែលពិតជាពុំមានស្នាមទឹកខ្មៅលុបមិនជ្រះមែន ។ ករណីឃើញមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះ ត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប ។

២.១០៧.១០.៣ ត្រូវជម្រាបអ្នកបោះឆ្នោតដែលចូលក្នុងការិយាល័យបោះឆ្នោត ឱ្យដើរតម្រង់ទៅតុលេខាធិការ និងឱ្យបង្ហាញ អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស ។

២.១០៧.១១ នៅពេលអ្នកបោះឆ្នោតចូលមកដល់ លេខាធិការ ត្រូវស្នើសុំឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស ។ ពេលនោះ លេខាធិការត្រូវ ៖

២.១០៧.១១.១ ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថាគ្មានស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ ។

២.១០៧.១១.២ រកឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត បន្ទាប់មកសូរបញ្ជាក់ឈ្មោះ ពិនិត្យផ្ទៀងផ្ទាត់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។

២.១០៧.១១.៣ ដាក់បន្ទាត់តម្រង់តាមបណ្តោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិកបញ្ជាក់ការមកបោះឆ្នោតរបស់អ្នកបោះឆ្នោតក្នុងប្រឡោះទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ ។ បន្ទាប់មកណែនាំអ្នកបោះឆ្នោតឱ្យគូសសញ្ញាធិកនៅចុងឈ្មោះរបស់គាត់ ។

២.១០៧.១១.៤ ហែកសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ១ (មួយ) សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង បត់ជា ៤ (បួន) ផ្នត់ តាមការណែនាំ រួចប្រគល់ជូនអ្នកបោះឆ្នោត ដែលមិនស្ថិតក្នុងស្ថានភាពដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ និង ២.១០៧.១៣ រួមជាមួយឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់ផង ។

២.១០៧.១១.៥ ជម្រាបអ្នកបោះឆ្នោតថា នេះគឺជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមានពណ៌ ។ លោក អ្នកត្រូវចូលទៅក្នុងបន្ទប់សម្ងាត់ទី ១ ប្រើប៊ិកដែលមាននៅទីនោះស្រាប់ ឬប្រើប៊ិកផ្ទាល់ខ្លួន (លើកលែងខ្មៅដៃ) អ្នកត្រូវគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែង នៃគណបក្សនយោបាយណាមួយដែលលោក អ្នកពេញចិត្ត ។ លោក អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់ មុននឹងគូសសញ្ញាគាំទ្រ ដើម្បីបង្ការការខូចសន្លឹកឆ្នោតដោយសារការផ្លាស់ប្តូរចិត្ត បន្ទាប់ពីបានគូសរួច ។

២.១០៧.១១.៦ មុននឹងចេញពីបន្ទប់សម្ងាត់ លោក អ្នកត្រូវបត់សន្លឹកឆ្នោតនេះ តាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលលោកអ្នកបានគូសស្ថិតនៅក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញាត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។

២.១០៧.១១.៧ លោក អ្នកត្រូវយកសន្លឹកឆ្នោតនេះទៅស៊កចូលក្នុងហិបឆ្នោត ដែលស្ថិតនៅលើតុរបស់អនុប្រធាន និងរង់ចាំគាត់ប្រគល់ជូនសន្លឹកឆ្នោត ១ (មួយ) សន្លឹកទៀត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៧.១១.៨ លេខាធិការមិនត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតបន្ទាប់ទេ បើអ្នកបោះឆ្នោតមុន មិនទាន់បានចេញផុតពីបន្ទប់សម្ងាត់ទី១ ។

២.១០៧.១១.៩ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់អះអាងថា គាត់នឹងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយទេ ត្រូវអនុវត្តការផ្ទៀងផ្ទាត់ដូចចំណុច ២.១០៧.១១.២ និង ២.១០៧.១១.៣ ហើយត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប ដើម្បីប្រធានបំពេញព័ត៌មានអំពីបញ្ហានេះទៅក្នុងក្រដាសកត់ត្រាព័ត៌មាន ដែលកំណត់ដោយ គ.ជ.ប ។

២.១០៧.១១.១០ ក្នុងករណីដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ ប្រសិនបើអ្នកបោះឆ្នោតនោះ អះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានីខេត្ត ត្រូវអនុវត្តបន្តតាមចំណុច ២.១០៧.១១.៤ ។

២.១០៧.១១.១១ ក្នុងករណីដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ ប្រសិនបើអ្នកបោះឆ្នោតនោះ អះអាងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ ត្រូវណែនាំគាត់ឱ្យទៅជួបអនុប្រធាន គ.ក.ប ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៧.១២ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ២.១០៧.១១.១ លេខាធិការបានរកឃើញ ថាមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះជាប់នៅនឹងម្រាមដៃអ្នកបោះឆ្នោត ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ត្រូវជូនអ្នកបោះឆ្នោតនោះ ទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ ។

២.១០៧.១២.១ ប្រធានត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះ ពន្យល់អំពីករណីនេះ ។

២.១០៧.១២.២ ប្រសិនបើអ្នកបោះឆ្នោតនោះមិនអាចផ្តល់ការពន្យល់របស់ខ្លួនបានសមហេតុផលអំពីករណីនេះ នោះគាត់នឹងត្រូវបានគេសន្និដ្ឋានថាមានបំណងបោះឆ្នោតលើសពីមួយដង ឬមានចេតនាទុច្ចរិតក្នុងការបោះឆ្នោត ដែលត្រូវមានទោសតាមច្បាប់ ។

២.១០៧.១២.៣ ប្រធានត្រូវដកហូត អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបយ.ស របស់គាត់ជាបណ្តោះអាសន្ន ហើយត្រូវបញ្ជូនករណីនេះទៅ គធ.ខប ដើម្បីចាត់វិធានការបន្ត ។

២.១០៧.១២.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះ នៅក្នុងកំណត់ហេតុនៃការបោះឆ្នោតទាំង ២ (ពីរ) ហើយត្រូវស្រង់ឈ្មោះ និងទិន្នន័យពី អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបយ.ស របស់ជននោះ សម្រាប់ជាការតាមដានបន្ថែមទៀត ។

២.១០៧.១២.៥ ប្រសិនបើអ្នកបោះឆ្នោតរូបនោះមិនយល់ព្រមតាមការអនុវត្តនីតិវិធីនេះ ប្រធាន គ.ក.ប ឬ/និង គធ.ខប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

២.១០៧.១៣ ប្រសិនបើក្នុងពេលអនុវត្តចំណុច ២.១០៧.១១.២ លេខាធិការរកមិនឃើញ ឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ ។

២.១០៧.១៣.១ ប្រធានត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះបានទេ ព្រោះគាត់មិនបានបំពេញគ្រប់ល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងប្រការ ២.៦៧ នៃ ប.ន.ក នេះ។

២.១០៧.១៣.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតនោះ អំពីទីតាំងការិយាល័យបោះឆ្នោតដែលគាត់ត្រូវទៅបោះឆ្នោត ។

២.១០៧.១៣.៣ ប្រធានត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

២.១០៧.១៤ បន្ទាប់ពីអ្នកបោះឆ្នោតបានទទួលសន្លឹកឆ្នោត និងបានអនុវត្តតាមការណែនាំរបស់លេខាធិការ ដូចមានចែងក្នុងចំណុច ២.១០៧.១១.៥ ២.១០៧.១១.៦ និង ២.១០៧.១១.៧ រួចហើយ អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ទី ១ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោត ដែលស្ថិតនៅលើតុរបស់អនុប្រធាន ។

២.១០៧.១៤.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួចដោយដាក់បែរផ្នែកខាងខ្នងដែលមានបោះត្រាសម្ងាត់ ទៅរកអនុប្រធាន គ.ក.ប ហើយស៊កសន្លឹកឆ្នោតនោះ ដោយខ្លួនឯង។ ក្នុងករណីអ្នកបោះឆ្នោតជាជនមានពិការភាពដែលមានអ្នកជួយជានីតិជន ឬបានស្នើសុំជំនួយពីប្រធាន គ.ក.ប នោះ អ្នកជួយជានីតិជន ឬ ប្រធាន គ.ក.ប ជាអ្នកជួយស៊កសន្លឹកឆ្នោតជូសគាត់ ។

២.១០៧.១៤.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោត ដែលបត់រួចបម្រុងនឹងស៊កទៅក្នុងហិបឆ្នោត អនុប្រធាន គ.ក.ប ត្រូវពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការពណ៌ ដែលមានបោះត្រាសម្ងាត់សម្រាប់ការិយាល័យនោះតែ ១ (មួយ) សន្លឹក ត្រូវបានស៊កចូលទៅក្នុងហិបឆ្នោត ដែលស្ថិតនៅលើតុរបស់គាត់ ។

២.១០៧.១៤.៣ ប្រសិនបើអនុប្រធានពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀត ចូលទៅក្នុងហិបឆ្នោត

អនុប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប ។ ក្នុងករណីនេះ ប្រធាន គ.ក.ប ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែកឆេររកសន្លឹកឆ្នោតផ្លូវការ ។

២.១០៧.១៥.៤ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ ដែលត្រូវបានចាប់ភស្តុតាងបានថា មានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពីមួយសន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោសដោយផ្អែកតាម ច.ប.ក ។

២.១០៧.១៥.៥ ប្រធាន គ.ក.ប ត្រូវឃាត់អ្នកបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.១០៧.១៥.៣ និង ២.១០៧.១៥.៤ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតក្លែងក្លាយនោះ និងឆែកឆេររកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រ ដែលមានកាខ្វងថា " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " បន្ទាប់មកត្រូវដកហូត អ.ខ ឬឯកសារបញ្ជាក់អត្តសញ្ញាណរបស់ជននោះជាបណ្ដោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្ដឹងចោទប្រកាន់ជនប្រព្រឹត្តអំពើល្មើសទៅ គធ.ខប ។

២.១០៧.១៥ បន្ទាប់ពីអ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទៅក្នុងហិបឆ្នោតដែលស្ថិតនៅលើតុរបស់អនុប្រធាន គ.ក.ប រួច ឬប្រសិនបើអ្នកបោះឆ្នោតអះអាងថា គាត់មិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងចំណុច ២.១០៧.១១.១១ និងបន្ទាប់ពីប្រធាន គ.ក.ប បានបំពេញក្រដាសព័ត៌មាន ដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ រួចរាល់ អនុប្រធាន គ.ក.ប ត្រូវហែកសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ១ (មួយ) សន្លឹក ចេញពីគល់បញ្ជីសន្លឹកឆ្នោត រួចបោះត្រាសម្ងាត់ នៅលើផ្នែកខាងខ្នង បត់ជា ៤ (បួន) ផ្នត់តាមការកំណត់របស់ គ.ជ.ប និងប្រគល់ទៅឱ្យអ្នកបោះឆ្នោតនោះ ។ អនុប្រធាន គ.ក.ប មិនត្រូវហែកសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ជូនអ្នកបោះឆ្នោតទេ

ប្រសិនបើគាត់អះអាងថាមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដូចមានចែងក្នុងចំណុច ២.១០៧.១១.១០ ដែលត្រូវបានប្រធាន គ.ក.ប កត់ត្រាព័ត៌មាននេះរួចរាល់ ។ អនុប្រធាន គ.ក.ប មិនត្រូវប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោតបន្ទាប់ទេ ប្រសិនបើអ្នកបោះឆ្នោតមុន មិនទាន់បានចេញផុតពីបន្ទប់សម្ងាត់ទី២ ។ នៅពេលប្រគល់សន្លឹកឆ្នោតឱ្យអ្នកបោះឆ្នោត ហើយអនុប្រធានត្រូវណែនាំជាសង្ខេបចំពោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត តាមលំនាំដូចមានចែងក្នុងចំណុច ២.១០៧.១១.៥ ២.១០៧.១១.៦ និង ២.១០៧.១១.៧ ។

២.១០៧.១៦ អ្នកបោះឆ្នោតត្រូវគោរពតាមគោលការណ៍សម្ងាត់ ដូចចែងក្រោមចំណុច ២.១០៧.១៩។ បន្ទាប់ពីបានទទួលសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងបន្ទាប់ពីអនុវត្តតាមការណែនាំរបស់អនុប្រធាន ដូចមានចែងក្នុងចំណុច ២.១០៧.១៥ រួចហើយ អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ទី២ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោតទី២ ។

២.១០៧.១៦.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួចដោយបែរផ្នែកដែលមានបោះត្រាសម្ងាត់ទៅរកសមាជិកទី១ ហើយស៊កសន្លឹកឆ្នោតនោះចូលទៅក្នុងហិបឆ្នោតដោយខ្លួនឯង ។ ក្នុងករណីអ្នកបោះឆ្នោតជាជនមានពិការភាព ដែលមានអ្នកជួយជានីតិជន ឬបានស្នើសុំជំនួយពីប្រធាន គ.ក.ប នោះ អ្នកជួយជានីតិជន ឬ ប្រធាន គ.ក.ប ជាអ្នកជួយស៊កសន្លឹកឆ្នោតជូនគាត់ ។

២.១០៧.១៦.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោតដែលបត់ រួចបម្រុងនឹងស៊កទៅក្នុងហិបឆ្នោត សមាជិកទី១ ត្រូវពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការតែ ១ (មួយ) សន្លឹក ដែលមានបោះត្រាសម្ងាត់ សម្រាប់ការិយាល័យនោះ ត្រូវបានស៊កចូលទៅក្នុងហិបឆ្នោត ។

២.១០៧.១៦.៣ បន្ទាប់មកអ្នកបោះឆ្នោតត្រូវយល់ព្រមឱ្យសមាជិកទី១ ជ្រលក់ម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត (ប្រសិនបើម្រាមចង្អុលដៃស្តាំពិការ) ចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះឱ្យលិចដល់គល់ក្រចកដូចមានចែងក្រោមចំណុច ២.១០៧.១៨ ខាងក្រោម ។

២.១០៧.១៦.៤ ប្រសិនបើសមាជិកទី១ ពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត សមាជិកទី១ ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប ។ ក្នុង

ករណីនេះ ប្រធាន គ.ក.ប ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែករកសន្លឹកឆ្នោតផ្លូវការ ។

២.១០៧.១៦.៥ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ ដែលត្រូវបានចាប់ភស្តុតាងបានថា មានបំណងសិកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពីមួយសន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោសដោយផ្អែកតាម ច.ប.ក ។

២.១០៧.១៦.៦ ប្រធាន គ.ក.ប ត្រូវឃាត់អ្នកបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ២.១០៧.១៦.៤ និង ២.១០៧.១៦.៥ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតក្លែងក្លាយនោះ និងឆែករកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រ ដែលមានកាខ្ទងថា " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " បន្ទាប់មកត្រូវដកហូត អ.ខ ឬឯកសារបញ្ជាក់អត្តសញ្ញាណរបស់ជននោះជាបណ្ដោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្ដឹងចោទប្រកាន់ជនប្រព្រឹត្តអំពើល្មើសទៅ គធ.ខប ។

២.១០៧.១៦.៧ ទោះបីអ្នកបោះឆ្នោតបានអះអាងថា នឹងមិនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ ក៏ដោយ គាត់ត្រូវតែយល់ព្រមឱ្យជំនួយការជ្រលក់ម្រាមដៃរបស់គាត់ចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ ដូចមានចែងក្នុងចំណុច ២.១០៧.១៨.៣ ។

២.១០៧.១៧ នៅពេលទទួលបានសន្លឹកឆ្នោត អ្នកបោះឆ្នោតមិនត្រូវសួរអ្នកណាម្នាក់ ក្នុងការិយាល័យបោះឆ្នោត ឬ/និងធ្វើសកម្មភាពណាមួយដែលរំលោភលើការសម្ងាត់នៃការបោះឆ្នោតឡើយ ។

២.១០៧.១៧.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យដឹងអំពីគណបក្សនយោបាយជាក់លាក់ណាមួយ ដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ ។

២.១០៧.១៧.២ ជាទូទៅអ្នកបោះឆ្នោតមិនអាចស្នើសុំជំនួយពីជនណាម្នាក់ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ឱ្យជួយគាត់ក្នុងការបោះឆ្នោត

ឡើយ លើកលែងតែអ្នកបោះឆ្នោតជាជនមានពិការភាព ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង (ប្រសិនបើមាន) មានសិទ្ធិជ្រើសរើសអ្នកជួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពីប្រធាន គ.ក.ប ។

២.១០៧.១៧.៣ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលស្ថិតក្នុងការិយាល័យបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតស្នើសុំឱ្យជួយក៏ដោយ ។

២.១០៧.១៧.៤ ហាមអ្នកបោះឆ្នោត និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប្រើទូរស័ព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀត ដែលអាចថតរូបបាន ឬ/និងហាមធ្វើសកម្មភាពទាំងឡាយណា ដែលរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ អ្នកសារព័ត៌មានដែលទទួលស្គាល់ដោយ គ.ជ.ប និងបានទទួលការអនុញ្ញាតពីប្រធាន គ.ក.ប អាចថតសកម្មភាពនៅការិយាល័យបោះឆ្នោត ប៉ុន្តែមិនត្រូវរំលោភលើការសម្ងាត់នៃការបោះឆ្នោត ។

២.១០៧.១៨ ទឹកខ្មៅលុបមិនជ្រះដែលអាចមើលឃើញច្បាស់ ត្រូវបានដាក់បញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សម្រាប់បង្ការមិនឱ្យមានការបោះឆ្នោតលើសពីមួយដង ។

២.១០៧.១៨.១ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបមិនជ្រះចំនួន ២ (ពីរ) ដប ។

២.១០៧.១៨.២ ទឹកខ្មៅលុបមិនជ្រះ ១ (មួយ) ដបត្រូវបានបើកគម្របប្រើ នៅពេលចាប់ផ្តើមការបោះឆ្នោត និងបម្រុងទុក ១ (មួយ) ដប សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទីមួយ ។

២.១០៧.១៨.៣ បន្ទាប់ពីអ្នកបោះឆ្នោតបានសិកសន្លឹកឆ្នោតរបស់ខ្លួន ទៅក្នុងហិបឆ្នោត ដូចមានចែងក្នុងចំណុច ២.១០៧.១៤.១ និង ២.១០៧.១៦.១ និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវយល់ព្រមឱ្យសមាជិកទី១ ជ្រលក់ម្រាមចង្អុលដៃស្តាំរបស់គាត់ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ ឱ្យលិចដល់គល់ក្រចក និងរង់ចាំឱ្យស្ងួតបន្តិច ប្រមាណសាមសិប (៣០) វិនាទី ទើបអនុញ្ញាតឱ្យគាត់ចេញពីការិយាល័យបោះឆ្នោត ។

២.១០៧.១៨.៤ ក្នុងករណីម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ៖ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវៈយវៈរបស់គាត់ ត្រូវទទួលយកជាបានការ ។

២.១០៧.១៨.៥ រៀងរាល់សាមសិប (៣០) នាទីម្តង ដបទឹកខ្មៅលុបមិនជ្រះត្រូវតែបានបិទគម្របយ៉ាងជិត ហើយក្រឡុក ។

២.១០៧.១៨.៦ ប្រសិនបើគ្មានវត្តមានអ្នកបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោតមួយរយៈពេលយូរបង្គួរ សមាជិកទី១ ត្រូវបិទគម្របដបទឹកខ្មៅលុបមិនជ្រះ ដើម្បីការពារកុំឱ្យហួត ។

២.១០៧.១៩ គ្មានជនណាម្នាក់អាចចូលទៅជ្រៀតជ្រែកនៅក្នុងការិយាល័យបោះឆ្នោត ឬជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ លើកលែងតែអ្នកបោះឆ្នោតនោះជាជនមានពិការភាព ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយបានស្នើសុំអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពីប្រធាន គ.ក.ប ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

២.១០៧.១៩.១ បន្ទាប់ពីបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជួយជានីតិជនម្នាក់ ដែលអមដំណើរជាមួយដើម្បីជួយគាត់ក្នុងការបោះឆ្នោត ត្រូវអនុវត្តជាបន្តបន្ទាប់តាមនីតិវិធីដូចមានចែងក្រោមចំណុច ២.១០៧.១០ ២.១០៧.១៤ ២.១០៧.១៥ ២.១០៧.១៦ និង ២.១០៧.១៧ ខាងលើ ។

២.១០៧.១៩.២ បន្ទាប់ពីបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនមានពិការភាព ដែលមានបំណងស្នើសុំជំនួយពីប្រធាន គ.ក.ប ត្រូវទៅជួបប្រធានដោយផ្ទាល់ ។ បន្ទាប់មកប្រធាន ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាពនោះ និងអនុវត្តជាបន្តបន្ទាប់តាម

នីតិវិធីដូចមានចែងក្រោមចំណុច ២.១០៧.១០ ២.១០៧.១៤ ២.១០៧.១៥ ២.១០៧.១៦ និង ២.១០៧.១៧ ។ ក្នុងករណីនេះ ប្រធានអាចចាត់សមាជិក គ.ក.ប ណាម្នាក់ឱ្យជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន ។

២.១០៧.១៩.៣ អ្នកបោះឆ្នោតជាជនមានពិការភាព ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ត្រូវសួរនាំ ឬ/និងប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលខ្លួនជ្រើសរើស តែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ ។

២.១០៧.១៩.៤ នៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជួយ ត្រូវសួរអ្នកបោះឆ្នោតនោះថាតើបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយសួរតិចៗធ្វើយ៉ាងណាកុំឱ្យមនុស្សនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ ។ បន្ទាប់មកប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ដែលឆ្លើយតបនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោតជាជនមានពិការភាព បន្ទាប់មកត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្រោមចំណុច ២.១០៧.១៤ ដល់ ២.១០៧.១៦ រួចត្រូវនាំអ្នកបោះឆ្នោតទៅកាន់ហិបឆ្នោត និងជួយស៊កសន្លឹកឆ្នោតរបស់គាត់ តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។

២.១០៧.១៩.៥ ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយ ដែលបានជួយអ្នកបោះឆ្នោតជាជនពិការនោះ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់។

២.១០៧.២០ ក្នុងអំឡុងពេលនៃការបោះឆ្នោត ប្រសិនបើក្នុងការិយាល័យបោះឆ្នោត គ្មានអ្នកបោះឆ្នោតទេនោះ សមាជិកទី១ និងអនុប្រធាន គ.ក.ប ត្រូវមូលភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតជាបណ្ដោះអាសន្ន ហើយត្រូវបើកឡើងវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត ។

២.១០៧.២១ គ្មានជនណាម្នាក់ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត អាចពិនិត្យមើលការគូសសញ្ញាលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតបានឡើយ លើកលែងតែអ្នកដែលជួយអ្នកបោះឆ្នោតជាជនមានពិការភាព ដូចមានចែងក្រោមចំណុច ២.១០៧.១៩ ខាងលើ ។

២.១០៧.២១.១ ជនណាក៏ដោយ ដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ជននោះនឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.ប ។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកធ្លាយការសម្ងាត់នៃការបោះឆ្នោត នឹងត្រូវចាត់ទុកថាជាការរំលោភទៅលើ ច.ប.ក ហើយជនដែលពាក់ព័ន្ធ ត្រូវតែបានបណ្តេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ក ។

២.១០៧.២១.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។

២.១០៧.២២ អ្នកបោះឆ្នោតណាម្នាក់ដែលបានធ្វើឱ្យខូចសន្លឹកឆ្នោត ឬធ្វើឱ្យរហែកដោយអចេតនា ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកទៀតពីប្រធាន គ.ក.ប ។

២.១០៧.២២.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកទៀត ត្រូវបត់សន្លឹកឆ្នោតដែលខូចនោះ តាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូនប្រធាន គ.ក.ប ។

២.១០៧.២២.២ ប្រធានត្រូវស៊កសន្លឹកឆ្នោតដែលខូចនោះ ទៅក្នុងស្រោមសំបុត្រមួយដែលមានកាខ្វងថា " សន្លឹកឆ្នោតខូច " ។

២.១០៧.២២.៣ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្តងហើយ ក្នុងប្រអប់នៅប៉ែកខាងដើមទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត តាមការណែនាំដូចមានចែងក្នុងចំណុច ២.១០៧.១១.៣ ខាងលើ មិនចាំបាច់គូសសញ្ញាសម្គាល់ជាលើកទីពីរឡើយ ប៉ុន្តែត្រូវកត់ចំណាំទុកសម្រាប់សរសេរចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

២.១០៧.២២.៤ ប្រធានត្រូវអនុញ្ញាតលេខាធិការ ឬអនុប្រធានឱ្យផ្តល់សន្លឹកឆ្នោត ១ (មួយ) សន្លឹកទៀត (តាមប្រភេទសន្លឹកឆ្នោត) ជូនអ្នកបោះឆ្នោតតែមួយលើកគត់ និងត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់ សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងត្រូវរំលឹកលេខាធិការ ឬអនុប្រធានឱ្យណែនាំអ្នកបោះឆ្នោត តាមខ្លឹមសារនៃចំណុច ២.១០៧.១១.៥ ខាងលើ ។

២.១០៧.២២.៥ ក្នុងករណីមានអ្នកបោះឆ្នោតមួយចំនួនជាបន្តបន្ទាប់គ្នាសុំសន្លឹកឆ្នោតមួយសន្លឹកផ្សេងទៀត ដូចមានចែងក្នុងចំណុច ២.១០៧.២២ ដែលអាចចាត់ទុកថា ជាភាពមិនប្រក្រតីមួយនោះ ប្រធាន គ.ក.ប អាចសម្រេចមិនផ្តល់សន្លឹកឆ្នោតមួយសន្លឹកផ្សេងទៀត តាមការស្នើសុំ និងឱ្យលេខាធិការ កត់ត្រាបញ្ហានេះចូលក្នុងកំណត់ហេតុនៃការបោះឆ្នោតទាំងពីរប្រភេទ ។

២.១០៧.២៣ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់ជំទាស់ ឬតវ៉ានឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬភាពមិនប្រក្រតីនៃការបោះឆ្នោត ឬ/និងសេចក្តីសម្រេចណាមួយរបស់ គ.ក.ប ភ្នាក់ងារនោះត្រូវលើកការជំទាស់ ឬតវ៉ានោះដោយផ្ទាល់ទៅប្រធាន គ.ក.ប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាង ដែលនាំឱ្យជឿថា មានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ក ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

២.១០៧.២៣.១ ប្រសិនបើយល់ឃើញថា សមហេតុសមផល ប្រធានត្រូវបញ្ឈប់ជាបណ្តោះអាសន្ន នូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់ ឬតវ៉ារបស់ភ្នាក់ងារគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គ.ក.ប ដទៃទៀត ។

២.១០៧.២៣.២ បន្ទាប់ពីបានពិនិត្យឡើងវិញអំពីករណី ដែលបានលើកការជំទាស់ ឬតវ៉ា ប្រសិនបើប្រធាន គ.ក.ប យល់ព្រមតាមការជំទាស់ ឬតវ៉ា ប្រធានត្រូវណែនាំ និងរំលឹកដល់សមាជិក គ.ក.ប និងអ្នកមានវត្តមានផ្សេងទៀតក្នុងការិយាល័យបោះឆ្នោត អំពីខ្លឹមសារពាក់ព័ន្ធដែលចែងក្នុង ច.ប.ក ប.ន.ក ហើយត្រូវរិះរកវិធីណាមួយ ដើម្បីដោះស្រាយភាពមិនប្រក្រតីនោះ ។

២.១០៧.២៣.៣ ប្រសិនបើប្រធាន គ.ក.ប បដិសេធការជំទាស់ ឬតវ៉ា គាត់ត្រូវផ្តល់ហេតុផលសមស្រប ពាក់ព័ន្ធនឹងការបដិសេធនោះ ។

២.១០៧.២៣.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា ប្រធាន គ.ក.ប ត្រូវកត់ត្រាការជំទាស់ ឬតវ៉ានេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោតទាំងពីរប្រភេទ ដោយឱ្យអ្នកជំទាស់ ឬតវ៉ានោះ ចុះហត្ថលេខាលើកំណត់ហេតុទាំងនេះ ។

២.១០៧.២៣.៥ ប្រសិនបើភ្នាក់ងារនោះមិនយល់ព្រមចុះហត្ថលេខា ករណីនៃការជំទាស់ ឬតវ៉ានេះ មិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោតឡើយ ។

២.១០៧.២៣.៦ សេចក្តីសម្រេចរបស់ប្រធាន គ.ក.ប ជាការសម្រេចក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត ។

២.១០៧.២៣.៧ ចំណុច ២.១០៧.២៣.៦ ខាងលើ មិនបានច្រានចោលនូវការណ៍ដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងជំទាស់ ឬតវ៉ាទៅ គធ.ខប អំពីករណីដែលគាត់បានលើកការជំទាស់ ឬតវ៉ាក្នុងការិយាល័យបោះឆ្នោតនោះទេ ប៉ុន្តែក្នុងស្ថានភាពនេះ គាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.ប ដោយមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

២.១០៧.២៣.៨ ប្រធានត្រូវផ្តល់ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹង ប្រសិនបើភ្នាក់ងារគណបក្សនយោបាយស្នើសុំសម្រាប់ប្តឹងបន្តទៅ គធ.ខប ។

២.១០៧.២៤ ប្រសិនបើអ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់កំពុងស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យបោះឆ្នោតក្តី ប្រធានត្រូវណែនាំឱ្យគាត់រក្សារបៀបរៀបរយ ។ ក្នុងករណីអ្នកបោះឆ្នោតនោះមិនគោរពតាមការណែនាំ ប្រធាន គ.ក.ប ត្រូវស្នើកម្លាំងសន្តិសុខឱ្យបណ្តេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

២.១០៧.២៥ ប្រធាន គ.ក.ប អាចស្នើសុំឱ្យកងកម្លាំងសន្តិសុខរៀបចំសាឡើងវិញនូវរបៀបរៀបរយខាងក្នុង និងខាងក្រៅការិយាល័យបោះឆ្នោត ប្រសិនបើកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិត ដែលធ្វើឱ្យអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី ។ ការរំខានដល់អ្នកបោះឆ្នោត ឬដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោត គឺជាសកម្មភាពទាំងឡាយណាដែលកើតមាននៅខាងក្នុង ឬបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ដូចខាងក្រោមនេះ ៖

២.១០៧.២៥.១ ការបញ្ចេញសម្រែកខ្លាំងៗ ឬការបញ្ចេញសម្ដីគំរាមកំហែង ឬជេរប្រមាថមាក់ងាយ ។

២.១០៧.២៥.២ ការធ្វើសកម្មភាពរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ។

២.១០៧.២៥.៣ ការរុញច្រានដោយប្រើកម្លាំងធ្ងន់ ។

២.១០៧.២៥.៤ ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត ។

២.១០៧.២៥.៥ ការអុកឡុកដោយបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត ។

២.១០៧.២៥.៦ ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ ។

២.១០៧.២៥.៧ ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗ ប្រកបដោយគ្រោះថ្នាក់ ។

២.១០៧.២៦ ប្រសិនបើការបោះឆ្នោតឈានដល់ម៉ោង ១៥:០០ (ដប់ប្រាំ) រសៀលនៃថ្ងៃបោះឆ្នោត ដែលជាពេលវេលាកំណត់ សម្រាប់បញ្ចប់ការបោះឆ្នោត ប៉ុន្តែនៅតែមានអ្នកបោះឆ្នោតកំពុងស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតទាំងអស់នោះ ត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ។

២.១០៧.២៦.១ ក្នុងករណីនេះសមាជិកទី២ ត្រូវប្រកាសប្រាប់អ្នកបោះឆ្នោតដែលមានវត្តមាននៅក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោត និងត្រូវប្រមូលយក អ.ខ ឬ ឯ.អ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបយ.ស ពីអ្នកបោះឆ្នោតដែលនៅក្នុងជួរ ដោយចាប់ផ្ដើមពីអ្នកបោះឆ្នោតដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ឱ្យសមាជិកទី៣ ។

២.១០៧.២៦.២ សមាជិកទី៣ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្ដងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតតាមលំដាប់លំដោយរហូតដល់អស់អ្នកបោះឆ្នោត ។

២.១០៧.២៦.៣ អ្នកបោះឆ្នោត ដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយនាម៉ោង ១៥:០០ (ដប់ប្រាំ) រសៀលនៃថ្ងៃបោះឆ្នោតទេ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

២.១០៧.២៧ ប្រសិនបើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួន នៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល នៃថ្ងៃបោះឆ្នោតបានឡើយ ។

២.១០៧.២៨ ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គ.ក.ប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួន នៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល ។

## ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត

### ប្រការ ២.១០៨.-

នៅពេលដែលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យ ប្រធានត្រូវចាត់ឱ្យសមាជិកទី២ ចាត់វិធានការចាំបាច់ ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោត កុំឱ្យអ្នកគ្មានភារកិច្ចចេញចូល ។ ប្រធាន គ.ក.ប ត្រូវប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មកត្រូវចាត់ចែងការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការបោះឆ្នោត ។

២.១០៨.១ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់ចែងតាមនីតិវិធីដើម្បីធានាសុវត្ថិភាពហិបឆ្នោតនីមួយៗ ដែលក្នុងនោះ ៖

២.១០៨.១.១ ប្រធានត្រូវបិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងហិបឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ព្រមទាំងបិទពាសក្រដាសស្តើងមួយសន្លឹកដែលមានចុះហត្ថលេខារបស់ប្រធាន គ.ក.ប និងភ្នាក់ងារគណបក្សនយោបាយ (ប្រសិនបើគាត់យល់ព្រម) ពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោតនីមួយៗនោះផង ។

២.១០៨.១.២ ប្រធានត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោតនីមួយៗ និងចាក់សោឃ្លុំមានលេខ នៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោតទាំងនោះ រួចត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំងនោះ ។

២.១០៨.១.៣ លេខាធិការត្រូវកត់ត្រាបន្ថែមនូវលក្ខណៈសម្គាល់ និងលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងក្រវិលហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១០១ស) លក្ខណៈសម្គាល់ និងលេខសោឃ្លុំដែលចាក់ភ្ជាប់នឹងក្រវិលហិបឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងកំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១០១ខ) និងពេលវេលានៃការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

២.១០៨.១.៤ ប្រធានត្រូវចាត់វិធានការការពារហិបឆ្នោត ដែលមានសន្លឹកឆ្នោតខាងក្នុង សម្រាប់ការរាប់សន្លឹកឆ្នោតនៅនឹងកន្លែងការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចឱ្យធ្វើដូច្នេះដោយ គ.ជ.ប ។

២.១០៨.១.៥ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតអាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោត ក្រោយពីការប្រកាសបិទការបោះឆ្នោតដោយសុំការអនុញ្ញាតពីប្រធាន គ.ក.ប ។

២.១០៨.២ បន្ទាប់មកស្ថិតនៅចំពោះមុខវត្តមាន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គ.ក.ប ត្រូវចាត់ចែងឱ្យសមាជិក គ.ក.ប ធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូចពេលបោះឆ្នោត (ប្រសិនបើមាន) ដែលក្នុងនោះ ៖

២.១០៨.២.១ លេខាធិការត្រូវរាប់ចំនួនគំនូសសញ្ញាក្នុងកូនប្រអប់ផ្នែកខាងដើមនៅក្នុងបញ្ជីបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.១០៧.១១.៣ ខាងលើ និងចំនួនអ្នកអះអាងមិនបោះឆ្នោតក្នុងក្រដាសព័ត៌មានដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ បន្ទាប់មកត្រូវរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ។

២.១០៨.២.២ អនុប្រធានត្រូវកត់សម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើ ម្តងមួយៗតាមប្រភេទក្រុមប្រឹក្សា រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូចដោយឡែកពីគ្នា ។ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបាន

ទទួលជាក់ស្តែង ដូចមានបញ្ជាក់ក្នុងចំណុច ២.១០៧.៧.៣ ខាងលើ ដកផលបូកចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដូចមានបញ្ជាក់ក្នុងចំណុច ២.១០៨.២.១ ខាងលើ ឬស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដូចមានបញ្ជាក់ក្នុងចំណុច ២.១០៨.២.១ ដកនឹងចំនួនអ្នកបោះឆ្នោត ដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនស្មើគ្នានេះក្នុង ទ.១១០១ស ឬ/និង ទ.១១០១ខ ។

២.១០៨.២.៣ ប្រសិនបើក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា នៅមានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត លេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរនូវចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោត និងចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ ហើយអនុប្រធានក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញដែរ នូវចំនួនសន្លឹកឆ្នោតដែលបានប្រើ ( រាប់ចំនួនសន្លឹកគល់បញ្ជីនៃសន្លឹកឆ្នោតដែលបានប្រើ ) សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូច ។ ប្រសិនបើភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនដែលខុសគ្នានោះក្នុង ទ.១១០១ស ឬ/និង ទ.១១០១ខ ហើយប្រធាន គ.ក.ប ត្រូវបន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត ។

២.១០៨.២.៤ លេខាធិការត្រូវកត់ត្រាចំនួនអ្នកបោះឆ្នោតដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយទៅក្នុង ទ.១១០១ស ឬ ទ.១១០១ខ ដោយស្រង់ចេញពីក្រដាសព័ត៌មាន ដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ ។

២.១០៨.២.៥ សមាជិកទី២ ត្រូវចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើទាំងអស់ ដោយប្រដាប់ចោះ ឬកន្ត្រៃ ដើម្បីធ្វើមោយភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ ។

២.១០៨.២.៦ អនុប្រធានត្រូវដាក់សន្លឹកឆ្នោតមោយភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ តាមប្រភេទក្រុមប្រឹក្សានីមួយៗទៅក្នុងស្បោងប្លាស្ទិកតែមួយដាច់ដោយឡែកពីគ្នា រួចបិទឱ្យជិត ។

២.១០៨.៣ ប្រធាន គ.ក.ប ត្រូវធានាថា លេខាធិការបានកត់ត្រាជាមុននូវលេខសោឃ្លុំ ដែលនឹងត្រូវប្រើសម្រាប់ចាក់ឃ្លុំមាត់ស្បោង " ខ " ដូចមានចែងក្នុងចំណុច ២.១១២.៩ ខាងក្រោម ទ.១១០១ស និង ទ.១១០១ខ និងត្រូវបោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុទាំងនេះ ។ ទ.១១០១ស និង ទ.១១០១ខ ចំនួន ៣ (បី) ច្បាប់ តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលលេខាធិការបានបំពេញរួច ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងប្រធានផ្ទាល់ ព្រមទាំងមានបោះត្រាការិយាល័យផង ។

២.១០៨.៣.១ ប្រធានត្រូវដាក់បង្ហាញកំណត់ហេតុ ដូចមានចែងក្នុងចំណុច ២.១០៨.៣ ខាងលើ ឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។

២.១០៨.៣.២ ភ្នាក់ងារគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះបាន ។

២.១០៨.៣.៣ ការមិនចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនៃការបោះឆ្នោត ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ ។

២.១០៨.៤ ប្រធាន គ.ក.ប ត្រូវរៀបចំទុកដាក់ ទ.១១០១ស និង ទ.១១០១ខ ដោយឡែកពីគ្នាតាមប្រភេទក្រុមប្រឹក្សានីមួយៗ ដូចមានចែងក្រោមចំណុច ២.១០៨.៣ ខាងលើ តាមការកំណត់ដូចខាងក្រោម ៖

២.១០៨.៤.១ ដាក់ ទ.១១០១ស ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១០១ស) " ផ្ញើជូន គ.ជ.ប ។

២.១០៨.៤.២ ដាក់ ទ.១១០១ខ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១០១ខ)" ផ្ញើជូន គ.ជ.ប ។

២.១០៨.៤.៣ ដាក់ ទ.១១០១ស ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១០១ស) " ផ្ញើជូន គធ.ខប ។

២.១០៨.៤.៤ ដាក់ ទ.១១០១ខ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ទង់ថា " កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១០១ខ) " ផ្ញើជូន គធ.ខប ។

២.១០៨.៥ បន្ទាប់មកប្រធាន គ.ក.ប ត្រូវរៀបចំដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់បញ្ចូលទៅក្នុងកញ្ចប់សុវត្ថិភាព " កស " ឬ " កខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលមានបោះពុម្ពសម្គាល់ថា " កំណត់ហេតុនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតលេខ..." ។

២.១០៨.៦ សម្ភារ ឯកសារបោះឆ្នោត ដែលត្រូវបញ្ចូលទៅក្នុងកញ្ចប់សុវត្ថិភាព " កស " រួមមាន ៖

២.១០៨.៦.១ ស្រោមសំបុត្រមានដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.១០៨.៤.១ ។

២.១០៨.៦.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោត ដែលបានប្រើក្នុងពេលបោះឆ្នោត និងក្រដាសព័ត៌មាន ដូចចែងក្នុងចំណុច ២.១០៧.១១.៩ ។

២.១០៨.៦.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ប្រសិនបើមាន) ។

២.១០៨.៦.៤ ស្បោងប្លាស្ទិកដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៨.៦.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១០៨.៦.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " (ប្រសិនបើមាន) ។

២.១០៨.៦.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត (ប្រសិនបើមាន) ។

២.១០៨.៧ សម្ភារ ឯកសារបោះឆ្នោត ដែលត្រូវដាក់បញ្ចូលទៅក្នុងកញ្ចប់សុវត្ថិភាព " កខ " រួមមាន ៖

២.១០៨.៧.១ ស្រោមសំបុត្រមានដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.១០៨.៤.២ ។

២.១០៨.៧.២ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " នៃក្រុមប្រឹក្សារាជធានី ខេត្ត។

២.១០៨.៧.៣ ស្បោងប្លាស្ទិកដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១០៨.៧.៤ ស្រោមសំបុត្រដាក់ត្រាសម្ងាត់ សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត។

២.១០៨.៧.៥ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " (ប្រសិនបើមាន) ។

២.១០៨.៧.៦ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត (ប្រសិនបើមាន) ។

២.១០៨.៨ ប្រធាន គ.ក.ប ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ថា រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារ ដូចមានចែងក្រោមចំណុច ២.១០៨.៦ និង ២.១០៨.៧ ខាងលើ ត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " ។ ប្រធាន គ.ក.ប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " នីមួយៗ មិនទាន់ត្រូវបានបិទភ្ជិតនៅពេលនេះនៅឡើយ ហើយនឹងត្រូវបានបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់ លុះណាតែ គ.ក.រ បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងបានដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធរួចរាល់សិន ។

២.១០៨.៨.១ ប្រធាន គ.ក.ប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " នីមួយៗ ដែលដាក់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារ ដូចមានចែងក្រោមចំណុច ២.១០៨.៨ ខាងលើ ត្រូវបានបំពេញលេខកូដការិយាល័យយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ ។

២.១០៨.៨.២ ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិកឱ្យរៀបចំទុកដាក់សម្ភារ ឯកសារដែលនៅសល់បញ្ចូលទៅក្នុងកេសស័ង្កសី និងវេចខ្ចប់ដបទឹកខ្មៅលុបលាងមិនជ្រះដោយឡែក ។ ទន្ទឹមនឹងនេះត្រូវរុះរើបន្ទប់សម្ងាត់ទាំង ២ (ពីរ) រួចច្រកចូលទៅក្នុងការុង ឬកេស តាមលំនាំដូចពេលបានទទួល ។

**ប្រការ ២.១០៩.-**

មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួន ស្ថិតក្នុងករណីកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាព មន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ឬ/និង ក្នុងបរិវេណខាងក្នុង នៃការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត នោះ ឬទាំងនោះបាន។ នីតិវិធីចាប់ពីប្រការ ២.១៣០ ដល់ប្រការ ២.១៣៤ ខាងក្រោម នៃ ប.ន.ក នេះ ត្រូវតែបានអនុវត្តចំពោះការបិទការិយាល័យ និងការសម្រេចមិនបើកការិយាល័យបោះឆ្នោតក្នុងកាលៈទេសៈមានអាសន្ន ។

# ផ្នែកទី ៨
# ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោត

## ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

**ប្រការ ២.១១០.-**

អនុលោមតាម ច.ប.ក ការរាប់សន្លឹកឆ្នោតត្រូវធ្វើដោយផ្ទាល់នៅការិយាល័យបោះឆ្នោតនីមួយៗ ដែលមានទីតាំងនៅទីប្រជុំជនក្រុង ស្រុក ខណ្ឌ នៅពេលបន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច លើកលែងតែការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារកាលៈទេសៈមានអាសន្ន ហើយដែល គ.ជ.ប បានសម្រេចឱ្យ គធ.ខប ចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យនោះនៅលេខាធិការដ្ឋាននៃ គធ.ខប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព ។

២.១១០.១ ក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតនោះនឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គ.ក.ប ក្លាយជា គ.ក.រ។ ក្នុងករណីនេះប្រធាន គ.ក.ប ដែលក្លាយជាប្រធាន គ.ក.រ ត្រូវចាត់វិធានការ ដោយអនុវត្តតាមចំណុច ២.១០៦.១ និង ២.១០៦.៣ នៃប្រការ ២.១០៦ ខាងលើ ហើយត្រូវចាត់ចែងឱ្យរៀបចំឡើងវិញ គំរូប្លង់បន្ទប់សម្រាប់ការរាប់សន្លឹកឆ្នោត ដែលក្នុងនោះត្រូវ ៖

២.១១០.១.១ រៀបចំតុធំមួយ ឬតុតូចច្រើនផ្គុំគ្នា និងកៅអីបួនសម្រាប់សមាជិក គ.ក.រ ដោយដាក់នៅចំកណ្ដាលបន្ទប់ ដើម្បីអាចឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដើរចុះឡើងជុំវិញតុក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត ។

២.១១០.១.២ លើកហិបឆ្នោតទាំង ២ (ពីរ) ដាក់នៅចំកណ្ដាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព " ក " ដូចបានបញ្ជាក់ក្នុងចំណុច ២.១០៨.៨ និងរាល់សម្ភារ ឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដាក់នៅលើតុ ត្រង់កន្លែងប្រធានអង្គុយ ។

២.១១០.១.៣ ចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យការពារមាត់ទ្វារ បង្អួច ដែលបើកចំហ កុំឱ្យមានអ្នកចេញចូល មើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោត ដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្ដាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

២.១១០.២ ប្រធាន គ.ក.រ ត្រូវចាត់ចែងអនុវត្តការរាប់សន្លឹកឆ្នោតដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដោយចាប់ផ្តើមពីការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌជាមុន បន្ទាប់មកទើបអនុវត្តការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តជាក្រោយ ។ កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ត្រូវធ្វើនៅតែមួយកន្លែងសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោតមួយ ហើយប្រសិនបើចាប់ផ្តើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយពុំត្រូវឈប់សម្រាកឡើយ ។ ប្រធាន គ.ក.រ ត្រូវចាត់ចែងត្រៀមឱ្យមានភ្លើងបំភ្លឺនៅការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការករណីការរាប់សន្លឹកឆ្នោត ត្រូវអូសបន្លាយដល់ពេលយប់ ។

២.១១០.២.១ ក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិត ល្មមដែលអាចសង្កេតមើលឃើញសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត ។

២.១១០.២.២ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាតចូលរួមសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោត នៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន (ទ.១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត ។

២.១១០.២.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចផ្លាស់ប្តូរភ្នាក់ងារបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យបានចប់ចុងចប់ដើម ។

២.១១០.២.៤ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចថតយករូបភាពនៅការិយាល័យរាប់សន្លឹកឆ្នោតបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ ។

២.១១០.៣ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខខ្លួន ហើយអនុប្រធាន និងសមាជិកទី១ ត្រូវអង្គុយនៅអមសងខាងតុទល់មុខគ្នា ។

២.១១០.៤ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងបន្ទប់រាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវប្រកាសចាប់ផ្តើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដោយចាប់ផ្តើមពីការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយត្រូវ ៖

២.១១០.៤.១ បម្រុងទុកនៅក្បែរខ្លួននូវ ៖

- កញ្ចប់សុវត្ថិភាព " កស " ដែលមានស្បោងប្លាស្ទិក ឬ/និងស្រោមសំបុត្រដាក់កំណត់ហេតុ នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសម្ភារឯកសារបោះឆ្នោតផ្សេងទៀត ។
- ទ.១២០២ សម្រាប់ផ្តល់ជូនភ្នាក់ងារគណបក្សនយោបាយបំពេញពាក្យបណ្តឹង ប្រសិនបើគាត់ស្នើសុំ ។
- ស្បោងប្លាស្ទិកថ្លាសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ។
- កៅស៊ូកង ។

២.១១០.៤.២ ប្រគល់ឱ្យអនុប្រធាន គ.ក.រ នូវតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) ១ (មួយ) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១១០.៤.៣ ប្រគល់ទៅលេខាធិការនូវ ទ.១១០២ស សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង ទ.១១០៨ស ១ (មួយ) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១ស) ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព " កស " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១១០.៤.៤ ប្រគល់ឱ្យសមាជិកទី១ នូវប៊ិកហ្វឺតធំ ១ (មួយ) ដើម និងផ្ទាំងក្រដាសធំ ១ (មួយ) ផ្ទាំង សម្រាប់កត់ត្រាសំឡេងឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១១០.៤.៥ ចាត់លេខាធិការឱ្យចាប់ផ្តើមបំពេញ ទ.១១០២ស ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួល សន្លឹកឆ្នោតដែលមិនបានប្រើ សន្លឹកឆ្នោតខូចពេលបោះឆ្នោត និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែលតួលេខទាំងនេះត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួចហើយ ដូចមានចែងក្រោមចំណុច ២.១១៦.២ ខាងលើ និងដែលមានកត់ត្រានៅក្នុង ទ.១១០១ស ។

២.១១០.៥ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ ប្រធាន គ.ក.រ ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំមានលេខដែលចាក់ជាប់នឹងគម្របខាងក្រៅនៃហិបឆ្នោតក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ស្ថិតក្នុងស្ថានភាពដើម រួចកាត់ផ្ដាច់សោឃ្លុំទាំងនេះ ដោយកន្ត្រៃ ឬកាំបិត ដែលអាចរកបានដោយខ្លួនឯង និងបើកគម្របខាងក្រៅចេញ ។ បន្ទាប់មកប្រធាន គ.ក.រ ត្រូវបន្តត្រួតពិនិត្យផ្ទៀងផ្ទាត់លេខសោឃ្លុំ ដែលចាក់ជាប់នឹងគន្លឹះខ្ទាស់គម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្ដើងដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថាគ្មានការរុះរើ រួចកាត់ផ្ដាច់សោឃ្លុំ និងហែកក្រដាសនេះចោល។ ចុងក្រោយ ប្រធានត្រូវបើកគម្របខាងក្នុងនៃហិបឆ្នោតពាក់ព័ន្ធ និងចាក់សន្លឹកឆ្នោតឱ្យអស់ពីហិបឆ្នោតដាក់នៅលើតុ ត្រង់ចន្លោះអនុប្រធាន និងសមាជិកទី១ ហើយដាក់ហិបឆ្នោតទទេនៅក្បែរគាត់ ។

២.១១០.៥.១ សមាជិកទី១ ត្រូវរើសយកវត្ថុមិនមែនជាសន្លឹកឆ្នោត ដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត (ប្រសិនបើមាន) ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ទៅក្នុងស្រោមសំបុត្រមួយបម្រុងស្រាប់ ។

២.១១០.៥.២ លេខាធិការត្រូវកត់ត្រាករណីដូចចែងក្នុងចំណុច ២.១១០.៥.១ ខាងលើ (ប្រសិនបើមាន) ក្នុង ទ.១១០២ស ។

២.១១០.៦ ប្រធាន គ.ក.រ ត្រូវបង្គាប់ឱ្យអនុប្រធាន និងសមាជិកទី១ លា និងតម្រៀបសន្លឹកឆ្នោតដែលទើបបានចាក់ចេញពីហិបឆ្នោត ដោយដាក់ផ្កាប់ចុះក្រោម និងដាក់សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង មួយបាច់មាន ២៥ (ម្ភៃប្រាំ) សន្លឹក នៅពំនូកទី១ ហើយដាក់សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) នៅពំនូកទី២ ។ បន្ទាប់មកអនុប្រធាន និងសមាជិកទី១ ត្រូវរាប់សន្លឹកឆ្នោតទាំងពីរពំនូកនេះ រួចរាយការណ៍ជូនប្រធានអំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ។ ប្រធាន គ.ក.រ ត្រូវធានាថា នីតិវិធីមួយចំនួន ដូចខាងក្រោមត្រូវតែបានអនុវត្ត ៖

២.១១០.៦.១ ក្នុងករណីចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ មានចំនួនសរុបស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬស្មើនឹងចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្ដែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននេះក្នុង ទ.១១០២ស ។

២.១១០.៦.២ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ មានចំនួនតិចជាង ឬច្រើនជាងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬមានចំនួនតិចជាង ឬច្រើនជាងផលសងរវាងចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើនោះ ប្រធាន គ.ក.រ ត្រូវរាប់សន្លឹកឆ្នោតដូចមានបញ្ជាក់ក្នុងចំណុច ២.១១០.៦ ខាងលើ ជាលើកទីពីរ ។

២.១១០.៦.៣ ប្រសិនបើបន្ទាប់ពីប្រធាន គ.ក.រ បានរាប់ឡើងវិញហើយ ប៉ុន្តែតួលេខនៃចំនួនសន្លឹកឆ្នោតនៅតែមានភាពខុសគ្នាដដែល ដូចមានបញ្ជាក់ក្នុងចំណុច ២.១១០.៦.២ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នានេះក្នុង ទ.១១០២ស ។

២.១១០.៦.៤ ប្រធាន គ.ក.រ ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោតដូចមានបញ្ជាក់ក្នុងចំណុច ២.១១០.៦.១ ឬ ២.១១០.៦.២ ឬ/និង ២.១១០.៦.៣ ខាងលើ ដើម្បីឱ្យអ្នកទាំងនោះ អាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនេះបាន ។

២.១១០.៦.៥ អនុប្រធានត្រូវប្រគល់សន្លឹកឆ្នោតពំនូកទី ២ ដែលគ្មានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) ជូនប្រធាន គ.ក.រ ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់ ។

២.១១០.៦.៦ អនុប្រធានត្រូវប្រគល់សន្លឹកឆ្នោតពំនូកទី ១ ដែលខ្ទាស់ជាបាច់ក្នុងមួយបាច់ ២៥ (ម្ភៃប្រាំ) សន្លឹក ជូនប្រធាន គ.ក.រ ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់ ។

២.១១០.៧ បន្ទាប់ពីការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតបានបញ្ចប់ ប្រធាន គ.ក.រ ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ជាដំបូងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ហើយបន្ទាប់មក ត្រូវប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។ ប្រធាន គ.ក.រ ត្រូវធានាថាកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ត្រូវបានអនុវត្តតាមលំដាប់លំដោយ ដូចខាងក្រោម ៖

២.១១០.៧.១ ផ្អែកតាមការកំណត់ ដូចមានចែងក្រោមប្រការ ២.១១៩ ខាងក្រោម ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតម្តង ១ (មួយ) សន្លឹកៗ ពីពំនូកទី១

មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោត ដែលបានកំណត់ហើយនោះ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បានមើលឃើញច្បាស់ ។

២.១១០.៧.២ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតណាមួយ ជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវប្រកាសថា " សន្លឹកឆ្នោតមិនបានការ " រួចដាក់សន្លឹកឆ្នោតនោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ដែលស្ថិតនៅខាងស្តាំដៃគាត់ ។

២.១១០.៧.៣ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតណាមួយ ជាសន្លឹកឆ្នោតបានការ គាត់ត្រូវប្រកាសឱ្យឮៗ នូវឈ្មោះគណបក្សនយោបាយ ដែលសន្លឹកឆ្នោតនោះត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ហើយត្រូវដាក់សន្លឹកឆ្នោតនោះ ទៅតាមពំនូកដោយឡែក សម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ ។

២.១១០.៧.៤ ផ្អែកតាមការប្រកាសរបស់ប្រធាន គ.ក.រ អនុប្រធាន និង លេខាធិការត្រូវគូសពិន្ទុ ១ (មួយ) សម្រាប់សន្លឹកឆ្នោត ១ (មួយ) សន្លឹក ដែលគណបក្សនយោបាយណាមួយត្រូវបានទទួល តាមការណែនាំរបស់ គ.ជ.ប នៅលើ ទ.១១០៨ស ។ ទន្ទឹមនឹងនេះសមាជិកទី១ ត្រូវប្រើប៊ិកហ្វឺតគូសពិន្ទុ ១ (មួយ) នៅលើផ្ទាំងក្រដាសធំ ដែលបិទភ្ជាប់នឹងជញ្ជាំង ឬនៅលើក្តារខៀន ។

២.១១០.៧.៥ ក្នុងករណីមានការជំទាស់ចំពោះសន្លឹកឆ្នោត ដែលបានកំណត់ដូចមានចែងក្នុងចំណុច ២.១១០.៧.៣ ខាងលើ ប្រធានត្រូវដាក់សន្លឹកឆ្នោតដែលមានការជំទាស់នោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ដូចមានចែងក្នុងចំណុច ២.១១០.៧.២ ខាងលើ ។ សន្លឹកឆ្នោតទាំងនេះនឹងត្រូវយកមកពិនិត្យផ្ទៀងផ្ទាត់ និងកំណត់ម្តងទៀតជាចុងក្រោយ ដោយអនុវត្តតាមចំណុច ២.១១០.៧.៦ ខាងក្រោម ។

២.១១០.៧.៦ នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតពីពំនូកទី១ ប្រធានត្រូវបន្តយកសន្លឹកឆ្នោតម្តង ១ (មួយ) សន្លឹកៗ ពីពំនូកសន្លឹកឆ្នោតមិនបានការ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្តងទៀតជាចុងក្រោយ ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតបានការ ឬមិនបានការ ។

២.១១០.៧.៧ ប្រសិនបើប្រធាន គ.ក.រ សម្រេចថា ជាសន្លឹកឆ្នោតបានការវិញ ត្រូវអនុវត្តចំណុច ២.១១០.៧.៣ និង ២.១១០.៧.៤ ខាងលើ ។

២.១១០.៧.៨ ប្រសិនបើប្រធាន គ.ក.រ សម្រេចថា ជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវដាក់សន្លឹកឆ្នោតនោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដដែល ។

២.១១០.៨ ក្នុងអំឡុងពេលនៃការពិនិត្យផ្ទៀងផ្ទាត់ និងកំណត់សន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ២.១១០.៧.១ និង ២.១១០.៧.៦ ខាងលើ ប្រសិនបើប្រធាន គ.ក.រ សម្គាល់ឃើញថា សន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនច្បាស់លាស់ ដោយយោងតាមការកំណត់ក្រោមប្រការ ២.១១១ ខាងក្រោម គាត់ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គ.ក.រ អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្តងទៀត ដើម្បីកំណត់ជាចុងក្រោយថាពិតជាសន្លឹកឆ្នោតបានការ ឬមិនបានការ ។

២.១១០.៨.១ ទោះបីប្រធាន គ.ក.រ កំណត់ថា ជាសន្លឹកឆ្នោតបានការក្តី ឬមិនបានការក្តី គាត់ត្រូវប្រកាសឱ្យឮៗអំពីហេតុផលនៃការកំណត់បែបនោះ និងត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើលសន្លឹកឆ្នោតបានការ ឬមិនបានការទាំងនោះ និងចោទសួរអំពីហេតុផលរបស់ប្រធានចំពោះសន្លឹកឆ្នោតនោះ ។ ក្នុងករណីនេះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ មិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ ។

២.១១០.៨.២ ក្នុងករណីប្រធានកំណត់ថាជាសន្លឹកឆ្នោតបានការ ត្រូវអនុវត្តតាមចំណុច ២.១១០.៧.៣ និង ២.១១០.៧.៤ ។

២.១១០.៨.៣ ក្នុងករណីប្រធានកំណត់ថាជាសន្លឹកឆ្នោតមិនបានការ ប្រធាន ត្រូវដាក់សន្លឹកឆ្នោតនោះនៅពំនូកសន្លឹកឆ្នោតមិនបានការ ។

២.១១០.៨.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់ មិនឯកភាពចំពោះសេចក្តីសម្រេចរបស់ប្រធាន ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬមិនបានការខាងលើ ភ្នាក់ងារនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។ ខ្លឹមសារ និងហេតុផលនៃការជំទាស់នេះមិនត្រូវបានកត់ត្រាឡើយ ក្នុងករណីភ្នាក់ងារគណបក្សនោះមិនយល់ព្រមចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

២.១១០.៨.៥ សេចក្ដីសម្រេចរបស់ប្រធាន គ.ក.រ ត្រូវតែមានប្រសិទ្ធភាពក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត ។

២.១១០.៨.៦ ការកំណត់ដូចមានចែងក្នុងចំណុច ២.១១០.៨.៥ ខាងលើ មិនច្រានចោលនូវករណី ដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្ដឹងជំទាស់ទៅ គធ.ឃប អំពីករណីនៃការជំទាស់ដូចមានចែងក្នុងចំណុច ២.១១០.៨.៤ ខាងលើនោះទេ ប៉ុន្តែភ្នាក់ងារគណបក្សនយោបាយនោះ ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.រ និងមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតឡើយ ។

២.១១០.៨.៧ ប្រធានត្រូវផ្ដល់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ជូនភ្នាក់ងារគណបក្សនយោបាយ ប្រសិនបើគាត់ស្នើសុំសម្រាប់បំពេញពាក្យបណ្ដឹងទៅ គធ.ឃប ។

២.១១០.៩ ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យរាប់សន្លឹកឆ្នោត ក្នុងពេលកំពុងរាប់សន្លឹកឆ្នោត ហាមជនគ្រប់រូបព្យាយាមដោយទុច្ចរិត ក្នុងគោលបំណងកត់សម្គាល់ ដើម្បីឱ្យដឹងថាតើអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ បានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

២.១១០.៩.១ ជនណាក៏ដោយដែលបានធ្វើសកម្មភាព ដូចមានចែងក្នុងចំណុច ២.១១០.៩ នឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.រ ។ ការធ្វើសកម្មភាពដដែលឡើងវិញជាលើកទីពីរ នឹងត្រូវចាត់ទុកថាជាការរំលោភលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ហើយជនដែលមានការពាក់ព័ន្ធត្រូវតែបានបណ្ដេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ក ។

២.១១០.៩.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត និងរាយការណ៍ជូន គធ.ឃប ។

២.១១០.៩.៣ ពេលទទួលបានកំណត់ហេតុដូចមានចែងក្នុងចំណុច ២.១១០.៩.២ ខាងលើភ្លាម គធ.ឃប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនេះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ប្រធាន គធ.ឃប ត្រូវប្ដឹងទៅ គ.ជ.ប ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់ ។

២.១១០.១០ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួចហើយ ប្រធាន គ.ក.រ ត្រូវចាត់អនុប្រធាន និងលេខាធិការឱ្យបូកសរុប និងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) ព្រមទាំងបង្គាប់សមាជិកទី១ ឱ្យធ្វើកិច្ចការដូចគ្នានេះនៅលើផ្ទាំងក្រដាសធំ ដែលបានប្រើសម្រាប់គូសសំឡេងឆ្នោត។ ទន្ទឹមនេះ ដោយមានការពិនិត្យសង្កេតមើលរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងការិយាល័យរាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវរាប់ចំនួនសន្លឹកឆ្នោតបានការតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងតាមពំនូកសន្លឹកឆ្នោតមិនបានការ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាមួយនឹងតួលេខចំនួនសន្លឹកឆ្នោត ដែលអនុប្រធាន លេខាធិការ និងសមាជិកទី១ បានបូកសរុបឃើញខាងលើ។ ប្រធាន គ.ក.រ ត្រូវធានាថា ទ.១១០៨ស ទាំង ២ (ពីរ) ច្បាប់ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ១ (មួយ) ផ្ទាំង ត្រូវបានចុះហត្ថលេខាដោយខ្លួនគាត់ផ្ទាល់ និងលេខាធិការ។ ភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន អាចចុះហត្ថលេខាលើ ទ.១១០៨ស បាន។ ការមិនចុះហត្ថលេខារបស់ភ្នាក់ងារគណបក្សនយោបាយ មិនអាចាត់ទុកតារាងទាំងនេះ ជាមោឃៈបានឡើយ ។

២.១១០.១១ ប្រធាន គ.ក.រ ត្រូវប្រកាសជាចំហនូវលទ្ធផលនៃការបូកសរុប និងការរាប់ចំនួនសន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ២.១១០.១០ ខាងលើ និងត្រូវផ្ទៀងផ្ទាត់ដោយធ្វើប្រមាណវិធី បូកបញ្ចូលគ្នានូវចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ និងចំនួនសន្លឹកឆ្នោតមិនបានការសរុប ។

២.១១០.១១.១ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះស្មើគ្នាទៅនឹងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចមានចែងក្នុងចំណុច ២.១១០.៦ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនសន្លឹកឆ្នោត ដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការទៅក្នុង ទ.១១០២ស ។

២.១១០.១១.២ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ មានចំនួនតិចជាង ឬច្រើនជាងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចមានចែងក្នុងចំណុច ២.១១០.៦ ខាងលើ ប្រធានត្រូវរាប់សន្លឹកឆ្នោតតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការឡើងវិញម្តងទៀត។

២.១១០.១១.៣ ប្រសិនបើបន្ទាប់ពីប្រធានបានរាប់ឡើងវិញ និងធ្វើប្រមាណវិធីបូក ឃើញថាផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះនៅតែមានភាពខុសគ្នាដដែល ម្យ៉ាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោត ឬ/និងគ្មានសន្លឹកឆ្នោតណាមួយ ឬច្រើន ត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយសារការធ្លាក់ជ្រុះទេនោះ ត្រូវសន្មតថាភាពខុសគ្នានេះបានកើតឡើងមុនជាយថាហេតុ ។ ក្នុងករណីនេះលេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះក្នុង ទ.១១០២ស ។

២.១១០.១២ ប្រធាន គ.ក.រ ត្រូវធានាថាសន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ និងដាក់ដោយឡែកពីគ្នា ។

២.១១០.១៣ ប្រធាន គ.ក.រ ត្រូវធានាថាសន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកង និងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្វងថា " សន្លឹកឆ្នោតមិនបានការ " ។

២.១១០.១៤ ប្រធាន គ.ក.រ ត្រូវធានាថាសន្លឹកឆ្នោតបានការ ដែលបានចងនឹងកៅស៊ូកង ដូចមានចែងក្នុងចំណុច ២.១១០.១២ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ដូចមានចែងក្នុងចំណុច ២.១១០.១៣ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ដូចមានចែងក្នុងចំណុច ២.១១០.១០ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចចែងក្នុងចំណុច ២.១១០.៥.១ ខាងលើ ត្រូវបានដាក់រួមគ្នាក្នុងស្បោងផ្លាស្ទិកតែមួយដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា " សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ការិយាល័យបោះឆ្នោតលេខ..." បន្ទាប់មកត្រូវចងមាត់ស្បោងប្លាស្ទិកនេះ និងត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយប្រើប៊ិកហ្វឺតធំលុបមិនជ្រះនៅលើផ្នែកខាងក្រៅនៃស្បោងប្លាស្ទិក ដើម្បីត្រៀមបញ្ជូន និងប្រគល់ជូន គធ.ខប ។

២.១១០.១៥ នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវបានបំពេញរួចរាល់ ប្រធាន គ.ក.រ ត្រូវចាត់ចែងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តជាបន្តទៀត ដោយអនុវត្តតាមលំនាំនីតិវិធីដូចមានចែងចាប់ពីចំណុច ២.១១០.១ ដល់ ២.១១០.១៤ ខាងលើ និងប្រើទម្រង់បែបបទពណ៌ស ក្នុងនោះមាន ៖

២.១១០.១៥.១ កំណត់ហេតុនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១០១ខ) ។

២.១១០.១៥.២ កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១០២ខ) ។

២.១១០.១៥.៣ តារាងកត់ត្រាសំឡេងឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១០៨ខ) ។

២.១១០.១៦ បន្ទាប់ពីបានអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្រោមប្រការ ២.១១០ ខាងលើ ប្រធាន គ.ក.រ ត្រូវចាត់លេខាធិការ អនុប្រធាន និងសមាជិកទី១ បំពេញ ទ.១១០២ តាមប្រភេទក្រុមប្រឹក្សានីមួយៗ សម្រាប់ការិយាល័យរបស់ខ្លួនតាមចំនួនដែលត្រូវប្រើប្រាស់ និងចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.រ ព្រមទាំងបោះត្រា សម្រាប់បន្តចាត់ចែងអនុវត្ត ដូចមានបញ្ជាក់ក្នុងប្រការ ២.១១២ ខាងក្រោម និងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន និងបញ្ជូនទៅ គធ.ខប ដើម្បីស្រង់ជាលទ្ធផលបឋមនៃការបោះឆ្នោត ។

២.១១០.១៧ ក្នុងអំឡុងពេលនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោត ។

## សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ

### ប្រការ ២.១១១.-

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេសប្រធាន និងអនុប្រធាន គ.ក.រ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

២.១១១.១ សន្លឹកឆ្នោតបានការគឺជាសន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅតាមការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌនីមួយៗ ដែលសន្លឹកឆ្នោតពណ៌សជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងសន្លឹកឆ្នោតប្រភេទពណ៌ជាសន្លឹកឆ្នោតសម្រាប់

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង ហើយដែលនៅលើសន្លឹកឆ្នោតនោះ អ្នកបោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ពីឆន្ទៈរបស់ខ្លួន ដោយមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត ។

២.១១១.២ សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវចាត់ទុកជាមោឃៈ ដែលក្នុងនោះរួមមានសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ ឬ/និងសន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូស ប៉ុន្តែ គ.ក.រ ពុំអាចសន្និដ្ឋានថាបោះឱ្យគណបក្សនយោបាយណាមួយ ឬ/និងសន្លឹកឆ្នោតដែលមានសញ្ញានាំឱ្យគេស្គាល់អ្នកបោះឆ្នោត ឬ/សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច ឬ/និងសន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។ សន្លឹកឆ្នោតមិនបានការរួមមាន ៥ (ប្រាំ) ប្រភេទ ដូចខាងក្រោម ដែលត្រូវបានចាត់ទុកជាមោឃៈ ។

២.១១១.២.១ សន្លឹកឆ្នោតមិនផ្លូវការ ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតមានខ្នាតតូចជាង ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្ដើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។
- សន្លឹកឆ្នោតមានពណ៌ផ្សេង ខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។
- សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើន ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ នៅក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។
- សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយ លើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។

- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេង មិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យ គ.ក.ប ពាក់ព័ន្ធ ។

២.១១១.២.២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែល គ.ក.វ ពុំអាចសន្និដ្ឋានថាបោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)។
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយលើសពីមួយគណបក្ស ។
- សន្លឹកឆ្នោតមានគំនូសសញ្ញា ក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយ ដោយគូសហួសចូលទៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយទៀត ។
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើន នៅក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ ។

២.១១១.២.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ នាំឱ្យគេស្គាល់ពីអត្តសញ្ញាណរបស់អ្នកបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះបីនៅក្នុង ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។

- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ ។
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណរបស់អ្នកបោះឆ្នោត ។

២.១១១.២.៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូចមិនអាចយកជាការបាន ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បូនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ។
- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង ។
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅផ្នែកខាងមុខ ឬ/និងផ្នែកខាងខ្នង ដែលមិនអាចមើលយល់រូបសញ្ញា និងអក្សរដែលត្រូវបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ ។

២.១១១.២.៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។
- សន្លឹកឆ្នោតមានបោះត្រា ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

**ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ**

**ប្រការ ២.១១២.-**

នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចមានចែងក្រោមប្រការ ២.១១០ ខាងលើ ត្រូវបានបំពេញរួចរាល់ ប្រធាន គ.ក.រ ត្រូវធានាថា ទ.១១០៨ស ចំនួន ២ (ពីរ) ច្បាប់ ទ.១១០២ស សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង ទ.១១០៨ខ ចំនួន ២ (ពីរ) ច្បាប់ ទ.១១០២ខ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ដែលបានបំពេញត្រឹមត្រូវរួចហើយ ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ ព្រមទាំងបោះត្រា ។ ប្រធាន គ.ក.រ ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " នីមួយៗដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតរបស់ខ្លួន ព្រមទាំងរាល់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ដើម្បីបញ្ជូនទៅ គធ.ខប ។

២.១១២.១ ប្រធាន គ.ក.រ ត្រូវបង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ដូចមានចែងក្នុងប្រការ ២.១១២ ខាងលើ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខាជាសាក្សី ។

២.១១២.១.១ ភ្នាក់ងារគណបក្សនយោបាយ អាចចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតខាងលើ ។

២.១១២.១.២ ការមិនព្រមចុះហត្ថលេខា លើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានឡើយ ។

២.១១២.២ ប្រធាន គ.ក.រ ត្រូវដាក់ ទ.១១០២ស ទ.១១០២ខ និង ទ.១១០៨ស ទ.១១០៨ខ ដូចមានចែងក្នុងប្រការ ២.១១២ ដោយឡែកពីគ្នាតាមប្រភេទក្រុមប្រឹក្សានីមួយៗ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្នងថា " ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតារាងកត់ត្រាសំឡេងឆ្នោត ផ្ញើជូន គ.ជ.ប " និងស្រោមសំបុត្រដែលមានកាខ្នងថា " ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងតារាងកត់ត្រាសំឡេងឆ្នោត ផ្ញើជូន គ.ជ.ប "។ បន្ទាប់មកត្រូវរៀបចំវេចខ្ចប់រាល់ស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដូចក្នុងចំណុច ២.១១២.៣ និង ២.១១២.៤ ខាងក្រោម ដែលកញ្ចប់សុវត្ថិភាព " កស " សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រីឯកញ្ចប់សុវត្ថិភាព " កខ " សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយត្រូវបិទភ្ជិតដោយការសុវត្ថិភាពដែលបម្រុងស្រាប់ និងបំពេញលេខកូដការិយាល័យនោះឱ្យបានត្រឹមត្រូវ ។

២.១១២.៣ ប្រធាន គ.ក.រ ត្រូវធានាថា នៅក្នុងកញ្ចប់សុវត្ថិភាព " កស " មានសម្ភារ ឯកសារ ដូចខាងក្រោម៖

២.១១២.៣.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងតារាងកត់ត្រាសំឡេងឆ្នោត ផ្ញើជូន គ.ជ.ប។

២.១១២.៣.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត និងក្រដាសព័ត៌មាន ដូចមានចែងក្នុងចំណុច ២.១០៧.១១.៩ ។

២.១១២.៣.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ប្រសិនបើមាន) ។

២.១១២.៣.៤ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១១២.៣.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់។

២.១១២.៣.៦ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវ ដែលបានដកហូត (ប្រសិនបើមាន)។

២.១១២.៣.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាង ដែលបានដកហូត (ប្រសិនបើមាន) ។

២.១១២.៣.៨ ស្បោងផ្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតនៃក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ។

២.១១២.៤ ប្រធាន គ.ក.រ ត្រូវធានាថា នៅក្នុងកញ្ចប់សុវត្ថិភាព " ក₂ " មានសម្ភារ ឯកសារដូចខាងក្រោម ៖

២.១១២.៤.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងតារាងកត់ត្រាសំឡេងឆ្នោត ផ្ញើជូន គ.ជ.ប ។

២.១១២.៤.២ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " នៃក្រុមប្រឹក្សារាជធានី ខេត្ត (ប្រសិនបើមាន) ។

២.១១២.៤.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " នៃក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១១២.៤.៤ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនត្រឹមត្រូវ ដែលបានដកហូត (ប្រសិនបើមាន) ។

២.១១២.៤.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

២.១១២.៤.៦ ស្បោងផ្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតនៃក្រុមប្រឹក្សារាជធានី ខេត្ត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ។

២.១១២.៥ ប្រធាន គ.ក.រ ត្រូវដាក់ ទ.១១០២ស ទ.១១០២ខ និង ទ.១១០៨ស ទ.១១០៨ខ ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលមានកាខ្ទងថា " កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ផ្ញើជូន គធ.ខប " និងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ទងថា " កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ផ្ញើជូន គធ.ខប " ដូចមានចែងក្នុងចំណុច ២.១០៨.៤.៣ និង ២.១០៨.៤.៤ ។

២.១១២.៦ ប្រធាន គ.ក.រ ត្រូវចាត់សមាជិកទី២ ឱ្យបិទផ្សាយ ទ.១១០២ស និង ទ.១១០២ខ ១ (មួយ) ច្បាប់ៗ តាមប្រភេទក្រុមប្រឹក្សានីមួយៗជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យបោះឆ្នោត និងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។ ទន្ទឹមនេះ ត្រូវចាត់សមាជិកទី២ ឱ្យនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តាមប្រភេទក្រុមប្រឹក្សានីមួយៗ ១ (មួយ) ច្បាប់ ទៅប្រគល់ជូន គធ.ខប ដោយផ្ទាល់ ក្នុងករណីការិយាល័យបោះឆ្នោតនៅជិត គធ.ខប ឬតាមរយៈគ្រូបង្គាត់ប្រចាំក្រុង ស្រុក ខណ្ឌ ដើម្បី គធ.ខប បញ្ចូលទិន្នន័យជាលទ្ធផលបឋម និងបញ្ជូនបន្តទៅ គ.ជ.ប តាមនីតិវិធីកំណត់ដោយ គ.ជ.ប ។

២.១១២.៧ ប្រធាន គ.ក.រ ត្រូវធានាថាលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) តាមប្រភេទក្រុមប្រឹក្សានីមួយៗ ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោត ដោយលេខាធិការ និងចុះហត្ថលេខាដោយប្រធានផ្ទាល់ សម្រាប់ប្រើក្នុងការបញ្ជូន និងប្រគល់ទទួលស្បោង " ខ " នៅ គធ.ខប ដែលស្បោង " ខស " សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រីឯស្បោង " ខខ " សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត និងត្រូវ ៖

២.១១២.៧.១ ដាក់ ១ (មួយ) ច្បាប់ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងស្បោង " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១១២.៧.២ ដាក់ ១ (មួយ) ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១១២.៧.៣ រក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលស្បោង " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗនៅ គធ.ខប ។

២.១១២.៨ ប្រធាន គ.ក.រ ត្រូវធានាថាសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម ត្រូវបានវេចខ្ចប់ដាក់ក្នុងស្បោង "ខស" និងស្បោង "ខខ" ដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដើម្បីបញ្ជូនទៅ គធ.ខប ៖

២.១១២.៨.១ កញ្ចប់សុវត្ថិភាព "កស" និង "កខ" ដាក់សម្ភារ ឯកសារ ដូចមានចែងក្រោមចំណុច ២.១១២.៣ និង ២.១១២.៤ ។

២.១១២.៨.២ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ផ្ញើជូន គធ.ខប ដូចចែងក្នុងចំណុច ២.១១២.៥។

២.១១២.៨.៣ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ២.១១២.៧.១ ។

២.១១២.៨.៤ ស្រោមសំបុត្រតូចដាក់ត្រាការិយាល័យបោះឆ្នោត (ដាក់ក្រោយពេលបានបោះត្រាលើ ទ.១១០៧ រួចរាល់ហើយ) ដែលត្រូវដាក់ក្នុងស្បោង "ខស" នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

២.១១២.៩ ប្រធាន គ.ក.រ ត្រូវធានាថាស្បោង "ខ" នៃប្រភេទក្រុមប្រឹក្សានីមួយៗ ដែលផ្ទុកសម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្រោមចំណុច ២.១១២.៨ ខាងលើ ត្រូវបានចងភ្ជិត ចាក់សោឃ្លុំមានលេខ និងសរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ។

២.១១២.១០ ប្រធាន គ.ក.រ ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានសង្កេតមើលការរៀបចំ និងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គធ.ខប និងបានកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់ស្បោង "ខ" ដូចមានចែងក្នុងចំណុច ២.១១២.៩ ខាងលើ ។

២.១១២.១១ ប្រធាន គ.ក.រ ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់សម្ភារឯកសារបោះឆ្នោតនៅសល់ ដែលត្រូវផ្ញើជូន គ.ជ.ប វិញដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ទឹកខ្មៅលុបមិនជ្រះ (ដែលត្រូវវេចខ្ចប់ដោយឡែក) ស្លាកសញ្ញាការិយាល័យបោះឆ្នោតជាដើម ហើយត្រូវបញ្ជូន និងប្រគល់សម្ភារ ឯកសារបោះឆ្នោតទាំងនោះជូន គធ.ខប អមជាមួយនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។ ប្រធាន គ.ក.រ ត្រូវធានាថា ទ.១១០៧ ចំនួន ២ (ពីរ) ច្បាប់ ត្រូវបាន

បំពេញលម្អិតមុខសម្ភារ ឯកសារនៅសល់ទាំងនោះ សម្រាប់ប្រើក្នុងពេលប្រគល់ទទួលនៅ គធ.ខប ។ ទន្ទឹមនេះប្រធាន គ.ក.រ ត្រូវយកបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ជូន គធ.ខប ស្របពេលនឹងការបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ។

**ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គធ.ខប**

**ប្រការ ២.១១៣.-**

បន្ទាប់ពីបានធ្វើការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតរួចសព្វគ្រប់ហើយ ប្រធាន គ.ក.រ ត្រូវចាត់វិធានការចាំបាច់ទាំងឡាយ ក្នុងការបញ្ជូនជាបន្ទាន់នូវស្បោង " ខ " ដូចមានចែងក្នុងចំណុច ២.១១២.៩ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ ដូចមានចែងក្នុងចំណុច ២.១១២.១១ ខាងលើ ឱ្យបានទៅដល់ គធ.ខប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ។

២.១១៣.១ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និងសភាពការណ៍សន្តិសុខ ប្រសិនបើប្រធាន គ.ក.រ យល់ថាអាចនឹងបញ្ជូនស្បោង " ខ " និងសម្ភារ ឯកសារ ដូចមានចែងក្នុងប្រការ ២.១១៣ ខាងលើ ទៅ គធ.ខប បានតាមពេលវេលាកំណត់ និងធានាបាននូវសុវត្ថិភាពនោះ ប្រធានត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ឱ្យចូលរួមក្នុងការបញ្ជូនខាងលើ និងត្រូវជូនដំណឹងអំពីពេលវេលានៃការចេញដំណើរ ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ ទទួលស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅ គធ.ខប ។

២.១១៣.២ ប្រធាន គ.ក.រ ដែលអមដំណើរដោយអនុប្រធាន ត្រូវទទួលខុសត្រូវក្នុងការដឹកជញ្ជូនដោយផ្ទាល់នូវស្បោង " ខ " និងសម្ភារ ឯកសារដូចមានចែងក្នុងប្រការ ២.១១៣ ទៅ គធ.ខប ។ ប្រធានត្រូវចាត់សមាជិក គ.ក.រ តាមការចាំបាច់ ដើម្បីជួយដឹកជញ្ជូនឱ្យអស់សម្ភារ ឯកសារនៅសល់ផ្សេងទៀត ។

២.១១៣.៣ ប្រសិនបើចាំបាច់ប្រធាន គ.ក.រ ត្រូវស្នើសុំកម្លាំងសន្តិសុខ ២ (ពីរ) រូប ដើម្បីអមដំណើរការដឹកជញ្ជូនស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត នៅសល់ទៅ គធ.ខប ។

២.១១៣.៤ នៅពេលទទួលស្បោង " ខ " និងសម្ភារ ឯកសារ ដូចមានចែងក្នុងប្រការ ២.១១៣ ខាងលើ គធ.ខប ត្រូវធានាថាបានត្រួតពិនិត្យរាល់សម្ភារ ឯកសារទាំងអស់ និងចុះហត្ថលេខាលើ ទ.១១០៧ បញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ ។ ដោយឡែកក្នុងការប្រគល់ ទទួលស្បោង " ខ " គធ.ខប ត្រូវ ៖

២.១១៣.៤.១ បើកស្បោង " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដើម្បីត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុង ដោយផ្អែកលើ ទ.១១០៧ ទាំង ៣ (បី) ច្បាប់ ប៉ុន្តែមិនត្រូវរុះរើកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធឡើយ ។

២.១១៣.៤.២ ចុះហត្ថលេខាលើ ទ.១១០៧ ទាំង ៣ (បី) ច្បាប់ បន្ទាប់ពីបានត្រួតពិនិត្យត្រឹមត្រូវហើយ ។

២.១១៣.៤.៣ អញ្ជើញភ្នាក់ងារគណបក្សនយោបាយ ចូលរួមចុះហត្ថលេខាជាសាក្សីលើ ទ.១១០៧ នេះ ។ ការមិនព្រមចុះហត្ថលេខារបស់ភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវ ទ.១១០៧ នេះបានទេ ។

២.១១៣.៤.៤ ប្រគល់ ទ.១១០៧ ដែលចុះហត្ថលេខារួច ១ (មួយ) ច្បាប់ ជូនប្រធាន គ.ក.រ ពាក់ព័ន្ធ ដាក់ ១ (មួយ) ច្បាប់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង " ខ " វិញ និងរក្សាទុក ១ (មួយ) ច្បាប់ ជាឯកសារ។

២.១១៣.៤.៥ ប្រមូលបញ្ជីវត្តមានអ្នកសង្កេតការណ៍ (ទ.១១២០) ពីគ្រប់ការិយាល័យបោះឆ្នោត ហើយធ្វើការបូកសរុបតួលេខក្នុងរាជធានី ខេត្តរបស់ខ្លួន និងត្រៀមទុកដាក់ក្នុងស្រោមសំបុត្រដោយឡែក សម្រាប់ប្រគល់ជូន គ.ជ.ប ។

២.១១៣.៥ រាល់ស្បោង " ខ " ដែល គធ.ខប បានទទួលខាងលើ ត្រូវតែបានកត់ចំណាំ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដោយដាក់តាមលំដាប់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១១៣.៦ គធ.ខប ត្រូវចាត់វិធានការយ៉ាងហ្មត់ចត់ ក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៃបន្ទប់រក្សាទុកស្បោង " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងនោះត្រូវ ៖

២.១១៣.៦.១ ទាក់ទងស្នើសុំកម្លាំងសន្តិសុខ ដើម្បីយាមការពារបរិវេណលេខាធិការដ្ឋាន គឃ.ខប ឬអគារដែលត្រូវរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត ។

២.១១៣.៦.២ ចាត់ចែងឱ្យមានភ្លើងបំភ្លឺនៅលេខាធិការដ្ឋាន គឃ.ខប ឬអគារដែលត្រូវរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត ។

២.១១៣.៧ នៅល្ងាចនៃថ្ងៃបោះឆ្នោត គឃ.ខប ត្រូវរង់ចាំទទួលកំណត់ហេតុនៃការរាប់សន្លឹកបោះឆ្នោត (ទ.១១០២) តាមប្រភេទក្រុមប្រឹក្សានីមួយៗ ពីគ្រប់ការិយាល័យបោះឆ្នោត ដើម្បីបញ្ចូលទិន្នន័យជាលទ្ធផលបឋមនៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ និងចាត់ចែងបញ្ជូនលទ្ធផលនេះ តាមកម្មវិធីកំណត់ដោយ គ.ជ.ប ។

២.១១៣.៨ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និងសភាពការណ៍សន្តិសុខ ប្រសិនបើប្រធាន គ.ក.រ យល់ថាមិនអាចបញ្ជូនស្បោង " ខ " និងសម្ភារ ឯកសារដូចមានចែងក្នុងប្រការ ២.១១៣ ខាងលើ ទៅ គឃ.ខប នៅវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោតបានទេនោះ ប្រធានត្រូវចាត់វិធានការដើម្បីថែរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅពេលយប់ នៅទីតាំងសុវត្ថិភាពណាមួយ ដោយត្រូវផ្តល់ព័ត៌មានអំពីបញ្ហានេះដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ។

២.១១៣.៨.១ ប្រធាន គ.ក.រ ត្រូវថែរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតខាងលើនៅផ្ទះរបស់គាត់ ឬផ្ទះរបស់សមាជិកណាម្នាក់នៃ គ.ក.រ ឬនៅទីតាំងសុវត្ថិភាពណាមួយដែលបានកំណត់ ។

២.១១៣.៨.២ ប្រធាន គ.ក.រ ត្រូវប្រាប់ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ឱ្យបានដឹងអំពីផ្ទះ ឬទីតាំងសុវត្ថិភាពដែលនឹងត្រូវរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតខាងលើ ហើយត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យចូលរួមថែរក្សាការពារ ។ ទន្ទឹមនឹងនេះត្រូវជូនដំណឹងអំពីពេលវេលានៃការចេញដំណើរនៅព្រឹកស្អែក និងពេលវេលានៃការប្រគល់ ទទួលស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅលេខាធិការដ្ឋាន គឃ.ខប ។

២.១១៣.៨.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា អាចស្នាក់នៅពេលយប់នៅផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត ។

២.១១៣.៨.៤ ប្រធានត្រូវចាត់សមាជិក គ.ក.រ យ៉ាងហោចណាស់ ៣ (បី) នាក់ គិតទាំងរូបគាត់ផង ឱ្យចូលរួមក្នុងការរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះ ។

២.១១៣.៨.៥ ប្រធាន គ.ក.រ មិនត្រូវទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតចោល ដោយគ្មានការយាមកាមទេ ។

២.១១៣.៨.៦ ប្រសិនបើចាំបាច់ ប្រធាន គ.ក.រ ត្រូវស្នើសុំកម្លាំងសន្តិសុខ ២ (ពីរ) នាក់ ដើម្បីយាមការពារបរិវេណផ្ទះ ឬទីតាំងដែលរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតនៅពេលយប់ ។

២.១១៣.៨.៧ នៅព្រឹកថ្ងៃបន្ទាប់ប្រធាន គ.ក.រ ត្រូវទទួលបន្ទុកក្នុងការបញ្ជូនស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅប្រគល់ជូន គធ.ខប ។ ក្នុងករណីនេះ ប.ន.ក ចាប់ពីចំណុច ២.១១៣.២ ដល់ ២.១១៣.៤ ខាងលើ ត្រូវតែបានអនុវត្ត ។

**ការរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាននៃ គធ.ខប ឬទីតាំងសុវត្ថិភាពណាមួយ**

**ប្រការ ២.១១៤.-**

ចំពោះការិយាល័យបោះឆ្នោតនៃក្រុង ស្រុក ខណ្ឌណាមួយដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារកាលៈទេសៈមានអាសន្នកើតឡើងនៅពេលបន្ទាប់ពីបានបិទការបោះឆ្នោត ព្រមទាំងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចនៅខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោត ព្រមទាំងឯកសារពាក់ព័ន្ធនៅរក្សាបានល្អ គ.ជ.ប ត្រូវណែនាំដល់ គធ.ខប ពាក់ព័ន្ធឱ្យចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅលេខាធិការដ្ឋាន គធ.ខប ឬនៅទីតាំងសុវត្ថិភាពណាមួយ ។

២.១១៤.១ ករណីកាលៈទេសៈមានអាសន្នត្រូវបានកំណត់ដូចមានចែងក្រោមចំណុច ២.១៣០.១ នៃ ប.ន.ក នេះ ។

២.១១៤.២ ក្នុងករណីកាលៈទេសៈមានអាសន្ន ដែលកើតឡើងនៅក្រោយពេល គ.ក.ប បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងក្រោមប្រការ ២.១០៨ ខាងលើ ហើយប្រសិនបើគ្រោះអាសន្ននោះ បានបណ្តាលឱ្យខូចខាតដល់ហិបឆ្នោតដែលមានសន្លឹកឆ្នោត និងឯកសារពាក់ព័ន្ធ និងរាល់កំណត់ហេតុនៃការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ ដូចខាងក្រោម ៖

២.១១៩.២.១ ធ្វើរបាយការណ៍ស្តីពីស្ថានភាពនៃករណីកាលៈទេសៈមានអាសន្ន ព្រមទាំងការខូចខាតជាក់ស្តែងជូន គធ.ខប ។

២.១១៩.២.២ ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារនៅសេសសល់ទាំងអស់ ដែលអមដោយរបាយការណ៍ខាងលើ រួចបញ្ជូន និងប្រគល់ជូន គធ.ខប ។

២.១១៩.២.៣ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ ទទួលនៅ គធ.ខប ។

២.១១៩.៣ នៅពេលប្រគល់របាយការណ៍ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើ ប្រធាន គធ.ខប ត្រូវចុះហត្ថលេខាលើ ទ.១១០៧ ទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូន ប្រធាន គ.ក.ប វិញ ១ (មួយ) ច្បាប់ ។

២.១១៩.៣.១ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សី លើ ទ.១១០៧ ខាងលើ ។

២.១១៩.៣.២ ការមិនព្រមចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយ មិនអាច ចាត់ទុកជាមោឃៈនូវ ទ.១១០៧ បានទេ ។

២.១១៩.៤ នៅពេលទទួលបានរបាយការណ៍ដូចមានចែងក្នុងចំណុច ២.១១៩.៣ ខាងលើ គធ.ខប ត្រូវបន្តលើកយោបល់ស្នើជាបន្ទាន់ទៅ គ.ជ.ប សុំឱ្យមានការបោះឆ្នោត សាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.១១៩.៥ ក្នុងករណីកាលៈទេសៈមានអាសន្ន ដែលកើតឡើងនៅក្រោយពេល គ.ក.ប បាន អនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធី ដូចមានចែងក្រោមប្រការ ២.១០៨ ខាងលើ ហើយប្រសិនបើគ្រោះអាសន្ននោះមិនបានបណ្តាលឱ្យខូចខាតដល់ហិបឆ្នោត ដែល មានសន្លឹកឆ្នោតនៅខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោតទេ ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោម ៖

២.១១៩.៥.១ ថែរក្សាហិបឆ្នោតដែលបានបិទភ្ជិត និងចាក់សោឃ្លុំមានលេខរួច ឱ្យ បានហ្មត់ចត់ ត្រៀមសម្រាប់ការបញ្ជូនទៅ គធ.ខប ។

២.១១៩.៥.២ រៀបចំស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចមាន ចែងក្នុងចំណុច ២.១០៨.៤ និងវេចខ្ចប់រាល់ស្រោមសំបុត្រ និង ស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្នុងចំណុច

២.១០៨.៥ ទៅក្នុងកញ្ចប់សុវត្ថិភាព " $ក_{ស}$ " និង " $ក_{ខ}$ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ប៉ុន្តែមិនចាំបាច់បិទភ្ជិតដោយការសុវត្ថិភាពនៅពេលនេះទេ បន្ទាប់មកត្រូវសរសេរលេខកូដការិយាល័យ-បោះឆ្នោតពាក់ព័ន្ធ ។

២.១១៥.៥.៣ វេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.១០៨.៤.៣ និង ២.១០៨.៤.៤ ខាងលើ ព្រមទាំងស្រោមសំបុត្រដាក់ត្រា គ.ក.ប (បន្ទាប់ពីបោះត្រាលើ ទ.១១០៧ រួច) ទៅក្នុងស្បោង " ខ " ហើយចងភ្ជិត និងចាក់សោឃ្លុំ ។

២.១១៥.៥.៤ ប្រមូល និងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទាំងអស់ដោយឡែក ។

២.១១៥.៥.៥ បំពេញ ទ.១១០៧ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ ទទួលនៅ គធ.ខប ។

២.១១៥.៥.៦ បញ្ជូន និងប្រគល់ហិបឆ្នោត ស្បោង " ខ " និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើជូន គធ.ខប ។ ប្រធានដែលអមដំណើរដោយអនុប្រធាន និងសមាជិក គ.ក.ប មួយចំនួនទៀត ត្រូវទទួលបន្ទុកក្នុងការបញ្ជូន និងប្រគល់ ទទួលនេះដោយផ្ទាល់ ព្រមទាំងត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួម និងត្រូវស្នើសុំកម្លាំងសន្តិសុខ ២ (ពីរ) នាក់ ឱ្យជួយការងារ និងជូនដំណើរនេះ ។

២.១១៥.៦ នៅពេលទទួលហិបឆ្នោត ដែលមានសន្លឹកឆ្នោតនៅខាងក្នុង ស្បោង " ខ " និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើ ប្រធាន គធ.ខប ត្រូវចុះហត្ថលេខាលើ ទ.១១០៧ ទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូនប្រធាន គ.ក.ប វិញ ១ (មួយ) ច្បាប់ ។

២.១១៥.៦.១ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើ ទ.១១០៧ ខាងលើ ។

២.១១៥.៦.២ ការមិនព្រមចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុក ទ.១១០៧ ជាមោឃៈបានទេ ។

២.១១៤.៧ បន្ទាប់ពីបានទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង " ខ " នៃការិយាល័យបោះឆ្នោត ដែលមិនអាចរាប់សន្លឹកឆ្នោតនៅនឹងកន្លែងបាន ដោយសារករណីកាលៈទេសៈមានអាសន្នភ្លាម គធ.ខប ត្រូវធ្វើការកត់ចំណាំ និងរក្សាទុកដោយឡែកនៅកន្លែងមានសុវត្ថិភាព និងត្រូវជូនដំណឹងដល់សមាសភាព គ.ក.ប នោះ ព្រមទាំងភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ឱ្យមកកាន់លេខាធិការដ្ឋាន គធ.ខប នៅវេលាម៉ោងប្រាំពីរ (៧:០០) ព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដើម្បីរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតរបស់ខ្លួន ។

២.១១៤.៧.១ គធ.ខប អាចចាត់ចែងសមាសភាព គ.ក.រ ផ្សេង ឬសមាជិក គធ.ខប ឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ប្រសិនបើសមាសភាព គ.ក.រ នោះអវត្តមាន ។

២.១១៤.៧.២ សមាសភាព គ.ក.រ ដែលត្រូវបំពេញភារកិច្ចរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាន គធ.ខប ត្រូវតែបានទទួលប្រាក់ឧបត្ថម្ភ សម្រាប់ការធ្វើដំណើរ និងអាហារ ក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនោះ ។

២.១១៤.៨ តាមពេលវេលាដូចចែងក្នុងចំណុច ២.១១៤.៧ ខាងលើ គធ.ខប ត្រូវចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលជួបករណីកាលៈទេសៈមានអាសន្ននៅលេខាធិការដ្ឋាន គធ.ខប ឬនៅទីតាំងសុវត្ថិភាពណាមួយ ។

២.១១៤.៩ នៅពេលសមាសភាព គ.ក.រ ឬមន្ត្រីបោះឆ្នោត ដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោតមានវត្តមាននៅបន្ទប់រាប់សន្លឹកឆ្នោតហើយ ប្រធាន គធ.ខប ត្រូវប្រគល់ហិបឆ្នោតសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលមានកញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោតពាក់ព័ន្ធ ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀតឱ្យទៅប្រធាន គ.ក.រ ដើម្បីអនុវត្តការរាប់សន្លឹកឆ្នោត ។ ប្រធាន គ.ក.រ ត្រូវ ៖

២.១១៤.៩.១ ចាត់ចែងអនុវត្តការរាប់សន្លឹកឆ្នោតដោយឡែកពីគ្នា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដោយចាប់ផ្តើមពីការរាប់សន្លឹកឆ្នោត ដែលបានបោះសម្រាប់ការជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌជាមុន បន្ទាប់មកទើបអនុវត្តការរាប់សន្លឹកឆ្នោត ដែលបានបោះសម្រាប់ការជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តជាក្រោយ ។

២.១១៨.៩.២ ពិនិត្យដើម្បីឱ្យប្រាកដថា ហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលបានទទួល ពុំត្រូវបានគេរុះរើឡើយ ។

២.១១៨.៩.៣ កាត់ផ្តាច់សោឃ្លុំស្បោង " ខ " តាមប្រភេទក្រុមប្រឹក្សានីមួយៗ និង ត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុង ដោយផ្ទៀងផ្ទាត់ទៅ នឹង ទ.១១០៧ ។

២.១១៨.១០ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតខាងលើ ទាំងការរាប់សន្លឹកឆ្នោតដែលបានបោះ សម្រាប់ការជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ទាំងការរាប់សន្លឹកឆ្នោតដែល បានបោះសម្រាប់ការជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវអនុវត្តតាមនីតិវិធីដូច មានចែងក្រោមប្រការ ២.១១០ ២.១១១ ២.១១២ និង ២.១១៣ នៃ ប.ន.ក នេះ ។ ដោយសារការរាប់សន្លឹកឆ្នោតនេះ ត្រូវបានធ្វើនៅលេខាធិការដ្ឋាន គធ.ខប ឬនៅទី តាំងដែលមានសុវត្ថិភាព នីតិវិធីពាក់ព័ន្ធមួយចំនួនដូចខាងក្រោមត្រូវបានកំណត់ ឱ្យអនុវត្តដោយឡែក ដែលក្នុងនោះប្រធាន គ.ក.រ ត្រូវ ៖

២.១១៨.១០.១ ទទួលខុសត្រូវនាំយក ទ.១១០២ស និង ទ.១១០២ខ ១ (មួយ) ច្បាប់ៗ ទៅបិទផ្សាយជាលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតនៅ ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.១១៨.១០.២ បង្គាប់សមាជិកទី២ ឱ្យបិទផ្សាយ ទ.១១០២ស និង ទ.១១០២ខ មួយច្បាប់ៗ នៅមុខលេខាធិការដ្ឋាន គធ.ខប និងចែកជូនភ្នាក់ងារ គណបក្សនយោបាយដែលមានវត្តមាន ។

២.១១៨.១០.៣ ធានាថាបន្ទាប់ពីការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវបានវេចខ្ចប់ក្នុងស្បោងប្លាស្ទិក ឬ/និងស្រោម សំបុត្រ និងដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ក$_{ស}$ " និង " ក$_{ខ}$ " តាម ប្រភេទក្រុមប្រឹក្សានីមួយៗ រួចបិទភ្ជិតដោយកាវសុវត្ថិភាពបម្រុង ស្រាប់ ។ បន្ទាប់មកស្បោង " ខ " ទាំងនោះត្រូវបានវេចខ្ចប់ជាថ្មី ដោយដាក់សម្ភារឯកសារតាមលំនាំដូចមានចែងក្នុងចំណុច២.១១២.៨ ខាងលើ រួចចងមាត់ស្បោងឡើងវិញ ហើយត្រូវប្រគល់ជូន គធ.ខប ដោយផ្ទាល់នៅបន្ទប់រាប់សន្លឹកឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារ គណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

២.១១៨.១០.៤ ប្រគល់ហិបឆ្នោតទទេជូន គធ.ខប ។

២.១១៨.១០.៥ ធានាថា ទ.១១០៧ ត្រូវបានបំពេញ និងប្រើប្រាស់ក្នុងការប្រគល់ ទទួលស្របតាមការកំណត់របស់ គ.ជ.ប ។

២.១១៤.១១ នៅពេលប្រគល់ ទទួលស្បោង " ខ " ដូចមានចែងក្នុងចំណុច ២.១១៤.១០.៣ ខាងលើ គធ.ខប ត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ២.១១៣.៤ និង ២.១១៣.៥ ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬ/និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅ គធ.ខប**

**ប្រការ ២.១១៥.-**

ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលមិនសុខចិត្តនឹងការសម្រេចរបស់ប្រធាន គ.ក.ប ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត ដូចមានចែងក្រោមចំណុច ២.១០៧.២៣ និងរាប់សន្លឹកឆ្នោត ដូចមានចែងក្រោមចំណុច ២.១១០.៨.៤ និងចំណុច ២.១១៤.១០ ខាងលើ ឬជំទាស់នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និងរាជធានី ខេត្ត អាចបំពេញទម្រង់បែបបទសម្រាប់ប្តឹងទៅ គធ.ខប។ ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នេះ ត្រូវធ្វើឡើងក្នុងរយៈពេល ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចរបស់ គ.ក.ប ឬបន្ទាប់ពីថ្ងៃបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។ ប្រសិនបើនៅក្នុងរយៈពេលដែលបានកំណត់ខាងលើនេះ គធ.ខប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ណាមួយទេ ចាត់ទុកថាគ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។

២.១១៥.១ ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដូចមានចែងក្នុងប្រការ ២.១១៥ ខាងលើ ជាពាក្យបណ្តឹងទាក់ទងដល់ការសុំកែតម្រូវលើលទ្ធផលនៃការបោះឆ្នោត ហើយមានកម្មវត្ថុបណ្តឹងចំនួន ៣ (បី) ប្រភេទផ្សេងគ្នា ដូចខាងក្រោម ៖

- ការស្នើសុំកែតម្រូវតួលេខនៃលទ្ធផលនៃការបោះឆ្នោត ។
- ការស្នើសុំរាប់សន្លឹកឆ្នោតឡើងវិញ ។
- ការស្នើសុំឱ្យមានការបោះឆ្នោតសាជាថ្មី ។

២.១១៥.២ អ្នកប្តឹង ត្រូវបំពេញ និងផ្តិតមេដៃលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ដែលក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម ៖

២.១១៥.២.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ។

២.១១៥.២.២ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត ។

២.១១៥.២.៣ ពេលវេលា និងទីកន្លែងកើតឡើងនូវភាពមិនប្រក្រតី ។

២.១១៥.២.៤ ប្រភេទនៃភាពមិនប្រក្រតី ឬកំហុសឆ្គង ដែលជាកម្មវត្ថុនៃបណ្តឹង។

២.១១៥.២.៥ ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ។

២.១១៥.២.៦ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី ប្រសិនបើមាន ។

២.១១៥.២.៧ សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗទៀត ប្រសិនបើមាន ។

២.១១៥.២.៨ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង ប្រសិនបើមាន ។

២.១១៥.៣ ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ២.១១៥ ខាងលើ ប្រធាន គធ.ឧប ឬសមាជិកទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយរយៈពេលកំណត់ ដូចនេះ គធ.ឧប មិនអាចទទួលយកមកដោះស្រាយបានទេ ។

២.១១៥.៤ ចំពោះពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ គធ.ឧប ត្រូវណែនាំអ្នកប្តឹង ឬតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាង មិនបានបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ឧប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ.ឧប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជា ឯកសារ ១ (មួយ) ច្បាប់ ។

២.១១៥.៥ ចំពោះពាក្យបណ្តឹងដែលបានទទួលក្នុងរយៈពេលកំណត់ និងមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ មន្ត្រីទទួលពាក្យបណ្តឹងនៃ គធ.ឧប ត្រូវធ្វើកំណត់ហេតុសាកសួរបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាង ចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ ។ ក្នុងករណីអ្នកប្តឹង ឬតំណាង មិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ មន្ត្រីទទួលពាក្យបណ្តឹងនៃ គធ.ឧប ត្រូវចុះនិទ្ទេសបញ្ជាក់អំពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ ។ បន្ទាប់មកត្រូវចុះកាលបរិច្ឆេទនៃការទទួលពាក្យបណ្តឹង ចុះហត្ថលេខា បោះត្រា គធ.ឧប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ បិទផ្សាយជា

សាធារណៈនៅ គធ.ខប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គធ.ខប ប្រើក្នុងពេលដោះស្រាយពាក្យបណ្ដឹង ។ មន្ត្រីទទួលពាក្យបណ្ដឹងនៃ គធ.ខប ត្រូវជម្រាបអ្នកប្ដឹងថា គធ.ខប នឹងដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ទាំងនេះ ក្នុងរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង ។

២.១១៥.៦ ក្នុងករណីពាក្យបណ្ដឹងគ្មានភស្តុតាងបញ្ជាក់ដែលអាចឱ្យជឿថា មានកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬ/និងពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ.ខប ត្រូវបដិសេធពាក្យបណ្ដឹងនោះ និងចាត់ចែងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្តជាធម្មតាតាមការកំណត់របស់ គ.ជ.ប ។ បន្ទាប់មក ប្រធាន គធ.ខប ត្រូវ ៖

២.១១៥.៦.១ ចាត់មន្ត្រីទទួលពាក្យបណ្ដឹងឱ្យបំពេញសម្រង់សេចក្ដីសម្រេចបដិសេធលើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ (ទ.១២០៣) ជា ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង ។

២.១១៥.៦.២ ចុះហត្ថលេខា និងកាលបរិច្ឆេទលើ ទ.១២០៣ ដែលមន្ត្រីទទួលពាក្យបណ្ដឹងបានបំពេញ រួចប្រគល់ជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

២.១១៥.៦.៣ ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេចបដិសេធ។

២.១១៥.៦.៤ ប្រគល់ជូនអ្នកប្ដឹងនូវ ទ.១២០២ សម្រាប់បំពេញពាក្យបណ្ដឹងចំនួន ៣ (បី) ច្បាប់ ប្រសិនបើគាត់ស្នើសុំ ។

២.១១៥.៧ ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់មានភស្តុតាងបញ្ជាក់ដែលអាចជឿថា មានកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬ/និងពាក់ព័ន្ធនឹងលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គធ.ខប ត្រូវ ៖

២.១១៥.៧.១ ចាត់ចែងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្ដឹង ។

២.១១៥.៧.២ បើកកញ្ចប់សុវត្ថិភាព "ក៥" ឬ "ក៦" ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដោយត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុង ប.ន.ក នេះ ។

២.១១៥.៧.៣ អនុញ្ញាតឱ្យអ្នកប្តឹង ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលរួមសង្កេតមើលដំណើរការត្រួតពិនិត្យបញ្ជាក់ និងការរាប់សន្លឹកឆ្នោតខាងលើនេះ ។

២.១១៥.៨ ក្នុងករណីចាំបាច់ គធ.ឃប អាចបើកការស៊ើបអង្កេតស្រាវជ្រាវលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដើម្បីមានមូលដ្ឋានក្នុងការសម្រេចឱ្យបើក ឬមិនបើកកញ្ចប់សុវត្ថិភាព "ក" ។

២.១១៥.៩ ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញ ដូចមានចែងក្នុងចំណុច ២.១១៥.៧ ខាងលើ គធ.ឃប មិនមានឃើញមានកំហុសឆ្គង ឬភាពមិនប្រក្រតីណាមួយ ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយទេ គធ.ឃប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ ។ ក្នុងករណីនេះ ប្រធាន គធ.ឃប ត្រូវ ៖

២.១១៥.៩.១ ចាត់លេខាធិការអង្គប្រជុំសម្រេច ឱ្យបំពេញសម្រង់សេចក្តីសម្រេចបដិសេធលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង ។

២.១១៥.៩.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដែលបានបំពេញ រួចប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.១១៥.៩.៣ ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ឃប ទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច ។

២.១១៥.៩.៤ ប្រគល់ជូនអ្នកប្តឹងនូវ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ចំនួន ៣ (បី) ច្បាប់ ប្រសិនបើគាត់ស្នើសុំ ។

២.១១៥.១០ ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញ ដូចមានចែងក្នុងចំណុច ២.១១៥.៧ ខាងលើ គធ.ឃប បានរកឃើញភស្តុតាងបញ្ជាក់ថា មានកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ.ឃប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងនោះ ដោយមានកំណត់ហេតុផង ។ ក្នុងករណីនេះ ប្រធាន គធ.ឃប ត្រូវ ៖

២.១១៥.១០.១ ចាត់លេខាធិការអង្គប្រជុំសម្រេច ឱ្យបំពេញសម្រង់សេចក្តីសម្រេចយល់ព្រមលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង ។

២.១១៥.១០.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើ ទ.១២០៣ ដែលបានបំពេញ រួចប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ហើយជម្រាបអ្នកប្តឹងថា គធ.ខប យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត ឬព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងធ្វើរបាយការណ៍លើកយោបល់អំពីករណីនេះ ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេច ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោតទៅ គធ.ខប**

**ប្រការ ២.១១៦.-**

ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលមិនសុខចិត្តនឹងការសម្រេចរបស់ គ.ក.ប ពាក់ព័ន្ធនឹងការតវ៉ា ឬ/និងការជំទាស់ទៅនឹងអំពើរំលោភ ឬដែលបានឃើញភាពមិនប្រក្រតីនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដែលបានកើតឡើងនៅក្នុងតំបន់បោះឆ្នោតណាមួយនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត អាចបំពេញបែបបទសម្រាប់ប្តឹងទៅ គធ.ខប ។ ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទៅនឹងអំពើរំលោភ ឬភាពមិនប្រក្រតីណាមួយដូចមានចែងក្នុងប្រការនេះ ត្រូវអនុវត្តតាមលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងប្រការ ២.១១៥ ខាងលើ ។

២.១១៦.១ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដូចមានបញ្ជាក់ក្នុងប្រការ ២.១១៦ ខាងលើ ត្រូវបានកំណត់ជាក់ស្តែងតាមរយៈកិច្ចសង្កេតការណ៍ ឬការរាយការណ៍ ឬការចោទប្រកាន់ដោយមានភស្តុតាងគ្រប់គ្រាន់ ដែលរួមមានប្រភេទបទរំលោភមួយចំនួន ដូចខាងក្រោម ៖

២.១១៦.១.១ ការប្រើកម្លាំងដកហូតឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតពីអ្នកបោះឆ្នោត ។

២.១១៦.១.២ ការប្រើកម្លាំង ឬអំពើហិង្សា ដើម្បីរាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ។

២.១១៦.១.៣ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំអ្នកបោះឆ្នោតឱ្យស្បថថានឹងបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ។

២.១១៦.១.៤ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត មិនឱ្យដំណើរការបាន ។

២.១១៦.១.៥ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង ឬអំពើហិង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ ។

២.១១៦.១.៦ ការប្រើកម្លាំង ឬអំពើហិង្សា ឬការបំភិតបំភ័យ ដែលបង្កឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ភាពច្របូកច្របល់ និងបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

២.១១៦.១.៧ ការបោកបញ្ឆោត ឬការលួងលោមដើម្បីទិញទឹកចិត្តអ្នកបោះឆ្នោតដោយការផ្តល់អំណោយជាសម្ភារ ឬប្រាក់កាស ។

២.១១៦.២ រូបភាពនៃការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកម្លាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈការស្តែងឡើងដោយពាក្យសម្តីជាលាយលក្ខណ៍អក្សរ ឬដោយកាយវិការ ដូចខាងក្រោម ៖

២.១១៦.២.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬដោយការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ ។

២.១១៦.២.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម ។

២.១១៦.២.៣ ការវាយតប់បន្តិចបន្តួច ឬធ្វូន់ធ្ងរលើបុគ្គលណាម្នាក់ ។

២.១១៦.២.៤ ការរំលោភដោយសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ ។

២.១១៦.២.៥ ការបង្ហាញ ឬការប្រើប្រាស់គ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។

២.១១៦.២.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាលដូចជាឃាតកម្ម ការវាយដំ ការរំលោភ ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

២.១១៦.២.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

២.១១៦.២.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណា ទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

២.១១៦.២.៩ ការបណ្ដើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍គាត់មានការភ័យខ្លាច ឬធ្វើឱ្យគាត់ខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសារគាត់ ។

២.១១៦.២.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ឬដកហូតមុខតំណែង ការដកហូតដីធ្លី ផ្ទះសម្បែង ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

២.១១៦.៣ ការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ដូចមានចែងក្នុងប្រការ ២.១១៦ ខាងលើ មិនច្រានចោលការប្ដឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៩ (ទោសប្បញ្ញត្តិ) នៃ ច.ប.ក ឡើយ។ ការប្ដឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៨ នៃ ច.ប.ក ត្រូវអនុវត្តតាម ច.ប.ក និងផ្នែកទី១១ នៃបទបញ្ជា និងនីតិវិធីនេះ ។

## ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោត នៅ គធ.ខប

### ប្រការ ២.១១៧.-

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ ។

២.១១៧.១ មជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតត្រូវមានទីតាំងនៅលេខាធិការដ្ឋាននៃ គធ.ខប ហើយត្រូវរៀបចំឱ្យមានកន្លែងបម្រុង ដូចខាងក្រោម ៖

២.១១៧.១.១ កន្លែងសម្រាប់ទទួល និងរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតដែលនៅសល់ តាមការិយាល័យបោះឆ្នោត។

២.១១៧.១.២ បន្ទប់ធំទូលាយមួយ ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងពេលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

២.១១៧.១.៣ បន្ទប់ស្អាតតូចមួយ សម្រាប់ដាក់គ្រឿងបរិក្ខារ កុំព្យូទ័រមួយសម្រាប់បំពាក់កម្មវិធី និងទម្រង់ឯកភាពមួយ សម្រាប់បញ្ចូលទិន្នន័យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត និងមានភ្ជាប់អ៊ីនធឺណិត ដើម្បីបញ្ជូនលទ្ធផលទៅ គ.ជ.ប ។

២.១១៧.២ គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលរបស់ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត និងត្រូវរៀបចំឱ្យមានបរិវេណសន្តិសុខមួយនៅអគារមជ្ឈមណ្ឌលនៃ គធ.ខប ដោយនៅបរិវេណខាងក្រៅត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់កម្លាំងការពារ និងនៅបរិវេណខាងក្នុងត្រូវរៀបចំចាត់ចែងកម្លាំងសន្តិសុខផ្ទាល់របស់ គ.ជ.ប ដើម្បីការពារ ។

២.១១៧.៣ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ត្រូវស្ថិតក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ.ខប ។

២.១១៧.៣.១ ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលនៃ គធ.ខប ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។

ត្រូវបានអនុញ្ញាតឱ្យចូលមជ្ឈមណ្ឌលនេះ នូវជនទាំងឡាយ ដូចខាងក្រោម ៖

- ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលបានទទួលការតែងតាំង ឬមន្ត្រី គធ.ខប ដែលចាត់ឱ្យជួយការងារ ។
- តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្ដឹង ។
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន ឬតំណាង គធ.ខប សំណូមពរក្នុងករណីចាំបាច់ ។

២.១១៧.៣.២ សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងមជ្ឈមណ្ឌលនៃ គធ.ខប ៖

- ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

២.១១៦.២.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណា ទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

២.១១៦.២.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍គាត់មានការភ័យខ្លាច ឬធ្វើឱ្យគាត់ខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសារគាត់ ។

២.១១៦.២.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ឬដកហូតមុខតំណែង ការដកហូតដីធ្លី ផ្ទះសម្បែង ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

២.១១៦.៣ ការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ដូចមានចែងក្នុងប្រការ ២.១១៦ ខាងលើ មិនច្រានចោលការប្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៨ (ទោសប្បញ្ញត្តិ) នៃ ច.ប.ក ឡើយ។ ការប្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី៨ នៃ ច.ប.ក ត្រូវអនុវត្តតាម ច.ប.ក និងផ្នែកទី១១ នៃបទបញ្ជា និងនីតិវិធីនេះ ។

**ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោត នៅ គធ.ខប**

**ប្រការ ២.១១៧.-**

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ ។

២.១១៧.១ មជ្ឈមណ្ឌលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ត្រូវមានទីតាំងនៅលេខាធិការដ្ឋាននៃ គធ.ខប ហើយត្រូវរៀបចំឱ្យមានកន្លែងបម្រុង ដូចខាងក្រោម ៖

២.១១៧.១.១ កន្លែងសម្រាប់ទទួល និងរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតដែលនៅសល់ តាមការិយាល័យបោះឆ្នោត។

២.១១៧.១.២ បន្ទប់ធំទូលាយមួយ ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងពេលត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

**កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

**ប្រការ ២.១១៨.-**

បន្ទាប់ពីបានទទួលស្បោង " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតរួចហើយ គធ.ខប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទាំងអស់ចំណុះរាជធានី ខេត្តនីមួយៗ បញ្ចូលគ្នាឱ្យរួចរាល់ ក្នុងរយៈពេលយ៉ាងយូរ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។ គធ.ខប ត្រូវធានាថាតារាងបូកសរុបលទ្ធផល កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផល និងក្រដាសលទ្ធផល តាមប្រភេទក្រុមប្រឹក្សានីមួយៗ ត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ចុះហត្ថលេខា និងបោះត្រាជាផ្លូវការ ។ កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវបានបិទផ្សាយជាសាធារណៈ នៅ គធ.ខប ។ ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្តរបស់ខ្លួន គធ.ខប ត្រូវចាប់ផ្ដើមពីការត្រួតពិនិត្យបញ្ជាក់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌជាមុន បន្ទាប់មកទើបអនុវត្តការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្តជាក្រោយ ។

២.១១៨.១ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្នុងរាជធានី ខេត្តពាក់ព័ន្ធ ។

២.១១៨.១.១ តំណាងគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃអង្គការនីមួយៗ ប្រចាំការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួន ១ (មួយ) នាក់ និងតំណាងបម្រុង ១ (មួយ) នាក់ សម្រាប់ចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្តរបស់ខ្លួន ។

២.១១៨.១.២ តំណាងគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលដំណើរនៃការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅរាជធានី ខេត្ត អាចផ្លាស់ប្ដូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន ។

២.១១៨.១.៣ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិត ល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការអនុវត្តខាងលើ ។

២.១១៨.១.៤ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អាចថតយករូបភាពនៃការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ ។

២.១១៨.២ កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌពីគ្រប់ការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត ប្រសិនបើចាប់ផ្ដើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយមិនត្រូវឈប់សម្រាកឡើយ ។

២.១១៨.៣ គធ.ខប ត្រូវត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ពីគ្រប់ការិយាល័យបោះឆ្នោត ដែលក្នុងនោះរួមទាំងលទ្ធផលបោះឆ្នោតនៃការិយាល័យដែលត្រូវបានរាប់សន្លឹកឆ្នោតនៅលេខាធិការដ្ឋាន គធ.ខប ឬនៅទីតាំងសុវត្ថិភាពណាមួយ រួមនឹងការិយាល័យដែលមានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ ត្រូវបាន គធ.ខប បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ២.១១៥.៧ និងត្រូវបាន គធ.ខប សម្រេចព្យួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតដូចមានចែងក្នុង ២.១១៥.១០ ផង ។

២.១១៨.៤ គធ.ខប ត្រូវធានាថា ទម្រង់បែបបទ និងសម្ភារៈ ឯកសារផ្សេងៗ សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតបានប្រគល់ជូនក្រុមត្រួតពិនិត្យលទ្ធផលរួចរាល់ និងគ្រប់គ្រាន់ ។

២.១១៨.៥ ក្នុងការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ប្រធានក្រុមត្រួតពិនិត្យ ត្រូវ ៖

២.១១៨.៥.១ បង្គាប់ជំនួយការឱ្យនាំយកស្បោង " ខ៥ " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌម្តងមួយៗពីកន្លែងរក្សាទុក មកដាក់នៅលើតុចំពីមុខគាត់ ។

២.១១៨.៥.២ បើកស្បោង " ខ៥ " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០១ស និង ទ.១១០២ស) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) ដែលផ្ញើជូន គធ.ខប មកដាក់នៅលើតុ ។

២.១១៨.៥.៣ ចាត់ចែងសមាជិកក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបតួលេខដែលមានកត់ត្រានៅក្នុង ទ.១១០១ស និង ទ.១១០៨ស រួចធ្វើការប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធ ដែលមានកត់ត្រាក្នុង ទ.១១០២ស ដើម្បីឱ្យដឹងប្រាកដថាលទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ ។

២.១១៨.៥.៤ ក្នុងករណីក្រុមត្រួតពិនិត្យ បានរកឃើញកំហុសក្នុងការគណនាតួលេខលទ្ធផលនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌណាមួយ ប្រធានត្រូវបង្ហាញកំហុស និងការកែតម្រូវ ព្រមទាំងហេតុផលនៃការកែតម្រូវនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុម ត្រូវគូសឆូតលើតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង ។ តំណាងគណបក្សនយោបាយមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវនេះ ។

២.១១៨.៥.៥ ធានាថា តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១៦គពស) បានបំពេញត្រឹមត្រូវដោយផ្អែកលើតួលេខក្នុង ទ.១១០២ស និងត្រូវបញ្ជាក់ឈ្មោះ និងលេខកូដក្រុង ស្រុក ខណ្ឌផង ។

២.១១៨.៥.៦ ណែនាំសមាជិកក្រុម ឱ្យបំពេញកំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១១ស) ចំនួន ៣ (បី) ច្បាប់ ដោយផ្អែកលើ ទ.១១០១ស និង ទ.១១០២ស ។

២.១១៨.៥.៧ ធានាថា ទ.១១១៦តពស ត្រូវបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។

២.១១៨.៥.៨ ធានាថា ទ.១១១៦តពស និង ទ.១១១១ស ខាងលើ ត្រូវបានដាក់ភ្ជាប់ជាមួយនឹង ទ.១១០១ស ទ.១១០២ស និង ទ.១១០៨ស នៃការិយាល័យបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌ ត្រៀមដាក់ជូន គធ.ខប ពិនិត្យសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ។

២.១១៨.៥.៩ ចាត់ចែងសមាជិកក្រុមឱ្យវេចខ្ចប់ស្បោង " ខ$_{ស}$ " ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " ក$_{ស}$ " និងស្រោមសំបុត្រដាក់ត្រា គ.ក.ប បន្ទាប់មកឱ្យនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

២.១១៨.៥.១០ ធានាថានីតិវិធីទាំងឡាយដូចមានចែងក្រោមចំណុច ២.១១៨.៥ ខាងលើ ត្រូវតែបានអនុវត្តដូចគ្នា សម្រាប់ស្បោង " ខ$_{ស}$ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌនៃការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្តរបស់ខ្លួន ។

២.១១៨.៦ ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ប្រធានក្រុម ត្រូវ ៖

២.១១៨.៦.១ បង្គាប់ជំនួយការឱ្យនាំយកស្បោង " ខ$_{ខ}$ " នៃក្រុមប្រឹក្សារាជធានី ខេត្តពីកន្លែងរក្សាទុក មកដាក់នៅលើតុចំពីមុខគាត់ ។

២.១១៨.៦.២ បើកស្បោង " ខ$_{ខ}$ " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០១ខ និង ទ.១១០២ខ) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ខ) ដែលផ្ញើជូន គធ.ខប មកដាក់នៅលើតុ ។

២.១១៨.៦.៣ ចាត់ចែងសមាជិកក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបតួលេខដែលមានកត់ត្រានៅក្នុង ទ.១១០១ខ និង ទ.១១០៨ខ នៃការិយាល័យបោះឆ្នោតនីមួយៗ រួចធ្វើការប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធដែលមានកត់ត្រាក្នុង ទ.១១០២ខ នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីឱ្យដឹងប្រាកដថាលទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ ។

២.១១៨.៦.៤ ក្នុងករណីក្រុមត្រួតពិនិត្យ បានរកឃើញកំហុសក្នុងការគណនាតួលេខលទ្ធផលនៃការិយាល័យបោះឆ្នោតណាមួយ ប្រធានត្រូវបង្ហាញកំហុស និងការកែតម្រូវ ព្រមទាំងហេតុផលនៃការកែតម្រូវនោះនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសឆូតលើតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង ។ តំណាងគណបក្សនយោបាយមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវនេះ ។

២.១១៨.៦.៥ ធានាថាតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) ត្រូវបានបំពេញត្រឹមត្រូវដោយផ្អែកលើតួលេខក្នុង ទ.១១០២ខ តាមការិយាល័យនីមួយៗ ។ ទន្ទឹមនេះចាត់ចែងសមាជិកក្រុមគណនាសរុបតួលេខលទ្ធផលដែលបានស្រង់ដាក់ក្នុង ទ.១១១០ខ ដោយធ្វើប្រមាណវិធីដោយដៃផង និងប្រើម៉ាស៊ីនគិតលេខផង បន្ទាប់មកផ្ទៀងផ្ទាត់លទ្ធផលគ្នា និងកត់ត្រាទិន្នន័យ និងតួលេខទាំងនេះទៅក្នុងតារាងត្រួតពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១៦តពខ) ។

២.១១៨.៦.៦ ធានាថា ទ.១១១៦តពខ ត្រូវបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។

២.១១៨.៦.៧ ណែនាំសមាជិកក្រុម ឱ្យបំពេញកំណត់ហេតុត្រួតពិនិត្យបញ្ជាក់និងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១១ខ) ចំនួន ៣ (បី) ច្បាប់ ដោយផ្អែកលើ ទ.១១១០ខ និង ទ.១១១១៦តពខ ដែលគណនា និងផ្ទៀងផ្ទាត់ ត្រឹមត្រូវហើយ ដូចមានចែងក្នុងចំណុច ២.១១៨.៦.៦ ។

២.១១៨.៦.៨ ធានាថា ទ.១១១៦តពខ ទ.១១១០ខ និង ទ.១១១១ខ ខាងលើ ត្រូវបានដាក់ភ្ជាប់ជាមួយនឹង ទ.១១០១ខ ទ.១១០២ខ និង ទ.១១០៨ខ តាមការិយាល័យបោះឆ្នោត ត្រៀមដាក់ជូន គធ.ខប ពិនិត្យសម្រេចតាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ។

២.១១៨.៦.៩ ចាត់ចែងសមាជិកក្រុមឱ្យវេចខ្ចប់ស្បោង " ខ៖ " ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " ក៖ " បន្ទាប់មកឱ្យនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

**ការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ហើយត្រូវបាន គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក "**

**ប្រការ ២.១១៩.-**

ចំពោះការិយាល័យបោះឆ្នោតណាមួយ ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់ក្នុងអំឡុងពេលដូចមានចែងក្នុងប្រការ ២.១១៥ និងប្រការ ២.១១៦ ខាងលើ ហើយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់នោះតម្រូវឱ្យ គធ.ខប បើកកញ្ចប់សុវត្ថិភាព "ក៙" ឬ/និង "ក៖" ណាមួយ ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចមានចែងក្នុងចំណុច ២.១១៥.៧ ខាងលើ ប្រធាន គធ.ខប ត្រូវណែនាំប្រធានក្រុមត្រួតពិនិត្យ ដូចខាងក្រោម ៖

២.១១៩.១ ដកយកកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គធ.ខប ពីក្នុងស្បោង " ខ " ពាក់ព័ន្ធ មកដាក់នៅលើតុក្បែរខ្លួនគាត់ ។

២.១១៩.២ បើកកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធ រួចដកយករាល់ស្រោមសំបុត្រ ឬ/និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នា នៅលើតុខាងមុខគាត់ ។ បើកស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់តាមនីតិវិធី ដូចមានចែងក្រោមចំណុច ២.១១៩.៣ ខាងក្រោម ។

២.១១៩.៣ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រូវចាត់ចែងការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះឡើងវិញ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ និងបញ្ហាជារួម ដូចខាងក្រោម ៖

២.១១៩.៣.១ ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោតនិងរាប់សន្លឹកឆ្នោត។

២.១១៩.៣.២ ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

២.១១៩.៣.៣ ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានមកបោះឆ្នោត (ប្រសិនបើពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត បញ្ជីបោះឆ្នោតត្រូវដកចេញពីកញ្ចប់សុវត្ថិភាព " កស " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ) ។

២.១១៩.៣.៤ ពិនិត្យផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ដែលមិនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ នៅក្នុងក្រដាសព័ត៌មាន (ប្រសិនបើមាន) ។

២.១១៩.៣.៥ ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោត ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតពាក់ព័ន្ធដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ ។

២.១១៩.៣.៦ រាប់ចំនួនសន្លឹកឆ្នោតខូចពេលបោះឆ្នោត (ប្រសិនបើមាន) ។

២.១១៩.៣.៧ រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ ។

២.១១៩.៣.៨ ពិនិត្យសន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត (ប្រសិនបើមាន)។

២.១១៩.៣.៩ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ ។

២.១១៩.៣.១០ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។

២.១១៩.៣.១១ ពិនិត្យមើលថាតើនៅក្នុង ទ.១១០១ និង ទ.១១០២ មានចុះអំពីភាពមិនប្រក្រតីដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត។

២.១១៩.៣.១២ ពិនិត្យមើលថាតើនៅក្នុង ទ.១១០១ និង ទ.១១០២ ភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាជាសាក្សីដែរឬទេ ។

២.១១៩.៣.១៣ អនុវត្តការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្តឹងនោះ ដោយអនុវត្តតាមលំនាំនីតិវិធី និងការកំណត់ដូចមានចែងក្រោមប្រការ ២.១១០.៧ ដល់ ២.១១០.៩ ខាងលើ ។

២.១១៩.៤ បន្ទាប់ពីអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ដូចមានចែងក្រោមចំណុច ២.១១៩.៣ ខាងលើរួចរាល់ហើយ ប្រធានក្រុមត្រូវធ្វើការប្រៀបធៀបលទ្ធផល ដែលបានត្រួតពិនិត្យ

ផ្ទៀងផ្ទាត់ឃើញ និងបានរាប់ឃើញជាមួយនឹងទិន្នន័យ និងតួលេខដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតហើយត្រូវចាត់ចែងអនុវត្ត ដូចខាងក្រោម ៖

២.១១៩.៤.១ ធ្វើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "កស" ឬ "កខ" ពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។ ក្នុងរបាយការណ៍នេះ ត្រូវតែមានការលើកយោបល់ស្នើសុំ គធ.ខប ពិនិត្យសម្រេច ៖

- យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ
- ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

២.១១៩.៤.២ ដាក់របាយការណ៍ខាងលើភ្ជាប់ជាមួយតារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារពាក់ព័ន្ធ ដាក់ជូន គធ.ខប ពិនិត្យសម្រេច។

២.១១៩.៤.៣ រក្សា ១ (មួយ) ច្បាប់ ទុកជាឯកសាររបស់ គធ.ខប ប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

២.១១៩.៤.៤ ដាក់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " តាមលំនាំដើមវិញ ។

២.១១៩.៤.៥ ដាក់កញ្ចប់សុវត្ថិភាព " ក " និងរាល់ស្រោមសំបុត្រទៅក្នុងស្បោង " ខ " ពាក់ព័ន្ធឡើងវិញ តាមលំនាំដើម រួចនាំយកទៅរក្សាទុកនៅកន្លែងដើម ដើម្បីប្រើប្រាស់ក្នុងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងត្រៀមវេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប ។

**ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់**

២.១១៩.៥ ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ គធ.ខប ត្រូវបដិសេធពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ។ ប្រធាន គធ.ខប ត្រូវ ៖

២.១១៩.៥.១ ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល និងលើរបាយការណ៍ ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " របស់ក្រុមត្រួតពិនិត្យលទ្ធផល នៃ គធ.ខប រួចចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទ ព្រមទាំង ដាក់បង្ហាញចំពោះអ្នកប្តឹង តំណាងគណបក្សនយោបាយ និងអ្នក សង្កេតការណ៍ដែលមានវត្តមាន ។

២.១១៩.៥.២ ចាត់លេខាធិការអង្គប្រជុំសម្រេច ឱ្យបំពេញសម្រង់សេចក្តីសម្រេច យល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យ បោះឆ្នោតពាក់ព័ន្ធ និងបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យ បណ្តឹងជំទាស់ (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ ដោយមានបញ្ជាក់ ពីមូលហេតុនៃការបដិសេធផង ហើយត្រូវចុះហត្ថលេខាដោយ លេខាធិការអង្គប្រជុំសម្រេច និងប្រធាន គធ.ខប ចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

២.១១៩.៥.៣ ប្រគល់ ទ.១២០៣ ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.១១៩.៥.៤ ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃ បានទទួលសម្រង់សេចក្តីសម្រេចបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និង ពាក្យបណ្តឹងជំទាស់ ។

២.១១៩.៥.៥ ប្រគល់ជូនអ្នកប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់នូវ ទ.១២០២ សម្រាប់ បំពេញពាក្យបណ្តឹង ចំនួន ៣ (បី) ច្បាប់ ប្រសិនបើគាត់ស្នើសុំ ។

២.១១៩.៦ ប្រសិនបើ គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅ ការិយាល័យបោះឆ្នោតពាក់ព័ន្ធ គធ.ខប ត្រូវយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬ/និង ពាក្យបណ្តឹងជំទាស់ និងត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យ បោះឆ្នោតពាក់ព័ន្ធនោះ ។ ប្រធាន គធ.ខប ត្រូវ ៖

២.១១៩.៦.១ ចារព្យួរលទ្ធផលលើតារាងត្រួតពិនិត្យលទ្ធផល និងលើរបាយការណ៍ ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " របស់ក្រុមត្រួតពិនិត្យលទ្ធផល នៃ គធ.ខប រួចចុះហត្ថលេខា បោះត្រា និងកាលបរិច្ឆេទ ព្រមទាំង ដាក់បង្ហាញចំពោះអ្នកប្តឹង តំណាងគណបក្សនយោបាយ និងអ្នក សង្កេតការណ៍ដែលមានវត្តមាន ។

២.១១៩.៦.២ ចាត់លេខាធិការអង្គប្រជុំសម្រេច ឱ្យបំពេញសម្រង់សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្នលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ ដោយមានបញ្ជាក់ពីមូលហេតុផង ហើយត្រូវចុះហត្ថលេខាដោយលេខាធិការ អង្គប្រជុំសម្រេច និងប្រធាន គធ.ខប ចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

២.១១៩.៦.៣ ប្រគល់ ទ.១២០៣ ជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងត្រូវថតចម្លងបន្ថែមជូនគ្រប់តំណាងគណបក្សនយោបាយ ។

២.១១៩.៦.៤ ប្រកាសថា លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ ត្រូវបានព្យួរជាបណ្ដោះអាសន្នដោយ គធ.ខប ហើយសេចក្ដីសម្រេចនេះស្ថិតក្រោមការត្រួតពិនិត្យរបស់ គ.ជ.ប ។

២.១១៩.៦.៥ ធានាថាសមាជិកទទួលបន្ទុករដ្ឋបាល បានដាក់ទៅក្នុងស្រោមសំបុត្រដោយឡែកពីគ្នាសម្រាប់ផ្ញើជូន គ.ជ.ប នូវសម្រង់សេចក្ដីសម្រេចរបស់ គធ.ខប ព្យួរជាបណ្ដោះអាសន្នលទ្ធផលនៃការបោះឆ្នោត តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផល និងរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដែលត្រូវបាន គធ.ខប ចារព្យួរជាបណ្ដោះអាសន្ន ក្នុងមួយមុខៗចំនួន ១ (មួយ) ច្បាប់ ។

២.១១៩.៧ ក្នុងករណី គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គធ.ខប ត្រូវរៀបចំវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទាំងអស់ជូន គ.ជ.ប មិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលចេញសម្រង់សេចក្ដីសម្រេចព្យួរលទ្ធផល ។ ប្រធាន គធ.ខប ត្រូវ ៖

២.១១៩.៧.១ ដាក់ទៅក្នុងស្រោមសំបុត្រធំមួយ នូវរាល់ស្រោមសំបុត្រដូចមានចែងក្នុងចំណុច ២.១១៩.៦.៥ និងសម្ភារ ឯកសារពាក់ព័ន្ធផ្ញើជូន គ.ជ.ប ហើយត្រូវសរសេរសម្គាល់ពីក្រៅថា " សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតលេខ.....(បំពេញលេខកូដក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តពាក់ព័ន្ធ) " ។

២.១១៩.៧.២ ចាត់ចែងបំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយរាយមុខសម្ភារ ឯកសារដែលមាននៅក្នុងស្រោមសំបុត្រធំ ។

២.១១៩.៧.៣ ដាក់ ទ.១១០៧ ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្រធំ រួចកិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំនេះ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.១១៩.៧.៤ ចាត់ចែងវេចខ្ចប់ស្បោង "ឃ" ដាក់ស្បោង "ខ" ផ្ទុកកញ្ចប់សុវត្ថិភាព " ក " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារនៃការិយាល័យបោះឆ្នោតដែលត្រូវបានព្យួរជាបណ្ដោះអាសន្ន សម្រាប់បញ្ជូនទៅ គ.ជ.ប ។

២.១១៩.៨ ប្រធាន គធ.ខប ត្រូវពិនិត្យសម្រេចលើតារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត (ទ.១១១៦គព) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត (ទ.១១១១) តាមប្រភេទក្រុមប្រឹក្សានីមួយៗ និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) ដែលដាក់ជូនដូចមានចែងក្នុងចំណុច ២.១១៨.៥.៨ និង ២.១១៨.៦.៨ ខាងលើ ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ ប្រធាន គធ.ខប ត្រូវផ្ដល់ការយល់ព្រម រួចចុះហត្ថលេខា បោះត្រា ចុះកាលបរិច្ឆេទ និងដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ហើយត្រូវ ៖

២.១១៩.៨.១ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើ ទ.១១១១ស និង ទ.១១១១ខ ។

២.១១៩.៨.២ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុនេះពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកកំណត់ហេតុនេះជាមោឃៈបានទេ ។

២.១១៩.៩ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១១ខ និង ទ.១១១១ស ) ដូចខាងក្រោម ៖

២.១១៩.៩.១ បិទផ្សាយ ១ (មួយ) ច្បាប់ៗ នៅលេខាធិការដ្ឋាននៃ គធ.ខប អមដោយកំណត់ហេតុស្ដីពីការបិទផ្សាយ ។

២.១១៩.៩.២ ផ្ញើ ១ (មួយ) ច្បាប់ៗ ជូន គ.ជ.ប ។

២.១១៩.៩.៣ អាចថតចម្លងសម្រាប់ចែកជូនតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ១ (មួយ) ច្បាប់ៗ តាមការស្នើសុំ ។

២.១១៩.៩.៤ រក្សាទុក ១ (មួយ) ច្បាប់ៗ សម្រាប់ប្រើក្នុងការបែងចែកអាសនៈតាមប្រភេទក្រុមប្រឹក្សានីមួយៗ ដែលក្រោយមកត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប ។

២.១១៩.១០ ទោះបី គធ.ខប បានសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយ និងបានលើកសំណើសុំ គ.ជ.ប ត្រួតពិនិត្យសម្រេចឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយនោះ ដូចមានចែងក្រោមចំណុច ២.១១៥.១០ ខាងលើ ក៏ដោយ ក៏ គធ.ខប ត្រូវត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ជាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធចំណុះរាជធានី ខេត្តរបស់ខ្លួនដែរ ។

## ការកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

**ប្រការ ២.១២០.-**

បន្ទាប់ពីបានត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ បានធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងការរាប់សន្លឹកឆ្នោត (ប្រសិនបើមាន) និងបានដោះស្រាយពាក្យបណ្តឹងនៅថ្នាក់របស់ខ្លួនចប់សព្វគ្រប់ ប្រធាន គធ.ខប ត្រូវកំណត់ចំនួនអាសនៈក្រុមប្រឹក្សាសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្តរបស់ខ្លួន និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាតាមប្រភេទនីមួយៗស្របតាមបញ្ញត្តិនៃ ច.ប.ក និង ច.គ.ខ.ស ។ ក្នុងការអនុវត្តភារកិច្ចនេះ គធ.ខប ត្រូវកំណត់ចំនួនអាសនៈក្រុមប្រឹក្សា សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្តឱ្យហើយរួចរាល់ មុននឹងអនុវត្តការកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ។

២.១២០.១ ប្រធាន គធ.ខប ត្រូវធានាឱ្យមានកុំព្យូទ័រមួយសម្រាប់ ដែលមានម៉ាស៊ីនស្កេន ម៉ាស៊ីនបោះពុម្ព ប្រព័ន្ធអ៊ីមែល និងដែលបំពាក់ដោយកម្មវិធីប្រតិបត្តិការបែងចែកអាសនៈផ្អែកតាមរូបមន្ត និងនីតិវិធីដូចចែងក្នុងជំពូកទី ២ ផ្នែកទី ២ នៃ ប.ន.ក នេះ ។ ប្រធាន គធ.ខប ត្រូវ ៖

២.១២០.១.១ ធានាថាគ្រឿងបរិក្ខារកុំព្យូទ័រដែលបានដំឡើង និងដំណើរការបាន ល្អត្រឹមត្រូវ ដោយមានផ្ទុកទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀត ។

២.១២០.១.២ ធានាឱ្យមានបញ្ជីបេក្ខជន នៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌទាំងអស់ចំណុះរាជធានី ខេត្ត (បញ្ជីផ្លូវការ) ១ (មួយ) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការពិនិត្យផ្ទៀងផ្ទាត់ ។

២.១២០.១.៣ ថែរក្សាថាសទន់ដែលផ្ទុកកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ និងទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្តពាក់ព័ន្ធឱ្យបានល្អ និងគត់មត់ ។

២.១២០.១.៤ ត្រូវរាយការណ៍ និងស្នើសុំជំនួយអន្តរាគមន៍ជាបន្ទាន់ពី គ.ជ.ប ក្នុងករណីថាសទន់ ដែលផ្ទុកកម្មវិធីប្រតិបត្តិការបែងចែកអាសនៈ ត្រូវខូច ឬមិនអាចប្រើប្រាស់បាន ។

២.១២០.២ ប្រធានក្រុមកំណត់បែងចែកអាសនៈ ត្រូវធានាថារាល់តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ (ទ.១១១៦គ៣) និងរបាយការណ៍ ដូចមានចែងក្នុងប្រការ ២.១២០ ខាងលើ ត្រូវតែបានត្រួតពិនិត្យសុពលភាពឱ្យប្រាកដថា ប្រធាន គធ.ខប បានចារយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ព្រមទាំងត្រូវបានរៀបចំដោយឡែក តាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ ។

២.១២០.៣ នៅក្នុងការគណនា និងកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធណាមួយ ប្រធានក្រុមកំណត់ចំនួនអាសនៈ ត្រូវ ៖

២.១២០.៣.១ ចាត់សមាជិកក្រុម និងលេខាធិការឱ្យសហការគ្នាបញ្ចូលយ៉ាងត្រឹមត្រូវនូវទិន្នន័យនៃចំនួនសំឡេងឆ្នោតគាំទ្រគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ

ក្រុង ស្រុក ខណ្ឌនីមួយៗ ទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ដោយផ្អែកតាមតួលេខលទ្ធផលនៅក្នុងកំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ទ.១១១១ស ឬ ទ.១១១១ខ) ពាក់ព័ន្ធ ។

២.១២០.៣.២ ធានាថាបន្ទាប់ពីបានបញ្ចូលទិន្នន័យត្រឹមត្រូវ និងបានបញ្ជាកម្មវិធីប្រតិបត្តិការកំណត់ចំនួនអាសនៈក្នុងកុំព្យូទ័រឱ្យគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធរួច លេខាធិការត្រូវបោះពុម្ពលទ្ធផលទាំងនេះ ១ (មួយ) ច្បាប់ ។

២.១២០.៣.៣ ចាត់សមាជិកដទៃទៀត ឱ្យអនុវត្តប្រមាណវិធីដោយដៃ ឬ/និងម៉ាស៊ីនគិតលេខ ដោយផ្អែកតាមរូបមន្តនៃការបែងចែកអាសនៈដូចមានចែងក្នុងជំពូកទី២ ផ្នែកទី២ នៃ ប.ន.ក នេះ ដើម្បីគណនារកលទ្ធផលនៃការកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ។

២.១២០.៣.៤ ចាត់ចែងសមាជិកក្នុងក្រុម ឱ្យសហការគ្នាផ្ទៀងផ្ទាត់ និងគណនាឡើងវិញដោយផ្អែកតាមរូបមន្តបែងចែកអាសនៈ ដូចមានចែងក្នុងជំពូកទី២ ផ្នែកទី២ នៃ ប.ន.ក នេះ ប្រសិនបើលទ្ធផលនៃការគណនាតាមរូបភាពទាំងពីរខាងលើមានភាពខុសគ្នា ។

២.១២០.៣.៥ ធានាថាក្រដាសលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈ តាមរបៀបទាំងពីរ ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវដូចគ្នាហើយ ត្រូវបានចុះហត្ថលេខា ដោយសមាសភាពទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ ។

២.១២០.៤ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចមានចែងក្រោមចំណុច ២.១២០.៣ និងផ្អែកលើលទ្ធផលនៃការគណនាកំណត់ចំនួនអាសនៈ ដូចមានចែងក្នុងចំណុច ២.១២០.៣.៥ ប្រធានក្រុមកំណត់ចំនួនអាសនៈ ត្រូវ ៖

២.១២០.៤.១ ចាត់ចែងសមាជិកក្រុមឱ្យបំពេញលទ្ធផលបណ្ដោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទ.១១១៤ស ឬ ទ.១១១៤ខ) ចំនួន ៣ (បី) ច្បាប់ នូវ ៖

- ឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ ចំនួនសំឡេងឆ្នោតគាំទ្រសរុប និងចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗទទួលបាន ដោយគិតតាមលំដាប់ពីខ្ពស់មកទាប ។
- ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ក្នុងនោះត្រូវបញ្ជាក់ចំពោះបេក្ខជនដែលត្រូវជាប់ជាប្រធានក្រុមប្រឹក្សាតាមប្រភេទនីមួយៗផង ។

២.១២០.៤.២ ធានាថាការស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ត្រូវតែផ្អែកលើបញ្ជីបេក្ខជនផ្លូវការនៃគណបក្សនយោបាយ ដែលបានទទួលអាសនៈ ដោយគិតតាមលំដាប់ពីខ្ពស់មកទាប ។

២.១២០.៤.៣ ធានាថា ទ.១១១៨ស ឬ ទ.១១១៨ខ ទាំង ៣ (បី) ច្បាប់ ត្រូវតែបានចុះហត្ថលេខាសង្ខេប ដោយសមាជិកទាំងអស់នៃក្រុមកំណត់ចំនួនអាសនៈ និងចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប ។

២.១២០.៥ លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ (ទ.១១១៨ស ឬ ទ.១១១៨ខ) ចំនួន ៣ (បី) ច្បាប់ ដូចមានបញ្ជាក់ក្នុងចំណុច ២.១២០.៤.៣ ត្រូវដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ។ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់ទម្រង់បែបបទខាងលើនេះ ដូចខាងក្រោម ៖

២.១២០.៥.១ ផ្ញើជូន គ.ជ.ប ពី (២) ច្បាប់ ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ទងថា " លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ លេខកូដ..... (បំពេញលេខកូដរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ) ផ្ញើជូន គ.ជ.ប " ។

២.១២០.៥.២ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

២.១២០.៦ ក្នុងករណីដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន មានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សាត្រូវបានជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

២.១២០.៧ ប្រសិនបើការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌណាមួយ ក្នុងការគណនារូបមន្តបែងចែកអាសនៈមានលទ្ធផលស្មើគ្នា រវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ដែលនឹងត្រូវបានទទួលអាសនៈក្នុងក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌណាមួយនោះ ប្រធាន គធ.ខប ត្រូវចាត់ចែងអនុវត្តការចាប់ឆ្នោត ដោយផ្អែកតាមលក្ខខណ្ឌ និងនីតិវិធីស្តីពីការចាប់ឆ្នោតដូចមានចែងក្នុងជំពូកទី ២ ផ្នែកទី២ នៃ ប.ន.ក នេះ ។ ប្រធាន គធ.ខប ត្រូវធានាថាកំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចមានបញ្ជាក់ក្នុងចំណុចនេះ ត្រូវបានធ្វើជា ២ (ពីរ) ច្បាប់ ដែល ១ (មួយ) ច្បាប់ ត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប និង ១ (មួយ) ច្បាប់ទៀត ត្រូវដាក់ក្នុងកញ្ចប់ " យ$_{ស}$ ពិសេស " ឬ " យ$_{ខ}$ ពិសេស " ផ្ញើជូន គ.ជ.ប ។

២.១២០.៨ ប្រសិនបើការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌណាមួយមានលទ្ធផលសំឡេងឆ្នោតស្មើគ្នា និងចំនួនអាសនៈស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរ ឬច្រើន ប្រធាន គធ.ខប ត្រូវចាត់ចែងអនុវត្តការចាប់ឆ្នោតដើម្បីកំណត់បញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវទទួលធ្វើជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ឬ ក្រុង ស្រុក ខណ្ឌ ដោយផ្អែកតាមនីតិវិធីដូចមានចែងក្នុងជំពូកទី ២ ផ្នែកទី២ នៃ ប.ន.ក នេះ ។ ប្រធាន គធ.ខប ត្រូវធានាថាកំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចមានបញ្ជាក់ក្នុងចំណុចនេះ ត្រូវបានធ្វើជា ២ (ពីរ) ច្បាប់ ដែល ១ (មួយ) ច្បាប់ ត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប និង ១ (មួយ) ច្បាប់ទៀតត្រូវដាក់ក្នុងកញ្ចប់ " យ$_{ស}$ ពិសេស " ឬ " យ$_{ខ}$ ពិសេស " ផ្ញើជូន គ.ជ.ប ។

**ការវេចខ្ចប់ និងការបញ្ជូនលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងរាល់សម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធ ទៅ គ.ជ.ប**

**ប្រការ ២.១២១.-**

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងចាប់ពីប្រការ ២.១១៨ ដល់ ២.១២០ ខាងលើ ប្រធាន គធ.ខប ត្រូវវេចខ្ចប់កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រភេទនីមួយៗ ដាក់ក្នុងកញ្ចប់ " យ$_{ស}$ ពិសេស " ឬកញ្ចប់ " យ$_{ខ}$ ពិសេស " ដោយឡែកពីគ្នា ។ ក្នុងការវេចខ្ចប់នេះប្រធាន គធ.ខប ត្រូវធានាថាសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១៦តពស) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើស

ជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១១ស) លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១៤ស) និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ " ឃស ពិសេស " ហើយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១១ខ) លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១៤ខ) និងឯកសារពាក់ព័ន្ធផ្សេងទៀត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ " ឃខពិសេស " ។ ឯរាល់ស្បោង " ខស " ដាក់សម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.១១៨.៥.៩ ត្រូវតែបានវេចខ្ចប់ទៅក្នុងស្បោង " ឃស " ហើយរាល់ស្បោង " ខខ " ដាក់សម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.១១៨.៦.៩ ត្រូវតែបានវេចខ្ចប់ទៅក្នុងស្បោង " ឃខ " និងត្រូវប្រគល់ជូន គ.ជ.ប បានយ៉ាងត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពី គ.ក.ប ។

២.១២១.១ ប្រធាន គធ.ខប ត្រូវចាត់ចែងវេចខ្ចប់ដាក់ក្នុងកញ្ចប់ " ឃស ពិសេស " នូវរាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសំខាន់ៗ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្នុងកញ្ចប់ " ឃខ ពិសេស " នូវរាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសំខាន់ៗដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ចំណុះរាជធានី ខេត្តរបស់ខ្លួន សម្រាប់ផ្ញើជូន គ.ជ.ប ។ ប្រធាន គធ.ខប ត្រូវត្រួតពិនិត្យឡើងវិញ និងរៀបចំចងជាបាច់ទៅតាមប្រភេទស្រោមសំបុត្រដាក់ឯកសារ ដែលត្រូវដាក់ក្នុងកញ្ចប់ " ឃ ពិសេស " ទាំងនោះ ។

២.១២១.២ ប្រធាន គធ.ខប ត្រូវធានាថាកញ្ចប់ " ឃស ពិសេស " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលត្រូវផ្ញើជូន គ.ជ.ប ត្រូវមានរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោត ដូចខាងក្រោម ៖

២.១២១.២.១ ស្រោមសំបុត្រតែមួយសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមួយ ដាក់តារាងត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១៦តពស) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់លទ្ធផលបណ្តោះអាសន្ន នៃការ

បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ (ទ.១១១១ស) លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (ទ.១១១៩ស) ។

២.១២១.២.២ រាល់ស្រោមសំបុត្រដាក់ច្បាប់ថតចម្លងនៃកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០១ស និង ទ.១១០២ស) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ស) ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ។

២.១២១.២.៣ ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសេចក្តីសម្រេចរបស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន) ។

២.១២១.២.៤ ស្រោមសំបុត្រតែមួយ ដាក់រាល់សម្រង់សេចក្តីសម្រេចរបស់ គធ.ខប ដែលបានបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ (ទ.១២០៣) ផ្ញើជូន គ.ជ.ប ។

២.១២១.២.៥ កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចមានចែងក្នុងចំណុច ២.១២០.៧ និង ២.១២០.៨ ។

២.១២១.២.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ។

២.១២១.៣ ក្នុងការវេចខ្ចប់កញ្ចប់ " ឃ$_{ខ}$ ពិសេស " នៃក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីផ្ញើជូន គ.ជ.ប ប្រធាន គធ.ខប ត្រូវដាក់រាល់ស្រោមសំបុត្រមានផ្ទុកសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម ៖

២.១២១.៣.១ ស្រោមសំបុត្រតែមួយសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ដាក់តារាងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ) តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១១ខ) លទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១៩ខ) ។

២.១២១.៣.២ រាល់ស្រោមសំបុត្រដាក់ច្បាប់ថតចម្លងនៃកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០១ខ និង ទ.១១០២ខ) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨ខ) ផ្ញើជូន គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ។

២.១២១.៣.៣ ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក₂ " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងសេចក្តីសម្រេចរបស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន) ។

២.១២១.៣.៤ ស្រោមសំបុត្រតែមួយដាក់រាល់សម្រង់សេចក្តីសម្រេចរបស់ គធ.ខប ដែលបានបដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ (ទ.១២០៣) ផ្ញើជូន គ.ជ.ប ។

២.១២១.៣.៥ កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចមានចែងក្នុងចំណុច ២.១២០.៧ និង ២.១២០.៨ ។

២.១២១.៣.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ។

២.១២១.៤ ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារៈ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ សម្រាប់កញ្ចប់ " ឃពិសេស " នីមួយៗ ដោយមានរាយមុខសម្ភារៈ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " ឃ₃ ពិសេស " ឬកញ្ចប់ " ឃ₂ ពិសេស " ខាងលើ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្ររួចដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " នីមួយៗ ហើយដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " ឃពិសេស " នីមួយៗនោះ និងត្រៀមទុក ១ (មួយ) ច្បាប់ៗ សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារៈ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

២.១២១.៥ ប្រធាន គធ.ខប ត្រូវធានាថារាល់ស្រោមសំបុត្រដាក់សម្ភារៈ ឯកសារបោះឆ្នោត ដូចចែងក្រោមចំណុច ២.១២១.២ និង ២.១២១.៣ ខាងលើ ត្រូវបានរៀបចំដាក់ក្នុងកញ្ចប់ " ឃ₃ ពិសេស " និងកញ្ចប់ " ឃ₂ ពិសេស " ឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ នៅមុនពេលត្រូវបិទភ្ជិតដោយការសុវត្ថិភាព ។ សម្រាប់កញ្ចប់ " ឃ₃ ពិសេស " ប្រធាន គធ.ខប ត្រូវសរសេរសម្គាល់ឈ្មោះ និងលេខកូដរាជធានី ឬខេត្ត និងក្រុង ឬស្រុក ឬខណ្ឌ និងសម្រាប់កញ្ចប់ " ឃ₂ ពិសេស " ត្រូវសរសេរតែឈ្មោះ និងលេខកូដរាជធានី ឬខេត្តប៉ុណ្ណោះ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ។

២.១២១.៦ ក្នុងករណី គធ.ឃប បានសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងចំណុច ២.១១៥.១០.២ ប្រធាន គធ.ឃប ត្រូវធានាថាសេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ទម្រង់បែបបទត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សម្ភារ និងឯកសារបោះឆ្នោតពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ត្រូវតែបានវេចខ្ចប់ដោយឡែកតាមប្រភេទក្រុមប្រឹក្សានីមួយៗ និងបញ្ជូនទៅ គ.ជ.ប ។ ក្នុងនេះប្រធាន គធ.ឃប ត្រូវ ៖

២.១២១.៦.១ រៀបចំដាក់ក្នុងស្រោមសំបុត្រធំមួយនូវឯកសារបោះឆ្នោត ដូចខាងក្រោម ៖

- របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " កស " ឬ " កខ " ពាក់ព័ន្ធ ដើម្បីពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។
- សេចក្តីសម្រេចយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលត្រូវព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ។
- ស្រោមសំបុត្រតែមួយដាក់តារាងត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទ.១១១៦តពស ឬ ទ.១១១៦តពខ) កំណត់ហេតុត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទ.១១១១ស ឬ ទ.១១១១ខ) លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ (ទ.១១១៤ស ឬ ទ.១១១៤ខ) និងតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត (ទ.១១១០ខ សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ) ។
- កំណត់ហេតុស្តីពីលទ្ធផលនៃការចាប់ឆ្នោត ដូចមានចែងក្នុងចំណុច ២.១២០.៧ និង ២.១២០.៨ (ប្រសិនបើមាន)។
- ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ។

២.១២១.៦.២ ចាត់ចែងដាក់ទៅក្នុងស្បោង " យស " ឬ/និង " យខ " ដោយឡែកនូវស្បោង " ខស " ផ្ទុកកញ្ចប់សុវត្ថិភាព " កស " ឬ/និងស្បោង " ខខ " ផ្ទុកកញ្ចប់សុវត្ថិភាព " កខ " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យនោះ ឬទាំងនោះ ត្រូវបានព្យួរជាបណ្ដោះអាសន្នដោយ គធ.ខប។

២.១២១.៦.៣ ចងភ្ជិតស្បោង " យ " ពាក់ព័ន្ធ រួចចាក់សោឃ្លុំ និងសរសេរសម្គាល់ខាងក្រៅស្បោង " យ " នោះ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឈ្មោះរាជធានី ខេត្ត និងលេខកូដមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ និងពាក្យថា " ព្យួរលទ្ធផល " ។

២.១២១.៦.៤ ចាត់ចែងបំពេញ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ សម្រាប់ស្រោមសំបុត្រធំមួយ និងស្បោង " យ " ពាក់ព័ន្ធ ដែលត្រូវដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្រធំ បន្ទាប់មកកិប ១ (មួយ) ច្បាប់ជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំនោះ និងត្រៀម ១ (មួយ) ច្បាប់ៗ សម្រាប់ប្រើនៅពេលប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

២.១២១.៦.៥ បញ្ជូនស្រោមសំបុត្រធំ និងស្បោង " យ " ដូចមានចែងក្នុងចំណុច ២.១២១.៦.១ និង ២.១២១.៦.៣ ខាងលើ ដើម្បីប្រគល់ជូន គ.ជ.ប យ៉ាងយូរត្រឹម ២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលដែល គធ.ខប បានចេញសេចក្ដីសម្រេចយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដែលត្រូវព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ។

២.១២១.៧ ចំពោះការិយាល័យបោះឆ្នោតក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្ត ដែលគ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ ប្រធាន គធ.ខប ត្រូវចាត់ចែងវេចខ្ចប់ស្បោង " យស " និងស្បោង " យខ " ពាក់ព័ន្ធតាមប្រភេទក្រុមប្រឹក្សា ត្រៀមសម្រាប់ការបញ្ជូន និងប្រគល់ជូន គ.ជ.ប ។ ប្រធាន គធ.ខប ត្រូវ ៖

២.១២១.៧.១ ចាត់ចែងវេចខ្ចប់រាល់ស្បោង " ខ$_{ស}$ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងនោះទៅក្នុងស្បោង " ឃ$_{ស}$ " នៃក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងរាល់ស្បោង " ខ$_{ខ}$ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក$_{ខ}$ " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងនោះទៅក្នុងស្បោង " ឃ$_{ខ}$ " នៃក្រុមប្រឹក្សារាជធានី ខេត្ត ។

២.១២១.៧.២ ចាត់ចែងបំពេញ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួល សម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់សម្រាប់ស្បោង " ឃ " នីមួយៗ ដែលត្រូវដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងស្បោង " ឃ " នីមួយៗនោះ បន្ទាប់មកដាក់ ១ (មួយ) ច្បាប់ទៀតក្នុងហោប៉ៅស្បោង " ឃ " ពាក់ព័ន្ធ និងត្រៀម ១ (មួយ) ច្បាប់ៗ សម្រាប់ប្រើនៅពេលប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

២.១២១.៧.៣ ចងភ្ជិតស្បោង " ឃ " រួចចាក់សោឃ្លុំមានលេខ និងសរសេរសម្គាល់ខាងក្រៅស្បោង " ឃ " ទាំងនោះ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យបោះឆ្នោតពីលេខប៉ុន្មានដល់លេខប៉ុន្មាន ឈ្មោះ និងលេខកូដរាជ ធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ និងពាក្យថា " ពិនិត្យរួច " ។

២.១២១.៨ ចំពោះការិយាល័យបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌណាមានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ ដែលមាន ឬគ្មានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រធាន គធ.ខប ត្រូវចាត់ចែងវេចខ្ចប់រាល់ស្បោង " ខ$_{ស}$ " ផ្ទុកកញ្ចប់សុវត្ថិភាព " ក$_{ស}$ " និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោង " ឃ$_{ស}$ មានបណ្ដឹង " ឬ/និងរាល់ស្បោង " ខ$_{ខ}$ " ផ្ទុកកញ្ចប់សុវត្ថិភាព "ក$_{ខ}$" និងរាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោង " ឃ$_{ខ}$ មានបណ្ដឹង " ពាក់ព័ន្ធ តាមប្រភេទក្រុមប្រឹក្សា ត្រៀមសម្រាប់ការបញ្ជូន និងប្រគល់ជូន គ.ជ.ប ។ ប្រធាន គធ.ខប ត្រូវ ៖

២.១២១.៨.១ ចាត់ចែងវេចខ្ចប់រាល់ស្បោង " ខ$_{ស}$ " ឬ/និងរាល់ស្បោង " ខ$_{ខ}$ " និង រាល់ស្រោមសំបុត្រដាក់សម្ភារ ឯកសារបោះឆ្នោត នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោង " យ$_{ស}$ " ឬ/និង " យ$_{ខ}$ " តាមប្រភេទក្រុមប្រឹក្សាពាក់ព័ន្ធ ។

២.១២១.៨.២ ចាត់ចែងបំពេញ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួល សម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ សម្រាប់ស្បោង " យ " នីមួយៗ ដែលត្រូវដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងស្បោង " យ " នីមួយៗនោះ បន្ទាប់មកដាក់ ១ (មួយ) ច្បាប់ទៀតក្នុងហោប៉ៅស្បោង " យ " ពាក់ព័ន្ធ និងត្រៀម ១ (មួយ) ច្បាប់ៗ សម្រាប់ប្រើនៅពេលប្រគល់ ទទួល សម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

២.១២១.៨.៣ ចងភ្ជិតស្បោង " យ " តាមប្រភេទក្រុមប្រឹក្សាពាក់ព័ន្ធ រួចចាក់សោឃ្លុំមានលេខ និងសរសេរសម្គាល់ខាងក្រៅស្បោង " យ " ទាំងនោះ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឈ្មោះ និងលេខកូដរាជធានី ខេត្ត ឬ/និងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ និងពាក្យថា " មានបណ្ដឹង " ។

២.១២១.៩ ប្រសិនបើស្បោង " យ " ដូចមានចែងក្រោមចំណុច ២.១២១.៧ ឬ/និង ២.១២១.៨ ខាងលើ មានចំនួនច្រើនលើសពីមួយ ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យសរសេរសម្គាល់លេខរៀងនៅខាងក្រៅស្បោង " យ " ទាំងនោះផង ។ ឧទាហរណ៍ ប្រសិនបើមានស្បោង " យ " ចំនួន ៣ (បី) ត្រូវសរសេរសម្គាល់ថា ១/៣ ២/៣ និង ៣/៣ ។

២.១២១.១០ ប្រធាន គធ.ខប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្ស និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ បានសង្កេតពិនិត្យមើលក្នុងរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គ.ជ.ប និងត្រូវអនុញ្ញាតឱ្យកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់ស្បោង " យ " ដូចមានចែងក្នុងចំណុច ២.១២១.៦.៣ ២.១២១.៧.៣ និង ២.១២១.៨.៣ ខាងលើ ។

២.១២១.១១ ប្រធាន គធ.ខប ត្រូវធានាថារាល់កញ្ចប់សន្លឹកឆ្នោតត្រៀមបម្រុងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃការិយាល័យបោះឆ្នោតនីមួយៗចំណុះរាជធានី ខេត្តរបស់ខ្លួន (ប្រសិនបើមាន) ដែលមិនត្រូវបានប្រើប្រាស់ ត្រូវតែបានវេចខ្ចប់ដោយឡែក និងមិនត្រូវដាក់ក្នុងស្បោង " យ " ណាមួយឡើយ ហើយត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប ស្របពេលជាមួយនឹងការបញ្ជូនកញ្ចប់ " យ ពិសេស " និងស្បោង " យ " ។ ក្នុងការវេចខ្ចប់បញ្ជូន និងប្រគល់ ទទួលសន្លឹកឆ្នោតត្រៀមបម្រុងនេះ ប្រធាន គធ.ខប ត្រូវធានាថា ទ.១១០៧ ត្រូវតែបានបំពេញ និងប្រើប្រាស់តាមការកំណត់ក្នុងការបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។

២.១២១.១២ ប្រធាន គធ.ខប ត្រូវធានាថារាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែលបានទទួលពី គ.ក.ប ចំណុះរាជធានី ខេត្ត ត្រូវតែបានវេចខ្ចប់ដោយដាក់ក្នុងកេស ឬស្បោង ទៅតាមសភាពជាក់ស្តែង និងបញ្ជូនទៅ គ.ជ.ប ស្របពេលជាមួយនឹងការបញ្ជូនកញ្ចប់ " យ ពិសេស " និងស្បោង " យ " ។ ក្នុងការវេចខ្ចប់បញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ប្រធាន គធ.ខប ត្រូវធានាថា ទ.១១០៧ ត្រូវតែបានបំពេញ និងប្រើប្រាស់តាមការកំណត់ ក្នុងការបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។

**ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់នៅ គ.ជ.ប ពាក់ព័ន្ធនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

**ប្រការ ២.១២២.-**

ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬតំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខប លើពាក្យបណ្តឹងរបស់ខ្លួន ពាក់ព័ន្ធនឹងកំហុសឆ្គងក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ២.១១៥.៦.១ ២.១១៥.៩.១ និងប្រការ ២.១១៦ ខាងលើ ឬជំទាស់នឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឬ/និងរាជធានី ខេត្ត មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធលើពាក្យបណ្តឹង ឬបន្ទាប់ពីថ្ងៃ គធ.ខប បិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ។

២.១២២.១ រាល់ពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដូចបញ្ជាក់ក្នុងប្រការ ២.១២២ ខាងលើ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងដាក់នៅទីស្ដីការ គ.ជ.ប ហើយ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្ដឹងទាំងនេះ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

២.១២២.២ ប្រសិនបើ នៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប មិនបានទទួលពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ណាមួយទេ ត្រូវចាត់ទុកថា គ្មានការប្ដឹងទៅនឹងសេចក្ដីសម្រេចបដិសេធរបស់ គធ.ខប ឬទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាណាមួយឡើយ ។

២.១២២.៣ អ្នកប្ដឹងជំទាស់ ឬតំណាងដែលមានបំណងប្ដឹងតវ៉ា ឬប្ដឹងជំទាស់ ដូចមានបញ្ជាក់ក្នុងប្រការ ២.១២២ ខាងលើ ត្រូវបំពេញ និងចុះហត្ថលេខាលើពាក្យបណ្ដឹង ដែលក្នុងនោះត្រូវផ្ដល់ព័ត៌មានច្បាស់លាស់មួយចំនួន ដូចមានចែងក្នុងចំណុច ២.១១៥.២ ខាងលើ ។

២.១២២.៤ ចំពោះពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដែលត្រូវបានដាក់ក្រោយពេលវេលាដូចមានចែងក្នុងប្រការ ២.១២២ ខាងលើ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា កាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូន គ.ជ.ប ចារបញ្ជាក់ពីការហួសពេលទទួលពាក្យបណ្ដឹង ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្ដឹងនោះ ហើយប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ និងជម្រាបអ្នកប្ដឹង ឬតំណាងថា ពាក្យបណ្ដឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ ដូចនេះ គ.ជ.ប មិនអាចទទួលដោះស្រាយបានទេ ។

២.១២២.៥ ចំពោះពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ណាដែលគ្មានបញ្ជាក់ព័ត៌មានច្បាស់លាស់គ្រប់គ្រាន់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវណែនាំអ្នកប្ដឹង ឬតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្ដឹង រួចកត់ត្រាក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹងមិនបានបំពេញបន្ថែមចំណុចខ្វះខាតនោះទេ គ.ជ.ប ត្រូវចារបដិសេធ

លើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខា និងបោះត្រា គ.ជ.ប ហើយប្រគល់ជូនអ្នកប្ដឹង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

២.១២២.៦ ចំពោះពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ណាមួយ ត្រូវបានដាក់ក្នុងរយៈពេលដូចមានចែងក្នុងប្រការ ២.១២២ ខាងលើ និងមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹងនៅ គ.ជ.ប ត្រូវធ្វើកំណត់ហេតុសាកសួរព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាង ចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុ ។ ក្នុងករណីអ្នកប្ដឹង ឬតំណាង មិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ មន្ត្រីទទួល និងពិនិត្យពាក្យបណ្ដឹង ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនេះ បន្ទាប់មកចុះកាលបរិច្ឆេទ និងពេលវេលានៃការទទួលពាក្យបណ្ដឹង ហើយត្រូវ ៖

២.១២២.៦.១ ប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ។

២.១២២.៦.២ រក្សាទុកប្រើពេលដោះស្រាយពាក្យបណ្ដឹង ១ (មួយ) ច្បាប់ ។

២.១២២.៦.៣ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

២.១២២.៦.៤ ជម្រាបអ្នកប្ដឹង ឬតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្ដឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះ ។

២.១២២.៧ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ អំពីករណីនៃពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដោយភ្ជាប់ពាក្យបណ្ដឹងដែលបានទទួល និងសម្រង់សេចក្ដីសម្រេចរបស់ គធ.ខប បដិសេធលើពាក្យបណ្ដឹងដែលត្រូវដកចេញពីកញ្ចប់ " យពិសេស " ដើម្បីសុំការណែនាំពី គ.ជ.ប សម្រេចកំណត់អំពីករណីនៃការត្រួតពិនិត្យ និងបញ្ជាក់លទ្ធផល និងអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការ ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ និងបញ្ជាក់លទ្ធផលឱ្យធ្វើការត្រួតពិនិត្យ និងបញ្ជាក់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពាក់ព័ន្ធ នឹងពាក្យបណ្ដឹងនោះនៅចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្ដឹង ។

**ការបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបម្រើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

**ប្រការ ២.១២៣.-**

ក្នុងគោលបំណងត្រួតពិនិត្យឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គ.ជ.ប ត្រូវបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ១ (មួយ) ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញមួយចំនួន តាមការចាំបាច់ និងក្រុមកំណត់បែងចែកអាសនៈ ១ (មួយ) ព្រមទាំងត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីបម្រើឱ្យការងារត្រួតពិនិត្យលទ្ធផលនេះ ។

២.១២៣.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតមួយត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីធានាការទទួលកញ្ចប់ " ឃពិសេស " ដាក់សំណុំឯកសារលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងស្បោង " ឃ " ដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ កញ្ចប់ដាក់សន្លឹកឆ្នោតបម្រុងដែលមិនបានប្រើ និងសម្ភារ ឯកសារផ្សេងទៀត ដែល គធ.ខប បានបញ្ជូន និងប្រគល់ជូន គ.ជ.ប ព្រមទាំងធានាការបែងចែក និងរក្សាទុកសម្ភារ ឯកសារទាំងនោះ នៅបន្ទប់ស្ដុកតាមរាជធានី ខេត្តនីមួយៗ ។

២.១២៣.១.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ត្រូវដឹកនាំដោយប្រធាននាយកដ្ឋានរដ្ឋបាល និងមានមន្ត្រីនាយកដ្ឋានប្រតិបត្តិការ ២ (ពីរ) រូប មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ១ (មួយ) រូប មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ១ (មួយ) រូប និងមន្ត្រីលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន ១ (មួយ) រូប ជាសមាជិក ។

២.១២៣.១.២ ក្រុមនេះរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ។

២.១២៣.២ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប មួយចំនួនត្រូវបានបង្កើតឡើងតាមការចាំបាច់ ដើម្បីអនុវត្តការត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ។ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរួមមានសមាសភាព ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋាននានា ចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប និងត្រូវបានបែងចែកឱ្យទទួលបន្ទុកត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌក្នុងរាជធានី ខេត្តមួយ ឬច្រើន ។

២.១២៣.២.១ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ត្រូវមានសមាសភាព ៤ (បួន) រូប ដែលដឹកនាំដោយប្រធាន ១ (មួយ) រូប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងជំនួយការ ១ (មួយ) រូប ។

២.១២៣.២.២ ក្រុមនេះរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ។